ឈៀ ថេន

(តាមលំនាំឯកសារលោក ហ៊ួនឹម)

# រឿងរ៉ាវនៃទឹកដី

# កម្ពុជាក្រោម

១ (ឬអតីតកូសាំងស៊ីន)




ISBN-9789995078089

www.elibraryofcambodia.org



ការផ្សាយរបស់

ឥន្ទ្រទេវី ™

The Indradevi Publishing

www.elibraryofcambodia.org

ទៀ ថេន
និពន្ធរៀបរៀង
( តាមលំនាំឯកសារ លោក ហ៊ូ នឹម )

# រឿងរ៉ាវនៃទឹកដី

# កម្ពុជាក្រោម

## ( ឬ អតីត កូសាំងស៊ីន)

## ស្ថានភាពគតិយុត្ត
## ច្បាប់សាធារណៈអន្តរជាតិ

www.elibraryofcambodia.org

**ការផ្សាយរបស់ ឥន្ទ្រទេវី**

ស្រាវជ្រាវ និងនិពន្ធរៀបរៀងដោយ :

**ឡៅ ថេន**

( តាមលំនាំឯកសារលោក ហ៊ូ ទឹម )

បោះពុម្ពលើកទី២
ខែ សីហា ឆ្នាំ២០០៥
ជាខេមរភាសានៅកម្ពុជា
រោងពុម្ព ឥន្ទ្រទេវី

រក្សាសិទ្ធិគ្រប់យ៉ាង

www.elibraryofcambodia.org

# សារបណ្ណ


វាចាអ្នកនិពន្ធរៀបរៀង ........................................................ ៥

ឧទ្ទិសកថា ........................................................ ៨

ព្រះរាជសារព្រះករុណា ព្រះករុណាអគ្គមហេសី ........................................................ ១២

បុព្វកថា ........................................................ ១៦

**ជំពូកមួយ** : គ្រឹះប្រវត្តិសាស្ត្រនៃអធិបតេយ្យភាពប្រទេសកម្ពុជា នៅលើកោះត្រល់ ........................................ ២៣

**ផ្នែកមួយ** : ការបង្កើតព្រះរាជាណាចក្រកម្ពុជា ........................................ ២៤

**ផ្នែកពីរ** : បូរណភាពទឹកដីនៃប្រទេសកម្ពុជា លាតសន្ធឹងដល់កោះត្រល់........................................ ៥១

**ជំពូកពីរ** : គ្រឹះគតិយុត្តនៃអធិបតេយ្យភាពអចិន្ត្រៃយ៍របស់ប្រទេស កម្ពុជានៅលើកោះត្រល់ ........................................ ៥៤

**ផ្នែកមួយ** : ការកាន់កាប់ខុសច្បាប់ ដោយកងទ័ពនូវ "កោះត្រល់" ទឹកដីខ្មែរដោយអណ្ដាម និងបន្ទាប់មកដោយបារាំង .......... ៥៨

**ផ្នែកពីរ** : ប្រទេសកម្ពុជាមិនដែលបោះបង់ចោលនូវសិទ្ធិរបស់ខ្លួននៅលើ ទឹកដីកម្ពុជាក្រោមនោះឡើយ ការតវ៉ារបស់ខ្លួនប្រឆាំង ការកាន់ កាប់ខុសច្បាប់នូវទឹកដីខ្មែរនេះត្រូវបានធ្វើជាប់ជាប្រចាំ ........................................ ១០៩

**ជំពូកបី** : ភស្តុតាងទាំងឡាយដែលបញ្ជាក់ថា កោះត្រល់ ជារបស់ ព្រះរាជាណាចក្រកម្ពុជា ........................................ ១៣២


www.elibraryofcambodia.org

ផ្នែកមួយ : ភស្តុតាងទាំងឡាយដែលប្រមូលបានដោយពួកអ្នកដំណើរ ទី១ និងអតីតផែនទីភូមិសាស្ត្រនៅអាស៊ីអាគ្នេយ៍ ............ ១៣៣
ផ្នែកពីរ : អតីតកាល និងជីវិតរបស់ខ្មែរកម្ពុជាក្រោម .................. ១៤៤
បញ្ចប់កថា .................................................................. ២០៩
ឧបសម្ព័ន្ធ១ : ដកស្រង់ចេញពី "បុរាណវត្ថុវិទ្យា នៅដីសណ្ដ ទន្លេមេគង្គ" របស់លោក Louis Malleret ........................................ ២១៨
ឧបសម្ព័ន្ធ២ : ផែនទីទាំងឡាយដើម្បីជាយយល់នូវសៀវភៅនេះ ជាកម្មវត្ថុនៃការបោះពុម្ពផ្សាយដ៏មានសារៈសំខាន់ ......... ២៥២
ឯកសារពិគ្រោះ (តាមឯកសារលោក ហ៊ូ នឹម) ............................ ២៦១

*** ដរាបណាបុគ្គលមានជីវិតរស់នៅ ដរាបនោះ**
**សេចក្ដីសង្ឃឹមរបស់គេក៏មាននៅ ។**

www.elibraryofcambodia.org

## អារម្ភកថានិពន្ធរៀបរៀង

អ្នកដែលរាប់អានស្រឡាញ់ប្រទេសកម្ពុជា តែងជំពាក់ចិត្តជាមួយ "វប្បធម៌, អារ្យធម៌ និងអតីតវិសាលភាពទឹកដីដ៏ស្រស់បវរ ដែលមាន រមណីយដ្ឋាន, បុរាណីយដ្ឋានជាច្រើនរបស់ប្រទេសនេះ ។ ...ជាងនេះទៅទៀត ទន្លេ, សមុទ្រដែលផ្ដល់ជាធនធានធម្មជាតិ យ៉ាងពិសេសដល់ប្រជាជនប្រទេសនេះ..." ។

អាងទឹកទន្លេមេគង្គ ដែលហូរកាត់តាមប្រទេសកម្ពុជា ហើយដែលបន្ទាប់មកហូរចាក់ក្នុងសមុទ្រនោះ បានធ្វើឲ្យពលរដ្ឋខ្មែរចាំមិនភ្លេច អំពីទឹកដីមួយចំណែកនៅភាគខាងត្បូងឈៀងខាងកើតប្រទេស (ជាប់ជាមួយសមុទ្រចិន) ដែលហៅថា "ដែនដីសណ្ដ ទន្លេមេគង្គ ឬហៅថាកម្ពុជាក្រោម... (Mekong Delta)" ជាទីចុងក្រោយបំផុតនៃ ទន្លេមេគង្គនេះ ។ ...ក្រោយអំពីអតីតកាលដ៏រុងរឿង និងវែងបំផុតមួយមក, ប្រទេសកម្ពុជាត្រូវច្បាំងប្រយុទ្ធជាមួយការឈ្លានពានពីនគរសៀម, អណ្ណាម, ចំប៉ា និង ជាចុងក្រោយ គឺអាណានិគមបារាំង ដែលបានដណ្ដើមត្រួតត្រាក្រុមប្រទេសឥណ្ឌូចិនទាំងស្រុង ។

រាប់រយឆ្នាំនៃការរងទុក្ខវេទនា ជាមួយនឹងការប្រយុទ្ធតស៊ូទាំងអស់សង្ឃឹម នៃក្រុមខ្មែរនៅកម្ពុជាក្រោម ចាប់តាំងពីឆ្នាំ ១៦២៣ មកនោះ, ក៏បានក្លាយទៅជាសេចក្ដីនឿយហត់ដ៏ក្រៃលែង ។ រយៈពេលប្រមាណ ៤០០ឆ្នាំ ចុងក្រោយនេះ ការប្រយុទ្ធតស៊ូរបស់ខ្មែរ បាននាំយកទៅជាមួយនូវជីវិតមនុស្សរាប់សិបលាននាក់ កប់ទៅក្នុងទឹកដីកម្ពុជាក្រោម ជាទីស្រឡាញ់របស់ពួកគេ, ហើយក៏នៅក្នុងនោះ គឺមានចាប់តាំងពីជីវិតរបស់ស្ដេចផែនដី មកដល់ប្រជារាស្ត្រ និងកូនចៅសំណព្វចិត្តរបស់គេទៀតផង ។

*** ការសិក្សាស្រាវជ្រាវទាំងឡាយរបស់ក្រុមអ្នកប្រាជ្ញបរទេស គឺជាភស្តុតាងដ៏ជាក់ស្ដែងលើផ្លូវច្បាប់ថា "ដូនតាខ្មែរ" មិនដែលបានបោះបង់ការតស៊ូ ដើម្បីទឹកដី

www.elibraryofcambodia.org

កម្ពុជាក្រោមឡើយ គឺប្រវត្តិសាស្ត្របានកត់ត្រាផ្សាយពេញពិភពលោកអំពីរឿងរ៉ាវអស់ទាំងនោះ ។ មែនហើយគេនិយាយថា "ចង់កំណត់អនាគតនៃជាតិរបស់ខ្លួន និងខ្លួនឯងផ្ទាល់, (មនុស្ស) ត្រូវស្គាល់និងដឹងច្បាស់អំពីដូនតារបស់ខ្លួនសិន"...។ ...ដូច្នេះតាមន័យនេះ យើងជាខ្មែរ... ត្រូវស្គាល់ថា "តើដូនតាខ្មែរបានធ្វើអ្វីខ្លះ ទុកឲ្យកូនខ្មែរឬទេ....?" ឆ្លើយ....ថា មាន! ....គឺលោកបានពង្រីកទឹកដី, ថែរក្សាព្រៃព្រឹក្សា, ទន្លេ សមុទ្រ ទុកឲ្យ... សម្រាប់វិស័យ កសិកម្ម, បានកសាងប្រាសាទរាប់រយ រាប់ពាន់ទុកឲ្យ... សម្រាប់វិស័យទេសចរណ៍ ដែលជា ឧស្សាហកម្មគ្មានផ្សែងបំពុលឡើយ ។ ...ពិសេសជាងនេះ គឺលោកបានទទួលយកមកទុក ជាកេរមត៌កក្នុងសង្គមជាតិ ជាទីពឹង គឺព្រះពុទ្ធសាសនា ដែលប្រដៅមនុស្សជាតិឲ្យរស់ ក្នុងសេចក្ដី សុចរិត, ថ្លៃថ្នូរ មានយុត្តិធម៌ និង ប្រជាធិបតេយ្យ...។

ជាការពិត, គឺថា ប្រជាជាតិមួយដែលអាចរឹងមាំទៅបាន លុះត្រាណាមានការឯកភាពជាតិ ជុំវិញស្ថាប័នកំពូលបំផុត, ពោលគឺ ល្គឹកណាតែមានការរួបរួមគ្នា ស្រុះចិត្ត មូលគំនិតតែមួយ មិនប្រឆាំងគ្នាឯង ផ្ទៃក្នុង ទើបពុំមានសត្រូវណាហ៊ានមើលងាយ ឬរំលោភឈ្លានពានមកបាន ។ ដូច្នេះ បើគេពិនិត្យថយក្រោយវិញ គេនឹងឃើញថា លទ្ធផលជាតឹកតាង គឺការរួមចិត្ត រួមគំនិត និងរួមកម្លាំងគ្នា ធ្វើឲ្យអាណាចក្រខ្មែរស្ថាបនាបានមូលដ្ឋាន មហាអំណាចដ៏ខ្លាំងក្លាពេញបន្ទុករាប់សតវត្សរ៍នៅ ទ្វីបអាស៊ី... នេះហើយ គឺជាអ្វីដែល "ដូនតាខ្មែរ" បានធ្វើទុកឲ្យអ្នកជំនាន់ក្រោយដើម្បីទទួលប្រយោជន៍ ។ ពិនិត្យពិច័យជាទូទៅ ក៏ឃើញនិយមន័យមួយដែលជាបំណងប្រាថ្នារបស់ "បុព្វបុរស ដូនតាខ្មែរ" ដែលមានគឺ : ចង់ឲ្យ អ្នកជាកូនចៅខ្មែរ មានសុទិដ្ឋិនិយម ដើម្បី**រស់ក្នុងអត្តភាព ដោយមិនឲ្យចំណុះចំពោះ អ្វីដែលខ្លួនមិនពេញចិត្ត**...។

ដូច្នេះ ដោយសរុបមកឃើញថាការរំលឹកមកវិញ អំពីរឿងរ៉ាវដ៏ត្រឹមត្រូវមួយដែលប្រទេសរបស់ខ្លួនសមនឹងទទួលបានមិនមែនដូចពាក្យគេថា "គាស់ខ្មោចយកមក

www.elibraryofcambodia.org

ហិត" នោះទេ... ប៉ុន្តែនោះគឺការលើកយកមកបង្ហាញ, រកយុត្តិធម៌ឲ្យខ្លួនឯងដោយពិត... ពីព្រោះថា ប្រសិនបើអ្នកដទៃ មិនផ្តល់យុត្តិធម៌ចំពោះយើងទេ គឺយើងខ្លួនឯងនោះហើយ ដែលត្រូវរកយុត្តិធម៌មកឲ្យខ្លួនឯង,.... ធ្វើបានដូច្នេះទើបជីវិតនោះរកបានសេចក្តីស្ងប់ស្ងាត់ខ្លះ... ។

នៅទីនេះ, លោក / អ្នក អាចរកឃើញសម្រាប់ខ្លួន នូវការបញ្ជាក់យ៉ាងច្រើនដែលអ្នកនិពន្ធលើកយកមកបង្ហាញ ហើយសុទ្ធតែជាឯកសារមានតម្លៃរបស់ពិភពលោកទាំងអស់, ពុំនោះសោត ភាគខ្លះគឺជាសុទិដ្ឋិនិយមរបស់អ្នកស្រាវជ្រាវ និយមវិទ្យាសាស្ត្រ ដ៏ពិតៗទៀតផង... គេច្បាស់ជាដឹងថា នេះជាប្រភេទឯកសារ "ពេញចំណាស់" ដែលអ្នកសិក្សារកបានដោយកម្របំផុត ។ ...និងជាទីបញ្ចប់ អ្នកនិពន្ធក៏សូមសប្បាយរីករាយជាមួយ លោក / អ្នក ដែលកំពុងតែពេញចិត្តយ៉ាងខ្លាំង ជាមួយនឹងគំហើញថ្មី របស់ខ្លួនឯងនេះ... ហើយ ដែលពិតប្រាកដតាមប្រវត្តិសាស្ត្រ និងដែលពុំអាចប្រកែកបានឡើយ...។

សូមលោកនិងអ្នកទទួលបានសេចក្តីសុខ, សេចក្តីសង្ឃឹម និងសេចក្តីយោគយល់យ៉ាងពេញលេញជាទីបំផុត...។

ព្រះរាជធានីភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ ២០០៥

ទៀ ថេន

www.elibraryofcambodia.org

# ឧទ្ទិសកថា

សូមឧទ្ទិសចំពោះ **មាតាបិតា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ខ្ញុំ ។

សូមឧទ្ទិសចំពោះ ដួងព្រះវិញ្ញាណក្ខន្ធ ព្រះវីរក្សត្រិយ៍, វីរសមណ និង វីរបុរសទាំងអស់ សូមបានទទួលនូវឥដ្ឋមនុញ្ញផល កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឧទ្ទិសចំពោះ លោក **ហ៊ូ នឹម** ដែលស្រឡាញ់ទឹកដីកម្ពុជាក្រោមស្មើជីវិត, សូមឲ្យវិញ្ញាណក្ខន្ធរបស់លោកបានទៅកាន់សុគតិភព កុំបីអាក់ខានឡើយ ។

www.elibraryofcambodia.org



ឧបាសក **ឆៀ អាន**



ឧបាសិកា **ឆី សា**



ឧបាសក **ត្រាន់ ជាន**



ឧបាសិកា **ឆី ហ៊ាត**

www.elibraryofcambodia.org



ព្រះករុណា ព្រះបាទ សម្តេចព្រះ
ហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ ព្រះអង្គដួង
សោយរាជ្យពីឆ្នាំ (១៨៤១-១៨៦០)



ព្រះករុណា ព្រះបាទ សម្តេចព្រះ
នរោត្តម សោយរាជ្យពីឆ្នាំ
(១៨៦០-១៩០៤)



ព្រះករុណា ព្រះបាទ សម្តេចព្រះ
ស៊ីសុវត្ថិ សោយរាជ្យពីឆ្នាំ
(១៩០៤-១៩២៧)



ព្រះករុណា ព្រះបាទ សម្តេច
ព្រះស៊ីសុវត្ថិ មុនីវង្ស សោយរាជ្យ
ពីឆ្នាំ (១៩២៧-១៩៤១)



ព្រះករុណា ព្រះបាទ សម្តេចព្រះ
នរោត្តម សុរាម្រិត សោ[illegible]
ពីឆ្នាំ (១៩៥៥-១៩៦០)



ព្រះជាយាលក្សណ៍នៃ សម្តេច
[illegible]
កុសមៈ នារីរ័តន៍សោយរាជ្យពីឆ្នាំ
([illegible])



ព្រះករុណា ព្រះបាទ សម្តេចព្រះ
នរោត្តម សីហនុវរ្ម័ន
សោយរាជ្យពីឆ្នាំ (១៩៤១-១៩៥៥)
([illegible])

www.elibraryofcambodia.org



ព្រះករុណា ព្រះបាទ សម្តេចព្រះ បរមនាថ នរោត្តម សីហមុនី សោយរាជ្យពីឆ្នាំ (២០០៤- )

ព្រះករុណា ព្រះបាទ សម្តេចព្រះ បរមនាថ នរោត្តម សីហមុនី នៅថ្ងៃយាងឡើងគ្រងរាជ្យសម្បត្តិ. ព្រះករុណា ព្រះវររាជបិតា នរោត្តម សីហនុ និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ ប្រទានព្រះសុគន្ធវារី ថ្វាយព្រះរាជបុត្រ ក្នុងព្រះរាជពិធីមុទ្ធាភិសេក ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រ កម្ពុជា ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤

www.elibraryofcambodia.org

# ព្រះរាជវង្សានុវង្ស ព្រះករុណា "អង្គឌួង" ហរិរក្សរាមា ឥស្សរាធិបតី




www.elibraryofcambodia.org



រូបថត : ចម្លងអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM)

លោក ហ៊ូ នឹម

អ្នកដែលស្រលាញ់ទឹកដីកម្ពុជាក្រោម ស្មើជីវិតរបស់ខ្លួន

www.elibraryofcambodia.org



ឧកញ៉ា ឧត្តមមន្ត្រី ញឹម ឯម



សម្តេច ពោធិវិសាលរាជ សឹង ឡៀប

www.elibraryofcambodia.org

## បុព្វកថា

ការពិនិត្យពិចារណាអំពីសភាពការណ៍របស់កម្ពុជាក្រោម (កម្ពុជាក្រោម ឬ កូសាំងស៊ីន មួយភាគធំនៃវៀតណាមខាងត្បូង) និងព្រះរាជាណាចក្រកម្ពុជា មើលឃើញនៅក្រោមទិដ្ឋភាព :

- នៃ ប្រវត្តិសាស្ត្រ
- នៃ គតិយុត្ត
- នៃ ភស្តុតាង

បានធ្វើឲ្យឃើញច្បាស់ថា **នៅលើលក្ខខណ្ឌគតិយុត្ត** ព្រះរាជាណាចក្រកម្ពុជា នៅតែរក្សាទុកអធិបតេយ្យភាពរបស់ខ្លួននៅកម្ពុជាក្រោមនៅឡើយ ។

**នៅលើលក្ខខណ្ឌនៃប្រវត្តិសាស្ត្រ** គេមិនគួរសង្ស័យទេថា តើទឹកដីកូសាំងស៊ីនគឺពិតជារបស់ព្រះរាជាណាចក្រកម្ពុជាឬទេនោះ?... ។

ប្រវត្តិសាស្ត្រទាំងឡាយ សៀវភៅទាំងឡាយ កាលប្បវត្តិ អ្នកប្រវត្តិសាស្ត្របុរាណវត្ថុវិទូ និងអ្នកនិពន្ធដ៏ចាស់ៗបំផុត បានបញ្ជាក់អះអាង ។

**នៅលើលក្ខខណ្ឌនៃគតិយុត្ត** គេបានកត់សម្គាល់ជាមួយលោក Moura (ព្រះរាជាណាចក្រកម្ពុជា-ទំព័រ៤៥២) ថា "គ្មានការអនុញ្ញាតជាក់លាក់ណាមួយ, គ្មានសន្ធិសញ្ញាត្រឹមត្រូវតាមច្បាប់ណាមួយ បានធ្វើអន្តរាគមន៍ដើម្បីដោះស្រាយ និងធ្វើឲ្យត្រឹមត្រូវតាមច្បាប់នូវការកាន់កាប់ដោយពួកអណ្ណាមមកលើប្រទេសកម្ពុជានោះទេ...ពុំមានបន្ទាត់ព្រំដែនណាមួយត្រូវបានគូសនោះទេ..." ។

**ព្រះមហាក្សត្រខ្មែរ និងប្រជាជនកម្ពុជា ជានិច្ចជាកាលបានប្រយុទ្ធប្រឆាំងនឹងពួកលុកលុយអណ្ណាម ដើម្បីរំដោះកម្ពុជាក្រោម ។ ការប្រយុទ្ធនេះដែលបានចាប់ផ្ដើមពីឆ្នាំ១៦២៣ ត្រូវបានបន្តរហូតដល់ការសោយទិវង្គតរបស់ព្រះករុណាព្រះអង្គដួងនៅឆ្នាំ១៨៦០... គឺរហូតមកទល់នឹងការមកដល់របស់បារាំង ។**

www.elibraryofcambodia.org

ព្រះមហាក្សត្រខ្មែរនិងប្រជាជនកម្ពុជា មិនដែលបោះបង់ចោលនូវសិទ្ធិរបស់ខ្លួន នៅលើទឹកដីកម្ពុជាក្រោមនោះឡើយ ។ ពួកគេបានតវ៉ានៅអមប្រទេសបារាំង នៅពេលដែលអធិរាជអណ្ណាម បានប្រគល់ឲ្យបារាំងនូវទឹកដីកម្ពុជាក្រោម ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សររបស់ព្រះករុណាព្រះអង្គដួង នៅក្នុងព្រះរាជសារលិខិតរបស់ព្រះអង្គនៅឆ្នាំ១៨៥៦ ទៅថ្វាយព្រះចៅ**ណាប៉ូឡេអុង** III គឺច្បាស់លាស់ណាស់អំពីចំណុចនេះ ។ ឯចំណែកសន្ធិសញ្ញា បារាំង–អណ្ណាម នៅឆ្នាំ១៨៦២ គឺទុកជាមោឃៈដោយពេញច្បាប់ ។

ព្រះមហាក្សត្រខ្មែរ ចាប់តាំងពីព្រះករុណា "នរោត្តម" ដែលនៅក្នុងឆ្នាំ១៨៦០ បានចាប់អនុវត្តឡើងវិញនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយព្រះបិតាជាទីគោរពរបស់ព្រះអង្គ រហូតដល់ព្រះករុណាព្រះបាទ "នរោត្តម សីហនុ" បានតវ៉ាប្រចាំងនឹងការកាន់កាប់របស់បារាំងនៅលើទឹកដីកម្ពុជាក្រោម នៅក្នុងអំឡុងពេលទាំងអស់នៃអាណាព្យាបាល ។

ការតវ៉ាទាំងនេះ មិនដែលឈប់សោះឡើយ... ។

ព្រះមហាក្សត្រនិងរាជរដ្ឋាភិបាលកម្ពុជា បានទាមទារយ៉ាងស្វាហាប់ ទាំងនៅអមរដ្ឋាភិបាលបារាំង ក៏ដូចជានៅក្នុងក្របខ័ណ្ឌសន្និសីទអន្តរជាតិ នៅពេលដែលបារាំងធ្វើកិច្ចព្រមព្រៀងនៃឆកសមុទ្រ d'Along នៅឆ្នាំ១៩៤៨ បានប្រគល់ឲ្យជាឯកតោភាគី នូវទឹកដីកម្ពុជាក្រោមទៅឲ្យអធិរាជ "បាវដាយ" ដើម្បីជាការទទួលស្គាល់នូវ "គីទាំង៣" (Trois Ky) *(តុងកឹង, អណ្ណាម, កូសាំងស៊ីន)* ។

កម្ពុជាក្រោម (Le Bas-Cambodge) *(បារាំងហៅថា កូសាំងស៊ីន)* បានស្ថិតនៅក្នុងទឹកដីរបស់កម្ពុជាទាំងស្រុង ។

មិនដែលមានការកាន់កាប់ទឹកដីដែលគ្មានម្ចាស់ ដោយអណ្ណាម និងបន្ទាប់មកដោយបារាំងនោះទេ ។ ទឹកដីកម្ពុជាក្រោម ការពិតគឺជារបស់ និងជារបស់កម្ពុជា

www.elibraryofcambodia.org

ដោយគតិយុត្តនៅឡើយ ចាប់តាំងពីសម័យ "ហ៊្វុណន" មកទល់បច្ចុប្បន្ន ។

ការធ្វើសញ្ជ័យដោយកម្លាំងទ័ព ឬក៏ការលុកលុយនូវទឹកដីមួយ តែងតែត្រូវបាន ផ្គន្ទាទោស មិនគ្រាន់តែដោយច្បាប់អន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយវិន័យអន្តរជាតិ បច្ចុប្បន្នផងដែរ ។

***សមាគមនៃប្រជាជាតិ ដែលអង្គការសហប្រជាជាតិបានបន្តវេននោះ បានបញ្ជាក់ អះអាងឡើងវិញនូវគោលការណ៍នេះ និងដាក់បង្ខំឲ្យសមាជិកទាំងអស់អនុវត្តតាម ។***

គេបានឃើញសេចក្តីរាយការណ៍នៅក្នុងបញ្ជីនៃសំណួរ ស្តីពីច្បាប់អន្តរជាតិទូទៅ (១៩២០–១៩៤០, យោង ៣៤១. S333 បណ្ណាល័យអង្គការសហប្រជាជាតិនៅ ញូវ យ៉ក) ច្បាប់ដែលមិនចេះប្រែប្រួលដូចតទៅនេះ (កថាខ័ណ្ឌ២២២, ៣៨៥ និង៣៨៧ នៃមាតិកា) :

– ការចូលលុកលុយទឹកដីមួយរបស់ប្រទេសមួយ គឺជាការប៉ះពាល់ដល់អធិប តេយ្យភាពរបស់ប្រទេសនោះ ដែលហាមឃាត់ដោយច្បាប់អន្តរជាតិជាវិជ្ជមាន ។

– ការកាន់កាប់ដោយកងទ័ពនូវទឹកដីមួយ វាមិនបាននាំទៅដល់ការផ្លាស់ប្តូរ អធិបតេយ្យភាពនោះឡើយ ។ វាជាសភាពការណ៍មួយដោយពិតទៅ វាមិនបានប៉ះ ពាល់ដល់អធិបតេយ្យភាពនោះទេ ។

– ការបាននូវទឹកដីណាមួយ មិនអាចត្រូវបានទទួលដោយការប្រើកម្លាំងទ័ពនោះ ឡើយ ។

វាជាក់ស្តែងណាស់ដែលពួកអណ្ណាមបានប្រើប្រាស់កម្លាំងទ័ព ដើម្បីចូលលុក លុយ "កម្ពុជាក្រោម" ។ ខាងប្រជាជនខ្មែរវិញ មិនដែលទុកឲ្យពួកអណ្ណាមតាំងនៅ ដោយសន្តិភាព នៅក្នុងខេត្តទាំងឡាយដែលពួកគេបានលុកលុយនោះទេ ។ លោក Moura សរសេរថា : "គឺនៅឆ្នាំ១៦៧៥ ដែលបានចាប់ផ្តើមធ្វើ**សង្គ្រាមមិនដែល ដាច់នេះ** រវាងប្រជារាស្ត្រទាំងពីរ និងការបញ្ចូលជាឧបសម្ព័ន្ធយ៉ាងលឿនទៅមុខ នូវ

www.elibraryofcambodia.org

ដែនដីសណ្តនៃទន្លេ ទៅក្នុងព្រះរាជាណាចក្រអណ្តាម" ។

ដូច្នេះវាមិនមែនជាទឹកដីមួយដែលគ្មានម្ចាស់ ដែលគេអាចកាន់កាប់ដោយមិនបាច់ប្រយុទ្ធនោះទេ ។ កម្ពុជាក្រោម ត្រូវបានរស់នៅដោយប្រជាជនខ្មែរ ហើយប្រជាជនខ្មែរនេះឯងបានការពារទឹកដីរបស់ខ្លួន តមកជារហូត...... ។

លោក Silvestre នៅក្នុងសៀវភៅមួយដែលសរសេរអំពីអាណាចក្រអណ្តាមនោះ លោកថែមទាំងបានសរសេរថា "ព្រះមហាក្សត្រខ្មែរបានគង់នៅព្រៃនគរ គឺថានៅសាយហ្គននៅឆ្នាំ២៨៩ មុនគ្រិស្តសករាជ" ។

យើងត្រូវបើកវង់ក្រចកភ្ជាមនៅកន្លែងនេះ ។ ពីដើម "ព្រៃនគរ" មានឈ្មោះថា "ព្រៃ-គ" ដែលពួកអណ្តាមបានបកប្រែថា : កីហ្គន "Cây Gon" គឺ (ដើម-គ) ហើយ បារាំងបានហៅក្លាយទៅជា "សាយហ្គន" (Sai Gon) ។

ប៉ុន្តែដូចលោក Moura បាននិយាយអីចឹង **"គឺពុំមានព្រំដែនត្រូវបានគូសទេ"** ។ **"ដើម្បីឲ្យគំនូសព្រំដែនមួយមានតម្លៃ គេត្រូវមានកិច្ចព្រមព្រៀងរបស់រដ្ឋទាំងឡាយ ដែលមានព្រំដែនទាំងនេះរួមគ្នា"** ។

ចាប់តាំងពីសមាគមរបស់បណ្តាប្រជាជាតិមក, គោលការណ៍នៃ "ការយល់ព្រម" របស់រដ្ឋជាសាមីនីមួយៗ គឺតែងតែត្រូវការដើម្បីកំណត់ព្រំដែន ។

គោលការណ៍នេះយកគំនិតតាមច្បាប់អន្តរជាតិ ឬច្បាប់ផ្ទៃក្នុង ដែលកំណត់ដោយច្បាស់លាស់នូវ "ជញ្ជាំងអឡូសិទ្ធិ" (Le mur mitoyen) (សិទ្ធិជាម្ចាស់ជញ្ជាំង "របង" ពាក់កណ្តាលម្នាក់) ។

ដូច្នេះគេឃើញនៅក្នុងបញ្ជីនៃសំណួរ ស្តីពីច្បាប់អន្តរជាតិទូទៅ នូវគោលការណ៍ទាំងឡាយដូចតទៅនេះ (កថាខ័ណ្ឌ២៥០ និង៣៥៤) :

**- ព្រំដែនរបស់រដ្ឋមួយដែលមានអធិបតេយ្យភាព មិនអាចត្រូវបានកំណត់ដោយគ្មានការយល់ព្រមរបស់សាមីប្រទេសនោះឡើយ ។**

www.elibraryofcambodia.org

**- ព្រំដែនរបស់រដ្ឋមួយអាចត្រូវបានកំណត់ តែដោយការយល់ព្រមរបស់សាមីប្រទេសនោះដោយផ្ទាល់ ។**

ចំពោះការអនុវត្តន៍ជាអន្តរជាតិទាំងអស់នេះ មានការបញ្ចេញឲ្យឃើញនូវគោលការណ៍មួយទៀតច្បាស់ជាង ដែលការពារច្បាប់របស់រដ្ឋមួយនៅលើផ្នែកមួយនៃទឹកដីរបស់ខ្លួន ដែលនៅក្នុងនោះរដ្ឋនេះមិនបានបោះបង់ចោលដោយដាច់ខាតនោះទេ ។

អធិបតេយ្យភាពរបស់រដ្ឋនេះ នៅលើផ្នែកនៃទឹកដីនេះ បានស្ថិតនៅទាំងស្រុងទោះបីជាមានអ្នកកាន់កាប់ក៏ដោយ ។ គឺនៅក្នុងន័យនេះហើយ ដែលព្រះមហាក្សត្រទាំងឡាយរបស់ប្រទេសកម្ពុជា និងរាជរដ្ឋាភិបាលរបស់ខ្លួន តាំងពីព្រះករុណា "ព្រះអង្គដួង" ដល់ព្រះករុណា "នរោត្តម សីហនុ" មិនបានបោះបង់ចោលនូវសិទ្ធិត្រឹមត្រូវតាមច្បាប់របស់ខ្លួន នៅលើខេត្តទាំងឡាយរបស់ខ្លួននៅកម្ពុជាក្រោមនោះឡើយ ដោយនៅមានគតិយុត្តអធិបតេយ្យភាពពេញលេញរបស់ខ្លួន នៅលើផ្នែកនៃទឹកដីរបស់ខ្លួននេះនៅឡើយ ។

កថាខ័ណ្ឌ ៣៩១នៃបញ្ជីលំដាប់នៃសំណួរ ស្តីពីច្បាប់អន្តរជាតិទូទៅ ដែលបានចោទសួរនៅចំពោះមុខសមាគមរបស់បណ្ឌិតប្រជាជាតិ បានបញ្ជាក់យ៉ាងច្បាស់អំពីជំហរគតិយុត្តរបស់ប្រទេសកម្ពុជានេះ" គឺ : **"អធិបតេយ្យភាពនៃទឹកដីមួយ មិនត្រូវបានផ្ទេរជាស្ថាពរឡើយ ល្គិកណារដ្ឋដែលមានអធិបតេយ្យភាពនេះ មិនបានបោះបង់ចោលដោយដាក់លាក់នូវសិទ្ធិទាំងឡាយរបស់ខ្លួននោះ"**

ការកាន់កាប់របស់បារាំងនៅកូសាំងស៊ីន មិនបានកែប្រែជំហរគតិយុត្តរបស់ប្រទេសកម្ពុជា នៅលើខេត្តទាំងឡាយរបស់ខ្លួននៅភាគខាងត្បូងប្រទេសនេះទេ ។

រដ្ឋមួយដែលគ្រាន់តែបានប្រគល់នូវសិទ្ធិរបស់ខ្លួន ដើម្បីគ្រប់គ្រងយុត្តិធម៌ ឬក៏ដើម្បីថែរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយនៅក្នុងខេត្តមួយនៃខេត្តទាំងឡាយរបស់ខ្លួននោះ មិនបានបាត់បង់នូវអធិបតេយ្យភាពរបស់ខ្លួន នៅលើផ្នែកនៃទឹកដី

www.elibraryofcambodia.org

របស់ខ្លួននោះទេ គឺជាអ្វីដែលបាននិយាយនៅក្នុងកថាខ័ណ្ឌ២៨២របស់បញ្ជីសំណួរដូចគ្នានេះ ហើយនេះគឺជាអត្ថបទ :

"រដ្ឋមួយដែលបានប្រគល់ឲ្យរដ្ឋមួយទៀត នូវសិទ្ធិដើម្បីគ្រប់គ្រងនូវយុត្តិធម៌ និងដើម្បីថែរក្សាសណ្តាប់ធ្នាប់នៅក្នុងផ្នែកមួយនៃទឹកដីរបស់ខ្លួន ក៏ដូចជាសិទ្ធិដើម្បីការពារនោះ មិនបានបាត់បង់នូវ**អធិបតេយ្យភាព**របស់ខ្លួន នៅលើផ្នែកនៃទឹកដីរបស់ខ្លួននេះឡើយ **ដរាបណាខ្លួនរក្សានូវសិទ្ធិនៃការផ្ទេរនេះ**" ។

**នោះហើយនៅលើលក្ខខ័ណ្ឌគតិយុត្ត ។**

**នៅលើលក្ខខ័ណ្ឌទី៣** អធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ត្រូវបានបញ្ជាក់អះអាងដោយ "**ភស្តុតាង**" ជាច្រើន ដោយកេរដំណែលពីអតីតកាល ដោយបូជនីយដ្ឋានជាស្លាដៃរបស់អ្នកស្រុកខ្មែរក្រោម ដោយវត្តអារាម និងភូមិខ្មែរទាំងឡាយដែលស្ថិតនៅបច្ចុប្បន្ននៅទូទាំងកម្ពុជាក្រោម ។

**ភស្តុតាង**ទាំងនេះត្រូវបានបំពេញដោយការនិទានរឿងរបស់អ្នកដំណើរជនជាតិអឺរ៉ុបលើកដំបូង ជាពិសេសជនជាតិព័រទុយហ្គេ និង អេស្ប៉ាញ៉ុល ដែលបានមកជាន់ដីខ្មែរនៅមុនការមកដល់របស់បារាំងនៅកម្ពុជាក្រោម ។

ចំណែកការគូរផែនទីរបស់លោកខាងលិច ក៏បានអះអាងដ៏ច្បាស់លាស់ផងដែរអំពី "កូសាំងស៊ីន ដែលហៅថាកូសាំងស៊ីនបារាំងសែស" នោះ គឺជារបស់ព្រះរាជាណាចក្រកម្ពុជា ។

ការសិក្សាលើកត្តាទាំង៣នេះ (ប្រវត្តិសាស្ត្រ គតិយុត្ត និង ភស្តុតាង) នៃស្ថានភាពរបស់កម្ពុជាក្រោមដូច្នេះ នឹងធ្វើឲ្យឃើញច្បាស់នូវ "**អធិបតេយ្យភាពជាអចិន្ត្រៃយ៍របស់ប្រទេសកម្ពុជា នៅលើទឹកដីកម្ពុជាក្រោម**" ។

ទោះបីជាមានការកែប្រែដែលផ្តល់ដល់លក្ខន្តិកៈនៃ "កូសាំងស៊ីន" (ការធ្វើអនុប្បទានកូសាំងស៊ីនទៅឲ្យបារាំងដោយអធិរាជអណ្ណាម បន្ទាប់មកការធ្វើអនុប្បទាន

www.elibraryofcambodia.org

ដោយបារាំងទៅឲ្យអធិរាជ "បាវ ដាយ" ការបង្កើតនូវសាធារណរដ្ឋវៀតណាមខាងត្បូង) ដីទាំងនេះដែលប្រជាជនកម្ពុជា ហៅជានិច្ចថា **កម្ពុជាក្រោម** នោះ ហើយ ដែលបារាំងបានដាក់ឈ្មោះថា "កូសាំងស៊ីន បារាំងសែស" នោះស្ថិតនៅជារបស់កម្ពុជាជានិច្ច ឯចំណែកលិខិតនៃការធ្វើអនុប្បទានទាំងអស់ ដែលទាក់ទងទៅនឹងខេត្តទាំងឡាយរបស់កូសាំងស៊ីន គឺទុកជា មោឃៈដោយពេញច្បាប់ ។

ជាពិសេសទៅទៀត លិក្ខិតទាំងឡាយដែលធ្វើឡើងដោយរដ្ឋសភាបារាំង នៅក្នុងអំឡុងពេលនៃការជជែកដេញដោលស្តីពីការផ្លាស់ប្តូរលក្ខន្តិកៈកូសាំងស៊ីន បានបង្ហាញច្បាស់នូវភាពត្រឹមត្រូវនៃនិក្ខេបបទរបស់**សម្តេចព្រះ នរោត្តម សីហនុ** គឺ : **"បើសិនជាប្រទេសបារាំងបានធ្វើលិក្ខិតទាំងនេះ នៅក្នុងលិខិតនៃការធ្វើអនុប្បទាន កូសាំងស៊ីនទៅឲ្យវៀតណាម គឺព្រោះតែបារាំងបាននិយាយថា កូសាំងស៊ីនមិនមែនជារបស់ខ្លួន ។ ហើយបើសិនជាបារាំងប្រគល់ទៅឲ្យវៀតណាម និងមិនមែនជាការធ្វើបច្ចានុប្បទាន"** (rétrocède) **នោះដែរ ព្រោះតែបារាំងបាននិយាយថា តាមគតិយុត្ត ដីនេះមិនដែលជារបស់អណ្ណាមទាល់តែសោះ ។ ដីនេះគឺជារបស់កម្ពុជា"** ។

**"...ចូរព្យាយាមឲ្យច្រើនបំផុត, ឲ្យអស់ពីកម្លាំងដែលអ្នកអាចធ្វើទៅបាន ក្នុងការចងមិត្តជាមួយនឹងមនុស្សដែលខ្ពស់ជាងអ្នក"** ។

www.elibraryofcambodia.org

# ជំពូកមួយ

## គ្រឹះប្រវត្តិសាស្ត្រនៃអធិបតេយ្យភាព របស់ប្រទេសកម្ពុជានៅលើ "កូសាំងស៊ីន"

**អធិបតេយ្យភាពរបស់ប្រទេសកម្ពុជានៅលើកូសាំងស៊ីន ត្រូវបានរៀបចំដោយប្រវត្តិសាស្ត្រ ។**

ប្រវត្តិសាស្ត្របង្ហាញថា ការឯកភាពរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានសម្រេចឡើងដោយការរំលាយបញ្ចូលគ្នានូវរបនទ្បាទឹកលិចពីសម័យបុរាណ ហ្វូណន នៃវស្សិកប្រវត្តិ (សៀវភៅដំណាលពីព្រឹត្តិការណ៍រាល់ឆ្នាំ) (annale) របស់ចិនជាមួយនិងរបនទ្បាដីគោក និងភាគខាងជើងនៃប្រទេសកម្ពុជាសម័យថ្មី ។

ចំពោះការបង្រួបបង្រួមនេះ ដែលប៉ុនប៉ងធ្វើឲ្យបានសម្រេចនៅសតវត្សរ៍ទី១៥ នោះ ការចូលលុកលុយរបស់ពួកអណ្ណាម ត្រូវបានវាយប្រយុទ្ធដោយឥតឈប់ឈរ ដោយប្រជាជនខ្មែរ ។

ក្រោយការមកដល់របស់បារាំង យើងបានឃើញនូវការកំណត់ព្រំដែនមួយ ដែលរំលោភមកលើប្រទេសកម្ពុជា និងកូសាំងស៊ីន ដែលហៅថា "កូសាំងស៊ីនបារាំងសែស" នោះ ។

ការរៀបចំគំនូសនៃព្រំដែននេះ បានរំលោភយ៉ាងអាក្រក់មកលើអធិបតេយ្យភាពនៃទឹកដីរបស់កម្ពុជា, ហើយត្រូវបានសម្រេចជាឯកតោភាគីដោយពួកអាជ្ញាធរបារាំង ដោយពុំមានការព្រមព្រៀងរបស់សាមីប្រទេសឡើយ គឺព្រះមហាក្សត្ររបស់ប្រទេសកម្ពុជា ។

ដូច្នេះនៅក្នុងជំពូកមួយនេះ យើងមានរឿងពីរសម្រាប់និយាយ គឺ :

**- ផ្នែកមួយ, អំពីការបង្កើតព្រះរាជាណាចក្រកម្ពុជា ។**

www.elibraryofcambodia.org

**- ផ្នែកពីរ, អំពីបុរាណកាលទឹកដីនៃប្រទេសកម្ពុជា ដែលលាតសន្ធឹងទៅដល់កូសាំងស៊ីន ។**

* *
*

## ផ្នែកមួយ
## ការបង្កើតព្រះរាជាណាចក្រកម្ពុជា

ការសិក្សាអំពីការបង្កើតព្រះរាជាណាចក្រកម្ពុជានេះ ធ្វើឲ្យគេបង្ហាញបាននូវក្របខ័ណ្ឌភូមិសាស្ត្រដែលចារិកអំពីអធិបតេយ្យភាពរបស់ខ្លួន ។ អាចឲ្យយើងដកបាននូវសេចក្ដីសន្និដ្ឋានថា : កូសាំងស៊ីនគឺជាផ្នែករួមបញ្ចូលរបស់ព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងការរំលឹកអំពីប្រវត្តិសាស្ត្រនេះ គេនឹងត្រូវពិនិត្យមើលមួយម្ដងៗនូវដំណាក់កាលធំៗដូចតទៅនេះ គឺ :

I.- អំពីបុរេប្រវត្តិសាស្ត្រ មកដល់ដំណាក់កាលប្រមូលរួបរួមតែមួយ ។

II.- សម័យកាលនៃរដ្ឋកាលបង្រួបបង្រួម ចេនឡា និង ហ៊្វូណន ។

III.- សម័យកាលនៃការវាតទី ឬសម័យកាលអង្គរ ។

IV.- សម័យកាលក្រោយអង្គរ ។

### I)- ពីបុរេប្រវត្តិសាស្ត្រ មកសម័យកាលបង្រួបបង្រួម

ជារួម ពួកអ្នកប្រវត្តិសាស្ត្រ និងពួកអ្នកបុរាណវិទូ បានយល់ស្របគ្នាថា សម័យ

www.elibraryofcambodia.org

néolithique ឬយុគថ្មរំលីង *(សម័យដែលមនុស្សយកថ្មធ្វើជារបស់ប្រើប្រាស់)* កុលសម្ព័ន្ធ "មន-ខ្មែរ" បានកាន់កាប់ឧបទ្វីបឥណ្ឌូចិន ។ ដូច្នេះជាតិសាសន៍ខ្មែរបាន កើតមានចាប់តាំងពីប្រហែលម្ភៃសតវត្សរ៍មុន គ្រិស្តសករាជ ។

ក្រុម "មន-ខ្មែរ" នេះ បានតាំងទីលំនៅ នៅលើអាងនៃទន្លេទាំង៣ គឺទន្លេ **មេគង្គ មេណាម** និង **ឥរាវតី** (Irawadi - *មហានទី នៃទឹកសន្សើម)* ។

នៅក្នុង "ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា" លោក Dauphin Meunier អនុប្រធាននៃសមាគមភូមិសាស្ត្រ សេដ្ឋកិច្ចបារាំង ក្រោយពីបានយកចេញពីក្នុង អត្ថបទរបស់សាលាបារាំងនៅចុងបូព៌ាប្រទេសមក បានសរសេរអំពីបុរេប្រវត្តិ សាស្ត្រខ្មែរថា :

"ប្រជាជនកម្ពុជា ឬដូចដែលពួកគេបានឲ្យឈ្មោះពួកគេផ្ទាល់ថា ជា**ខ្មែរ**នោះ បង្កើតនូវក្រុម អូស្ត្រូ-អាស៊ី (austro-asiatique) មួយ ដែលតាំងទីលំនៅ នៅ ឥណ្ឌូចិន ចាប់តាំងពីជំនាន់ *(*néolithique*)* ប្រហែលជាម្ភៃ សតវត្សរ៍មុនសករាជ យើងនេះ ។ ក្រុមនេះនៅមានតំណាងរបស់ពួកគេនៅឡើយ នៅប្រទេសភូមាខាង ក្រោម និងនៅតាមដួរភ្នំអណ្ណាម ។សមាសភាពនៃជនជាតិ ម៉ុងហ្គោលី គឺមាននៅ ទីនោះថ្មីៗបំផុត ។

"ប្រជាជនទាំងឡាយនៅឥណ្ឌូចិន, ប្រជាជនខ្មែរ គឺជាប្រជាជនដែលកាន់កាប់ ចាស់ជាងគេបំផុត នូវទីលំនៅរបស់ខ្លួន ។ មានតែរាប់ពាន់ឆ្នាំយូរក្រោយមកទេ គឺនៅសតវត្សរ៍ទី១៣នៃសករាជរបស់យើងនេះ ដែលទាក់ទាញដោយដីសណ្ដនិង ដោយសមុទ្រ និងការដេញពីចិនដោយពួកម៉ុងហ្គោលីនោះទេ ទើបបានលេចឡើង ប្រជាជនវៀតណាម ប្រជាជនថៃ និងប្រជាជនភូមា ដែលបានរុញច្រានប្រជាជន ខ្មែរនិង ឪពុកម្ដាយជិតជិតរបស់ពួកគេ គឺប្រជាជន"មន"ពីទន្លេមេណាម និងទន្លេ "ឥរាវតី" ។

www.elibraryofcambodia.org

នៅក្នុងសៀវភៅមួយដែលនិយាយអំពីអាដ្ឋាធរ "អង្គរ មនុស្ស និង ថ្ម" បុរាណវត្ថុវិទូដ៏ឧត្តម លោក Bernard Philippe Groslier អ្នកទទួលមរតករបស់អ្នកជីកកកាយបុរាណវត្ថុខ្មែរ អតីតអគ្គនាយកនៃសាលាបារាំងនៅចុងបូព៌ាប្រទេស (១៩៥០-១៩៥៤) បានផ្តល់នូវភាពជាក់លាក់នៅលើក្របខ័ណ្ឌទាំងពីរនេះ គឺភូមិសាស្ត្រ និងប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា ។

របទាសម្ព័ន្ធរូបសាស្ត្រនៃប្រទេសកម្ពុជា តាមលក្ខណៈភូមិសាស្ត្រត្រូវបានបង្កើតឡើងជាពីរផ្នែក មួយផ្នែកដែលមានភ្នំច្រើនលាតសន្ធឹងទៅខាងជើងភ្នំដងរែក និងមួយផ្នែកទៀតលិចទឹក លាតសន្ធឹងទៅខាងត្បូងជួរភ្នំអណ្តាម និងជួរភ្នំដងរែក តំបន់ដែលបុរាណវត្ថុវិទូហៅថា "ប្រទេសខាងក្រោម" ដែលត្រូវបានគេកំណត់ទុកថា ជាតំបន់ប្រសប់មុខគ្នានៅអាស៊ី ។

គេអាចសង្កេតឃើញទៀតពីភ្នំគូលេន នូវស្នាដៃនៃរលកសមុទ្រ ដែលបានពង្រីកថ្មនៅផ្នែកដែលមានភ្នំច្រើននៅដងរែកបន្តិចម្តងៗ ។ ដូច្នេះ "ប្រទេសខាងក្រោម" នៅដើមកំណើត គឺជាឈូងដីពិតប្រាកដមួយនៅជើងភ្នំដងរែក ។ គឺជាការងាររបស់សមុទ្រ ដែលធ្វើឲ្យលេចចេញពីដីនូវដុំថ្មធំៗកម្រាស់ប្រហែល២០ម៉ែត្រ ស្ថិតនៅកំពូលនៃភ្នំគូលេន ហើយដែលត្រូវបានគេឆ្លាក់ធ្វើជារូបភាព របស់ "ព្រះពុទ្ធចូលនិព្វាន" ។

គឺទន្លេមេគង្គដែលបានកសាងប្រទេសកម្ពុជាបច្ចុប្បន្ន និងកម្ពុជាក្រោម (អតីតកូសាំងស៊ីន) ដោយសារដីល្បាប់ដ៏មានជីវជាតិរបស់ខ្លួន ។

សូមស្តាប់លោក B.P. Groslier និយាយ :

**"ប្រទេសកម្ពុជាស្ថិតនៅលើទីទនដលិកបឋមដ៏សំខាន់មួយ គ្របដណ្តប់ដោយស្រទាប់ថ្មភក់ ។ ទល់នឹងថ្មភក់ទន់ៗនេះ រលកសមុទ្រមកពីភ្នំហិមពាន្ត បានហៀរហូរចូល, ប៉ុន្តែដោយអស់កម្លាំងរួច ទើបវាគ្រាន់តែអាចគ្របដណ្តប់ និងស្ថិតនៅ**

www.elibraryofcambodia.org

**ព័ទ្ធជុំវិញសងខាង និងស្ថិតនៅបន្ទាំងនៅក្នុងពាក់កណ្ដាលរង្វង់មូលនៃភ្នំទាំងឡាយ : ភ្នំក្រវាញ ផ្លូវភ្នំដងរែក មាត់តែមខាងលិចនៃខ្ពង់រាប "ម៉ុយ" (moï) ។ បន្ទាប់មកសមុទ្របានចូលពាសពេញប្រទេសខាងក្រោមទាំងអស់ បង្កើតបានជាឈូងសមុទ្រដ៏ធំមួយនៅជើងភ្នំដងរែកនេះតែម្ដង...។ ទន្លេមេគង្គគឺជាអ្នកកសាងដីសម្បើមមួយ ។ ការពូនដោយយឺតៗនូវដែនឥណ្ឌូចិន វាបានលុបបន្តិចម្ដងៗនូវឈូងនេះ និងបានរបនាថ្មភក់ ដីទន់នេះ និងដីល្បាប់ដ៏មានជីវជាតិរបស់វានៅប្រទេសកម្ពុជា និងកូសាំងស៊ីន បច្ចុប្បន្ន" ។**

ដើម្បីពិពណ៌នាអំពីអាថ្វាបញ្ហានៃភូមិសាស្ត្ររបស់ប្រទេសកម្ពុជា លោក Groslier បានសរសេរថា :

**"របនាសម្ព័ន្ធរូបសាស្ត្រ ក៏ដូចជាអាកាសធាតុរបស់ខ្លួន បានគូសនូវខ្សែបន្ទាត់ដ៏ធំនៃវាសនារបស់ខ្លួន..." ហើយលើសពីនេះទៀត : "ប្រទេសកម្ពុជានៅទីបញ្ចប់គឺជាកន្លែងប្រសប់មុខមួយ ។ ជាផ្លូវបំបែកលើដីឆ្ពោះទៅប្រទេសសៀម ទៅឯនាយទៀតដល់ប្រទេសភូមា បន្ទាប់មកប្រទេសឥណ្ឌា ឆ្ពោះទៅឆ្នេរសមុទ្រខាងកើត និងទ្វីបចិន ឆ្ងាយទៅដល់ប្រទេសលាវ ផ្លូវបំបែកនេះបានជ្រុលទៅមុខថែមទៀត តាមចុងខាងត្បូងរបស់ខ្លួន ទៅដល់បេះដូងនៃសមុទ្រចិន ដែលវាមានលក្ខណៈបន្តិចដូចជាស្បែកជើងកវែងរបស់អ៊ីតាលី នៅសមុទ្រម៉េឌីទែរ៉ាណេ ។**

**"កុំមានប្រទេស ឥណ្ឌូចិនណាមួយ ត្រូវបានផ្ដល់នូវអត្ថប្រយោជន៍ច្រើនដូច្នេះឡើយ ហើយខ្មែរបានប្រើប្រាស់នូវអំណោយធម្មជាតិទាំងនេះ ដើម្បីកសាងអារ្យធម៌ដ៏ភ្លឺចិញ្ចាចក្រៃលែង ដូចដែលគេបានឃើញការលូតលាស់នៅសមុទ្រខាងត្បូង" នោះស្រាប់ ។**

ការពិពណ៌នាដ៏ត្រឹមត្រូវ និងគួរឲ្យចាប់អារម្មណ៍ខ្លាំងនេះ បានធ្វើឲ្យលេចឡើងនូវអាថ្វាបញ្ហាភូមិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលពីដើមមានព្រៃដែនធម្មជាតិ

www.elibraryofcambodia.org

របស់ខ្លួនយ៉ាងធំទូលាយក្រៃលែង ។

ហេតុដូច្នេះហើយនៅក្នុងអាងនៃទន្លេធំៗទាំង៣ ទន្លេមេគង្គ មេណាម និង ឥរាវតី គឺមានក្រុម"មន-ខ្មែរ"តាំងនៅ ។ ចំណែកពួកអណ្ណាម និងពួកថៃ ពួកគេបានកកើត នៅលើដីសណ្តនៃទន្លេក្រហមនិងទន្លេខៀវ ។

លោក B.P. Groslier បាននិយាយចំពោះបញ្ហានេះថា :

"ហេតុដូច្នេះហើយនៅភាគខាងត្បូងនៃឥណ្ឌូចិន ស្របជាមួយនឹងពួកអណ្ណាម និងពួកថៃ ដែលបានកកើតនៅលើដីសណ្តនៃទន្លេក្រហម និងទន្លេខៀវនោះ ក្រុម "មន-ខ្មែរ"បានរីកចម្រើននៅក្នុងអាងនៃទន្លេមេគង្គ មេណាម និង ឥរាវតី..."។

នៅក្នុងទំហំរបស់ខ្លួន "ប្រជាជនខ្មែរដែលមានដើមកំណើតពីអង្គរនៅប្រទេស កម្ពុជាបច្ចុប្បន្ន" លោក André Migot បានផ្តល់នូវការពិពណ៌នាអំពីព្រំដែន ប្រទេសកម្ពុជាពីដើមថា : "...ប្រទេសកម្ពុជាបានលយហៀរចេញយ៉ាងធំទូលាយនូវ វិសាលភាពទឹកដីរបស់ខ្លួន ដែលបច្ចុប្បន្នវិសាលភាពនេះត្រូវបានរួញ ពីព្រោះ ថាវាមានដី**ឧបទ្វីបកោះ**កូសាំងស៊ីន (វៀតណាមខាងត្បូងបច្ចុប្បន្ន) មួយភាគនៃវៀត ណាមកណ្តាល និងប្រទេសថៃ" ។ A.Migot បានចម្លងឡើងវិញនូវផែនទីប្រវត្តិ សាស្ត្រ និងបុរាណវត្ថុវិទ្យាដ៏គួរឲ្យចាប់អារម្មណ៍មួយរបស់ឥណ្ឌូចិននៅសតវត្សរ៍ ទី១១ ទី១២ និងទី១៣ ដែលបានបង្ហាញនូវ "ចក្រភពខ្មែរ-កំប៊ុយហ្សាដេសា" (Empire Khmer-Kambujadeca) ដែលបានកាន់កាប់ឧបទ្វីបឥណ្ឌូចិនស្ទើរតែ ទាំងអស់ និងមួយភាគនៃទឹកដីសៀម ។

A.Migot បានផ្តល់ការពិពណ៌នាដូចតទៅនេះ គឺ :

ផែនទីភូមិសាស្ត្រមួយរបស់ឥណ្ឌូចិនបានបង្ហាញនូវការក្រឡេកមើលជាដំបូង ថា គ្រោងឆ្អឹងរបស់ខ្លួនត្រូវបានបង្កបង្កើតឡើងដោយ ភ្នំខ្ពស់ៗ និងយ៉ាងវែង គឺជួរភ្នំ អណ្ណាម ។ កើតចេញពីភ្នំធំៗទាំងឡាយនៅតុងកឹងលើ នៅយុនណាន និងនៅភូមា

www.elibraryofcambodia.org

កំពែងដែលជ្រុលទៅមុខរបស់ហិមពាន្តខាងកើត ហើយនិងខ្ពង់រាបរបស់ទិបេ វ៉ា បង្កើតបានជាថ្ពើងខ្ពង់នៃឧបទ្វីប គ្របដណ្តប់ស្ថានភាពដីដ៏សម្បើមរបស់ខ្លួន, កំពូលភ្នំទាំងឡាយរបស់ខ្លួន ដែលកំពូលភ្នំខ្លះមានកម្ពស់លើសពី២,០០០ម. ឆ្នេរសមុទ្រដ៏វែង និង យ៉ាងវិចិត្ររបស់អណ្តាម ដោយបានកប់បាត់នៅលើខ្ពង់រាប ដារឡាក់ (Darlac) និងជ្រោយសិលាខ្ពស់ៗនៃជ្រោយ Vorella ជ្រោយ Padaran និងជ្រោយ Saint-Jacques នៅមិនឆ្ងាយប៉ុន្មានពីសាយហ្គន ដែលវ៉ាបានលិចនៅក្នុងសមុទ្រចិន" ។

នៅក្នុងភាគបន្តនៃសៀវភៅរបស់លោក A.Migot បានរាយការណ៍អំពីភាពខុសគ្នា ដែលកើតមានរវាងប្រទេសវៀតណាមនិងប្រទេសខ្មែរ ។ គាត់បាននិយាយថា មជ្ឈដ្ឋានភូមិសាស្ត្រនេះមិនមែនជាឧបទ្ទវហេតុភូមិសាស្ត្រនោះទេ ។ តាមពិតជួរភ្នំអណ្តាមនេះបានខណ្ឌតំបន់ពីរដែលមានវិសាលភាពមិនស្មើគ្នាទេ និងមានប្រជាជន ភាសា វប្បធម៌ និង សាសនារបស់ពួកគេខុសគ្នាទាំងស្រុង ។ A.Migot បាននិយាយថា : **"គឺពិភពលោកពីរ ដែលគេអាចហៅដោយបំព្រួញថា ឥណ្ឌា និង ចិន ។ បើសិនជាវៀតណាមជារបស់ពិភពលោកចិន ប្រទេសខ្មែរគឺជារបស់ពិភពលោកឥណ្ឌា"** ។

ដូច្នេះគ្របខ័ណ្ឌភូមិសាស្ត្រនេះមានការទាក់ទងគ្នាជាមួយនឹងគ្របខ័ណ្ឌនយោបាយ និងសង្គម ។ នៅពេលចាប់ផ្តើមនៃប្រវត្តិសាស្ត្រ គឺមានការបញ្ជាក់នៃភូមិសាស្ត្រដែលបង្កើតនូវប្រជាជនមួយ នូវអារ្យធម៌មួយ ។ នៅផ្នែកខាងត្បូងទាំងអស់នៃ "កំពែងលយទៅមុខ" នេះ នៅអាស៊ីអាគ្នេយ៍ដែលជាដីឡើបកោះឥណ្ឌូចិន ត្រូវបានរស់នៅដោយសាសន៍មួយដែលហៅថាខ្មែរ ដូចនៅភាគខាងជើងត្រូវបានរស់នៅដោយសាសន៍វៀតណាមដើមកំណើតចិន និងដោយសាសន៍ថៃមានដើមកំណើតដូចគ្នា ។ ជួរភ្នំអណ្តាម ទន្លេមេគាម និងសមុទ្រចិន ហ៊ុមព័ទ្ធទៅដោយ

www.elibraryofcambodia.org

ស្ថានភាពភូមិសាស្ត្ររបស់អតីតប្រទេសកម្ពុជា ។

តាមការសិក្សារបស់ពួកបុរាណវត្ថុវិទូ ពួកគេបានសន្និដ្ឋានថា គឺមកដល់សតវត្សរ៍ទី១នៃគ្រិស្តសករាជ ដែលក្រុម"មន-ខ្មែរ"បានទទួលរងនូវឥទ្ធិពលពីឥណ្ឌា ។ ការនាំមករបស់ជនជាតិឥណ្ឌាទាំងនេះ (សម័យកាលឥណ្ឌាភាវូបនីយកម្ម) ដែលបានបន្ថែមទៅលើការនាំមករបស់ជនជាតិមុំងហ្គោល ក៏បានកើតឡើងនូវអារ្យធម៌ ឥណ្ឌា-មន -ខ្មែរ ។

នៅឆ្នាំ៥០ ព្រឹត្តិការណ៍របស់ព្រះបាទ កោណ្ឌញ្ញ (Kaundinya) បាននាំមកនូវសម្ពុះថ្មីនៃអារ្យធម៌ឥណ្ឌា-មន-ខ្មែរ ។

បន្ទាប់មកទៀតយើងបានមកដល់សម័យកាល "Proto-Khmère" ដែលបានផ្សាយចេញទៅគ្រប់ទិសទីនៅក្នុងអំឡុងជាច្រើនសតវត្សរ៍ (ពីសតវត្សរ៍ទី២ដល់សតវត្សរ៍ទី៦) ។

អារ្យធម៌ "ខ្មែរដើម" "Proto-Khmère" ត្រូវបានកត់សម្គាល់ដោយការរីកចម្រើនដ៏អស្ចារ្យនៅកម្ពុជាក្រោម ដែលមានកំពង់ផែដ៏សំខាន់មួយនៅ Oc-Eo (អុកអែវ ឬអូរកែវ) បានទទួលនាវារបស់អ្នកធ្វើជំនួញដែលនៅឆ្ងាយក្រៃលែងពីឆ្នេរសមុទ្រអាស៊ី ហើយប្រហែលជាមកពីអាហ្វ្រិកផងដែរ ។ ពិសេសទៅទៀត Oc-Eo មិនគ្រាន់តែជាកំពង់ផែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបុរីសមុទ្រមួយដ៏ពិតប្រាកដដែលត្រូវបានដាក់ឲ្យដំណើរការ និងសិក្សាដោយពួកបុរាណវត្ថុវិទូ នៅសាលាបារាំងចុងបូព៌ាប្រទេស ។ វាជាភស្តុតាងដែលមិនអាចប្រកែកបាន និងពិតប្រាកដថាកូសាំងស៊ីនគឺជារបស់ព្រះរាជាណាចក្រខ្មែរ ។

ក្នុងពេលដែល Oc-Eo ស្គាល់នូវភាពរីកចម្រើនបែបនេះ "ព្រៃនគរ","ព្រះរាជព្រៃ" របស់មហាក្សត្រខ្មែរ បានកាន់កាប់ទីកន្លែងនៃទីក្រុងសាយហ្គនបច្ចុប្បន្ន ។ ព្រៃនគរគឺជាកន្លែងព្រះរាជដំណាក់របស់ព្រះមហាក្សត្រខ្មែរ ចាប់តាំងពីសតវត្សរ៍

www.elibraryofcambodia.org

ទី៣មុនគ្រិស្តសករាជ ។ លោក Sylvestre នៅក្នុងសៀវភៅមួយដែលនិយាយអំពីអាណាចក្រអណ្ណាម បានថ្លែងដោយគាំទ្រអាជ្ញាធរ Aymônier និង Francis Garnier ថា :

"ព្រះមហាក្សត្រ Aschay ត្រូវបានដកហូតរបស់ទ្រព្យដោយប្រជាជនខ្មែរនៅឆ្នាំ២៨៩ មុនគ្រិស្តសករាជ ហើយថាពួកចាមដែលបានតាំងទីលំនៅនៅក្នុងប្រទេសគោកធ្លក គឺថាប្រទេសកម្ពុជាពេលនោះត្រូវបានបែកខ្ញែកនិងបរាជ័យ ហើយបានដកថយទៅទិសខាងត្បូង ។

"យូរក្រោយមក អ្នកផ្ញើសញ្ជ័យទឹកដី ពួកគេផ្ទាល់បានចុះរហូតដល់ព្រៃដងនៃមាត់ពាមសមុទ្រ (estuaire).... ។ ព្រះមហាក្សត្រខ្មែរមួយព្រះអង្គត្រូវបានគង់នៅសាយហ្គន ហើយឈ្មោះព្រៃនគរ "ព្រះរាជព្រៃ" ដែលយកធ្វើជារាជធានីនៅពេលនោះ "បានចង្អុលបញ្ជាក់នូវលិខិតភាពលំនៅ (état des lieux) យ៉ាងគ្រប់គ្រាន់"។

ចំណែក Oc-Eo បានថែរក្សាអារ្យធម៌ដ៏ត្រចះត្រចង់របស់ខ្លួន ក្នុងអំឡុងពេល ៤សតវត្សរ៍ ពីសតវត្សរ៍ទី២ដល់សតវត្សរ៍ទី៦ ។ លោក Dauphin Meunier បានពោល, ហើយដែលលោក Louis Malleret បានសរសេរបន្ត ចំពោះបញ្ហានេះថា **"កំពង់ផែដ៏សំខាន់របស់ព្រះរាជាណាចក្រ គឺ Oc-Eo នៅខាងត្បូងភ្នំបាថេ (Phnom Bathé) នៅក្បែរាំងស៊ីន នៅលើស្ថានីយ néolithique មួយដែលពួកអ្នកធ្វើដំណើរ តាមនាវាជនជាតិឥណ្ឌាបានស្គាល់រួចហើយនោះ"** ។

កំពង់ផែនេះមិនគ្រាន់តែទទួលសំពៅមកពីប្រទេសចិន ម៉ាឡេស៊ុី និងប្រទេសឥណ្ឌាប៉ុណ្ណោះទេ ប៉ុន្តែក៏មកពីប្រទេសហ្សុលឡង់ផងដែរ ដែលនាវាដឹកទំនិញទាំងនេះគឺដួលដោយពួកឈ្មួញមកពីខេត្តរបស់អាណាចក្ររ៉ូម៉ាំង នៅត្រង់ព្រៃប្រទល់សមុទ្រក្រហម ។ តាមការពិតគេបានរកឃើញនៅ Oc-Eo នៅជិតត្រា ដែលមានសិលាចារិកអក្សរសំស្ក្រឹត មានមេដាយមាសមួយ មានកាលបរិច្ឆេទតាំងពីឆ្នាំ១៥២

www.elibraryofcambodia.org

ដែលមានរូបសំណាកព្រះចៅអធិរាជរ៉ូម៉ាំង ព្រះនាម Antonin និងថ្មឆ្លាក់ក្រហូង មានដើមកំណើតនៅមេឌីទែរ៉ាណេ ។

កាសែត Le "Journal d'Extreme-Orient" នៅក្នុងលេខរបស់ខ្លួន ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ១៩៦២ បានផ្សាយនូវសេចក្ដីថ្លែងការណ៍ផ្លូវការមួយ ដែលនៅក្នុងនោះពួកអាជ្ញាធរវៀតណាមនៅកៀងយ៉ាង បានវាយតម្លៃ Oc-Eo ថាជាទីក្រុង "Venise នៅអាស៊ី" ។ ដូច្នេះពួកអណ្ណាមខ្លួនគេផ្ទាល់បានទទួលស្គាល់នូវការពិតនៃប្រវត្តិសាស្ត្រនៃតំបន់របស់ប្រទេសកម្ពុជានេះ ដែលពីដើមហៅថា ហ៊្វុណន នោះ ។ ដូច្នេះសេចក្ដីថ្លែងការណ៍នេះបានសម្ដែងឲ្យឃើញនូវកិត្តិនាមដ៏រុងរឿង និងភាពចម្រុងចម្រើនរបស់អារ្យធម៌ខ្មែរនៅក្នុងសម័យនោះ គឺ :

"Oc-Eo គឺជាតំបន់មួយស្ថិតនៅក្នុងចំណុះខេត្តកៀងយ៉ាង នៅជើងភ្នំបាថេ (Ba-thê) និងនៅទិសអាគ្នេយ៍ ។

បើតាមបុរាណវត្ថុវិទូ L.Malleret បានឲ្យដឹងថា Oc-Eo កាលពីពេលមុនគឺជាបុរីមួយ ប្រហែលថែមទាំងជារាជធានីរបស់ប្រទេសហ៊្វុណនទៀតផង ។ ក្នុងពេលបច្ចុប្បន្ននេះ វាគ្រាន់តែជាកូនភ្នំតូចមួយរាងចតុកោណកែង មានបណ្ដោយប្រវែង ៣គ.ម និងទទឹង១,៥គ.ម មានផ្ទៃសរុបប្រហែលជា ៤៥០ហិកតា គឺថាពាក់កណ្ដាលនៃផ្ទៃក្រឡាអង្គរធំ ។

បើតាមការស្រាវជ្រាវរបស់លោក L.Malleret, Oc-Eo ប្រហែលជាត្រូវបានហៅថា ជាទីក្រុង Venise នៅអាស៊ី ជាបុរីមួយដែលលយទៅក្នុងទឹក ជាមួយនឹងគេហដ្ឋានទាំងឡាយដែលត្រូវបានកសាងឡើងដោយសម្ភារៈស្រាល។ និងតម្រៀបជាជួរ ទៅតាមការប្រែប្រួលនៃជលធារាសាស្ត្រធម្មជាតិ ឬសិប្បនិម្មិត ។ នៅឯនេះខ្លះ ឯនោះខ្លះ គេឃើញមានព្រះវិហារធ្វើអំពីថ្មឬឥដ្ឋដែលនៅបច្ចុប្បន្ននេះ គេឃើញនៅសល់តែគ្រឹះខ្លះកប់នៅក្រោមស្រទាប់ដីជាច្រើននោះ ។

www.elibraryofcambodia.org

ដោយសារការស្រាវជ្រាវដីខ្លាប់ខ្លួន អ្នកបុរាណវិទូអាចរកឃើញឧបករណ៍ជាថ្មរលីង នូវគ្រឿងចានថ្នាំងធ្វើអំពីដី គជ់ និងខ្សែ-ក, កង-ក ធ្វើអំពីកែវ ឬអំពីថ្មមានតម្លៃរាប់ពាន់ រូបចម្លាក់និងសរណវត្ថុធ្វើអំពីសំណប៉ាហាំងជាច្រើន របស់ធ្វើអំពីដែក និងវត្ថុធ្វើអំពីមាសចំនួន១.៣០០ ដែលមានទម្ងន់១.១២០ក្រាម...។

មានបន្ទះដែកមួយចំនួនត្រូវបានឆ្លាក់ជាអក្សរបាលី ដោយសារចម្លាក់នេះគេអាចដឹងថា អារ្យធម៌នៅ Oc-Eo បានកើតមាននៅចន្លោះសតវត្សរ៍ទី២ និងសតវត្សរ៍ទី៣ និងបានទៅដល់ភាពរុងរឿងពេញបរិបូរណ៍របស់ខ្លួន នៅចន្លោះសតវត្សរ៍ទី៤ និងសតវត្សរ៍ទី៥ ។

អារ្យធម៌ Oc-Eo ត្រូវបានបង្កើតឡើងដោយការលាយបញ្ចូលគ្នានៃអារ្យធម៌ផ្សេងៗទៀតជាច្រើន ដែលអារ្យធម៌ទីមួយហើយដែលសំខាន់បំផុតនោះ គឺហាក់ដូចត្រូវបានបង្កើតឡើងដោយក្រុមមនុស្សមួយក្រុមមាន "ដើមកំណើតជាជនជាតិឥណ្ឌូនេស៊ី" ។ បន្ទាប់មកមានឈ្មួញឥណ្ឌាមួយចំនួនបានបន្សល់ទុកនូវស្នាមដ៏ជ្រៅនៃអារ្យធម៌ឥណ្ឌានៅក្នុងប្រទេសហ្វូណន ហើយប្រទេសឥណ្ឌាខ្លួនឯងផ្ទាល់ត្រូវផ្តល់នូវបរិមាណដ៏សំខាន់នៃវត្ថុធាតុដើម ដើម្បីអាចឲ្យ Oc-Eo ផលិតនូវវត្ថុឧស្សាហកម្ម និងវត្ថុសិល្បៈ ដែលយើងទើបនឹងបាននិយាយមកនេះ ។

ប្រព័ន្ធផ្លូវទឹកដែលមានស្ទើរតែគ្រប់គ្រាន់សម្រាប់ឲ្យប្រជាជនហ្វូណនរៀបចំទឹកដើម្បីបម្រើឲ្យវិស័យកសិកម្ម ។

ចំនួនគ្រឿងចានថ្នាំងធ្វើអំពីដី ដែលមិនអាចគណនាបាន ជួនកាលមានលក្ខណៈជារបៀបទៅជនបទ ជួនកាលមានលក្ខណៈជាសិល្បៈនោះ បានបង្ហាញឲ្យឃើញនូវការរាតទីនៃសិប្បកម្ម ។ ឧស្សាហកម្មធ្វើអំពីដែក និងសំណប៉ាហាំង ក៏បានឈានទៅដល់កម្រិតមួយនៃការរីកចម្រើនដែលមិនអាចបដិសេធបាន ហើយផលិតផលដ៏ប្រណីត ។ធ្វើឡើងដោយពួកជាងធ្វើ ថ្នាំង ខ្ទះ, ជាងតុបតែងលំអ និងជាងចម្លាក់

www.elibraryofcambodia.org

បាននាំមកនូវភស្តុតាងនៃកម្រិតដ៏ខ្ពស់របស់សង្គមមួយដែលមានការរៀបចំ និង ការបូជានៅក្នុងវិស័យសិល្បៈ ។

ប៉ុន្តែ កសិកម្មនិងឧស្សាហកម្ម មិនគ្រប់គ្រាន់ដើម្បីនាំមកនូវភាសារុងរឿង បែបនេះនៅ Oc-Eo នោះទេ, បើសិនជាគ្មានកត្តាជាមូលដ្ឋានគឺការទាក់ទងខាង ពាណិជ្ជកម្មជាមួយប្រទេសជិតខាងទេនោះ ។ នៅសម័យនោះ Oc-Eo មានចម្ងាយ ពីឈូងសមុទ្រថៃចំនួន១១គីឡូម៉ែត្រ (ឥឡូវនេះចម្ងាយ២៥ គ.ម ដោយសារមូល ហេតុទឹកនាចជាប្រចាំ) គឺជាកំពង់ផែពាណិជ្ជកម្មមួយដែលតភ្ជាប់ឈូងសមុទ្រ និងទន្លេមេគង្គដោយប្រឡាយទឹកជាច្រើន ។ ម្យ៉ាងទៀត Oc-Eo បានស្ថិតនៅកន្លែង ប្រសប់មុខនៃផ្លូវថ្នល់ នៅចន្លោះប្រទេសចិន ប្រទេសឥណ្ឌា និងបណ្តាប្រទេស លោកខាងលិច ។ មានវត្ថុជាច្រើនដែលត្រូវបានគេរកឃើញនៅ កន្លែងនេះបាន បង្ហាញស្រាប់ : លោក L.Malleret បានរកឃើញនូវមេដាយនៃ ទីក្រុងរ៉ូម ជា បន្ទះមាសដែលមានរូបសំណាក Antonin le Pieux ដែលមានកាលបរិច្ឆេទនៅ ឆ្នាំ១៥២ និងមនុស្សរាយរងម្នាក់ទៀត គឺ Marc Aurèl... ។

តាមការស្រាវជ្រាវដែលបានរំលឹកនៅក្នុងសេចក្តីថ្លែងការណ៍នេះ និងការនិទាន របស់អ្នកធ្វើដំណើរចិននោះ បានបង្ហាញឲ្យឃើញថា Oc-Eo មិនគ្រាន់តែរីក ចម្រើននៅលើវិស័យពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងវិស័យសិប្បកម្មនិង កសិកម្មផងដែរ ។

រឿងនិទានរបស់បេសកជនចិនបាននិយាយថា "ព្រះមហាក្សត្រខ្មែរទាំងឡាយ ដឹកនាំដោយប៉ិនប្រសប់នូវនយោបាយកសិកម្មរបស់ហ្វូណន ។ កសិកម្មមានការ រីកចម្រើនខ្លាំងណាស់ ជាពិសេសនៅប្រទេសក្រោម (កូសាំងស៊ីន) ដែលដីមានជីវ ជាតិល្អក្រៃលែង ។ ព្រះមហាក្សត្របានឲ្យគេសង់ទំនប់ទឹក និងជីកព្រែក ។ ស្នាដៃ របស់ព្រះមហាក្សត្រឃើញមាននៅឡើយនៅកូសាំងស៊ីន បច្ចុប្បន្ននេះ ។

www.elibraryofcambodia.org

លោក Dauphin Meunier បានសង្ខេបការងាររបស់អ្នកឯកទេសទាំងឡាយ និងជាពិសេសគឺការងាររបស់លោក L.Malleret ដែលជាអ្នករកឃើញ Oc-Eo បានសរសេរបន្ថែមទៀតអំពីបញ្ហាអារ្យធម៌ Proto-Khmère :

"កសិកម្មគឺចម្រុងចម្រើនណាស់ ។ ព្រះមហាក្សត្រទាំងឡាយ ទ្រង់ប្រុងប្រយ័ត្ន ចំពោះការកសាង និងការថែទាំអាងទឹក និងព្រែកជីក ដើម្បីស្រោចស្រពផ្ទៃស្រែ ។ ព្រះអង្គបានប្រែក្លាយកូសាំងស៊ីនក្រោម ពីដីភក់ឲ្យទៅជាដីល្បាប់ដ៏មានជីវជាតិ ដោយឲ្យគេជីកព្រែកបញ្ចូលទឹកសាបបានជាង២០០គ.ម និងបញ្ចេញទៅសមុទ្រ នូវទឹករីង (ធ្វើឲ្យជាទឹកស្មើនឹងមាត់សមុទ្រ) ។

**ដូច្នេះបើតាមអ្វីដែលបាននិយាយពីមុននេះ គេអាចសន្និដ្ឋានបានថា ខ្មែរបានរស់នៅ និងធ្វើឲ្យមានតម្លៃនូវដីកម្ពុជាក្រោម ចាប់តាំងពីសតវត្សរ៍ទី១នៃគ្រិស្តសករាជមកម្ល៉េះ ។**

ចំណែកនៅសាយហ្គន ឬព្រៃនគរ ត្រូវបានបង្កើតឡើងប្រហែល ពីរសតវត្សរ៍ មុនគ្រិស្តសករាជ គឺប្រហែលនៅឆ្នាំ២៨៩ មុនគ្រិស្តសករាជ ដែលព្រះមហាក្សត្រខ្មែរទាំងឡាយបានទៅគង់នៅនេះ បើតាមសៀវភៅ "អាណាចក្រអណ្ណាម" របស់លោក Sylvestre ។

ប៉ុន្តែពីសតវត្សរ៍ទី១ដល់សតវត្សរ៍ទី៦ ទឹកដីដែលបានបង្កើតព្រះរាជាណាចក្រកម្ពុជា ត្រូវបានចែកចេញជាពីរផ្នែក គឺ : ហ្វូណនខាងត្បូង នៅលើផ្នែកដែលលិចទឹករបស់អនាគតកូសាំងស៊ីន និងចេនឡាខាងជើង នៅលើអាងមធ្យមនៃទន្លេមេគង្គ ។

ដោយពន្យល់អំពីការបង្កើតព្រះរាជាណាចក្រខ្មែរ លោក B.P. Groslier នៅក្នុងសៀវភៅ "អង្គរ មនុស្ស និងថ្ម" *(ទំព័រ៩)* បានផ្តល់នូវសេចក្តីបញ្ជាក់ដូចតទៅនេះ ស្តីអំពីកំណើតរបស់រដ្ឋហិណ្ឌូពីរ ដែលជាបុព្វបុរសរបស់ប្រទេសកម្ពុជា

www.elibraryofcambodia.org

បច្ចុប្បន្ន គឺ :

– **ភូមិដែលទាក់ទងទៅនឹង ហ៊្វូណន** (LE FOUNAN)

"នៅកណ្ដាលសករាជនៃការវាតទីរបស់ឥណ្ឌាតែម្ដង ឥណ្ឌូចិនខាងត្បូងបានក្លាយទៅជាទីស្នាក់ការដ៏ខ្លាំងបំផុតរបស់រដ្ឋហិណ្ឌូ គឺ ហ៊្វូណន ។ ពីសតវត្សរ៍ទី២ដល់សតវត្សរ៍ទី៦ ព្រះរាជាណាចក្រនេះបានកាន់កាប់ភាគធំបំផុតនៃប្រទេសកម្ពុជាខាងត្បូង និងកូសាំងស៊ីនបច្ចុប្បន្ន ដោយពង្រីកនូវឥទ្ធិពលរបស់ខ្លួនកាន់តែកើនឡើងជាលំដាប់ទៅប្រទេសសៀម ម៉ាឡេស៊ី និងថែមទាំងទៅដល់ឆ្នេរសមុទ្រជ្វា (Java) ដ៏សែនឆ្ងាយ និងប្រទេសភូមាផងដែរ ។ ប្រជាជន"**មន–ខ្មែរ**"របស់ខ្លួន បានទទួលយ៉ាងច្រើននូវលក្ខណៈស្លាកស្នាមរបស់ឥណ្ឌា ។ គឺនៅក្នុងឡូវលាយរបស់ប្រជាជនហ៊្វូណនដែលបានរំលាយបញ្ចូលគ្នា នូវវត្ថុធាតុរបស់ជនអន្តោប្រាណ (ជនកើតក្នុងស្រុក) និងការនាំមករបស់ប្រជាជនឥណ្ឌា ដើម្បីបង្កើតអារ្យធម៌ដើមមួយដែលខ្មែរបានទទួលមរតក ហើយដែលបានដឿនលឿនដល់ភាពកំពូលរបស់ខ្លួននោះ ។

– **ចំពោះចេនឡា** (LE TCHENLA)

ស្របទៅនឹងហ៊្វូណនដែលបានរីកចម្រើននោះ ព្រះរាជាណាចក្រហិណ្ឌូមួយទៀតគឺចេនឡា ដែលស្ថិតនៅលើអាងមធ្យមនៃទន្លេមេគង្គ បានបង្ហាញអំពីសតវត្សរ៍នៃក្សត្រប្រទេស Kambuja ដែលនៅក្នុងនោះប្រទេសកម្ពុជាត្រូវយកឈ្មោះរបស់ខ្លួន ។ ការស៊ីជម្រៅនៃជាតិពន្ធុរបស់ខ្លួន ពិតជាពិបាកខ្លាំងណាស់ ថ្វីបើជា**មន–ខ្មែរ**ក៏ដោយ ក៏មានការខុសគ្នាបន្តិចបន្តួចពីប្រទេសហ៊្វូណនដែរ ។ សរុបមកពួកអ្នកស្រុកចេនឡាមានការវិវត្តន៍នៅក្នុងមជ្ឈដ្ឋានមួយផ្សេង មិនសូវរងឥទ្ធិពលរបស់ឥណ្ឌាប៉ុន្មានទេ ។ ទិកភាព ដើមនេះ(ការរួមគ្នាពីរផ្សេងគ្នា) ស្ថិតនៅយ៉ាងយូរនៅក្នុងអារ្យធម៌ខ្មែរដែលកើតចេញពីការបញ្ចូលគ្នានៃហ៊្វូណន និង ចេនឡា" ។

ការបញ្ជាក់របស់ B.P. Groslier ស្ដីអំពីការបង្កើតរដ្ឋខ្មែរទាំងពីរ គឺសំខាន់

www.elibraryofcambodia.org

ណាស់សម្រាប់ការសិក្សារបស់យើង ។ ការបញ្ជាក់នេះបានបញ្ជាក់អំពីដើមកំណើត របស់ពាក្យ "ខ្មែរ" មួយផ្នែក និងពាក្យ "Kambuja" មួយផ្នែកទៀត ។ ព្រមជាមួយ គ្នានេះ វាក៏ពន្យល់អំពីដើមកំណើតនៃមេ**សន្តតិវង្សកម្ពុជា**បច្ចុប្បន្ននេះដែរ ។

**ដោយហេតុនេះ មេសន្តតិវង្សខ្មែរកើតចេញពីការបង្កាត់រវាង "មន-ខ្មែរ" និង ហិណ្ឌូ និងមានដើមកំណើតរបស់វានៅ ហ៊្វូណន (នៅកម្ពុជាក្រោមទាំងអស់ គឺថា កូសាំងស៊ីនបូកបន្ថែមមួយផ្នែកនៃបណ្តាខេត្តបច្ចុប្បន្ននៅភាគខាងត្បូង)** ។

ចំណែក**មេសន្តតិវង្ស** "Kambuja" កើតចេញពីការបង្កាត់រវាង **"មន-ខ្មែរ** មុំងហ្គោល" និង "Kambuja មកពីឥណ្ឌា" ដើមកំណើតរបស់វាគឺនៅចេនឡា ។

បន្ទាប់មកទៀតក្រុម **"ឥណ្ឌូ-មនខ្មែរ"** នៅហ៊្វូណន ទទួលរងឥទ្ធិពលគួរឲ្យកត់ សម្គាល់យ៉ាងខ្លាំងពីចិន ។ ដូច្នេះប្រជាជននៅភាគកណ្តាលនៃប្រទេសកម្ពុជាបច្ចុប្បន្ន និងនៅកូសាំងស៊ីនទាំងមូល មានដើមកំណើតជាតិពន្ធុរួមបញ្ចូលគ្នា ច្រើនជាង បងប្អូនរបស់ខ្លួននៅភាគខាងជើង ដើមកំណើតនេះគឺជា**មេសន្តតិវង្ស "ចិន-ឥណ្ឌូ- មនខ្មែរ"** ។

លោក Groslier បានសម្គាល់ឃើញអំពីភាពខុសគ្នារវាងមនុស្សនៅហ៊្វូណន និងមនុស្សនៅចេនឡា ។ បច្ចុប្បន្ននេះក៏គេនៅបានសម្គាល់ឃើញថា ថ្វីបើមាន លក្ខណៈស្រាលក្តី ក៏ពន្ធុភាពនៃជាតិពន្ធុខុសគ្នារវាងខ្មែរនៅស្ទឹងត្រែង ក្រចេះ សៀម រាប កំពង់ធំ មួយផ្នែក និងខ្មែរក្រោមនៅកូសាំងស៊ីន ស្វាយរៀង តាកែវ ឬនៅ កំពតមួយផ្នែកទៀត ។ ចំណែកខ្មែរនៅកណ្តាលប្រទេស គឺនៅកំពង់ចាម កណ្តាល ជាឧទាហរណ៍គឺមានការកើតចេញពីការបញ្ចូលគ្នាបន្តិចបន្តួច រវាង**មេសន្តតិវង្ស** នៅហ៊្វូណន **(ក្រុមចិន-ឥណ្ឌូ-មនខ្មែរ)** និងមេសន្តតិវង្ស "Kambuja" នៅចេន ឡា ។

បច្ចុប្បន្នការខុសគ្នានេះ ដែលត្រូវបានគេកត់សម្គាល់នោះ គឺការសម្តែង

www.elibraryofcambodia.org

ចេញនៅក្នុងសំនៀងនិយាយ និងនៅក្នុងចិត្តគំនិតរបស់ប្រជាជនដែលកើតចេញពីក្រុមជាតិពន្ធុដើម មួយក្រុមឬក៏ក្រុមមួយទៀត ។

ទោះបីជាមានភាពខុសគ្នានៃដើមកំណើតនៃជាតិពន្ធុក៏ដោយ ក៏ទាំងអស់គ្នាបង្កើតបាននូវប្រជាជន "ខ្មែរ" នៅក្នុងពេលបច្ចុប្បន្ននេះ ដែលចារាំងហៅថា "ប្រជាជនកម្ពុជា" ។

**គេគ្រាន់តែត្រូវកត់សម្គាល់ថា ពាក្យ "ខ្មែរ" មកពីពាក្យ "មនខ្មែរ" ឬ "ខ្មែរនៅហ្វូណន" ហើយនិងពាក្យ "ប្រជាជនកម្ពុជា" មកពីពាក្យ "Kampuchea" ដែលមកពីពាក្យ "Kambuja" នៅចេនឡា ។**

**II)- ដំណាក់កាលបង្រួបបង្រួម ចេនឡា និង ហ្វូណន**

ថ្វីបើក្រុម **"មន-ខ្មែរ"** បានរស់នៅលើឧបទ្វីបឥណ្ឌូចិនទាំងមូលប្រហែលជា ២.០០០ឆ្នាំមុនគ្រិស្តសករាជក្តី ក៏បានលេចចេញប្រវត្តិសាស្ត្រ និងបុរាណវត្ថុវិទ្យាថា រដ្ឋទាំងពីរដែលបង្កើតប្រទេសកម្ពុជា គឺ ចេនឡា និង ហ្វូណន បានចាប់កំណើតនៅ សតវត្សរ៍ទី១នៃគ្រិស្តសករាជដែរ ។

ពីសតវត្សរ៍ទី១ដល់សតវត្សរ៍ទី៦ មានរដ្ឋជាបងប្អូនពីរ គឺ : **ចេនឡា** លាតសន្ធឹងនៅខាងជើង នៅលើផ្នែកទាំងអស់នៃឧបទ្វីបដែលមានភ្នំច្រើន ហើយហ្វូណនលាតសន្ធឹងនៅខាងត្បូង នៅលើវិសាលភាពនៃដីសណ្តទន្លេមេគង្គទាំងអស់ ។ អ្នកស្រុករបស់រដ្ឋទាំងពីរនេះ ថ្វីបើខុសគ្នាលើចំណុចជាតិពន្ធុក្តី ក៏អ្នកស្រុកនៅ**ចេនឡា** ដែលស្ថិតនៅក្នុងពួក "Kambuja" របស់**មេសន្តតិវង្ស មុំងហ្គោលី** ដែរ ចំពោះអ្នកស្រុកហ្វូណនដែលកើតចេញពីពួក **"មន-ខ្មែរ"** ជាមួយនឹងលក្ខណៈឥណ្ឌាដ៏ខ្លាំងនោះ បានទទួលរងទៅវិញទៅមកនូវឥទ្ធិពលហិណ្ឌូដូចគ្នា ដូច្នេះទទួលបាននូវចិត្តគំនិតដូចគ្នា ភាសាមួយដូចគ្នា ទំនៀមទម្លាប់ដូចគ្នា និងកាន់សាសនាដូចគ្នា ។

ពីសតវត្សរ៍ទី១ដល់សតវត្សរ៍ទី៦ ព្រហ្មញ្ញសាសនាបានគ្របដណ្តប់ទឹកដីទាំង

www.elibraryofcambodia.org

អស់ដែលបង្កើតប្រទេសកម្ពុជា ។ ប៉ុន្តែ គេបានសង្កេតឃើញផងដែរអំពីវត្តមាន "ព្រះពុទ្ធសាសនាមហាយាន" ។ សូមបើកវង់ក្រចកនៅទីនេះ ដើម្បីរៀបរាប់នូវសង្កាត់ទាំងឡាយនៃសៀវភៅរបស់លោក Dauphin Meunier (ទំព័រ១៧) :

"សាសនារបស់វាំងនិងរបស់មន្ត្រី ដែលភាគច្រើនជាប្រជាជនឥណ្ឌានៃមេសន្តតិវង្សឥណ្ឌា គឺជាព្រហ្មញ្ញសាសនា... ។ ព្រះពុទ្ធសាសនាមហាយានដែលបញ្ចូលទៅក្នុងជំនឿជីវចលនិយម (animisme) ដ៏យូរយារមកហើយនោះ គឺជាសាសនាដ៏មានប្រជាប្រិយមួយ..." ។

ដោយហេតុមានលក្ខណៈដូចគ្នានេះ អ្នកស្រុករបស់រដ្ឋទាំងពីរនេះ អាចត្រូវបានប្រមូលផ្តុំទៅជាប្រជាជនតែមួយ ។ ការបង្រួបបង្រួមនេះ គឺជាស្នាដៃរបស់ព្រះមហាក្សត្រដ៏ថ្លៃថ្លាទាំងឡាយ នៅមុនសម័យអង្គរនិងសម័យអង្គរ ក្នុងចំណោមព្រះមហាក្សត្រទាំងនោះ គឺមានពីរព្រះអង្គស្ថិតនៅលំដាប់ខ្ពស់ជាងគេ គឺព្រះបាទ "ភវវរ្ម័ន" និង "ព្រះបាទជ័យវរ្ម័នទី២" ។

**១)- ព្រះបាទភវវរ្ម័នសម្រេចបានការបង្រួបបង្រួម ចេនឡា និង ហ្វូណន នៅឆ្នាំ៥៥០ ក្រោយគ្រិស្តសករាជ ។**

រដ្ឋទាំងពីរនេះ **ហ្វូណន** និង **ចេនឡា**, ហ្វូណនគឺជារដ្ឋខ្លាំងបំផុត ។ ដូច្នេះចេនឡាស្ថិតនៅជារដ្ឋចំណុះហ្វូណនក្នុងពេលដ៏យូរ ។

គឺនៅពាក់កណ្តាលសតវត្សរ៍ទី៦ មានព្រះអង្គម្ចាស់មួយអង្គនៅក្នុងសន្តតិវង្សហ្វូណនគឺព្រះអង្គម្ចាស់ ភវវរ្ម័ន ជាព្រះរាជនត្តារបស់ព្រះមហាក្សត្រ "រុទ្រវរ្ម័ន" (Rudra Varman) បានរៀបអភិសេកជាមួយព្រះអង្គម្ចាស់ក្សត្រីមួយព្រះអង្គ នៅក្នុងព្រះរាជវង្សានុវង្សរបស់ប្រទេសចេនឡា (សន្តតិវង្សនៃគ្រុតវរ្ម័ន "Cruta-Varman") ។ ការរួបរួមគ្នានេះ បានអនុញ្ញាតឲ្យព្រះបាទ ភវវរ្ម័ន ដែលបានឡើងសោយរាជ្យនៅប្រទេសចេនឡានៅឆ្នាំ៥៥០ ដើម្បីធ្វើការឲ្យបានសម្រេចនូវការ

www.elibraryofcambodia.org

ឯកភាព របស់រដ្ឋទាំងពីរនេះ ។

ការច្របូកច្របល់បានផ្ទុះឡើងនៅប្រទេសហ្វូណន អ្នកដណ្តើមរាជបល្ល័ង្ករបស់ព្រះបាទ រុទ្រវរ្ម័ន បានដណ្តើមយករាជធានី វ្យៈធៈបុរៈ (Vjâdhapura) ។ ព្រះបាទ ភវវរ្ម័ន បានក្លាយទៅជាព្រះមហាក្សត្ររបស់ចេនឡា បានចាប់ផ្តើមធ្វើសញ្ជ័យប្រកបដោយថាមពល នូវកេរមរតករបស់ព្រះអយ្យកោ របស់ព្រះអង្គ និងបានទាមទារដើម្បីព្រះអង្គនូវភាពជាក្សត្រនៃប្រទេសហ្វូណន ។

ព្រះបាទ ភវវរ្ម័ន នៅក្នុងរជ្ជកាលរបស់ព្រះអង្គ (៥៥០–៦០០) បានទទួលជោគជ័យក្នុងការធ្វើសញ្ជ័យប្រទេសហ្វូណន ។

ការធ្វើសញ្ជ័យនេះ បើតាមលោក G. Coedès គឺជា "ឧបកថា (épisode) ទី១ នៅឥណ្ឌូចិន ក្នុងការជម្រុញទៅភាគខាងត្បូង ដែលបង្កឡើងដោយកម្លាំងទាញនៃដីសណ្ត និងសមុទ្រ និងដែលម្យ៉ាងទៀតបានពន្យល់អំពីការបែងចែកក្រុមជាតិពន្ធុបច្ចុប្បន្នផងដែរ ។

ការធ្វើសញ្ជ័យប្រទេសហ្វូណនដោយប្រទេសចេនឡានេះ បានធ្វើឲ្យសម្រេចនូវការបញ្ចូលគ្នានៃរដ្ឋទាំងពីរ ។ ដោយសារការបញ្ចូលគ្នានេះ ក៏បានកើតឡើងនូវប្រទេសខ្មែរ ហើយព្រះបាទ ភវវរ្ម័ន គឺជាស្ថាបនិកដ៏ពិតប្រាកដនៃព្រះរាជាណាចក្រកម្ពុជា ។

ពួកបុរាណវត្ថុវិទូទាំងអស់ បានឯកភាពគ្នាជាឯកច្ឆន្ទ ដើម្បីអះអាងអំពីការសម្រេចបាននូវការឯកភាពគ្នានេះ ។ ចំពោះលោក B.P Groslier បានអះអាងថា គឺជាស្នាដៃរបស់ព្រះបាទ ភវវរ្ម័ន (សៀវភៅ "អង្គរ មនុស្ស ថ្ម" ទំព័រ១៧) ។

លោក A.Migot បានធ្វើអត្ថាធិប្បាយដូច្នេះថា (សៀវភៅ "ប្រជាជនខ្មែរ" ទំព័រ៣៨) "...រេចញពីការធ្វើសញ្ជ័យប្រទេសហ្វូណនដោយប្រទេសចេនឡា និងការបញ្ចូលប្រទេសទាំងពីរនេះ បានកើតឡើងនូវប្រទេសខ្មែរ ហើយគេអាចចាត់ទុក

www.elibraryofcambodia.org

ព្រះបាទ ភវវរ្ម័ន ថាជាស្ថាបនិកដ៏ពិតប្រាកដរបស់ខ្លួន ។ ប៉ុន្តែជាយូរក្រោយមកទៀត នៅក្នុងព្រះរាជាណាចក្ររួបរួមគ្នានេះ នៅតែមានស្លាកស្នាមទិកភាពដើម (អ្វីៗដែលរួបរួមគ្នាជាពីរ) ។ ទិកភាពនៃវប្បធម៌និងប្រពៃណី និងប្រហែលជាទិកភាពនៃជាតិពន្ធផងដែរ ។ ប្រសិនជាប្រជាជននៅចេនឡាត្រូវបានភ្ជាប់គ្នាដូចជាហ៊្វុណនទៅនឹងគ្រួសារធំ **"មន–ខ្មែរ"** នោះ វាមានលក្ខណៈពិសេសមួយចំនួនដែលកើតចេញពីការនាំមកនូវសមាសភាព ម៉ុងហ្គោល មកពី យុនណាន និងភូមា លើ" ។ ព្រះមហាក្សត្រ ស្នងរាជ្យក្រោយៗរបស់ព្រះបាទ ភវវរ្ម័ន បានបន្តស្នាដៃបង្រួបបង្រួមរដ្ឋទាំងពីរនេះ ។

លោក Moura នៅក្នុងសៀវភៅរបស់លោក (សរសេរនៅដំណាច់សតវត្សរ៍កន្លងមកនេះ) "ការធ្វើដំណើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រទេសលាវ" បានយកឆ្នាំ ៦២៧ ធ្វើជាកាលបរិច្ឆេទនៃការចេញដំណើរធ្វើការបង្រួបបង្រួមប្រទេសហ៊្វុណន និងប្រទេសចេនឡានេះ គឺជាស្នាដៃរបស់ព្រះបាទ ឦសានវរ្ម័ន (Içana-Varman) (៦១៥–៦៣៥) ព្រះរាជបុត្រារបស់ព្រះបាទ ចិត្រាសេនា (Chitra séna) ព្រះមហាក្សត្រអង្គនេះ ទ្រង់បានស្នងរាជ្យបន្តពីព្រះរៀមរបស់ព្រះអង្គ ព្រះបាទ ភវវរ្ម័ន ដោយយកព្រះនាមថា ព្រះបាទ មហិន្ទ្រាវរ្ម័ន (Mahen dra-Varman) ។

ជាពិសេសលោក Moura បាននិយាយថា នៅឆ្នាំ៦២៧ "ព្រះមហាក្សត្រនៃប្រទេសចុនឡាប (ចេនឡា) បានបង្រួបបង្រួមប្រទេសហ៊្វុណនទាំងអស់នៅក្រោមអំណាចរបស់ខ្លួន ។ ចាប់ពីពេលនោះមក អ្នកសរសេរប្រវត្តិសាស្ត្រចិនបានកំណត់ឈ្មោះប្រទេសហ៊្វុណននៅក្រោមឈ្មោះចុនឡាប (ចេនឡា, កម្ពុជា) កាលប្រវត្តិសាស្ត្ររបស់អណ្ណាមក៏ដូចគ្នាដែរ" ។

លោក J. Bouchot នៅក្នុងអំឡុងសន្និសីទមួយ ធ្វើនៅសាយហ្គន នៅថ្ងៃទី៩

www.elibraryofcambodia.org

ខែឧសភា ១៩២៦ បានឲ្យដឹងថា "សាយហ្គន ស្ថិតនៅក្រោមការត្រួតត្រារបស់កម្ពុជា" (ព្រឹត្តិបត្ររបស់សមាគមនៃការសិក្សាឥណ្ឌូចិន, ឆ្នាំ១៩២៦) បានប្រកាសផងដែរថា "គឺមកដល់ពាក់កណ្ដាលទី១នៃសតវត្សរ៍ទី៧ថា ប្រទេសហ៊្វូណនត្រូវបានផ្លាស់ទៅនៅក្រោមការត្រួតត្រារបស់ព្រះមហាក្សត្រខ្មែរ" ។ លោក Bouchot បានរៀបរាប់អំពី "Sin T'ang Chou ឬប្រវត្តិសាស្ត្រថ្មីរបស់ T'ang : ៦១៨-៩០៦" (K, 222, P.2V) ដែលបានសរសេរថា "ព្រះមហាក្សត្រ ក្សត្រិយ៍ : ឦសាន : (Ksatriya Içana) នៅដើមសម័យកាលចេងគួន (Tcheng Kuon) (៦២៧-៦៤៩) បានចុះចូលប្រទេសហ៊្វូណន និងបានទឹកដីនេះ" ។

ទោះជាយ៉ាងណាក៏ដោយ លោក B.P. Groslier ដោយរុលទៅមុខនៅឆ្នាំ៥៥០ នៅដើមដំបូងនៃការបង្រួបបង្រួមនោះ សំអាងទៅលើហេតុការណ៍នៃការរកឃើញនិងការងារទាំងឡាយនៅខាងក្រោយលោក Moura និងលោក J. Bouchot ។

ការបង្រួបបង្រួមរវាង ចេនឡា និង ហ៊្វូណន ដែលចាប់ផ្ដើមដោយព្រះមហាក្សត្រ ភវវរ្ម័ន និងបន្តដោយព្រះមហាក្សត្រ ឦសានវរ្ម័ន គឺនៅជុយស្រួយណាស់ ។ ការឯកភាពរបស់ប្រទេសកម្ពុជា បានស្ថិតនៅមួយរយៈពេល និងបានរលាយទៅវិញនៅសតវត្សរ៍ទី៨ ។

ការផុះបែកនៃការឯកភាពនេះ គឺជាផលនៃការចលាចលដែលបង្កើតឡើងដោយពួកអ្នកលុកលុយបរទេស ។ រដ្ឋពីរដែលមានព្រះអង្គម្ចាស់ដឹកនាំ ត្រូវបានបង្កើតឡើងជាថ្មីនៅពេលនោះ : នៅភាគខាងជើង គឺ**ប្រទេសកម្ពុជាដីគោក** (ប្រទេសលាវខាងក្រោមនិងកណ្ដាល) នៅខាងត្បូងគឺ**ប្រទេសកម្ពុជាទឹកលិច** (តំបន់ទន្លេនិងបឹងដែលគ្របដណ្ដប់អាងទន្លេមេគង្គ ទឹកធ្លាក់នៅខាងទៅសមុទ្រ) នៅ កន្លែងនៃប្រទេសហ៊្វូណន ។

បើតាមអ្នកប្រវត្តិសាស្ត្របានឲ្យដឹងថា គឺ "ពួកចោរសមុទ្រជ្វា" ដែលបានឆ្លៀត

www.elibraryofcambodia.org

ឱកាសនៃការប្រកួតប្រជែងរបស់សន្តតិវង្សនៃប្រទេសចេនឡានិងប្រទេសហ្វូណន បានបំផ្លាញប្រទេសកម្ពុជានៅក្នុងអំឡុងឆ្នាំ៧៧៤ និង ៧៨៧ ។ ពួកចោរសមុទ្រទាំងនេះបានទទួលជោគជ័យក្នុងការដាក់បង្ខំទៅលើព្រះមហាក្សត្រនៃប្រទេសចេនឡា និងប្រទេសហ្វូណនទាំងពីរជាបងប្អូន នូវអធិរាជភាពរបស់ពួកគេ ។ អធិរាជភាពរបស់ពួកជ្វានេះ មិនស្ថិតនៅទេ ។

ព្រះមហាក្សត្រដ៏ធំមួយព្រះអង្គ គឺព្រះបាទ ជ័យវរ្ម័នទី២ ដែលបានធ្វើឲ្យប្រទេសកម្ពុជាមានអានុភាពធំនោះ បានលេចឡើងនៅលើឆាក ។ ដោយបណ្តេញពួកជ្វាចេញពីប្រទេសនោះ ព្រះអង្គបានធ្វើឲ្យសម្រេចនៅក្នុងឆ្នាំ៨០២ នូវការរួបរួមទាំងស្រុងនៃរដ្ឋពីរដែលមានព្រះអង្គម្ចាស់ដឹកនាំនោះ គឺ "កម្ពុជាដីគោកនិងកម្ពុជាទឹកលិច" ។

## ២)- ការបង្រួបបង្រួមព្រះរាជាណាចក្រកម្ពុជា ត្រូវបានស្ដាបនាឡើងវិញ និងពង្រឹងដោយព្រះបាទជ័យវរ្ម័នទី២ ព្រះមហាក្សត្រខ្មែរដ៏ថ្មើម

លោក André Migot បានទាញហេតុផលសំអាងនៅក្នុងសៀវភៅ ("Les Khmers", ទំព័រ៦៩) ថា :

"នៅដើមដំបូងនៃសតវត្សរ៍ទី៩ ព្រះមហាក្សត្រដ៏ថ្មើមមួយព្រះអង្គបានលេចឡើង គឺព្រះបាទ ជ័យវរ្ម័នទី២ ។ ព្រះអង្គគឺជាអ្នករំដោះប្រទេសចេនឡា, ជាអ្នកបង្រួបបង្រួមរបស់ខ្លួន និងជាស្ថាបនិកនៃសន្តតិវង្សរបស់ព្រះមហាក្សត្រខ្មែរ" ។ ព្រះបាទជ័យវរ្ម័នទី២ គឺជាព្រះអង្គម្ចាស់ខ្មែរ ដែលពួកម៉ាឡេនៅកោះជ្វា (Java) បានចាប់ព្រះអង្គនៅក្នុងអំឡុងការលុកលុយរបស់ពួកគេនៅប្រទេសកម្ពុជា នៅដំណាច់សតវត្សរ៍ទី៨ ។

សិលាចារិកមួយនៅសតវត្សរ៍ទី១០ ដែលរៀបរាប់ដោយលោក A. Migot បានរំលឹកអំពីការលេចឡើងរបស់ព្រះបាទ ជ័យវរ្ម័នទី២ ថា "ដើម្បីសេចក្តីចម្រុង

www.elibraryofcambodia.org

ចម្រើនរបស់ប្រជារាស្ត្រ នៅក្នុងពូជសាសន៍ដ៏បរិសុទ្ធទាំងស្រុងជាព្រះមហាក្សត្រនេះ ដូចជាផ្កាឈូកដ៏ធំដែលគ្មានទង់នោះ ព្រះអង្គបានលេចឡើងដូចជារដូវផ្ការីកថ្មី" ។

លោក Dauphin Meunier ដោយសង្ខេបអំពីអ្នកនិពន្ធដែលជាអ្នកទទួលអំណាចនោះ បានបង្ហាញកាលបរិច្ឆេទនៃព្រឹត្តិការណ៍របស់ខ្លួន ("ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" ទំព័រ២៧) ថា : "...នៅក្នុងពេលដែល Charlemagne ស្ថាបនាឡើង វិញនូវអាណាចក្ររ៉ូម៉ាំងនៅលោកខាងលិច ព្រះមហាក្សត្រ ជ័យវរ្ម័នទី២ ដ៏ថ្មើម (៨០២–៨៥០) បានរំដោះប្រទេសកម្ពុជាឲ្យរួចខ្លួនពីអធិរាជភាពរបស់ជ្វា និងបានរៀបចេញជាមូលដ្ឋាននៃចក្រភពអង្គរ" ។

"យាងចូលប្រទេសកម្ពុជាវិញ ដ៏គួរឲ្យភ្ញាក់ផ្អើលនៅឆ្នាំ៨០០, មុនដំបូងព្រះបាទជ័យវរ្ម័នទី២ត្រូវធ្វើឲ្យគេព្រមទទួលព្រះអង្គ ។ ព្រះអង្គគង់នៅតំបន់ត្បូងឃ្មុំ ហើយចេញ ពីទីនោះ ដោយប្រើរហស្សបាយ (ឧបាយកលសម្ងាត់ ឬដោយអាវុធ) នោះ, ខេត្តទាំងឡាយត្រូវបានចុះចូលជាបន្តបន្ទាប់ ហើយខេត្តទាំងនោះបានឯករាជ្យឡើងវិញនៅប្រទេសកម្ពុជាទិសលិច...."។

ដោយសារព្រះបាទ ជ័យវរ្ម័នទី២ ព្រះរាជាណាចក្រកម្ពុជាបានរកឃើញឡើងវិញនូវការរួបរួមរបស់ខ្លួន, និងរក្សានូវស្ថិរភាពនៅក្នុងអំឡុងសតវត្សរ៍ជាច្រើន ។ ព្រះបាទ ជ័យវរ្ម័នទី២ គឺជាស្ថាបនិកនៃសន្តតិវង្សដ៏ធំរបស់អង្គរ ។

ចាប់តាំងពីរជ្ជកាលរបស់ព្រះអង្គមក ប្រទេសកម្ពុជាបានស្គាល់នូវសម័យកាលមួយនៃការពង្រីកទឹកដី ។ បញ្ហានេះ នឹងធ្វើជាកម្មវត្ថុក្នុងភាគទី៣ នៃការសិក្សារបស់យើងស្តីពីការបង្កើតព្រះរាជាណាចក្រកម្ពុជា ។

**III)- នៅក្នុងសម័យអង្គរ ព្រំដែននៃព្រះរាជាណាចក្រខ្មែរ ត្រូវបានលាតសន្ធឹង និងកំណត់សម្រាប់រយៈពេល៦សតវត្សរ៍ (ពីសតវត្សរ៍ទី៩ ដល់សតវត្សរ៍ទី១៤)**

យើងទើបនឹងបានឃើញអំពីការបង្រួបបង្រួមជាស្ថាពរនូវប្រទេសកម្ពុជាដ៏គោក

www.elibraryofcambodia.org

ជាមួយប្រទេសកម្ពុជាទឹកលិច ត្រូវបានសម្រេចឡើងដោយព្រះបាទ ជ័យវរ្ម័នទី២ នៅឆ្នាំ ៨០២ យ៉ាងច្បាស់ក្រឡែត ។

យើងក៏បានឃើញផងដែរថា ការធ្វើឲ្យរុងរឿងឡើងវិញនូវការឯកភាពប្រទេសកម្ពុជា គឺគ្រាន់តែជាការអះអាងអំពីជីវិតសម្ព័ន្ធភាពរបស់ប្រជាជនខ្មែរតែប៉ុណ្ណោះ ដែលចាប់តាំងពីរាប់សតវត្សរ៍មកហើយ បានចង្អុលបង្ហាញអំពីវត្តមានរបស់ប្រទេសខ្លួន ។

"ការពង្រីកអាណាចក្រខ្មែរ នៅក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី២ ត្រូវបានកត់សម្គាល់ដោយអ្នកប្រវត្តិសាស្ត្រទាំងអស់ ។ ការពង្រីកនេះ ត្រូវបានបង្ហាញដោយសិលាចារិកពីរ ដែលបានចង្អុលនៅក្នុងសៀវភៅរបស់លោក A. Migot ។ សិលាចារិកមួយ គឺទាក់ទងទៅនឹងការកសាងកន្លែងសក្ការៈបូជាព្រះសិវៈ ឬព្រះឥសូរ នៅ**ភ្នំបាយ៉ង់ក្នុងតំបន់ចូវដុក** នៅភាគខាងត្បូងបំផុតនៃដែនឡាទឹកលិច គឺទឹកដីកូសាំងស៊ីនបច្ចុប្បន្ននេះ ។ សិលាចារិកមួយទៀត គឺជាសិលាចារិកអំពីព្រះពុទ្ធសាសនានៅឆ្នាំ៨៨៦ ដែលត្រូវបានរកឃើញនៅទិសពាយ័ព្យនៃអ៊ូប៊ុន (Ou Bon) នៅខាងជើង បាសាក់ គឺប្រទេសលាវបច្ចុប្បន្ន ដែលសៀវភៅនេះបានសរសេរនៅក្នុង *(ទំព័រ១២)* ថា ព្រះបាទ ឥន្ទ្រាវរ្ម័ន គឺជាព្រះមហាក្សត្រ ។ ប៉ុន្តែនៅទីនោះមានតំបន់មួយដែលជាផ្នែកនៃដែនឡាដីគោក ។ ការបង្រួបបង្រួមដែនឡាទាំងពីរនេះ *(ទំព័រ១៣)* បានរីកចម្រើនក្នុងជំហានដ៏ធំ..." ។

**ព្រមជាមួយព្រះបាទជ័យវរ្ម័នទី២ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាក៏បានចូលទៅក្នុង "សម័យកាលអង្គរប្រកបដោយកិត្តិគុណ" ផងដែរ**

នៅក្នុងអត្ថបទមួយផ្សាយដោយកាសែត "Réalités Cambodgiennes" នៅក្រោមចំណងជើងថា "La Monarchie Cambodgiennes" *(រាជាធិបតេយ្យកម្ពុជា)* សម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គទ្រង់ព្រះលិខិតថា : **"ចាប់តាំងពី**

www.elibraryofcambodia.org

**ពេលនោះមក ព្រះបាទជ័យវរ្ម័នទី២បានទទួលជោគជ័យក្នុងការបង្រួបបង្រួមព្រះរាជាណាចក្រ ឬឡាំងដណ្តើមឯករាជ្យជាតិបានមកវិញ និងបានបោះទីតាំងរាជាធិបតេយ្យខ្មែរនៅតំបន់អង្គរ" ។**

សម័យកាលនេះ ដែលបានចាប់ផ្តើមតាំងពីឆ្នាំ៨០២ (ឆ្នាំមុទ្ធាភិសេកព្រះបាទជ័យវរ្ម័នទី២) បានប្រព្រឹត្តទៅជាង៦សតវត្សរ៍ ។

**ព្រះមហាក្សត្រទាំងពីរអង្គដ៏ថ្មើមក្រៃលែងរបស់ខ្លួន គឺព្រះបាទសុរិយាវរ្ម័នទី២ (១១១៣–១១៥០) និងព្រះបាទជ័យវរ្ម័នទី៧ (១១៨១–១២០០) នៅក្រោមរជ្ជកាលរបស់ព្រះអង្គ ប្រទេសកម្ពុជាបានរីកចម្រើនដល់កម្រិតកំពូលរបស់ខ្លួន ។**

សម្តេចព្រះ"**នរោត្តម សីហនុ**" នៅក្នុងអត្ថបទដែលបាននិយាយខាងលើ ព្រះអង្គបានរំលឹកអំពីចរិតលក្ខណៈដ៏ថ្មើមរបស់ព្រះមហាក្សត្រប្រកបដោយកិត្តិនាមទាំងពីររបស់ព្រះអង្គថា :

"ព្រះបាទ សុរិយាវរ្ម័នទី២ បានដឹកនាំកងទ័ពខ្មែរទៅយ៉ាងឆ្ងាយក្រៃលែង ដែលពួកគេមិនដែលបានទៅដល់ ។ ព្រះមហាក្សត្ររបស់ប្រទេសផ្សេងៗទៀត ដែលព្រះអង្គចង់បង្ក្រាបនោះ ព្រះអង្គបានឃើញព្រះមហាក្សត្រទាំងនោះនាំសួយសារអាករមកថ្វាយព្រះអង្គ ។ ព្រះអង្គថែមទាំងបានយាងផ្ទាល់ព្រះអង្គនៅក្នុងប្រទេសជាសត្រូវរបស់ព្រះអង្គ ហើយព្រះអង្គបានចាំងកិត្តិគុណរបស់ រ៉ាហ្គូ (Raghu) (បុព្វបុរសរបស់រាមា) ទៀតផង ។ "ការពង្រីកដ៏ធំនូវអធិបតេយ្យភាពកម្ពុជា នៅលើឧបទ្វីបឥណ្ឌូចិន នៅពាក់កណ្តាលសតវត្សរ៍ទី១២ត្រូវបានកត់ត្រាទុកដោយ "ប្រវត្តិសាស្ត្ររបស់ Song " ដែលនៅក្នុងនោះ ប្រទេសកម្ពុជាមានព្រំប្រទល់ខាងត្បូងទល់នឹងប្រទេសចំប៉ា ខាងជើង និងខាងកើតទល់នឹងសមុទ្រ ខាងលិចទល់នឹងព្រះរាជាណាចក្រប៉ាហ្គាន (Pagan) និង ហ្គ្រាហ៊ី (Grahi) នៅក្នុងតំបន់ចៃយ៉ា (Chaya) និងឆកបានឌូ (Bandou) នៅលើឆ្នេរខាងកើតនៃឧបទ្វីបម៉ាឡេ នៅទិសខាងត្បូង ។

www.elibraryofcambodia.org

ព្រះបាទ ជ័យវរ្ម័នទី៧ បានធ្វើឲ្យប្រទេសចំប៉ាក្លាយទៅជាខេត្តមួយរបស់ខ្មែរ (១២០៣-១២២០) ។

ព្រះអង្គក៏បានរុញច្រានទៅទិសខាងជើង និងទិសខាងលិច នូវព្រំដែននៃអាណាចក្ររបស់ខ្លួន ដែលបានលាតសន្ធឹងរហូតដល់ក្រុងវៀងច័ន្ទ ។ ព្រះអង្គបានវាយដណ្តើមយកប្រទេសថៃបច្ចុប្បន្នស្ទើរតែទាំងអស់ និងមួយភាគនៃឧបទ្វីបម៉ាឡេស៊ី និងភូមា ។

នៅក្នុងសម័យអង្គរដ៏រុងរឿង បើតាមអ្នកប្រវត្តិសាស្ត្របានឲ្យដឹងថា ប្រទេសកម្ពុជាមានប្រជាជនយ៉ាងហោចណាស់ក៏ដប់លាននាក់ដែរ ។

ចាប់ពីរជ្ជកាលរបស់ព្រះបាទ ជ័យវរ្ម័នទី៧ យើងអាចរៀបរាប់បានទៀតនូវអ្វីដែលលោក Dauphin Meunier បានរាយការណ៍ (ទំព័រ១៧) ដែលបានសង្កត់ទៅលើអ្នកនិពន្ធដែលបានទទួលសិទ្ធិដូចជាលោក Moura និងលោក Coedes គឺ : បើតាមព្រះមាតារបស់ព្រះអង្គ ព្រះបាទ ជ័យវរ្ម័នទី៧ ជាព្រះមហាក្សត្រដែលមានជ័យជំនះ (១១៨១-១២០១) ជាប់ខ្សែទៅនឹងសន្តតិវង្សសម័យមុនអង្គរ ហើយបើតាមព្រះបិតារបស់ព្រះអង្គវិញ ព្រះអង្គជាប់ខ្សែជាមួយសន្តតិវង្ស មហិន្ទ្រាបុរៈ (Mahi dharapura) ។ នៅក្នុងរាងកាយរបស់ព្រះអង្គ មានការផ្សំគ្នានូវគុណធម៌ខ្លាំងពូកែរបស់មនុស្សមួយ និងមនុស្សមួយទៀត ។ នៅក្រោមរជ្ជកាលរបស់ព្រះអង្គ ប្រទេសកម្ពុជាពិតជាបានសម្រេចការពង្រីកទឹកដីរបស់ខ្លួនយ៉ាងធំសម្បើម ពីព្រោះថាប្រទេសនេះបានគ្របដណ្តប់ក្រៅពីប្រទេសខ្មែរ គឺប្រទេសចំប៉ា ទឹកដីបច្ចុប្បន្នរបស់ប្រទេសលាវ និងប្រទេសថៃ មួយភាគនៃឧបទ្វីបម៉ាឡេ (រហូតដល់ជ្រោយ Kra) និងប្រទេសភូមា (នៅចន្លោះទន្លេ Salwan និង Irawadi :) ។ នេះបានបញ្ជាក់ថានៅក្នុងកងទ័ពខ្មែរ ដែលត្រូវបានដឹកនាំប្រឆាំងអណ្ណាមនៅក្នុងឆ្នាំ១២០៧ គឺមានក្រុមកងទ័ពថៃនិងភូមា" ។

www.elibraryofcambodia.org

ចំពោះលោក Moura វិញ លោកបានសរសេរថា : "អតីតព្រះរាជាណាចក្រខ្មែរ នៅក្នុងអំឡុងពេលនៃភាពរុងរឿងដ៏ខ្លាំងបំផុតរបស់ខ្លួន គឺបានលាតសន្ធឹងពីខ្សែស្របទី៩នៃទិសខាងជើង រហូតដល់ខ្សែស្របទី១៥ គឺថាចាប់តាំងពីសមុទ្រចិន រហូតដល់រដ្ឋ Korat ដ៏តូច ក៏ត្រូវបានរាប់បញ្ចូលដែរ ។

**"ក្លស៊ាំងស៊ីនចារាំងទាំងមូល គឺជារបស់ប្រទេសកម្ពុជាក្នុងពេលនោះ"...**

ឥទ្ធិពលនយោបាយ និងការត្រួតត្រារបស់ខ្មែរ បានកាន់កាប់នូវរដ្ឋជាច្រើននៃប្រទេសលាវ ថែមទាំងរហូតដល់ប្រទេសសៀមទៀតផង ។

**IV)- សម័យកាលក្រោយអង្គរ**

ដោយមានការបង្រួបបង្រួមលើកទី១ ដោយព្រះបាទ ភវវរ្ម័ន នៅឆ្នាំ៥៥០ ក្រោយគ្រិស្តសករាជ និងលើកទី២ដោយព្រះបាទ ជ័យវរ្ម័នទី២ នៅឆ្នាំ៨០២ ក្រោយគ្រិស្តសករាជ ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅក្នុងសម័យនៃការបង្រួបបង្រួម និងនៅក្នុងសម័យនៃការឯកភាពរបស់ខ្លួន នូវអតីតទឹកដីទាំងឡាយរបស់ចេនឡា និងហ្វូណន ។

ព្រះរាជាណាចក្រនេះ បានស្គាល់នូវសម័យកាលមួយនៃការពង្រីកទឹកដី នៅក្នុងសករាជអង្គរ (ពីព្រះបាទជ័យវរ្ម័នទី២ដល់ការបោះបង់អង្គរ ដោយព្រះបាទពញាយ៉ាត នៅឆ្នាំ១៤៣៤) ។ ចាប់ពីសតវត្សរ៍ទី១៣ និងសតវត្សរ៍ទី១៤ ពួកសៀមបានវាយប្រហារមកទិសខាងកើត ហើយពួកអណ្ណាមបានវាយប្រហារមកទិសខាងត្បូង។ ប្រជាជនកម្ពុជាត្រូវបានវាយច្រានមកដល់ព្រៃដែនទី១របស់ខ្លួនវិញ គឺព្រៃដែនដែលមានរួមបញ្ចូលប្រទេសហ្វូណន និងប្រទេសចេនឡា ។ បន្ទាប់មកទៀត ពួកឈ្លានពានបន្តរុញច្រានចូលរហូតទៅដល់ខាងក្នុងព្រៃដែនទាំងនេះ និងជិះជាន់ទឹកដីរបស់បុព្វបុរសរបស់ពួកគេ(ខ្មែរ)ថែមទៀតផង ។

ក្រោយពីបានលុកលុយទឹកដីរបស់ ចេនឡា និង ហ្វូណន (ដែលត្រូវបានបង្រួប

www.elibraryofcambodia.org

បង្រួមដោយព្រះមហាក្សត្រអង្គ) ហើយពួកអ្នកលុកលុយបានដាក់ធ្វើជាបញ្ហាអំពីបុរាណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

គឺចាប់ពីសតវត្សរ៍ទី១៣ ឬសតវត្សរ៍ទី១៤ ដែលព្រះរាជាណាចក្រសៀម និងព្រះរាជាណាចក្រអណ្ណាមបានចាប់ផ្ដើមប៉ុនប៉ងបំបែកបំបាក់បូរណភាពនៃទឹកដីនេះ ។

លោក Charles Lemire នៅក្នុងសេចក្ដីរាយការណ៍ស្ដីពីកាលប្រវត្តិនៃទំនាក់ទំនងជាមួយប្រទេសកម្ពុជា បានបញ្ជាក់ (ទំព័រ៩) ថា : "...នៅឆ្នាំ១៥៥៨ នៅពេលដែលប្រទេសសៀមបានឯករាជ្យឡើងវិញ និងបន្តធ្វើសង្គ្រាមជាមួយ Pégou ប្រទេសកម្ពុជាបានដឹកនាំការវាយប្រហារមួយនៅទិសខាងកើតដូចពីមុន ។ ការវាយប្រហារនេះតាមការពិត គឺជាការវាយបកភ្លាម ៗទៅនឹងការឈ្លានពានរបស់អណ្ណាម ។

ការពង្រីកព្រះរាជាណាចក្រអណ្ណាម បានកើតមាននៅឆ្នាំ១៤៦០ គឺចាប់តាំងពីដំណាក់កាលនេះ ដែលពួកអណ្ណាមក្រោយពីបានរំដោះខ្លួនចេញពីការត្រួតត្រារបស់ចិនមក, បានដណ្ដើមយកប្រទេសមួយដែលប្រទេសកម្ពុជាបានធ្វើសញ្ជ័យ គឺប្រទេសចំប៉ា ។ Charles Lemire បាននិយាយអំពីបញ្ហានេះថា : "នៅឆ្នាំ១៤៦០ នៅក្រោមសន្តតិវង្ស Lê, Thanh, Tong, Tuân, Tuân hoa (Huê បច្ចុប្បន្ន) និង Quang-Nam, ពួកចាម ឬ (Tsiampois) ទើបនឹងត្រូវច្បាំងដណ្ដើមយកបាន ។ ពួក (Tsiampois មានដើមកំណើតម៉ាឡេ និង mahomé-tants ។ គឺជាអតីតប្រជាជននៃ Lam-Ap ។ ចាប់ពីឆ្នាំ១៥០៥ ការធ្វើសញ្ជ័យរបស់អណ្ណាមលើ Tsiampa ត្រូវបានសម្រេច, ចំណែកការធ្វើសញ្ជ័យកម្ពុជាក្រោម ទើបតែបានចាប់ផ្ដើមនៅសតវត្សរ៍ទី១៧ ។

**"គេត្រូវតែធ្វើការបញ្ជាក់នៅទីនេះថា ប្រទេសចំប៉ាមិនមែនជាទឹកដីដើមរបស់ខ្មែរទេ ។ ទឹកដីនេះត្រូវបានកាន់កាប់ដោយពួកចាមមកពីកោះជ្វា (Java) ហើយ**

www.elibraryofcambodia.org

ត្រូវបានច្បាំងដណ្ដើមយកដោយពួកខ្មែរ នៅមុនពេលដែលត្រូវបានច្បាំងដណ្ដើមយកដោយពួកអណ្ណាម ។ ដោយហេតុនេះ ការកាន់កាប់ប្រទេសចំប៉ាដោយពួកវៀតណាមនេះ, ខ្មែរមិនអាចធ្វើជាកម្មវត្ថុនៃការតវ៉ាមួយបានឡើយ ។ មិនដូចគ្នានឹងកម្ពុជាក្រោមទេ ។ កម្ពុជាក្រោមបច្ចុប្បន្ន (អតីតកូសាំងស៊ីនបារាំង) ដែលពួកមន-ខ្មែរបានរស់នៅជាងម្ភៃសតវត្សរ៍មកហើយ, ហើយក្រោយពី "មន-ខ្មែរ" មក គឺប្រជាជនខ្មែរដែលបានជាប់ពូជពីនោះ បានកាន់កាប់ប្រទេសនេះរហូតមកដល់បច្ចុប្បន្នដោយពុំមានការផ្អាកឡើយ ។

ដូច្នេះ ការលុកលុយចូលកម្ពុជាក្រោម ដោយពួកវៀតណាម បណ្ដាលឲ្យកើតចេញបាតុភូតពីរយ៉ាងគឺទី១ ជាកម្មវត្ថុ នៃការតវ៉ាជាប់ជាប្រចាំរបស់កម្ពុជា, ទី២ ជាបុព្វហេតុនៃការប្រយុទ្ធ ដោយឥតឈប់ឈរ ដើម្បីរំដោះទឹកដីនេះផងដែរ ។ ការប្រយុទ្ធនេះ បានបន្តក្នុង របៀបដោយគ្មានការបញ្ឈប់ រហូតទល់គ្នានឹងការមកដល់របស់បារាំង"... ។

* ពួកជនដែលមិនមានសេចក្ដីខ្មាសអៀន
រមែងមិនអើពើដល់សេចក្ដីខុសត្រូវ ។

* សេចក្ដីស្ទាត់ជំនាញ និងទំនុកចិត្ត ជាកងទាហាន
ដែលមិនមានអ្នកណាគំរាមឲ្យបាញ់បាន ។

www.elibraryofcambodia.org

# ផ្នែកពីរ

## បុរាណភាពទឹកដីនៃប្រទេសកម្ពុជា គ្របដណ្តប់ "កូសាំងស៊ីន" ទាំងមូល

ការរំលឹកដោយសង្ខេបនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រស្តីពីព្រះរាជាណាចក្រកម្ពុជានេះ យើងអាចទាញនូវការសន្និដ្ឋានមួយ ដែលទាក់ទងទៅនឹងបុរាណភាពទឹកដីនៃប្រទេសនេះ ។

សេចក្តីសន្និដ្ឋានសង្ខេប ៦ចំណុច :

១)- ព្រះរាជាណាចក្រខ្មែរត្រូវបានបង្កើតឡើងជាប្រវត្តិសាស្ត្រ ចាប់តាំងពីសតវត្សរ៍ទី១នៃគ្រិស្តសករាជរបស់យើង ។ ការបង្រួបបង្រួមរវាងកម្ពុជាដីគោក (ចេនឡា) និងកម្ពុជាទឹកលិច (ហ៊្វូណន) ត្រូវបានសម្រេចទាំងស្រុងនៅសតវត្សរ៍ទី៨ ។ ភាគខាងត្បូងទាំងអស់នៃឧបទ្វីបឥណ្ឌូចិន ដោយមានអតីតកូសាំងស៊ីនរួមផង គឺជា ផ្នែករួមបញ្ចូលរបស់ព្រះរាជាណាចក្រកម្ពុជា ។

២)- ប្រទេសកម្ពុជាដែលបានរួបរួមរួចហើយ ត្រូវបានពង្រីកឲ្យធំ និងបានឃើញនូវការពង្រីកដ៏ពេញលេញរបស់ខ្លួន នៅក្នុងរយៈពេលប្រមាណ៦សតវត្សរ៍ (ពីឆ្នាំ៨០២ ព្រឹត្តិការណ៍របស់ ជ័យវរ្ម័នទី២ រហូតដល់ដំណាច់សតវត្សរ៍ទី១៤) ។ នៅក្នុងអំឡុងសម័យកាលនេះ ទឹកដីរបស់ខ្លួនមានរាប់បញ្ចូលប្រទេសចំប៉ា ប្រទេសលាវខាងក្រោម ប្រទេសថៃ រហូតដល់ព្រំដែននៃប្រទេសភូមាខាងជើង និងព្រំដែននៃប្រទេសម៉ាឡេស៊ីខាងត្បូង ។ នោះគឺជា"សម័យនៃចក្រភពខ្មែរ" ។

៣)- នៅសតវត្សរ៍ទី១៥ ព្រះរាជាណាចក្រកម្ពុជាបានបាត់បង់នូវខេត្តចំណុះរបស់ខ្លួន (ចំប៉ា, ប្រទេសលាវខាងក្រោម, ប្រទេសថៃ) និងបានរកឃើញឡើងវិញ

www.elibraryofcambodia.org

នូវព្រំដែនដើមរបស់ខ្លួន គឺព្រំដែនដែលខ្លួនមាននៅក្នុងពេលនៃការបង្រ្កួបបង្រួម របស់ខ្លួន (ដើមសតវត្សរ៍ទី៩) ។

៤)- កម្ពុជាក្រោមបច្ចុប្បន្ន (អតីតកូសាំងស៊ីនបារាំង-ពីមុនជា ហ្វូណន) គឺជាទឹកដីរបស់ខ្មែរជាប្រវត្តិសាស្ត្រ និងមិនអាចប្រកែកបានឡើយ ។

៥)-អណ្ណាមចាប់ផ្តើមប្រើកម្លាំងទ័ពដើម្បីបញ្ចូលជាឧបសម្ព័ន្ធទឹកដីកម្ពុជាក្រោម នៅសតវត្សរ៍ទី១៧ ដូច្នេះចាប់ពីកាលបរិច្ឆេទដែលអាចប្រែប្រួលថ្មីៗនេះ (យើងនឹងនិយាយនៅខាងមុខឆ្ងាយទៀត) ។ កម្ពុជាក្រោម ប្រទេសខ្មែរ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអាជ្ញាធរខ្មែរ ចាប់តាំងពីដើមមកម្ល៉េះ ។ ក្រោមការកាន់កាប់របស់អណ្ណាម បន្ទាប់មកក្រោមការកាន់កាប់របស់បារាំង, រាជាធិប-តេយ្យ កម្ពុជានៅតែរក្សាបាននូវកិត្យានុភាពរបស់ខ្លួននៅជិតប្រជាជនខ្មែរដែលរស់នៅកម្ពុជាក្រោម ។

គេត្រូវតែបង្ហាញផងដែរថា នៅក្រោមការកាន់កាប់របស់បារាំង, ព្រះមហាក្សត្រខ្មែរបានបន្តអនុវត្តនូវអធិបតេយ្យភាពនៃសាសនារបស់ព្រះអង្គ អំពីឋានានុក្រមព្រះពុទ្ធសាសនានៅកូសាំងស៊ីន ។

ឋានានុក្រមនេះ បានបន្តស្ការអំណាចនៃលំដាប់ស័ក្តិជាន់ខ្ពស់ខាងសាសនានៃប្រទេសកម្ពុជា (ប្រទេសនេះ) បានតែងតាំងមេគណ និងចៅអធិការ (មេគណនៅតាមមណ្ឌលសាសនា និងចៅអធិការនៅតាមវត្តរៀងៗខ្លួន) ។ បង្កើតទីស្នាក់ការនៃ "ផ្នែកខាងត្បូងនៃវិជ្ជាស្ថានព្រះពុទ្ធសាសនា" -ហៅថា : "ពុទ្ធសាសនាបណ្ឌិត្យរង" ស្ថិតនៅជានិច្ចនៅចំកណ្តាលកូសាំងស៊ីន (គឺនៅចំកណ្តាលទីរួមខេត្តឃ្លាំង - Soc Trang) ដែលជាទីបុងបំផុតនៃទន្លេមេគង្គ (Mekong), ការរៀបចំរចនាបទព្រះពុទ្ធសាសនាដែលលាតសន្ធឹងតាមបណ្តោយនៃដងទន្លេមេគង្គ ។

របបរបស់ប្រធានាធិបតី យ៉ឹម (Diêm) ចាប់តាំងពីការចូលកាន់អំណាចរបស់

www.elibraryofcambodia.org

ខ្លួនមក បានស្វែងរកគ្រប់វិធី ដើម្បីបំផ្លាញចោលនូវភស្តុតាងទាំងនេះ (ដែលមិនអាចបដិសេធបាន រវាងភស្តុតាងនៅកូសាំងស៊ីននៃប្រទេសកម្ពុជា) ដោយបញ្ញត្តិនូវវិធានការផ្ទាល់ខ្លួន ដើម្បីផ្តាច់ពុទ្ធសាសនិកជនខ្មែរនៅកូសាំងស៊ីន ពីបងប្អូនរបស់ពួកគេនៅកម្ពុជា ។

លោក Moura នៅក្នុងសៀវភៅរបស់លោក (ដែលបានរៀបរាប់មកហើយ) ស្តីអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បានរាយការណ៍អំពីការប្រយុទ្ធនិងសង្គ្រាមមិនដែលដាច់ ដែលប្រជាជនខ្មែរបានធ្វើដើម្បីរំដោះខេត្តទាំងឡាយរបស់ពួកគេនៅខាងត្បូងចេញពីអំណាចរបស់វៀតណាម ។ គាត់បានគូសបញ្ជាក់ថា ពុំមានអនុសញ្ញា ឬក៏សន្ធិសញ្ញា ណាមួយត្រូវបានធ្វើអន្តរាគមន៍ដើម្បីធ្វើឲ្យត្រឹមត្រូវតាមច្បាប់ នូវការកាន់កាប់របស់អណ្ណាមនៅលើកូសាំងស៊ីននោះទេ :

– "គឺនៅឆ្នាំ១៦៧៥ ដែលបានចាប់ផ្តើមនូវសង្គ្រាមមិនដែលដាច់ទាំងនេះ រវាងប្រជាជនទាំងពីរ និងការបញ្ចូលជាឧបសម្ព័ន្ធជាលំដាប់ នូវដីសណ្តទាំងអស់នៃទន្លេទៅក្នុងព្រះរាជាណាចក្រអណ្ណាម..." ។

– "ប៉ុន្តែពុំមានអនុសញ្ញាជាក់លាក់ណាមួយ ពុំមានសន្ធិសញ្ញាត្រឹមត្រូវតាមច្បាប់ណាមួយ, ត្រូវបានធ្វើអន្តរាគមន៍ដើម្បីសម្រេចឲ្យត្រឹមត្រូវតាមច្បាប់ នូវការកាន់កាប់ធ្វើជារបស់ខ្លួនដោយពួកអណ្ណាម មកលើប្រទេសដ៏ធំនិងមាននេះទេ ។ គឺពុំមានព្រំដែនដែលបានគូសឡើយ..."

៦)–ដូច្នេះបូរណភាពទឹកដីនៃប្រទេសកម្ពុជា លាតសន្ធឹងចាប់តាំងពីសម័យហ្វូណន និង ចេនឡា មាន :

– នៅលើខេត្តទាំង១៧នៃកម្ពុជាដីគោក (ប្រទេសកម្ពុជាបច្ចុប្បន្ន)

– នៅលើអតីតខេត្តរបស់កម្ពុជាទឹកលិច (អតីតកូសាំងស៊ីន)កម្ពុជាក្រោមរបស់ខ្មែរ ។ ដោយហេតុនេះ ការកាន់កាប់កូសាំងស៊ីនដោយអណ្ណាមនៅសតវត្សរ៍ទី១៧

www.elibraryofcambodia.org

និង ដោយប្រទេសបារាំង នៅពាក់កណ្ដាលសតវត្សរ៍ទី១៩ គឺបានរំលោភលើទឹកដីនៃប្រទេសកម្ពុជា ។

ការកាន់កាប់នេះ (ដែលតាមសភាពការណ៍មួយដ៏ពិតនោះ) គឺមិនបានប៉ះពាល់អ្វីឡើយ ដល់ស្ថានភាពគតិយុត្តនៃកម្ពុជាក្រោម ដែលនៅតែជាដីរបស់ខ្មែរនោះឡើយ ។

## ជំពូកពីរ

## គ្រឹះគតិយុត្តនៃអធិបតេយ្យភាពអចិន្ត្រៃយ៍ របស់ប្រទេសកម្ពុជានៅលើ "កូសាំងស៊ីន"

បូរាណភាពទឹកដីនៃប្រទេសកម្ពុជា លាតសន្ធឹងដល់ កូសាំងស៊ីន ដូចដែលយើងបានបង្ហាញនៅក្នុងជំពូកទីមួយ រួចហើយ យើងអាចទាញនូវសេចក្ដីសន្និដ្ឋាននេះថា "ការកាន់កាប់កម្ពុជាក្រោមដោយវៀតណាម មិនមែនជាការកាន់កាប់ទឹកដីមួយដែលគ្មានម្ចាស់នោះទេ" ។ ផ្ទុយមកវិញ គឺជាការកាន់កាប់ដោយខុសច្បាប់... ។

សម្ដេចព្រះ នរោត្តម សីហនុ នៅក្នុងអត្ថបទ "រាជាធិបតេយ្យកម្ពុជា" ដែលបោះពុម្ពផ្សាយដោយទិនានុប្បវត្តិប្រចាំសប្ដាហ៍ "Réalités Cambodgiennes" (ការពិតនៃប្រទេសកម្ពុជា) (បាននិយាយខាងលើរួចហើយ) បានគូសបញ្ជាក់ថា "ប្រជារាស្ត្ររបស់យើង និងភាគច្រើននៃព្រះមហាក្សត្ររបស់យើង, ព្រះអង្គម្ចាស់ និងព្រះអង្គម្ចាស់ក្សត្រី បានទទួលរងការឈឺចាប់ និងបានបង្ហូរឈាមរបស់ខ្លួនដើម្បីថែរក្សានូវបូរាណភាពជាតិ" ។

**"អពមង្គលរបស់យើង កើតចេញពីការក្បត់មួយចំនួន ដែលបានឈានទៅដល់ការធ្វើអនុប្បទាន (ការប្រគល់ឲ្យ) នូវខេត្តទាំងឡាយដែលពុំមានច្បាប់គតិយុត្តណាមួយ ដែលធ្វើឲ្យមានសុពលភាពនោះឡើយ"** ។

www.elibraryofcambodia.org

**ពាក្យថា "ពុំមានច្បាប់គតិយុត្ត ដែលធ្វើឲ្យមានសុពលភាពនោះ" បញ្ជាក់ច្បាស់ថា ស្ថានភាពគតិយុត្តរបស់ "កូសាំងស៊ីន" ស្ថិតនៅជារបស់ខ្មែរជានិច្ច ។**

J. Moura បានបញ្ជាក់ផងដែរថា នៅដំណាច់សតវត្សរ៍កន្លងមក ពុំមានអនុសញ្ញា ជាក់លាក់ណាមួយ ពុំមានសន្ធិសញ្ញាត្រឹមត្រូវតាមច្បាប់ណាមួយបានធ្វើអន្តរាគមន៍ ដើម្បីរៀបចំឲ្យត្រឹមត្រូវតាមច្បាប់នូវការកាន់កាប់ដោយពួកអណ្ណាមមកលើទឹកដីនេះទេ ។ គាត់បានបន្ថែមថា : ...ពុំទាន់មានព្រំដែនត្រូវបានគូសនោះ ទេ..." ។

អធិបតេយ្យភាពគតិយុត្តរបស់ប្រទេសកម្ពុជា នៅលើទឹកដីកម្ពុជាក្រោម បានស្ថិតនៅលើគោលការណ៍ការពារដោយច្បាប់អន្តរជាតិ និងការប្រតិបត្តិរបស់អន្តរជាតិ។

**ចំពោះបញ្ហានេះ មានទស្សនៈកម្ម៣ ដែលត្រូវបងថា គឺ :**

**១)-** ការកាន់កាប់ទឹកដី កូសាំងស៊ីន ដោយពួកអណ្ណាម គឺជាការកាន់កាប់មួយដោយកម្លាំងទ័ពនិងអាវុធ នូវទឹកដីមួយដែលមានប្រជាជនខ្មែរជាម្ចាស់ពេញទីប្រជាជនខ្មែរបានចិញ្ចឹមចិត្តធ្វើការប្រយុទ្ធមិនឈប់ឈរដើម្បីរំដោះទឹកដីនេះពីអ្នកលុកលុយ គឺអណ្ណាម ។

ច្បាប់អន្តរជាតិដែលអនុវត្តដោយ សមាគមនៃប្រជាជាតិ (បញ្ជីសំណួរស្ដីពីច្បាប់អន្តរជាតិទូទៅ ដែលចោទសួរនៅចំពោះមុខ S.D.N (សមាគមនៃបណ្ដាប្រជាជាតិ) ឆ្នាំ១៩២០-១៩៤៩ ទំព័រ២២២ ៣៨៥ និង ៣៨៧) និងចាប់ប្រើតទៅទៀតនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ (កថាខ័ណ្ឌ II នៃបុព្វកថា) បានប្រឆាំងដោយជាក់លាក់ ចំពោះការប្រើប្រាស់កម្លាំងអាវុធ ដើម្បីកាន់កាប់ទឹកដីរបស់រដ្ឋមួយ ។

**២)-** ព្រះមហាក្សត្រខ្មែរនិងប្រជាជនខ្មែរ មិនដែលបោះបង់ចោលនូវសិទ្ធិរបស់ខ្លួននៅលើទឹកដី កូសាំងស៊ីន នោះទេ ។ ព្រះមហាក្សត្រខ្មែរនិងប្រជាជនខ្មែរ បានតវ៉ា

www.elibraryofcambodia.org

ដោយស្វាហាប់និងយ៉ាងខ្ជាប់ខ្ជួន ប្រឆាំងនឹងការកាន់កាប់របស់ប្រទេសនេះ ទាំងជាមួយអធិរាជអណ្ណាម ក៏ដូចជាជាមួយប្រទេសបារាំង នៅក្នុងពេលដែលបារាំងនៅឥណ្ឌូចិន និងនៅពេលដែលបារាំងបានប្រគល់ កូសាំងស៊ីន ទៅឲ្យអធិរាជ បាវដាយ។

ចំពោះសមាគមនៃបណ្ដាប្រជាជាតិ (លេខ៣៩១នៃបញ្ញើលំដាប់រឿងដូចបានរៀបរាប់ខាងលើ) និងចំពោះមរតករបស់ខ្លួន អង្គការសហប្រជាជាតិបានឲ្យដឹងថាអធិបតេយ្យភាពនៃទឹកដីមួយ មិនត្រូវបានផ្ទេរឡើយ ដរាបណារដ្ឋដែលរក្សាទុកអធិបតេយ្យភាពនេះ មិនបានបោះបង់ចោលដោយជាក់លាក់នូវសិទ្ធិរបស់ខ្លួនទេនោះ ។

**៣)-** នៅមុនពេលការមកដល់របស់បារាំង ពុំមានព្រំដែនត្រូវបានគូសរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមឡើយ ។ បន្ទាប់មកប្រទេសកម្ពុជាមិនបានផ្ដល់នូវការព្រមព្រៀងរបស់ខ្លួនចំពោះគំនូសជាឯកតោភាគីនៃព្រំដែនខ្មែរ-កូសាំងស៊ីននោះទេ ។ គំនូសព្រំដែននោះត្រូវបានធ្វើឡើងជា ឯកតោភាគីដោយប្រទេសបារាំង គឺពុំមានច្បាប់ពេញលេញឡើយ ។

មាត្រាលេខ១២៥០ និងលេខ១៣៥៤ នៃបញ្ញើលំដាប់សំណួរនៃច្បាប់អន្តរជាតិទូទៅដាក់នៅចំពោះមុខសមាគមនៃបណ្ដាប្រជាជាតិ (S.D.N) បានបញ្ជាក់ថា "**ព្រំដែនរបស់រដ្ឋមួយអាចត្រូវបានកំណត់ លុះណាតែមានការយល់ព្រមរបស់ខ្លួន**" ។

ទឡ្ហីករណ៍សំខាន់ដែលយើងត្រូវធ្វើអត្ថាធិប្បាយ ដើម្បីគូសបញ្ជាក់មូលដ្ឋាន

គតិយុត្តរបស់អធិបតេយ្យភាពនៃប្រទេសកម្ពុជា នៅលើទឹកដីកម្ពុជាក្រោមនឹងត្រូវបានគាំទ្រដោយឯកសារផ្លូវការទាំងឡាយ និងដោយកំណត់សម្គាល់ដីបរិបូរណ៍របស់អ្នកប្រវត្តិសាស្ត្រ ឬក៏របស់អ្នកកាលប្បវត្តិ ដែលទាក់ទងមិនគ្រាន់តែទៅនឹងការតវ៉ាដែលបានធ្វើឡើងប៉ុណ្ណោះទេ ប៉ុន្តែនិងជាពិសេស គឺដោយសារការប្រយុទ្ធជានិច្ច ដែលចូលរួមដោយព្រះមហាក្សត្រទាំងឡាយនិងប្រជារាស្ត្រខ្មែរដើម្បី ដណ្ដើមយកមកវិញនូវខេត្តទាំងឡាយរបស់ខ្មែរនៅកូសាំងស៊ីន ។

www.elibraryofcambodia.org

នៅក្នុងការបោះពុម្ពផ្សាយមួយរបស់ព្រះបរមរាជវាំងនៅភ្នំពេញ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៥៧ នៅក្រោមចំណងជើងថា "ព្រះមហាក្សត្រនៃប្រទេសកម្ពុជា" សម្ដេច "ប៉ែន នុត" ព្រឹទ្ធបុរសនៃឧត្ដមក្រុមប្រឹក្សារបស់ព្រះមហាក្សត្រ ក្នុងការសរសេរអារម្ភកថានៃសៀវភៅស្ដើងនេះ បានសរសេរថា :

"...សៀវភៅនេះមានគោលបំណងដើម្បីជម្រាបឲ្យដឹងអំពីការខិតខំប្រឹងប្រែងមិនឈប់ឈររបស់ព្រះមហាក្សត្រយើង ដើម្បីយកមកវិញនូវទឹកដីកម្ពុជាក្រោមដែលត្រូវបានកាន់កាប់ ដោយប្រឆាំងនឹងច្បាប់ទាំងអស់ដោយព្រះរាជវាំងនៅ វៀ និងគោលបំណងរបស់ពួកគេ នៅចំពោះមុខអាជ្ញាធរក្នុងស្រុក និងរដ្ឋាភិបាលបារាំង ដើម្បីការពារប្រជាជនរបស់ខ្លួន ប្រឆាំងនឹងការរំលោភរបស់អាណាព្យាបាល" ។

"...ផលប្រយោជន៍នៃលិខិត និងស្នាដៃរបស់ព្រះមហាក្សត្រ និងព្រះអង្គម្ចាស់ទាំងឡាយ គឺមានជាក់ស្ដែង នោះគឺជាការបញ្ជាក់ឲ្យដឹងសម្រាប់ខ្មែរជាច្រើននាក់ និងជាប្រធានបទមួយគួរឲ្យចូលចិត្តសម្រាប់ជនបរទេស..."។

យើងបានឃើញនៅក្នុងការបោះពុម្ពផ្សាយនេះ នូវឯកសារផ្លូវការដ៏សំខាន់ក្រៃលែង ជាពិសេសព្រះរាជសាររបស់ព្រះករុណាព្រះបាទ"អង្គដួង" ផ្ញើថ្វាយ "**ព្រះចៅណាប៉ូឡេអុងទី III**" អធិរាជនៃប្រទេសបារាំង ដើម្បីទាមទារពីព្រះអង្គនូវខេត្តទាំងឡាយរបស់ ខ្មែរ នៅកូសាំងស៊ីន ។

ទឡ្ហីករណ៍នេះ បានធ្វើជាកម្មវត្ថុនៅលើផ្នែកពីរ ។

**ផ្នែកមួយ** :ការកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ និងដោយកម្លាំងកងទ័ពលើកូសាំងស៊ីន (ទឹកដីនៃប្រទេសកម្ពុជា) ដោយអណ្ណាម បន្ទាប់មកដោយបារាំង។

**ផ្នែកពីរ** :ការតវ៉ាយ៉ាងខ្ជាប់ខ្ជួនរបស់ប្រទេសកម្ពុជា ប្រឆាំងនឹងអ្នកកាន់កាប់កូសាំងស៊ីន ។

www.elibraryofcambodia.org

ការទុកជាមោឃៈ នៃការធ្វើអនុប្បទានទឹកដី កូសាំងស៊ីន ដោយប្រទេសបារាំង ទៅឲ្យអធិរាជ បាវដាយ និងការទុកជាមោឃៈនូវគំនូសព្រំដែនជាឯកតោភាគី ដែល ធ្វើឡើងដោយប្រទេសបារាំង នូវព្រំដែន **ខ្មែរ–កូសាំងស៊ីន** ។

* *

*

## ផ្នែកមួយ

## ការកាន់កាប់ខុសច្បាប់ និងដោយកម្លាំងធំ មកលើទឹកដី "កូសាំងស៊ីន", ដោយអណ្ណាម និងបន្ទាប់មកដោយប្រទេសបារាំង

*** ការពិនិត្យពិច័យទូទៅ**

កូសាំងស៊ីន ត្រូវបានរស់នៅដោយប្រជាជនខ្មែរ ចាប់តាំងពីសម័យហ៊្វូណនមក ម្ល៉េះ (២.០០០ឆ្នាំ មុនគ្រិស្តសករាជ) ។

នៅដើមសតវត្សរ៍ទី១៧ ពួកអណ្ណាមដោយសារឧបាយកល និងដោយសារ សង្គ្រាម បានជ្រៀតជ្រែកចូលមកក្នុងទឹកដីខ្មែរនៅ កូសាំងស៊ីន ។

ប្រជាជនខ្មែរ (ទាំងខ្មែរកម្ពុជាក្រោម) ក៏ដូចជាខ្មែរនៅកម្ពុជា មិនទុកឲ្យពួកអ្នក លុកលុយកាន់កាប់ដោយសន្តិភាព នូវខេត្តទាំងឡាយរបស់ពួកគេនោះឡើយ ។ ពួក គេបានប្រយុទ្ធប្រឆាំងនឹងពួកអណ្ណាម និងបានរុញច្រានទៅវិញជាច្រើនដង ។

ដូច្នេះការកាន់កាប់ទឹកដី កូសាំងស៊ីន ដោយអណ្ណាម និងបន្ទាប់មកទៀតដោយ ពួកបារាំង **"មិនមែនជាការកាន់កាប់ទឹកដីមួយដោយគ្មានម្ចាស់នោះទេ"** ។ **ព្រោះ ហេតុនោះ ការកាន់កាប់នេះ គឺខុសច្បាប់ ។**

www.elibraryofcambodia.org

នៅក្នុង "ការអត្ថាធិប្បាយស្តីពីច្បាប់អន្តរជាតិសាធារណៈ" របស់ខ្លួន (ឬក៏ច្បាប់នៃសន្តិភាព) លោក Marcel Sibert នាយកនៃវិទ្យាស្ថានសិក្សាជាន់ខ្ពស់អន្តរជាតិនៃសកលវិទ្យាល័យទីក្រុងប៉ារីស បានផ្តល់នូវអត្ថន័យនៃការកាន់កាប់ដូចតទៅនេះ (ទំព័រ៦០០-ទំព័រ៨៦០) :

"ការកាន់កាប់ គឺជាទង្វើរបស់រដ្ឋមួយ ដើម្បីចាប់យកដោយមានគោលបំណង ដើម្បីអនុវត្តអធិបតេយ្យភាពលើទឹកដីមួយដែលគ្មានម្ចាស់ នៅក្នុងពេលដែលការកាន់កាប់បានបំពេញ គឺថា**ពុំទាន់បានធ្វើ ឬក៏មិនបានធ្វើជាកម្មវត្ថុនៃការកាន់កាប់អធិបតេយ្យភាព នោះឡើយ**"។

លោក Vattel នៅក្នុងការអធិប្បាយរបស់ខ្លួន "ស្តីពីច្បាប់អន្តរជាតិ" (សៀវភៅលេខ១ ជំពូក XVIII- ទំព័រ២០៧) ដោយការបង្កើតការកាន់កាប់ទឹកដីមួយដែលគ្មានម្ចាស់ ទៅលើច្បាប់ធម្មជាតិ បានប្រកាសថា"...មនុស្សទាំងអស់មានច្បាប់ស្មើគ្នាចំពោះវត្ថុទាំងឡាយ ដែលនៅមិនទាន់ធ្លាក់ទៅជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ ហើយគាត់បានបន្ថែមថា "**វត្ថុទាំងនោះគឺជារបស់អ្នកកាន់កាប់ទី១**"។

ដូច្នេះគេមិនអាចប្រកែកបានទេថា "**ប្រជាជនខ្មែរគឺជាអ្នកកាន់កាប់ទី១នូវទឹកដីកូសាំងស៊ីន**" មិនមែនជាប្រជាជនវៀតណាមនោះឡើយ ។

* *

*

**ជាអ្នកកាន់កាប់ទី១នៃទឹកដីកម្ពុជាក្រោមគឺពូជអម្បូរខ្មែរ ហើយប្រជាជនខ្មែរមិនដែលបោះបង់បោល ទឹកដីនេះឡើយ និងបានតស៊ូមិនដែលដាច់ចំពោះការឈ្លានពាននៃអណ្ណាម** ។

លោក Moura បានបញ្ជាក់យ៉ាងច្បាស់ថា "គឺនៅឆ្នាំ១៦៧៥ ដែលបានចាប់

www.elibraryofcambodia.org

ផ្តើមធ្វើសង្គ្រាមមិនឈប់ឈរនេះ រវាងប្រជារាស្ត្រទាំងពីរ និងការដាក់បញ្ចូលជាឧបសម្ព័ន្ធយ៉ាងរហ័សនូវដែនដីសណ្តទាំងអស់នៃទន្លេមេគង្គ ទៅក្នុងព្រះរាជាណាចក្រអណ្ណាម ។ ប្រយោគរបស់លោក Moura នេះ ដោយអះអាងអំពីការតស៊ូរបស់ប្រជាជន ខ្មែរនោះ បានបង្ហាញច្បាស់អំពីការកាន់កាប់ខុសច្បាប់នូវទឹកដីមួយដែលត្រូវបានផ្តន្ទាទោសដោយច្បាប់អន្តរជាតិ និងវិន័យអន្តរជាតិ ។

ចំពោះការធ្វើសញ្ជ័យ វាត្រូវបានផ្តន្ទាទោសដោយច្បាប់អន្តរជាតិ ដែលថែមទាំងទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញបារាំងទៀតផង (*ភាគ VI*) ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ ១៧៩១ : **"...ប្រជាជាតិបារាំងបានបោះបង់ការធ្វើសង្គ្រាមណាមួយ ក្នុងគោលបំណងដើម្បីធ្វើសញ្ជ័យនោះ ហើយនិងមិនប្រើប្រាស់កងទ័ពប្រឆាំងនិងសេរីភាពរបស់ប្រជាជនណាមួយឡើយ"** ។

បើតាមបុព្វកថា នៃកតិកាសញ្ញារបស់សមាគមនៃប្រជាជាតិ បានឲ្យដឹងថា រដ្ឋនីមួយៗត្រូវយល់ព្រមទទួលយកកាតព្វកិច្ច "មិនពឹងផ្អែកលើសង្គ្រាមនោះឡើយ" ហើយនិងថែរក្សានូវទំនាក់ទំនងអន្តរជាតិដែលបង្កើតឡើងនៅលើភាពយុត្តិធម៌ និងកិត្តិយស ។

ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ នៅក្នុងបុព្វកថា ក៏ដូចជានៅមាត្រា២ (*ទំព័រ៥*) របស់ខ្លួន បានហាមឃាត់ដល់រដ្ឋទាំងឡាយ "មិនឲ្យពឹងផ្អែកលើការគំរាមកំហែង ឬក៏ការប្រើប្រាស់កម្លាំង គឺជាការរំលោភបូរណភាពទឹកដី ឬឯករាជ្យនយោបាយរបស់រដ្ឋទាំងអស់ គឺជាប្រឆាំងនឹងវិសមិត្ត (*ដែលមិនត្រូវគ្នា*) ផ្សេងៗទៀត ជាមួយនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ" ។

នៅក្នុងសម័យប្រជុំនៃសមាគមរបស់ប្រជាជាតិ តុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិ (C.P.J.I) "បានទទួលស្គាល់ (*សូមមើលអង្គការអន្តរជាតិទាំងឡាយនៅឆ្នាំ១៩៦១ របស់* Marc Stanislas Korowiez) អធិបតេយ្យ (*ឯករាជ្យ*) របស់រដ្ឋ

www.elibraryofcambodia.org

ទាំងឡាយ ធ្វើជាគោលការណ៍មូលដ្ឋាននៃច្បាប់អន្តរជាតិ" ។

តុលាការអន្តរជាតិនៃយុត្តិធម៌ (C.I.J) បច្ចុប្បន្ននៅក្នុងផែ្នករបស់ខ្លួន បាន ប្រកាន់យកនូវជំហរដោយផ្ទាល់ជាច្រើនដង ចំពោះបញ្ហាទាំងឡាយដែលទាក់ទង ដោយផ្ទាល់ទៅនឹងអធិបតេយ្យភាពរបស់រដ្ឋទាំងឡាយ ដោយការផ្តន្ទាទោសនូវការ ធ្វើអន្តរាគមន៍ដោយកម្លាំងតាមគ្រប់រូបភាព ។

នៅក្នុងសាលដីកា របស់ខ្លួន ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៤៩ (C.I.J.Rec.1949 ទំព័រ៣៥) **នៅក្នុងកិច្ចការដែលសមុទ្រ Corfou** តុលាការអន្តរជាតិនៃយុត្តិធម៌ បាន រំលឹកថា **"រវាងរដ្ឋឯករាជ្យទាំងឡាយ ការគោរពអធិបតេយ្យភាពទឹកដី គឺជាមូល ដ្ឋានដ៏សំខាន់មួយនៃទំនាក់ទំនងអន្តរជាតិ"** ។

នៅក្នុងសាលដីកានេះ តុលាការបានថ្លែងម្យ៉ាងទៀតប្រកបដោយភាពស្វាហាប់ ប្រឆាំងនឹងការធ្វើអន្តរាគមន៍តាមគ្រប់រូបភាព គឺ : "ច្បាប់ដែលអះអាងអំពីការធ្វើ អន្តរាគមន៍ អាចត្រូវបានពិនិត្យមើលដោយអនុក្រិត្យនេះ ដូចជាការសម្តែងនយោ បាយមួយរបស់កងទ័ព នយោបាយដែលនៅក្នុងអតីតកាល បានផ្តល់ឲ្យកើតមាននូវ ការរំលោភដ៏ធ្ងន់ធ្ងរបំផុតនោះ ហើយទោះបីជាមានការអន់ថយរបស់ អង្គការអន្តរ ជាតិនៅពេលបច្ចុប្បន្ននេះក៏ដោយ ក៏មិនអាចរកឃើញកន្លែងណាមួយនៅក្នុងច្បាប់ អន្តរជាតិនោះឡើយ..." ។

**ដូច្នេះ "ការកាន់កាប់ដោយកងទ័ពនូវទឹកដីរបស់រដ្ឋមួយ ត្រូវបានផ្តន្ទាទោសជា ឯកច្ឆន្ទដោយច្បាប់អន្តរជាតិ" មុនដំបូងការកាន់កាប់ដោយពួកវៀតណាម បន្ទាប់ មកដោយពួកបារាំងលើទឹកដី "កូសាំងស៊ីន" "ទឹកដីដែលជាផ្នែកមួយរបស់ព្រះរាជា ណាចក្រកម្ពុជា ត្រូវតែស្ថិតនៅក្នុងការផ្តន្ទាទោសតាមរបៀបដូចគ្នានេះ... !"**

***

www.elibraryofcambodia.org

****.- ហេតុការណ៍នៃប្រវត្តិសាស្ត្រ**

ការកាន់កាប់ដោយខុសច្បាប់នូវទឹកដីកូសាំងស៊ីន ដែលជាទឹកដីរបស់ប្រទេសកម្ពុជា ដោយពួកវៀតណាម ។

គេត្រូវញែកចេញជាពីរសម័យកាល : គឺសម័យកាលនៅមុនព្រឹត្តិការណ៍របស់ព្រះមហាក្សត្រអង្គដួង និងសម័យកាលដែលមានជាបន្តបន្ទាប់មកទៀត ។

**ក).- សម័យកាលមុនព្រឹត្តិការណ៍របស់ព្រះមហាក្សត្រ "អង្គដួង"**

**១)- បណ្តាឆ្នាំដំបូងនៃការឈ្លានពានរបស់វៀតណាម**

មានអ្នកប្រវត្តិសាស្ត្រជាច្រើនបានដាក់កាលបរិច្ឆេទនៃទំនាក់ទំនងដែលបានបង្កើតឡើងរវាងអណ្ណាមនិងប្រទេសកម្ពុជា ដោយការមកដល់ព្រះរាជវាំងខ្មែរនូវម្ចាស់ក្សត្រីអណ្ណាមមួយអង្គ ដែលព្រះបាទជ័យជេដ្ឋា ឬជ័យចេស្តាទី២ (១៦១៨-១៦២៨) បានរៀបអភិសេកនៅក្នុងឆ្នាំ១៦២០ ហើយដែលព្រះអង្គបានតម្លើង (ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, A. Leclère ទំព័រ៣៣៣) ទៅដល់ឋានៈដ៏ខ្ពង់ខ្ពស់ជាព្រះមហាក្សត្រិយានី ដោយមានងារជាសម្តេចភគវតី ព្រះស្រីវក្សត្រីយ៍"។ នៅឆ្នាំ១៦២៣ ព្រះមហាក្សត្រអណ្ណាមបានទទួលពីព្រះបាទ "ជ័យចេស្តាទី២" នូវការអនុញ្ញាតដើម្បីបង្កើតគ្រឹះស្ថានជំនួញនៅភាគខាងត្បូងបំផុតនៃកូសាំងស៊ីនជាពិសេសនៅក្រុងព្រៃនគរ (លោក Leclère) បានកត់សម្គាល់បញ្ហានេះថា "... ប្រទេស ដែលបច្ចុប្បន្ននេះមានភូមិព្រៃនគរ និងភូមិចឹឡឹង មិនមែនឈ្មោះថា "ព្រៃនគរ" ទេ ។ លោក Leclère បាននិយាយថា ឈ្មោះរបស់ភូមិនេះ គឺ "ព្រៃ គ" ។ ហើយ ចេញពីឈ្មោះនេះហើយ ដែលពាក្យសាយហ្គនត្រូវបានយកចេញពីឈ្មោះនេះ ។ អក្សរពីរ របស់ចិន ដែលតាមការពិតគេបានសរសេរដែលមានន័យថា "ព្រៃ និង គ" ។

www.elibraryofcambodia.org

គេត្រូវកត់សម្គាល់ជាបន្ថែមទៀតថា ច្បាប់អនុញ្ញាតដែលយល់ព្រមដោយព្រះបាទ ជ័យចេស្តាទី២ ថ្វាយដល់ព្រះមហាក្សត្រ ក្រុងវ៉េ មិនមែនជាច្បាប់គតិយុត្តមានតម្លៃជាសន្ធិសញ្ញាមួយ ដែលផ្តល់ កូសាំងស៊ីន ទៅឲ្យប្រជាជនអណ្ណាមនោះទេ ។ ប៉ុន្តែ,វាគ្រាន់តែជាការអនុគ្រោះមួយ យល់ព្រមដោយព្រះមហាក្សត្រមួយអង្គចំពោះជនបរទេសតែប៉ុណ្ណោះ ។ ច្បាប់នេះស្រង់ចេញពីច្បាប់ផ្ទៃក្នុងរបស់រដ្ឋមួយ ប៉ុន្តែ ពួកអណ្ណាមបានឆ្លៀតឱកាសនៃការអនុគ្រោះ របស់ព្រះបាទ ជ័យចេស្តាទី២ ដើម្បីវាយប្រហារប្រជាជនខ្មែរ និងដណ្តើមយកខេត្តរបស់ពួកខ្មែរ នៅកូសាំងស៊ីន ។

លោក A. Leclère សរសេរនៅក្នុងសៀវភៅ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា" (ទំព័រ៣៣៩) ថា : **"...នៅឆ្នាំ១៦២៣ អ្នកស្រីឯកអគ្គរាជទូតអណ្ណាមម្នាក់ បាននាំមកនូវជន្វាយដ៏ស្តុកស្តម្ភ មកថ្វាយព្រះមហាក្សត្រ "ជ័យចេស្តាទី២" ជាព្រះរាជសុណិសា របស់ព្រះមហាក្សត្រអណ្ណាម ដើម្បីស្នើសុំអនុញ្ញាត ពីព្រះអង្គបង្កើតនូវគ្រឹះស្ថានទាំងឡាយរបស់អណ្ណាម នៅភាគខាងត្បូងបំផុត នៃព្រះរាជាណាចក្រ និងដើម្បីតាំងឲ្យពួកគេមានច្បាប់បង្កើតកន្លែងហូតពន្ធមួយនៅ ព្រៃ គ (សាយហ្គន)។ ដោយហេតុថា ព្រះមហាក្សត្រ ពុំហ៊ានប្រានបោលនូវសេចក្តីស្នើនេះ និងដោយហេតុថា មហាក្សត្រីយានីអណ្ណាមបានសន្យាចំពោះទូតនោះថា នឹងទទួលគេឲ្យបានល្អនោះ, ព្រោះថាឯកអគ្គរាជទូតនេះត្រូវបានព្រះបិតាព្រះនាងចាត់មកនោះ, ព្រះបាទជ័យ ចេស្តាទី២ក៏បាន អនុញ្ញាតយល់ព្រមថ្វាយតាមការសុំទាំងពីរនេះ, ហើយដោយរបៀបនេះហើយ ទើបពួកយួន និងអណ្ណាមបានចូលមកប្រទេសកម្ពុជា និងចាប់ផ្តើមដណ្តើមយកប្រទេសនេះ ដែលបច្ចុប្បន្នយើងហៅថា "កូសាំងស៊ីននោះឯង" ។**

លោក A. Megot នៅក្នុងសៀវភៅរបស់លោក ("ប្រជាជនខ្មែរ" ទំព័រ២៦៩) បាននិយាយថា "ការទន្ទ្រានយករបស់អណ្ណាម មានសភាពកាន់តែខ្លាំងឡើង រហូត

www.elibraryofcambodia.org

ដល់ការដណ្តើមយកស៊ើរតែទាំងអស់នូវទឹកដីកម្ពុជា" ហើយលោកបានបន្ថែមថា "បច្ចុប្បន្ននេះទៀតសោត រឿងដ៏សំខាន់បំផុតនៃការទាមទាររបស់ប្រទេសនេះ គឺការត្រឡប់មកមាតុភូមិដើមវិញរបស់ខេត្តនេះ ដែលនៅក្នុងចំណោមប្រជាជនរបស់ខ្លួន មានប្រជាជនកម្ពុជាជាង៣០០.០០០នាក់នោះ" ។

១៩ឆ្នាំក្រោយមក នៅក្រោមរជ្ជកាលរបស់ព្រះបាទ បុទុមរាជាទី២ ដែលគេស្គាល់នៅក្រោមព្រះនាមថា "ពញាច័ន្ទ ស្តេចចូលសាសនាជ្វា" (១៦៤២-១៦៥៩) ប្រទេសកម្ពុជាមានការលំបាកជាមួយពួកហុល្លង់ ជាក្រុមពាណិជ្ជករដែលមកតាំងទីលំនៅនៅប្រទេសកម្ពុជា ។ ពួក ហុល្លង់ ទាំងនេះបានរកឃើញពួក ព័រទុយហ្គេ (មកនៅកម្ពុជាពីឆ្នាំ១៥៥៣) ដែលជាសត្រូវរបស់ពួកគេនៅទីនោះ ។ តាមលោក A. Leclère, ("សៀវភៅ ប្រវត្តិសាស្ត្រកម្ពុជា" ទំព័រ៣៤៦) បានឲ្យដឹងថា ប្រជាជាតិទាំងពីរនេះ មានការប្រកួតប្រជែងគ្នាយ៉ាងខ្លាំង និងស្អប់គ្នាទៅវិញទៅមកផង...។ តាមការញុះញង់របស់ពួក ព័រទុយហ្គេ និងពួក ម៉ាឡេ ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ដោយសង្ស័យថា ប្រជាជន ហុល្លង់ ជា "ចារបុរសរបស់សៀម" ទើបមានការសម្លាប់ និងរួចរឹបអូសយកគ្រឿងស្ពានរបស់ពួកគេ និងដណ្តើមយកនាវារបស់ពួកគេ "Le Noor dwyck" និងនាវាផ្ទុកកំសាន្តរបស់ពួកគេ "Le Ryswyck" (ទំព័រ៣៤៨) ។

ដោយទទួលបានដំណឹងនេះ ពួក ហុល្លង់ "បានសម្រេចចិត្តធ្វើការសងសឹកចំពោះការសម្លាប់រង្គាលនេះ" ។ ដូច្នេះប្រជាជនវៀតណាមមិនមែនមានតែម្នាក់ឯងនៅក្នុងសហគ្រាសនៃការឈ្លានពានរបស់ពួកគេនោះឡើយ ។ លោក Charles Le mire នៅក្នុង "សេចក្តីរាយការណ៍របស់ខ្លួន ស្តីពីកាលប្បវត្តិវិទ្យា" បានរាយការណ៍ថា នៅក្នុងឆ្នាំ១៦៤៣ លោក Rogemontes ឯកអគ្គរដ្ឋទូត ហុល្លង់ និងអ្នកបម្រើរបស់ខ្លួនត្រូវគេសម្លាប់ ។ ពួក ហុល្លង់នៅក្នុងនាវា ត្រូវបានគេសម្លាប់មួយផ្នែក ។

www.elibraryofcambodia.org

នៅបណ្ដាឆ្នាំបន្តបន្ទាប់មក ពួកគេបានធ្វើការសង់សឹក ដោយជម្រុញឲ្យពួកអណ្ណាម ធ្វើសង្គ្រាមជាមួយប្រទេសកម្ពុជា និងដណ្ដើមយកប្រទេសនេះ" ។

ព្រឹត្តិការណ៍ទាំងអស់នេះ បានផ្ដល់អំណោយផលយ៉ាងខ្លាំងដល់មហិច្ឆតារបស់ពួកអណ្ណាម ដែលក្រោយពីការ "លេបយក" ប្រទេសចំប៉ាទាំងមូលមកនោះ ចង់លេបយក កូសាំងស៊ីន ផង និងប្រទេសកម្ពុជាទាំងអស់ថែមទៀត ។ ភាពសម្បូរធនធាននៃប្រទេសកម្ពុជា ទឹកដីដ៏មានជីវជាតិរបស់ប្រទេសនេះ បានធ្វើឲ្យពួកវៀតណាមមានចំណង់ចង់បានយ៉ាងខ្លាំង ។ យើងបានឃើញការបញ្ជាក់អះអាងចេញពីក្រអូមមាត់របស់អ្នកប្រវត្តិសាស្ត្រវៀតណាមម្នាក់ គឺលោក ទ្រឿង វិញគី (Truong Vinh Ky) ។ លោក A. Leclère បានរៀបរាប់ថា : អ្នកប្រវត្តិសាស្ត្រ ទ្រឿង វិញគី បាននិយាយថា "ព្រះរាជាណាចក្រកម្ពុជា ជាមួយ នឹងទន្លេដ៏ធំរបស់ខ្លួន ព្រៃកជីកដ៏ច្រើនរាប់មិនអស់របស់ខ្លួន និងស្រែដែលឲ្យផលដ៏ច្រើន របស់ខ្លួននោះ គឺជាចំណីដ៏ល្អសម្រាប់គាត់" (Truong Vinhky) ។

ពួកអណ្ណាមដោយមានការជួយពី**មហេសីវៀតណាម** របស់ព្រះបាទ **ជ័យចេស្ដាទី២,** នៅពេលនោះ បានចាប់ផ្ដើមធ្វើការវាយប្រហារលើកដំបូងៗរបស់ពួកគេប្រឆាំងប្រទេសកម្ពុជា ។ នៅក្នុងឆ្នាំ១៦៥៨ កងទ័ពមួយដែលមានទាហាន ២០.០០០នាក់ នៅក្រោមបញ្ជារបស់ឧត្ដមសេនីយ៍ Ong-Chieng-Thu បានវាយប្រហារព្រះបាទ **អង្គច័ន្ទ** ។ ឧត្ដមសេនីយ៍អណ្ណាមបានទទួលជ័យជំនះ ហើយព្រះមហាក្សត្រខ្មែរ ត្រូវបានពួកអណ្ណាមចាប់យកទៅជាមួយនឹងមន្ត្រីហែហមរបស់ព្រះអង្គ និងត្រូវពួក អណ្ណាម ដាក់ឃុំនៅក្នុងទ្រុងដែក និងត្រូវបាននិរទេសទៅក្វាងប៊ិញ (Quang Binh) បណ្ដោយព្រំដែន "អណ្ណាម តុងកឹង" ។

ប៉ុន្តែពួកអណ្ណាមនៅមិនទាន់បានធ្វើជាម្ចាស់នៃសភាពការណ៍នេះនៅឡើយទេ ។ ព្រះមហាក្សត្រខ្មែរទាំងឡាយបានធ្វើការប្រឆាំង និងប្រមែប្រមូលកងទ័ព ដើម្បី

www.elibraryofcambodia.org

វាយកម្ចាត់ឧត្តមសេនីយ៍ Ong-Chieng-Thu និងកងទ័ពរបស់គេ ។ តាមលោក Leclère (H.C ទំព័រ៣៥២) បានឲ្យដឹងថា ឧត្តមសេនីយ៍រូបនេះ "ត្រូវបានបង្ខំចិត្តធ្វើការប្រយុទ្ធដើម្បីដកថយ និងបានចេញពីប្រទេសកម្ពុជានៅឆ្នាំ១៦៥៩ ដោយបានដឹកជញ្ជូនយកទៅជាមួយនូវទ្រព្យសម្បត្តិរបស់ខ្មែរយ៉ាងច្រើន" ។

នោះហើយជាការប្រព្រឹត្តទៅនៃការឈ្លានពានរបស់អណ្ណាម នៅក្នុងបណ្តាឆ្នាំដំបូងៗយ៉ាងដូចម្តេចនោះ... ។ ថ្វីបើប្រជាជនខ្មែរអាចបណ្តេញពួកឈ្លានឈានចេញពីប្រទេសកម្ពុជាក៏ដោយ ក៏នៅសល់សមាសភាពមួយចំនួនតិចដែលគេមិនចង់ឃើញមុខ បានតាំងនៅពេលនោះនៅខេត្តបារៀ និងខេត្តដូងណៃ (ដូនណៃ)។

នៅក្នុងពេលមានជម្លោះនៅក្នុងវាំង នៅឆ្នាំ១៦៥៨ ព្រះអង្គទាំងឡាយបានដើបបះបោរប្រឆាំងនឹងព្រះមហាក្សត្រ (ព្រះអង្គច័ន្ទ) ។ លោក A. Leclère បានសរសេរចំពោះបញ្ហានេះថា :

"...ព្រះអង្គម្ចាស់ទាំងឡាយបានទទួលបរាជ័យ នៅក្នុងពេលជួបគ្នាលើកដំបូង និងបានទៅជ្រកកោននៅក្បែរមហាក្សត្រីយានី ដែលមានវ័យចំណាស់ហើយ និងជាមហេសីមេម៉ាយ របស់ព្រះ ជ័យជេដ្ឋាទី២, ព្រមទាំងមានដើមកំណើតជាជនជាតិអណ្ណាម ។ មហាក្សត្រីយានីមេម៉ាយនេះ បានសម្រេចស្នើសុំការជួយពីព្រះមហាក្សត្រអណ្ណាម ។ ព្រះមហាក្សត្រីយ៍អង្គនេះដោយមានពពួកក្រុមមនុស្សដែលជាជនអនាថា, ជាអ្នករត់ បោលផ្លូវ, ជាអ្នកត្រូវបានគេបំបរបង់, និងប្រភេទមនុស្សផ្សេងៗទៀត បានមករស់នៅប្រទេសកម្ពុជា និង បានទៅរស់នៅលាយឡំជាមួយប្រជាជនម្ចាស់ស្រុក និងបានតាំងទីលំនៅ,. ជាពិសេសនៅក្នុងខេត្តបារៀ និងខេត្តដូនណៃ, ដោយជឿថា នឹងរកឃើញនូវឱកាសដ៏ល្អមួយដើម្បីដណ្តើមយកប្រទេសនេះ" ។

www.elibraryofcambodia.org

**២)– ប្រជាជនចិនចំនួន ៣.០០០នាក់ ត្រូវបានបញ្ជូនមកប្រទេសកម្ពុជា ដោយព្រះមហាក្សត្រអណ្ណាម**

តាមលោក Leclère បានឲ្យដឹងថា "...នៅឆ្នាំ១៦៨០ (*រជ្ជកាលរបស់ព្រះអង្គសូរ ឬ ជ័យជេដ្ឋាទី៤–១៦៧៥–១៦៨៨*) មានឧត្តមសេនីយ៍ចិនម្នាក់ឈ្មោះ Duong-ngan-Dich បក្សពួករបស់រាជវង្សមិញ (Minh) ដោយចាញ់កងទ័ព Khan-Hi បានឡើងគោកនៅអណ្ណាម ។ ក្នុងចំណោមសំពៅចំនួន២០០នៃកងទ័ព របស់ពួកគេ គឺនៅសល់សំពៅប្រហែល៥០សំពៅ ជាមួយនឹងទាហាន៣.០០០នាក់ ។ ឧត្តម–សេនីយ៍ រូបនេះបានទៅកាន់ Tourane ជាមួយនឹងកងទ័ពរបស់ខ្លួនបានចុះចូលជាមួយ អណ្ណាម និងបានសុំដីធ្លីដើម្បីរស់នៅ ។

លោក Leclère បានសរសេរថា "...ព្រះមហាក្សត្រអណ្ណាមដែលមិនចង់បានជន បរទេស៣.០០០នាក់នេះនៅក្បែរខ្លួននោះ... មិនបានថ្វាយដំណឹងដល់ព្រះមហាក្សត្រជ័យជេដ្ឋាឲ្យបានដឹងជាមុនផង ក៏បានបញ្ជូនពួកគេឲ្យមកប្រទេសកម្ពុជានៅ ខេត្តបារៀ និងខេត្តដូងណៃ ។ ប៉ុន្តែដោយមិនសប្បាយចិត្តរស់នៅក្នុងខេត្តបារៀ ឧត្តមសេនីយ៍ចិនរូបនេះក៏បាន ជ្រើសរើសយកខេត្តមីថ (*ស្មឹធរ (ជា)មេ–ស*) ជាមួយនឹងកងទ័ពរបស់ខ្លួនចំនួនពាក់កណ្តាល និងបានទុកពាក់កណ្តាលនៅបារៀ នៅក្រោមបញ្ជាការរបស់ភូឈួយរបស់ខ្លួនឈ្មោះ ត្រឹង "។

នេះក៏ជាអំពើមួយខុសច្បាប់ដែរ !... ព្រះមហាក្សត្រអណ្ណាមមិនមានសិទ្ធិអនុញ្ញាតឲ្យជនបរទេសមកតាំងនៅក្នុងប្រទេសកម្ពុជានោះឡើយ ។ ការតាំងទីលំនៅរបស់ជនភៀសខ្លួនចិនចំនួន៣.០០០នាក់នៅខេត្តបារៀនិងមីថ មិនបានចោទជាបញ្ហាចំពោះអធិបតេយ្យភាពរបស់ប្រទេសកម្ពុជានៅលើតំបន់នេះទេ ។

**៣)– ការប្រជែងគ្នារវាងសៀមនិងអណ្ណាម ដើម្បីវែបងវែកចំណីរបស់ពួកគេ "គឺប្រទេសកម្ពុជា"...**

www.elibraryofcambodia.org

នៅឆ្នាំ១៦៦០ ពួកសៀមដោយច្រណែននិងការដើរលឿនទៅមុខរបស់អណ្ណាមនោះ បានប៉ុនប៉ងប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីកម្ចាត់ពួកអណ្ណាមចេញពីទឹកដីមួយដែលពួកគេចាត់ទុកដូចជាចំណីក្នុងពេលអនាគតរបស់ពួកគេ (ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាដោយ A. Leclère ទំព័រ៣៥២) ។ ...ហេតុដូច្នេះហើយចាប់ពីកាលបរិច្ឆេទនេះតទៅ ពួកសៀមក៏បានយកចិត្តទុកដាក់លើ "ដែនដីកូសាំងស៊ីន" ច្រើនឡើងៗ ។

លោក Leclère បាននិយាយថា "...នៅឆ្នាំ១៦៨៤ មហាក្សត្រ អាយុធ្យា ដែលស្វែងរកតែការបញ្ឆេះសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជាឡើងវិញនោះ, បានបញ្ជូនកងទ័ពជើងគោកនិងជើងទឹកមកប្រទេសកម្ពុជា ដែលត្រូវបានកម្ទេចដោយព្រះមហាក្សត្រ អង្គសូរ" ។

ចំណែកពួកអណ្ណាមវិញ ពួកគេបានបញ្ជូនកងទ័ពមួយដែលមានទាហានចំនួន ៥.០០០នាក់ ។ កងទ័ពនេះបានជួបនឹងកងទ័ពភូមិន្ទកម្ពុជា ដែលបញ្ជាដោយលោក "ពញាភក្តីសង្គ្រាម" នៅវាលហុង ។ លោក Leclère បាននិយាយថា "...កងទ័ពអណ្ណាម នេះត្រូវបរាជ័យ និងត្រូវបង្ខំចិត្តដកថយយ៉ាងឆាប់រហ័សនៅជ្រោយចង្វា ។ ឧត្តមសេនីយ៍កម្ពុជា ដោយមើលឃើញនូវភាពច្របូកច្របល់របស់ពួកគេនោះ លោកបានដេញតាមពួកអណ្ណាម ដោយឆ្លងកាត់ទន្លេតាមក្បួន រួចវាយប្រហារបន្ទាយនៅកោះនេះ និងដណ្តើមយកបានមកវិញ" ។

លោក Leclère បានបន្ថែមថា "...កងទ័ពសត្រូវ (ទំព័រ៣៥៩) មានការភ័យស្លន់ស្លោ បែកខ្ញែកគ្នារត់ច្របូកច្របល់ អូសទាញប្រធានរបស់ពួកគេ ហើយពួកឧត្តមសេនីយ៍អណ្ណាមទាំងនោះជួបការលំបាកយ៉ាងខ្លាំង ក្នុងការត្រឡប់ទៅ កូសាំងស៊ីនវិញ" ។ ជាថ្មីម្តងទៀត ការតស៊ូរបស់ខ្មែរត្រូវបានសម្តែងចេញនៅចំពោះមុខការឈ្លានពានរបស់អណ្ណាម និងបានទទួលជ័យជំនះ ។

www.elibraryofcambodia.org

## ៤)– ការបះបោររបស់ចិននៅមីថ (ស្នើរ)

តាមការញុះញង់របស់ ហ្វិញ តឹង (Huynh Tân) (ដែលជាអនុសេនីយ៍ទោចិនម្នាក់) ពួកចិន នៅ មី–ថ បានសម្លាប់ Duong-ngan-Dich និងចង់កសាងប្រទេសទៅជារដ្ឋមួយដែលមានព្រះអង្គម្ចាស់ជាប្រមុខ (Prina-pauté) ។ ផ្លូវទាំងឡាយត្រូវបានរាំងខ្ទប់ ហើយប្រជាជនកម្ពុជាត្រូវបានចាប់ខ្លួន ។

ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ព្រះអង្គបានមានការប្រុងប្រយ័ត្ន ដោយកសាងបន្ទាយតូចៗនៅភ្នំពេញ, នៅ បាក់–អូណាម (បាណាម) និងនៅ Gô-bich ។

កងទ័ពអណ្ណាមក្រោយពីមានជោគជ័យក្នុងការ បង្ក្រាបពួកចិននៅមីថ មកក៏បន្តដំណើរចូលមកភ្នំពេញទៀត, ប៉ុន្តែកងទ័ពភូមិន្ទខ្មែរបានវាយរុញច្រានពួកគេឲ្យត្រឡប់ទៅវិញ ។

## ៥)– ការកាន់កាប់ខេត្តនៅភាគខាងត្បូង : សាយហួន បារៀ និង បៀងហ្វា នៅឆ្នាំ១៦៩៩

សម្តេចព្រះ នរោត្តម សីហនុ បានរាយការណ៍នៅក្នុងសៀវភៅ "រាជាធិបតេយ្យកម្ពុជា" អំពីកាលៈទេសៈនៃការកាន់កាប់របស់អណ្ណាម នូវខេត្តបៀងហ្វា បារៀ និងសាយហួន របស់ខ្មែរ ។

"៣ឆ្នាំបានកន្លងផុតទៅ (ប្រហែលនៅក្នុងឆ្នាំ១៦៩៩) ។ មន្ត្រីលោកឧកញ៉ា នរិន្ទឯម បានបង្កើតគម្រោងផ្តួលរំលំព្រះមហាក្សត្រ (អង្គសូរ) ។

ពួកអណ្ណាមបានគាំទ្រឧកញ៉ានេះ ជាមួយនឹងកងទ័ព ២០.០០០នាក់ ។

អ្នកកត់ត្រាប្រវត្តសាស្ត្របាននិយាយថា ព្រះមហាក្សត្រ ជ័យជេដ្ឋាទី៤ ដោយភ្ញាក់ផ្អើលនឹងការឈ្លានពានដ៏ចាប់រហ័សនេះ បានដកថយទៅគង់នៅខេត្តពោធិសាត់ ។ នៅទីនោះព្រះអង្គអាចប្រមូលផ្តុំកងទ័ពបានចំនួន ៤០.០០០នាក់ ។ កងទ័ពខ្មែរនិងកងទ័ពអណ្ណាម បានជួបគ្នានៅខេត្តកំពង់ឆ្នាំង ។ កងទ័ពអណ្ណាមត្រូវបានកង

www.elibraryofcambodia.org

ទឹកខ្មែរវាយច្រានទៅដល់មាត់ពាមទន្លេមេគង្គ ដែលនៅទីនោះពួកអណ្ណាមអាច រក្សាខ្លួន និងតាំងនៅជាស្ថាពរនៅបៀនហ្វា បារៀ និង សាយហ្គន" ។

បើតាមលោក Leclère បានឲ្យដឹងថា "ជនក្បត់ នរិន្ទ ឯម ត្រូវបានទាហាន អណ្ណាមសម្លាប់ នៅមុនពេលដែលកងទ័ពរបស់ខ្លួនបានធ្វើដំណើរត្រឡប់ទៅទិស ខាងត្បូងវិញបន្តិច" ។

**៦)– អំពើលួចប្លន់តាមសមុទ្ររបស់ចិន ម៉ាក់ គីវ (Mac-Cuu) នៅលើមាត់ឈូងសមុទ្រសៀម (ហាទៀង–ក្វុក) ឆ្នាំ១៧១៥**

ម៉ាក់ គីវ (Mac-Cuu) ជនជាតិចិនម្នាក់ ដើមកំណើតនៅក្វាងទុង គឺជាមេភាស៊ីម្នាក់នៅភ្នំពេញ ។ បានក្លាយទៅជាអ្នកមាន ក្រោយមកទៀតគាត់បានរើរវាយ ចង់ឲ្យកាន់តែមាន ជាងនេះទៀត ។ គាត់បានទៅតាំងទីលំនៅ នៅមាត់ពាម (ហាទៀង) ។ លោក Leclère បានសរសេរថា : "...ពួកចោរលួច ចោរប្លន់ ចិន និងអណ្ណាម ជា ពួកចោរ ហនេយ្យ៉ំ បានប្រមូលផ្តុំនៅជុំវិញគាត់ ។ ពួកនេះបានស្នើ នៅបម្រើក្រោម ប្រធានម្នាក់ប្រកបដោយថាមពល គឺ ម៉ាក់ គីវ" ។

Mac-Cuu បានទទួលជោគជ័យក្នុងការដណ្តើមយកមជ្ឈមណ្ឌលសំខាន់ៗចំនួន ពាដិបូងពីពាម ដែលបានទទួលឈ្មោះថាជា ហាទៀង ភូក្វុក ដែលនៅពេលនោះ កម្ពុជាហៅថាកោះត្រល់ ស្រែល្បួង–ភ្លើ ដែលជាស្រែអំបិល (នៅក្នុងខេត្តកំពង់ សោម), រាំងធំ (កំពង់សោម), អតីតក្រមួន–ស, កូវវ៉ូត (កំពត) និង កា–ម៉ៅ ពីមុនហៅថា ទឹកខ្មៅ នៅភាគខាងត្បូងប្រទេស ។

មជ្ឈមណ្ឌលបុងក្រោយទាំងនេះ ត្រូវបានយកមកវិញនៅពេលយូរក្រោយមក ដោយព្រះមហាក្សត្រនៃប្រទេសកម្ពុជា ។ គឺមានតែមជ្ឈមណ្ឌលពីរប៉ុណ្ណោះដែល ស្ថិត នៅក្រោមការគ្រប់គ្រងរបស់មេចោរ Mac-Cuu គឺ ពាម និង កោះត្រល់ ។ Mac- Cuu បានប្រគល់មជ្ឈមណ្ឌលនេះទៅឲ្យមហាក្សត្រអណ្ណាម ដែលអណ្ណាមបាន

www.elibraryofcambodia.org

តែងតាំងគាត់ឲ្យធ្វើជាចៅហ្វាយខេត្តនិងជាឧត្តមសេនីយ៍នៅតំបន់នេះ(១៧១៥) ។

អំពើប្លន់ទាំងនេះ ច្បាស់ជាណាស់ គឺពុំមានតម្លៃជាគតិយុត្តបន្តិចណាឡើយ, ម៉ាក់គីវ (MAC-CUU) គ្មានសិទ្ធិស្របច្បាប់ណាមួយដើម្បីប្រគល់ទឹកដីខ្មែរទៅឲ្យស្តេចប្រទេសអណ្ណាម ឡើយ ។

៧)– ថ្វីបើមានការតស៊ូដែលចាត់ចែងឡើងដោយព្រះមហាក្សត្រ និងប្រជារាស្ត្រខ្មែរក៏ដោយ ក៏ពួកអណ្ណាមបានទទួលជោគជ័យក្នុងការប្រគោងយក មី ថ (ស្មឹធរ), វីញឡុង និងបន្ទាប់មកទៀត បាសាក់ ។

នៅក្នុងពេលដែលពួកអណ្ណាមបានរុលទៅមុខ ទៅក្នុងភាគអាគ្នេយ៍នៃ កូសាំងស៊ីនពួកសៀមបានប្រតិបត្តិការនៅទិសពាយ័ព្យ នៃព្រះរាជាណាចក្រ (ពីឆ្នាំ១៧១៩ ទៅឆ្នាំ១៧២២) ។

មនុស្ស ៥.០០០នាក់បានឡើងគោកនៅពាម (ហាទៀង) និង ១០.០០០នាក់ផ្សេងទៀត បានឡើងពីទន្លេឧដុង្គ ។

នៅហាទៀង កងទ័ពខ្មែរមានប្រៀបជាងពួកសៀម ហើយបានទទួលជោគជ័យក្នុងការវាយពន្លិចនាវាជាច្រើនគ្រឿងរបស់សៀម ដោយការបាញ់កាំភ្លើងធំ ។ ប៉ុន្តែឧដុង្គត្រូវពួកសៀមវាយយកបាន ហើយព្រះរាជវាំងត្រូវទទួលស្គាល់អធិរាជភាពរបស់សៀម ។

នៅឆ្នាំ១៧៣០ មានជនជាតិលាវម្នាក់នៅភូមិព្រះសូត្រ (បាភ្នំ) បាននាំខ្មែរជាច្រើននាក់ធ្វើការបះបោរ និងអនុវត្តការវាយថ្មក់ទៅលើប្រទេសដែលកាន់កាប់ដោយពួកអណ្ណាម និងបានធ្វើការកាប់សម្លាប់ដ៏ធំមួយចំពោះសត្រូវ ។

នៅឆ្នាំ១៧៣១ មហាក្សត្រអណ្ណាម ដោយចង់លាងជម្រះនូវការខូចកិត្តិយសនេះ បានចាប់ផ្តើមធ្វើការសងសឹក ដោយប្រើកម្លាំងកងទ័ពយ៉ាងច្រើនសម្បើមប្រឆាំងប្រទេសកម្ពុជា ។ ប៉ុន្តែកងទ័ពអណ្ណាមត្រូវបានកម្ទេចដោយកងទ័ពរបស់**ព្រះសុធា**

www.elibraryofcambodia.org

ដែលក្រោយពីការដកថយទៅកាន់ពាមវ៉ែត្រង់ បានត្រាស់បង្គាប់ឲ្យមានការធ្វើកំណែនជាទូទៅមួយ និងដើរប្រឆាំងសត្រូវរហូតដល់ភ្នំពេញ ។

ប៉ុន្តែពួកអណ្ណាមមិនដកថយឡើយ ។ ពួកវាបានត្រឡប់មកវិញជាមួយនឹងកងទ័ពយ៉ាងច្រើនសម្បើមជាងលើកទី១ ។

នៅសន្ទុក ព្រះមហាក្សត្របានរៀបចំការតស៊ូ និងបានទទួលជោគជ័យជាថ្មីក្នុងការរុញច្រានពួកអ្នកលុកលុយឲ្យចាកចេញពីព្រះរាជាណាចក្រ ។ ប៉ុន្តែពួកអ្នកលុកលុយបានមានលទ្ធភាពតាំងនៅ មី ថ និង រីញឡុង ។

ពួកអ្នកវាយលុកអណ្ណាម បានធ្វើទុក្ខបុកម្នេញចៅហ្វាយខេត្តខ្មែរនៅបាសាក់ (សុកត្រាំង ឬ ស្រុកឃ្លាំង) លោក នរិន្ទ តុក, ហើយបានលុកលុយខេត្តនេះ ។ លោក តុក បានទទួលជោគជ័យក្នុងការរុញច្រានពួកអណ្ណាមឲ្យទៅវិញ ក្រោយពីមានការប្រយុទ្ធគ្នាយ៉ាងសាហាវនៅកោះ "កា-ហុង, ពាម-មីសា" ។ ប៉ុន្តែពួកអណ្ណាមបានវិលត្រឡប់មកវិញ និងបានដណ្តើមយកខេត្តបាសាក់ (សុក-ត្រាំង) ម្តងទៀត ។

នៅក្នុងកំឡុងនៃរជ្ជកាលរបស់ព្រះបាទ ធម្មោ រាជា (១៧៣៨-១៧៤៧)ប្រវត្តិសាស្ត្របានកត់ត្រាអំពីការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា រវាងខ្មែរនៅបាសាក់ និងអ្នកលុកលុយអណ្ណាម ។

លោក A. Leclère បានសរសេរ ( ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ទំព័រ៣៧៨) នៅក្នុងកាលបរិច្ឆេទនេះថា "...ពួកអ្នកវិភាគបានកត់ត្រាអំពីទឹកជំនន់ដ៏អស្ចារ្យមួយនៃទន្លេមេគង្គ និងការប្រយុទ្ធដែលបានកើតឡើងរវាងប្រជាជនកម្ពុជានៅបាសាក់ (សុកត្រាំង) និងពួកអណ្ណាមនៅខេត្តដូចគ្នានេះ ។ ពួកអណ្ណាមដោយទទួលបរាជ័យបានដកថយទៅកោះ ហុង, ពាម, មេ-ស ជាកោះមួយនៃទន្លេមេគង្គ និងបានរៀបចំខ្លួនធ្វើដូចជាអធិបតី ។

### ៨)- ព្រះបាទ "ធម្មោ រាជា" ប៉ុនប៉ងយក ហាទៀង វិញ

www.elibraryofcambodia.org

ពីរឆ្នាំ, ក្រោយពីការស្លាប់របស់ Mac-Cuu នៅឆ្នាំ១៧៣៨ ព្រះមហាក្សត្រកម្ពុជា ធម្មា រាជា ព្រះអង្គបានឆ្លៀតឱកាសនៃជម្លោះដែលបានកើតឡើងរវាងប្រជាជនកម្ពុជានៅ ហាទៀង និងមនុស្សរបស់ Mac-Ton (ដែលបានបន្តវេនពីឪពុករបស់ខ្លួន (ម៉ាក់ គីវ)- ១៧៣៦) ដើម្បីប៉ុនប៉ងដណ្តើមយកដោយព្រះអង្គផ្ទាល់នូវខេត្ត ហាទៀងមកវិញ ។ ការប៉ុនប៉ងនេះ ត្រូវទទួលបរាជ័យ ។

**៩)- ថ្វីបើមានការតវ៉ារបស់ប្រជាជនខ្មែរក៏ដោយ** ក៏មហាក្សត្រអណ្ណាមបានតែងតាំងនៅក្នុងឆ្នាំ១៧៥៤ នូវ**អនុមហាក្សត្រមួយអង្គសម្រាប់កូសាំងស៊ីនក្រោម** (ពី ប៊ិញ ធ្វីង ទៅ វីញឡុង) ដែលបានគង់នៅព្រៃនគរ (សាយហ្គន) ។ ចំពោះ ហាទៀង គឺតែងតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Mac-Ton (អណ្ណាមហៅ Mac-Thieu Tu – អ្នកប្រុសត្រកូលម៉ាក់) ហើយប្រជាជនខ្មែរហៅ ស៊ូតុត ។

**១០)- នៅឆ្នាំ១៧៥៦ ប្រជាជនខ្មែរបានកម្ចាត់ជនជាតិ ម៉យ ចំនួន៥.០០០នាក់ នៅ មី ថ**

លោក Charles Lemire បានរាយការណ៍ព្រឹត្តិការណ៍នេះដូច្នេះថា : "...កងទ័ពធំរបស់អណ្ណាម ស្ថិតនៅឯបន្ទាយតូចនៅ មី ថ កងទ័ពនេះមានកងទ័ពជំនួយជាជនជាតិ ម៉យ ចំនួន១០.០០០នាក់ មកពីភ្នំប៊ិញធ្វីង ដើម្បីទៅតាំងនៅ (ហ្គូវយ៉ាប) Go-Vap ។ ប៉ុន្តែបន្ទាប់ពីមានការប៉ះទង្គិចមួយជាមួយប្រជាជនកម្ពុជា ជនជាតិម៉យប្រមាណ ៥.០០០នាក់បានស្លាប់ ហើយជនជាតិម៉យផ្សេងៗទៀតបានទៅតាំងទីនៅជិតភ្នំ គីនិញ" ។

**១១)- នៅក្នុងកំឡុងរជ្ជកាលរបស់ព្រះអង្គតន់ (១៧៧៥-១៧៧៩) ការតស៊ូខ្មែរបាននាំមកនូវជ័យជំនះដ៏ត្រចះត្រចង់ និងបានទទួលជោគជ័យក្នុងការយកបានមកវិញនូវខេត្តវីញឡុង និង មី ថ ។**

ឡើងគ្រងរាជ្យនៅក្នុងព្រះជន្ម៣៦ព្រះវស្សា ព្រះអង្គតន់ ឬព្រះអង្គ**រាមរាជា** បាន

www.elibraryofcambodia.org

សិតពុម្ពធ្វើកាណុង ធ្វើកាំភ្លើងគ្រាប់រំសេវ គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងធម្មតា និងកសាងទូវបន្ទាយប្រាការ (បន្ទាយមានកំផែងការពារប្រាង្គប្រាសាទស្តេចគង់) មួយនៅភ្នំពេញមួយទៀតនៅមុខកំពូល ដើម្បីតស៊ូប្រឆាំងការឈ្លានពានមិនឈប់ឈររបស់ពួកអណ្ណាម និងដើម្បីរំដោះខេត្តខ្មែរទាំងឡាយនៅកូសាំងស៊ិន ។

ការបះបោររបស់ តី ស៊ិន បានផ្ទុះឡើង និងគំរាមកំហែង វ៉េ (ឆ្នាំ១៧៧៥) ។ ចៅហ្វាយខេត្តអណ្ណាមនៅសាយហ្គន និងមហាក្សត្រ យ៉ា ឡុង (ង្វៀង ភឿកអ៊ឹង ហៅ យ៉ា ឡុង) មានការព្រួយបារម្ភ ។ នៅ កូសាំងស៊ិនក្រោម មានការបះបោរមួយបានកើតឡើង ហើយចៅហ្វាយខេត្តអណ្ណាម Ong Chas Ches នៅលើកនេះមិនបានប្រឆាំងព្រះមហាក្សត្រកម្ពុជាទេ ផ្ទុយទៅវិញបែរជាសុំឲ្យព្រះមហាក្សត្រកម្ពុជាទៅជួយវិញ ។

**ព្រះអង្គចន់** ដោយស្គាល់ប្រទេសជិតខាងរបស់ព្រះអង្គ បានបដិសេធនិងបានមានព្រះរាជបន្ទូលថា **"ព្រះអង្គពុំចង់បានទំនាក់ទំនងណាមួយជាមួយពួកអណ្ណាមដែលព្រះអង្គបានប្រយុទ្ធនៅមុនពេលដែលព្រះអង្គឡើងគ្រងរាជ្យនោះទេ"** ។

ចៅហ្វាយខេត្តអណ្ណាមមិនបានទទូចទៀតទេ ប៉ុន្តែនៅមុនពេលបង្ក្រាបឧទ្ទាមកម្មនៅកូសាំងស៊ិនក្រោម គេបានប៉ុនប៉ងធ្វើការសងសឹក ដោយផ្ញើសង្គ្រាមនៅប្រទេសកម្ពុជា ។ នៅភ្នំពេញ ចៅហ្វាយខេត្តអណ្ណាមបានប្រឈមមុខនឹងកងទ័ពដ៏ខ្លាំងពូកែមួយរបស់ខ្មែរ ។ បើតាមលោក A. Leclère បានឲ្យដឹងថា **"មានការប្រយុទ្ធគ្នាចំនួន២០លើក បានកើតឡើងនៅជុំវិញបន្ទាយប្រាការ ហើយពួកអណ្ណាមបានទទួលបរាជ័យស្ទើរតែគ្រប់លើក** ។ នៅពេលដែលពួកអណ្ណាមបានបាត់បង់មនុស្សអស់ជាច្រើននាក់នោះ ពួកគេមិនមានលទ្ធភាពដើម្បីផ្គត់ផ្គង់ស្បៀងអាហារបានឡើយ **ពីព្រោះថាប្រទេសទាំងមូលបានងើបឡើងបះបោរប្រឆាំងនៅជុំវិញពួកគេ និងជាពិសេសនៅខាងក្រោយពួកគេ** ។" នៅពេលនោះពួកគេក៏បានរត់គេចខ្លួន

www.elibraryofcambodia.org

ពីបន្ទាយ" ។ ព្រះមហាក្សត្របានដេញតាម និងយកខេត្ត រីញឡុង និង មីថ នៅឆ្នាំ ១៧៧៦ ("ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" ដោយ A. Leclère ទំព័រ៣៩០) ។

**១២)– មហាក្សត្រសៀមបានផ្តល់កងទ័ពមួយដែលមានទាហានខ្មែរផង ទៅឲ្យមហាក្សត្រអណ្ណាម ដើម្បីបង្ក្រាបការបះបោររបស់ តី សឺន ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងដៃរបស់មន្ត្រី វៀន**

នៅឆ្នាំ១៧៨៤ មហាក្សត្រអណ្ណាម យ៉ា ឡុង បានឲ្យាយព្រះហស្តលេខាជាមួយ មហាក្សត្រ ចាត ទ្រី នៃប្រទេសសៀម នូវសន្ធិសញ្ញាសម្ព័ន្ធភាពមួយ ដែលមហាក្សត្រអង្គនេះបានផ្តល់ឲ្យស្តេច យ៉ា ឡុង នូវកងទ័ពមួយដែលមិនមែនជាកងទ័ពសៀមទេ ប៉ុន្តែគឺជាកងទ័ពខ្មែរ ។

លោក Charles Lemire នៅក្នុងរបាយការណ៍កាលប្រវត្តិ" របស់លោក (ទំព័រ ២១) បានសរសេរថា : "...មហាក្សត្រសៀមបានផ្តល់ឲ្យមហាក្សត្រ យ៉ា ឡុង នូវកងទ័ពមួយដែលមានទាហាន២០.០០០នាក់ ។ នៅក្នុងជួរកងទ័ពនេះ គឺជាទាហានខ្មែរ ដែលត្រូវបានជ្រើសរើសនៅ ណាំ វ៉ាង (ភ្នំពេញ) និងនៅ សាដែក ។ ស្តេច យ៉ា ឡុង មុនដំបូងបានទទួលជោគជ័យយ៉ាងធំធេង, ប៉ុន្តែទីបំផុតនៅតែចាញ់ពួក តី សឺន ។ ស្តេច យ៉ា ឡុង នៅសល់កងទ័ពតែ ២.០០០ ទៅ ៣.០០០នាក់ ឆ្លងកាត់ប្រទេស កម្ពុជា" ។

ក្រោយពីទទួលបរាជ័យមក នៅឆ្នាំ១៧៨៧ ស្តេច យ៉ា ឡុង បានយាងទៅប្រទេសសៀម រីឯទីក្រុង ហ្វេ ត្រូវបានកាន់កាប់ដោយពួក តី សឺន ។

ស្តេច យ៉ា ឡុង បានគេចខ្លួនពីទីក្រុងបាងកក និងយាងទៅពួននៅកោះត្រល់ (ភូក្វុក) ។ ដោយធ្វើការជ្រើសរើសនិងប្រមូលបាននូវទាហានជំនួយមួយចំនួនធំនោះ ស្តេច យ៉ា ឡុង បានលុកលុយខេត្តទឹកខ្មៅ (កាម៉ៅ) ខេត្តត្រាំងយ៉ាង (រ៉ាច់យ៉ា) និងដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់ខ្លួន ។ នៅពេលនេះ វាសនារបស់

www.elibraryofcambodia.org

ប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងដៃរបស់យមរាជ ប៉ែន ជាមនុស្សរបស់សៀម គឺ "ជនទុយឺស ប៉ែន" ដូចលោក J. Moura បានហៅ ។

ដោយលើកតម្កើងបាននូវកិត្តិយសរបស់ខ្លួន ស្ដេច យ៉ា ឡុង បានយាងមកឧដុង្គ ស្នើសុំការគាំទ្រពីជប្រា ប៉ែន ដើម្បីកម្ចាត់ តី សឺន ពីសាយហ្គន ដោយគាត់បានបញ្ជាកូសាំងស៊ីនខាងត្បូងទាំងអស់) ។ "ជនទុយឺស ប៉ែន" បានយល់ព្រមជួយស្ដេច យ៉ា ឡុង ដោយបង្កើតនូវកងទ័ពមួយឲ្យចូលរួមជាមួយកងទ័ពអណ្ណាមរបស់ស្ដេច យ៉ា ឡុង ហើយបានចេញដំណើរទៅកាន់សាយហ្គន ជាមួយចក្រី និងយមរាជ (H.C. A. Leclère ទំព័រ៤០១) ។

"...ដោយសារការជួយរបស់កងទ័ពខ្មែរ ពួក តី សឺន បានទទួលបរាជ័យ ហើយមេរបស់ពួកគេ Ong-Choc Sim ត្រូវបានសម្លាប់ ។ ស្ដេច យ៉ា ឡុង បានយាងទៅវើ វិញ ហើយកងទ័ពកម្ពុជាបានវិលត្រឡប់មកឧដុង្គឮជ័យ (១៧៩២)" ។

ស្ដេច យ៉ា ឡុង មានការដឹងគុណដ៏តិចតួចចំពោះប្រទេសកម្ពុជា ដែលបានជួយផ្ដល់កងទ័ពខ្មែរចំនួន ២០.០០០នាក់ ដែល ប៉ែន បានបញ្ជូនឲ្យទៅជួយដើម្បីវាយកម្ចាត់ តី សឺន ។

"នៅឆ្នាំ ១៨០៦ (លោក Charles Lemire បានឲ្យយើងដឹងថា) ស្ដេច យ៉ា ឡុង បានសម្ដែងនូវការប៉ុនប៉ងដើម្បីលុកលុយព្រំដែនរបស់ប្រទេសកម្ពុជា ។

នៅក្នុងសម័យដែល អ្នកអង្គ ច័ន្ទ បានក្លាយទៅជាព្រះមហាក្សត្ររបស់ប្រទេសកម្ពុជា ស្ដេច កូសាំងស៊ីន ដោយទតឃើញថា ស្ដេចខ្មែរនៅក្មេង ក៏បានបញ្ជូនមនុស្សឲ្យឆ្លងកាត់ព្រំដែនប្រទេសកម្ពុជា ដើម្បីបំភិតបំភ័យ និងជិះជាន់សង្កត់សង្កិនប្រជាជនរបស់ប្រទេសនេះ" ។

ចំណែក "ជនទុយឺស ប៉ែន" ក្រោយពីបានផ្ដល់ខេត្តបាត់ដំបងនិងអង្គរ ទៅឲ្យសៀម ហើយ ក៏សោយរាជ្យនៅបាត់ដំបង ក្នុងនាមជា "អនុមហាក្សត្រ" ដោយទទួលបញ្ជា

www.elibraryofcambodia.org

ផ្ដាល់ពីមហាក្សត្រសៀម ដែលបានផ្ដល់ឋានៈឲ្យជា ហូ មឿង (Hua-Moeung) ។ បែន បានស្លាប់នៅប្រទេសសៀម និងក្លាយជាជនក្បត់ជាតិខ្មែរនៅឆ្នាំ ១៨១១" ។

**១៣)– ជម្លោះនិងល្បិចកលទុច្ចរិតរបស់សៀម និងពួកអណ្ណាម នៅក្នុងការធ្វើវិនាសកម្ម និងការជ្រើសត្រាំមរបស់ពួកគេ ដើម្បីផ្ដាច់ដៃជើងប្រទេសកម្ពុជា បានបន្តនបាប់តាំងពីឆ្នាំ១៨០៦ (ឆ្នាំនៃព្រឹត្តិការណ៍របស់ព្រះអង្គច័ន្ទ)**

លោក A. Leclère បានសរសេរថា "...សត្រូវទាំងពីរនេះ ធ្វើជាខ្លាចគ្នាទៅវិញទៅមក ហើយប្រទេសកម្ពុជាដែលជាចំណីនោះ ស្ថិតនៅក្នុងដៃរបស់ពួកគេ និងមានការភ័យញ័រ និងត្រៀមខ្លួនឲ្យគេស៊ី ប៉ុន្តែយ៉ាងណាក៏ដោយ ក៏គេហ៊ានធ្វើការប្រយុទ្ធគស៊ូលុះត្រាទីបំផុតដែរ" ។

នៅឆ្នាំ១៨១៣ អធិរាជ យ៉ា ឡុង ចង់បន្ថយឥទ្ធិពលសៀមនៅប្រទេសកម្ពុជា បានបញ្ជូនកងទ័ពមួយដែលបញ្ជាដោយឧត្តមសេនីយ៍ ឡេ វ៉ាន់ យៀត ដើម្បីដាក់ជំនួស "ព្រះអង្គច័ន្ទ" នៅលើរាជបល្ល័ង្ក ។

ចំណែកឯពួកសៀមវិញ (ដោយសារការក្បត់របស់ "ម៉េង" ចៅហ្វាយខេត្តខ្មែរខេត្តកំពង់ស្វាយ) បានកាន់កាប់ដោយយោធានៅឆ្នាំ១៨១៤ នូវខេត្តម្លូព្រៃ ស្ទឹងពោធិ ទន្លេរពៅ និង ស្ទឹងត្រែង ហើយនៅឆ្នាំ១៨៣២ ដោយឆ្លៀតឱកាសនៃការរត់គេចខ្លួនរបស់ "កា" ចៅហ្វាយ ខេត្តពោធិសាត់ ជាមួយនឹងអ្នកស្រុកចំនួន២/៣ បានលុកលុយខេត្តនេះ និងខេត្តកំពង់ឆ្នាំង ។

នៅឆ្នាំ១៨៣៤ ប្រជាជនខ្មែរដែលបញ្ជាដោយ "ចក្រី ឡុង" បានដឹកនាំការវាយបកវិញប្រកបដោយសេចក្ដីក្លាហាន និងដេញកម្ចាត់ពួកសៀមឲ្យទៅទិសខាងជើង។

ប៉ុន្តែពួកសៀមដោយបរាជ័យនៅទិសខាងកើតនោះ បានរុលមកទិសខាងត្បូងវិញ និងដណ្ដើមយកបានខេត្តចូវដុក ។ នៅទីនោះពួកសៀមបានជួបពួកអណ្ណាមដែលបានវាយកម្ទេចទ័ពសៀមនៅ វិញឡុង ដេញតាមរហូតដល់ទិសខាងជើង និង

www.elibraryofcambodia.org

បានថ្វាយតំណែងដល់"ព្រះអង្គច័ន្ទ"ឡើងវិញនៅឧដុង្គ ។

ពួកសៀមទាំងនេះ ត្រូវបានបង្កើតឡើងដោយកងទ័ពចំនួន៤កង និងបញ្ជាដោយឧត្តមសេនីយ៍ដ៏គួរឲ្យខ្លាចម្នាក់ គឺឧត្តមសេនីយ៍ "ចៅឃុន បូឌិន" ។ នៅ វិញឡុង ដែលព្រះមហាក្សត្រខ្មែរបានភៀសព្រះកាយទៅគង់នៅនោះ "បូឌិន" បានទទួលជ័យជំនះដ៏ត្រចះត្រចង់ ។ លោក Leclère បាននិយាយថា "...ដោយភ័ព្វចំពោះ "បូឌិន" កងនាវារបស់គាត់ត្រូវបានកម្ទេចនៅក្នុងការប្រយុទ្ធមួយតាមដងទន្លេ ដែលមានលក្ខណៈសាហាវគួរឲ្យខ្លាច ។ ចំពោះឧត្តមសេនីយ៍សៀមរូបនេះដែលពុំមានកងទ័ព និងពុំមានមធ្យោបាយណាមួយដើម្បីតស៊ូនឹងកងទ័ពអណ្ណាម ដែលបានមកដល់តាមជើងគោកនិងតាមជើងទឹក ហើយម្យ៉ាងទៀតពួកនេះមានវិន័យ និងមានការរៀបចំយ៉ាងល្អខាងក្បួនទ័ព ដែលផ្តល់ឲ្យដោយ**នាយទាហានបារាំង**ដែលបានចូលបម្រើស្តេច យ៉ា ឡុង ដែលនៅក្នុងនោះមានវរៈសេនីយ៍ទោ Laurent Barisy" សូមបើកវង់ក្រចកនៅទីនេះ : គឺជាលើកទីមួយហើយដែលបានកត់សម្គាល់អំពីវត្តមានរបស់នាយទាហានបារាំងនៅអមអធិរាជអណ្ណាម ។

ឧបរាជ "អង្គអឹម" និងព្រះអង្គម្ចាស់ "អង្គដួង" ដែលនៅក្រុងភ្នំពេញជាមួយកងទ័ពរបស់ "បូឌិន" បានយាងទៅប្រទេសសៀម ។

ពួកអណ្ណាមដែលបានធ្វើឲ្យទ័ពសៀមបរាជ័យ បានកម្ចាត់ពួកនេះពីប្រទេសកម្ពុជាមួយរយៈពេល ។

Leclère (H.C ទំព័រ៤១៨) បានសរសេរថា : "...ពួកអណ្ណាមបានឡើងធ្វើជាម្ចាស់ប្រទេសកម្ពុជាជាថ្មី ។ ស្តេចអណ្ណាមបានបញ្ជូនមនុស្សចំនួន១៥.០០០នាក់ និងដើម្បីបង្ហាញនូវភាពយុត្តិធម៌របស់ព្រះអង្គ និងធានាដល់ប្រជាជនកម្ពុជា ក៏បានបញ្ជូនប្រាក់ចំនួន១៤១ដុំ បែងចែកថ្វាយស្តេចខ្មែរ ដើម្បីចេញថ្លៃដំរីចំនួន៨៨ក្បាល ដែលឧត្តមសេនីយ៍របស់ព្រះអង្គម្នាក់បាននាំយកចេញពីប្រទេសកម្ពុជា ដោយគ្មាន

www.elibraryofcambodia.org

បញ្ហាពីព្រះអង្គ" ។

"វាមិនមែនថ្លៃទេចំពោះដីមួយក្បាល ដែលមានតម្លៃតែ១៣០ហ្វ្រង់នោះ ប៉ុន្តែទំនងជាបញ្ហានយោបាយប៉ុណ្ណោះ ។ បន្ទាប់មកដោយធ្វើតាមបែបនេះដែរ ពួកអធិរាជចិន និងម៉ុងហ្គោល បានថ្វាយអំណោយដល់ស្តេចខ្មែរ នូវសម្លៀកបំពាក់ប្រពៃណីអណ្ណាមមួយសម្រាប់ដីល្អ ដោយរួមទាំងមួកផង ។

"ថ្ងៃស្អែកឡើង ព្រះមហាក្សត្រនៃប្រទេសកម្ពុជា បានលេចព្រះភក្ត្រនៅភ្នំពេញជាមួយនឹងសម្លៀកបំពាក់នេះ និងមានមនុស្សជាច្រើនបានធ្វើត្រាប់តាមដោយរបៀបថោកទាប និងដោយរបៀបបញ្ឆោរ និងដោយសារពួកគេបានទទួលនូវសម្លៀកបំពាក់បែបនេះពីស្តេចអណ្ណាម និង**តាមបញ្ហា**ផងដែរ ។ ម្តងនេះគេបានឃើញច្បាស់ថា ពួកអណ្ណាមបានឈ្នះពួកសៀម" ។

ប៉ុន្តែព្រឹត្តិការណ៍ដែលមានបន្តបន្ទាប់មកទៀត បានបរិហារអាកប្បកិរិយាចិត្តបុណ្យពិសពុលរបស់អធិរាជអណ្ណាម ។

**១៤)– នៅក្រោមរជ្ជកាលរបស់ "ព្រះអង្គច័ន្ទ" នៅឆ្នាំ១៨១៥ គេបានជីកព្រែក វិញតេ** (VINH THÊ)

មនុស្ស១០.០០០នាក់ ដែល៥.០០០នាក់ ជាប្រជាជនកម្ពុជា ត្រូវបានគេប្រើដើម្បីឲ្យជីកព្រែកតភ្ជាប់ព្រែក "វិញ តេ" ទៅមាត់ពាម ហាទៀង គឺព្រែកជីកដែលមានបណ្តោយប្រវែង៥៣គ.ម ទទឹង ៣,៥គ.ម និងជម្រៅ២,៦០ម ។ វាបានភ្ជាប់ការទាក់ទងដែនទន្លេមេគង្គខាងលិចជាមួយឈូងសមុទ្រសៀម (ពីមាត់ជ្រូក ឬ ចូវដុក ទៅព្រែក ទាន់ហាន់) ។

គឺប្រជាជនខ្មែរជាអ្នកជីកនាំការងារ និងត្រូវបានគេប្រហារជីវិត ។ នៅក្នុងនោះប្រជាជនខ្មែរចំនួន៤.០០០នាក់ បានបាត់បង់ជីវិតនៅក្នុងកំឡុងពេល៥ឆ្នាំនៃការងារជីកព្រែកនេះ (១៨១៥-១៨១៩) ។

www.elibraryofcambodia.org

លោក Henri Aurillac នៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើងថា "កូសាំងស៊ីន អណ្ណាម ម៉ាយ និងកម្ពុជា" ទំព័រ២៧ បានរាយការណ៍ថា : **"...ព្រៃកដីក វិញគេដឹងល្បីល្បាញ ដែលបានតភ្ជាប់ទៅទន្លេធំ ត្រូវបានបង្កើតឡើងទាំងស្រុងដោយពួកអ្នកចាញ់ ដើម្បីជាផលប្រយោជន៍ដល់ពួកអ្នកឈ្នះ ។ ប្រជាជនកម្ពុជា ជាង ៤.០០០នាក់ បានស្លាប់ដោយសារជំងឺគ្រុនចាញ់"** ។

មនុស្សនៅ"ពាម, បន្ទាយមាស, ទ្រាំង និង ព្រែកប្បាស" បាននឹករឃើញជានិច្ច នូវសម័យកាលដ៏ចង្រៃឃោរឃៅនេះ ។ គេបានរក្សាទុកនូវអនុស្សាវរីយ៍ដ៏ជូរចត់ បំផុតដែលទឹកដីទាំងអស់នៃបណ្តាខេត្តកសិកម្មនៅកូសាំងស៊ីន ដែលស្ថិតនៅខាងត្បូងព្រែកជីក ហាទៀង គឺស្ថិតនៅក្រោមការកាត់យកទាំងស្រុងដោយអាជ្ញាធរវៀតណាម នៅពេលដែលព្រែកជីកនេះត្រូវបានជីកហើយរួចរាល់ជាស្ថាពរ (H.C. Leclère ទំព័រ ៤១៣) ។

យូរក្រោយមក នៅពេលដែលប្រទេសបារាំងកាន់កាប់កូសាំងស៊ីន ដែលយកធ្វើជាអាណានិគមរបស់ខ្លួនផ្ទាល់នោះ បានចាត់ទុកដូចជាទឹកដីបារាំងតែម្តង មិនត្រាន់តែទឹកដីទាំងអស់នៅខាងត្បូងព្រែកជីក បានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់បារាំងប៉ុណ្ណោះទេ ប៉ុន្តែក៏មានទឹកដីមួយភាគធំនៅទិសខាងជើងផងដែរ ។

ព្រំដែនដែលត្រូវបានគូសជាឯកតោភាគីដោយបារាំង ដូចយើងបាននិយាយរួចហើយនោះថា "វាពុំមានតម្លៃនៅលើផែនគតិយុត្តនោះឡើយ" ។

អនុស្សាវរីយ៍ប្រកបដោយទុក្ខព្រួយនេះ បានថ្លាក់ជាប់ជានិច្ចនៅក្នុងស្មារតីរបស់ប្រជាជនខ្មែរគ្រប់រូប ដូចដែលពួកគេស្ថិតនៅក្នុងសម័យកាលនោះដែរ A. Leclère (H.C ទំព័រ៤១៣) "...នៅពេលដែលគេស្នើសុំអ្នកធ្វើការ ដើម្បីលើកផ្លូវថ្នល់ដែលអាជ្ញាធរបារាំងបានឲ្យកសាងនោះ វាមិនមែនជារឿងដ៏កម្រនោះទេ ថ្វីបើថ្ងៃបំពេញការងារត្រូវបានបេញថ្លៃឲ្យយ៉ាងហោចណាស់ក៏៤ដងដែរនោះ និងដើម្បី

www.elibraryofcambodia.org

ស្ដាប់ការ រំលឹកឡើងវិញរបស់ជនជាប់កំរ៉ែណនទូវសម័យកាលប្រកបដោយទុក្ខ ព្រួយនេះ ដែលនៅក្នុងរជ្ជកាលមួយទាំងមូល គេត្រូវធ្វើការជីកព្រែកឲ្យយួន (អណ្ណាម)។

"...ប្រជាជនកម្ពុជា ដោយការងារបានបំពេញរួចហើយនោះ មានការមិនសប្បាយចិត្តយ៉ាងខ្លាំង ដែលពួកអណ្ណាមបានដាក់បញ្ចូលជាឧបសម្ព័ន្ធទូវទឹកដីទាំងអស់ដែលស្ថិតនៅខាងត្បូងព្រែកជីក ដែលចាប់ពីពេលនេះតទៅ ពួកគេបានចាត់ទុកដូចជា ព្រំដែនរវាងរដ្ឋទាំងពីរ ហើយដែលពួកគេបានបង្កើតប៉ុស្ដិ៍គយនៅលើត្រើយខាងស្ដាំនៃទន្លេមេគង្គ នៅផ្លូវចូលទៅរកព្រែកជីកនៅកោះក្ដាក់ និងនៅពាមជីវ"។

## ១៥)– ពួកអណ្ណាមបានរៀបចំការបញ្ចូលជាឧបសម្ព័ន្ធទូវប្រទេសកម្ពុជាទាំងមូល នៅក្រោមរជ្ជកាល "ព្រះអង្គ ម៉ី" (១៨៣៤–១៨៤១)

យើងបានឃើញហើយថា ពួកអណ្ណាមបានបង្ហាញទូវចិត្តសប្បុរសយ៉ាងខ្លាំង នៅក្នុងពេលយាង "ព្រះអង្គច័ន្ទ" ឲ្យឡើងសោយរាជ្យ ។ ព្រះមហាក្សត្រអណ្ណាមបានបញ្ជូនទៅថ្វាយព្រះមហាក្សត្រ "អង្គច័ន្ទ" នូវមនុស្សចំនួន១៥.០០០នាក់ និងប្រាក់ចំនួន ១៤១ដុំវែង ដើម្បីចេញថ្លៃដីរំចំនួន៨៨ក្បាល !។

តើពួកអណ្ណាមទាំង ១៥.០០០ នាក់នេះ នឹងក្លាយទៅជាអ្វី ? យើងនឹងបានដឹងដោយធ្វើការសិក្សាអំពីរជ្ជកាលព្រះអង្គម៉ី ដែលអ្នកប្រវត្តិសាស្ត្របានចាត់ទុកថាជា "អាណាព្យាបាលអណ្ណាមនោះ"។

នៅពេល "ព្រះអង្គច័ន្ទ" សោយទិវង្គតនៅឆ្នាំ ១៨៣៤ ពួកវៀតណាមបានប្រើឧបាយកលកម្ចាត់ព្រះអនុជរបស់ព្រះអង្គច័ន្ទ (ឧបរាជ អង្គអ៊ីម ព្រះអង្គម្ចាស់ "អង្គដួង"និង"អង្គស្ងួន") ចេញពីរាជបល្ល័ង្ក នៅក្រោមលេសថា ព្រះអង្គទាំងនោះជាអ្នកនិយមសៀម ។ តាមការពិតពួកគេកម្ចាត់ព្រះអង្គម្ចាស់ទាំងអស់នេះ ដើម្បីឲ្យមាន

www.elibraryofcambodia.org

អំណាចយ៉ាងសេរីនៅលើប្រទេសកម្ពុជា ពីព្រោះថាព្រះអង្គម្ចាស់ទាំងនេះ ជាពិសេសព្រះអង្គម្ចាស់ "អង្គដួង" មានព្រះហឫទ័យស្នេហាជាតិយ៉ាងខ្ពស់ក្រៃលែង... ។

ដូច្នេះពួកអណ្ណាមបានជ្រើសរើសស្តេចមួយអង្គដែលខ្សោយ ដែលអាចឲ្យពួកគេរៀបចំការបញ្ចូលជាឧបសម្ព័ន្ធប្រទេសកម្ពុជាបាន ។

ព្រះបាទ "អង្គច័ន្ទ" ពុំមានព្រះរាជបុត្រាទេ មានតែព្រះរាជបុត្រី ។

តាមបញ្ជារបស់ស្តេច មិញម៉ាង (ស្តេចស្នងរាជ្យពីស្តេច យ៉ា ឡុង) ចាប់តាំងពី ឆ្នាំ១៨១១ អាំង ខាំម៉ាង ពេលនោះជាប្រធានបេសកកម្មអណ្ណាម នៅអមព្រះរាជវាំងនៃប្រទេសកម្ពុជា (H.C.Leclère ទំព័រ៤១៩) បានទទួលពីក្រុមប្រឹក្សាថ្នាក់ធំ (មន្ត្រីថ្នាក់ខ្ពស់, រដ្ឋមន្ត្រី, ប្រធានសង្ឃ និងបាគូ) នូវការជ្រើសរើសព្រះអង្គម្ចាស់ក្សត្រីក្មេងម្នាក់ គឺ "**ព្រះអង្គម៉ី**" មានព្រះជន្ម២០ឆ្នាំ ជាព្រះរាជបុត្រីរបស់ព្រះបាទអង្គច័ន្ទ ធ្វើជាព្រះមហាក្សត្រីយានីនៃប្រទេសកម្ពុជា ។ ដូច្នេះ អាំង ខាំម៉ាង បានទទួលជោគជ័យក្នុងការបំបែកព្រះអង្គម្ចាស់ទាំង៣ និងព្រះរាជបុត្រីច្បងរបស់ព្រះអង្គច័ន្ទ ព្រះនាម អង្គ ប៉ែន (ដែលជាក្មួយស្រីរបស់ ឧកញ៉ាប៉ែន) ឲ្យបែកគ្នាអស់ពីក្សត្រី អង្គម៉ី ។

ពួកអណ្ណាមបានថ្វាយដល់ម្ចាស់ក្សត្រីអង្គម៉ី (១៨៣៤-១៨៤១) នូវព្រះរាជឋានៈជា "បា កុង ជួ" ដែលមានន័យថា "ព្រះរាជនី, ម្ចាស់ស្រីនៃជីវិត" ។

ដូចសម្តេចព្រះ "នរោត្តម សីហនុ" មានព្រះបន្ទូលនៅក្នុងសៀវភៅ "រាជាធិបតេយ្យកម្ពុជា" ថា តាមការពិត "អង្គម៉ី" ពុំមានអំណាចអ្វីបន្តិចឡើយ ។ សេចក្តីសម្រេចរបស់ព្រះអង្គទាំងអស់ ត្រូវដាក់ស្នើសុំការយល់ព្រមជាមុនពីតំណាងរដ្ឋាភិបាលអណ្ណាម ។

តំណាងស្តេចអណ្ណាមនៅអមម្ចាស់ក្សត្រីអង្គម៉ី នៅពេលនោះ គឺឧត្តមសេនីយ៍អុង-ទ្រឿង-គ្វឹន (ONG-TRUONG-QUÂN) គឺលោកមេទ័ពធំ ដែលស្តេចអណ្ណាម

www.elibraryofcambodia.org

ឲ្យទទួលបន្ទុករៀបចំដាក់បញ្ចូលជាឧបសម្ព័ន្ធនូវប្រទេសកម្ពុជាទាំងមូល ។ អុង-ទ្រឿង-គ្វីន មានអ្នកជំនួយការនៅក្នុងបេសកកម្មរបស់ខ្លួននូវមន្ត្រី៣នាក់ ដើម្បីធ្វើវិទ្ធង្សនា គឺ : ទ្រឿង មិញយ៉ាង, ដាម វ៉ាន់ឡេន និង ត្រឹង វ៉ាន់ណាង ។

ពួកអណ្ណាមចង់កែប្រែទាំងអស់ ។ ពួកគេ "ធ្វើវៀតណាមូបនីយកម្ម" ប្រទេសកម្ពុជា ។ អុង-ទ្រឿង-គ្វីន បានបង្ខំមន្ត្រីខ្មែរឲ្យស្លៀកពាក់សម្លៀកបំពាក់អណ្ណាម, ឲ្យប្តូរឋានៈខ្មែរទៅជាឋានៈវៀតណាម និង "បានដាក់វ៉េស៊ីដង់អណ្ណាមម្នាក់នៅអមចៅហ្វាយខេត្តខ្មែរនីមួយៗ ដើម្បីត្រួតត្រាការប្រព្រឹត្ត និងការដឹកនាំរដ្ឋការរបស់ពួកគេ" ។

Leclère បាននិយាយថា "...អុង-ទ្រឿង-គ្វីន ចង់ធ្វើច្រើនទៅទៀត និងស្រមើស្រមៃ ធ្វើការកែប្រែប្រទេសកម្ពុជាទាំងអស់ និងព្រះរាជាណាចក្រខ្មែរ ដោយផ្លាស់ប្តូរឈ្មោះនៃទឹកន្លែងទាំងអស់" ។

ភ្នំពេញបានបាត់បង់ឈ្មោះរបស់ខ្លួន និងបានក្លាយទៅជា "ណាំ-វ៉ាង" ។ ខេត្តទាំង៥៦របស់ខ្មែរត្រូវបានបង្រួញឲ្យមកនៅចំនួន៣៣ និងមានឈ្មោះអណ្ណាមទាំងអស់ A.Leclère ទំព័រ៤២២ និង៤២៣) ។ ទ្រឿង មិញយ៉ាង ត្រូវបានតែងតាំងជា "ទ្រឿង គ្វីន" ឬសេនាប្រមុខភ្នំពេញ ។ មហាក្សត្រិយានីអង្គម៉ី ព្រះអង្គផ្ទាល់បានទទួលឋានៈអណ្ណាម ជា "មី-ឡឹម កុង ជួ" (My Lâm Công Chúa) (ឬជាមហាក្សត្រិយានីនៃ ភូមិ មី-ឡឹម) ។

មនុស្ស១៥.០០០នាក់ ដែលត្រូវបានបញ្ជូនមកក្នុងឋានៈជា "អំណោយនៃការដឹងគុណ" ចំពោះព្រះមហាក្សត្រអង្គច័ន្ទ បានក្លាយទៅជាកម្មាភិបាលធ្វើវិទ្ធង្សនារបស់អណ្ណាម និងបានរៀបចំដើម្បីដាក់បញ្ចូលជាឧបសម្ព័ន្ធនូវទឹកដីខ្មែរទាំងអស់ ។

**១៦)– ការបះបោរយ៉ាងសាហាវរបស់ប្រជាជនកម្ពុជាប្រឆាំងពួកអណ្ណាម**

ប្រជារាស្ត្រខ្មែរមិនសប្បាយចិត្តក្នុងការជ្រើសរើសព្រះអង្គម៉ីឲ្យឡើងសោយរាជ្យនោះទេ ។ ការធ្វើកំណែន និងនាំសួយសារអាករគ្រប់ប្រភេទទាំងអស់ ដែលពួក

www.elibraryofcambodia.org

អណ្ណាមដាក់បង្ខំដល់ប្រជារាស្ត្រខ្មែរនៅក្នុងកំឡុងពេលនៃ "ការតាំងខ្លួនជាអាណាព្យាបាល" នោះ បានជម្រុញឲ្យប្រជារាស្ត្រខ្មែរងើបឡើងបះបោរប្រឆាំងពួកអណ្ណាមអ្នកជណ្តើមទឹកដីខ្មែរ ។ នៅឆ្នាំ ១៨៣៥ "ឧកញ៉ា ជ័យ និង ជូ" នៅកំពង់សោម បានបដិសេធមិនគោរពតាមបញ្ជាអណ្ណាម និងបានងើបឡើងកាន់អាវុធ ។

នៅឆ្នាំ ១៨៣៦ លោក "តេជោរាម" នៅកំពង់ស្វាយ បានបះបោរប្រឆាំងរបបអណ្ណាម លោកត្រូវបានគេចាប់ខ្លួន និងសម្លាប់តាមបញ្ជារបស់ អុង ឡើង គ្ញីន ។ ឆ្នាំបន្ទាប់មកលោក "ស្នង អ៊ី" ដែលជំនួសលោក តេជោរាម បានឲ្យគេសម្លាប់វេស៊ីដង់ អណ្ណាម និងបានដឹកនាំកងទ័ពមួយ ។ លោកត្រូវបានបង្ខំចិត្តដកថយនៅចំពោះមុខកម្លាំងកងទ័ពអណ្ណាម ដែលមានចំនួនច្រើនជាង និងទៅជ្រកកោននៅទន្លេរពៅ ។ នៅពេលនោះពួកអណ្ណាមបានសម្លាប់ប្រជាជនខ្មែរនៅកំពង់ស្វាយក្នុងចំនួនយ៉ាងច្រើន (H.C.,Leclère ទំព័រ៤២៥) ។

ប្រជារាស្ត្រដែលកាន់តែមានការមិនសប្បាយចិត្តខ្លាំងឡើងៗនោះ បានក្រឡេកមើលទៅខេត្តបាត់ដំបង ជាកន្លែងដែលព្រះអង្គម្ចាស់ទាំងពីរ គឺ "ព្រះអង្គអិម" និង "ព្រះអង្គដួង" បានភៀសព្រះកាយទៅគង់នៅ ។

ឧត្តមសេនីយ៍អណ្ណាម អុង-ឡើង-គ្ញីន ដោយមើលឃើញគ្រោះថ្នាក់នៃការបះបោរជាទូទៅមួយជិតមកដល់ ដែលបង្កើតឡើងដោយព្រះអង្គម្ចាស់ទាំងពីរនេះ ទើបគាត់រិះរកល្បិចកលនានាដើម្បីបំបែកបំបាក់ ឬពុំនោះទេធ្វើឲ្យវិនាសតែម្តង ។

Leclère បាននិយាយថា "...គាត់ (អុង-ឡើង-គ្ញីន) បានសម្រេចកម្ចាត់ (ព្រះរាជ វង្សានុវង្ស) ដោយធ្វើការបំបែកបំបាក់ព្រះអង្គម្ចាស់ខ្មែរទាំងពីរអង្គ ដែលរហូតមកដល់ពេលនោះ តែងតែរួបរួមគ្នាជានិច្ច, ហើយបន្ទាប់មកដោយឆ្លៀតឱកាសនៃព្រឹត្តិការណ៍ទាំងឡាយ បូកផ្សំផងជួយឲ្យ ឡើង គ្ញីន បង្កើតនូវផែនការបំបែកបំបាក់នោះ ដើម្បីកម្ចាត់ស្តេចខ្មែរ ។ ជនជាតិអណ្ណាមម្នាក់ត្រូវឲ្យក្លែងខ្លួន

www.elibraryofcambodia.org

ជាជនជាតិខ្មែរ, ហើយបានក្លែងថ្វាយនូវលិខិតមួយច្បាប់ (ដែលជាអន្ទាក់) ដល់ព្រះអង្គអឹម, សូមយាងព្រះអង្គចេញពីខេត្តបាត់ដំបង ។ ហើយតាមការ ចោទប្រកាន់របស់ព្រះវៀម (ព្រះអង្គអឹម) ដែលមិនយល់ ពីល្បិចកលរបស់ អណ្ណាមនោះថា "ព្រះអង្គដួងត្រូវបានចាប់ខ្លួន ដោយស្តេចសៀម" (ស្តេចសៀមបានទទួលសារលិខិតមួយច្បាប់ពីអង្គអឹម ដែលលិខិតនេះត្រូវបានរៀបចំ ដោយ អុង-ទ្រឿង-គ្វីន ដែលបាននិយាយថា ព្រះអង្គដួង រួមគំនិតប្រឆាំង សៀម) ។ ព្រះអង្គអឹម មិនយាងត្រឡប់មកភ្នំពេញតែមួយអង្គឯងនោះទេ ។ ព្រះអង្គបាននាំមក ជាមួយព្រះរាជវង្សានុវង្សរបស់ព្រះអង្គ ព្រះរាជបុត្រ របស់ព្រះអង្គដួង (មានព្រះរាជ បុត្រា៣ ព្រះអង្គ និង ព្រះរាជបុត្រីមួយព្រះអង្គ គឺ : ព្រះអង្គវតី ឬ ព្រះ នរោត្តម ប្រសូតនៅឆ្នាំ ១៨៣៤, ព្រះអង្គម្ចាស់ក្សត្រី ចង្កុលណី (Choang Kolaney) ប្រសូតនៅឆ្នាំ ១៨៣៩, ព្រះអង្គម្ចាស់ កែវ ឃ្វា (Kêv Kvea) (កែវ ហ្វា) ឬ ព្រះ ស៊ីសុវត្ថិ ប្រសូតនៅឆ្នាំ ១៨៤០, ព្រះអង្គម្ចាស់ ស្រីវត្ថា ឬ ស៊ីវត្ថា ប្រសូតនៅឆ្នាំ ១៨៤១, ឯព្រះរាជបុត្រ ១ព្រះអង្គ ទៀត ព្រះនាម "ស៊ីរីវង្ស" ទ្រង់បួសសាងព្រះផ្នួស នៅស្រុកសៀម (H.C.,Leclère ទំព័រ៤២៩) និងនាម៉ឺនខ្មែរជាច្រើននាក់ទៀត ។

នៅភ្នំពេញប្រជារាស្ត្រខ្មែរបានអបអរសាទរព្រះអង្គអឹមដោយសប្បាយរីករាយ ។ ប៉ុន្តែនៅពេលយប់ ឧត្តមសេនីយ៍អណ្ណាមបានចាប់ព្រះអង្គអឹមដាក់ឃុំនៅក្នុងទ្រុងដែក លុះព្រឹកឡើងគេបានបញ្ជូនទៅក្រុងវ៉េ (១៨៤០)" ។

ចំណែកពួកនាម៉ឺនវិញ ជាច្រើននាក់ត្រូវបានសម្លាប់ ហើយអ្នកដទៃទៀតត្រូវអណ្ណាមបញ្ជូនទៅ វ៉េ ដែរ ។

ការត្រួតត្រារបស់វៀតណាមនៅមិនទាន់អស់ទេ ។

ពួកវៀតណាមមិនគ្រាន់តែចង់ផ្លាស់ប្តូរសាសនាខ្មែរប៉ុណ្ណោះទេ ប៉ុន្តែពួកវាំនៅចង់កម្ទេចពុទ្ធបដិមាទាំងឡាយចោលដែរ ។

www.elibraryofcambodia.org

ពួកវៀតណាមបានដកហូតអ្នកដឹកនាំរបស់ប្រជាជនខ្មែរ ដោយបញ្ជូនរដ្ឋមន្ត្រីទាំងអស់របស់ "ព្រះអង្គម៉ី" ទៅកាន់ វេ ។ មហាក្សត្រីយានី និងព្រះអនុជទាំងពីររបស់ព្រះអង្គ គឺព្រះអង្គពៅ និងព្រះអង្គស្ងួន ក៏ត្រូវបានគេបញ្ជូនទៅសាយហ្គនដែរ ក្សត្រិ អង្គម៉ុំ (ព្រះអនុជ) ត្រូវចូលទិវង្គត ។ ព្រះក្សត្រី អង្គប៉ែន (ក្មួយស្រីរបស់ឧកញ៉ា ប៉ែន) ត្រូវបានគេនាំទៅកាន់ លង់ ហោរ (វិញ ឡុង) ហើយដាក់ឲ្យគេយាមកាមយ៉ាងតឹងរ៉ឹង ពីព្រោះថាព្រះបិតុលារបស់ព្រះអង្គ គឺឧកញ៉ាប៉ែន ជាសត្រូវម្នាក់ ដែលអណ្ណាមត្រូវការបំផុត ។

**...ការមិនសប្បាយចិត្ត បានផ្សព្វផ្សាយជាទូទៅ និងបានទៅដល់កម្រិតខ្ពស់បំផុតរបស់ខ្លួន ។ ពួកអ្នកដើរតាមព្រះអង្គម្ចាស់ទាំងពីរ គឺព្រះអង្គអិម និង ព្រះអង្គដួង "បានធ្វើដំណើរជាសម្ងាត់ទៅកាន់ស្រុកស្រែចម្ការ បំបះបំបោរប្រជាជន ហើយ (បើតាមលោក Leclère បាននិយាយ) គឺពួកគេបានសម្លាប់វគ្គាលពួកអណ្ណាមដោយចាប់ផ្ដើមស្ទើរតែមួយពេលនៅគ្រប់ទីកន្លែងទាំងអស់ ។ រហូតដល់ទីក្រុងភ្នំពេញ ពេលដែលទាហានអណ្ណាមបានជ្រកពួនជាហ្វូង។ ត្រូវបានសម្លាប់ដោយជនមិនស្គាល់មុខនៅពេលយប់" ។**

**Leclère បានបន្ថែមថា ...នៅក្នុងរយៈពេល៨ថ្ងៃ "ប្រទេសទាំងមូល លើកលែងនៅកន្លែងមជ្ឈមណ្ឌលធំៗត្រូវបានរំដោះបានពីសត្រូវរបស់ខ្លួន នៅពេលនោះគេស្ទើរតែមិនជឿថា ប្រជាជនកម្ពុជាមានសមត្ថភាពធ្វើសកម្មភាពទាំងអស់គ្នាបែបនេះទេ...?" ។**

ប្រជារាស្ត្របានក្រោកឡើងបះបោរគ្រប់ទីកន្លែង ទាម៉ឺនធំៗបានប្រជុំគ្នាជាសម្ងាត់ ហើយការយាងត្រឡប់របស់ "ព្រះបាទអង្គដួង" ពីប្រទេសសៀម ត្រូវបានសម្រេច ។

* *
*

www.elibraryofcambodia.org

## ១.- ព្រឹត្តិការណ៍របស់ព្រះករុណា "ព្រះបាទ អង្គដួង" (១៨៤១-១៨៥៩)

ស្តេចសៀមមិនបានប្រឆាំងចំពោះការយាងត្រឡប់របស់ព្រះអង្គម្ចាស់នោះទេ ។ ព្រះអង្គមានការសប្បាយព្រះហឫទ័យយ៉ាងខ្លាំង ដោយបានឃើញប្រជារាស្ត្រខ្មែររួមគ្នាតស៊ូរំដោះខ្លួនចេញពីអំណាចរបស់អណ្ណាម និងឃើញការបរាជ័យរបស់អណ្ណាមនៅប្រទេសកម្ពុជា ។

ស្តេចសៀមដោយយល់ព្រមទៅតាមការស្នើសុំរបស់ប្រជារាស្ត្រកម្ពុជា ព្រះអង្គបានបាត់ឲ្យ ឧត្តមសេនីយ៍វ័យចាស់ឈ្មោះ "ចៅ យុទ បូឌីន" កសាងកងទ័ពមួយ និងដើម្បីលើកឲ្យសោយរាជ្យឡើងវិញនូវសន្តតិវង្សនៅលើរាជបល្ល័ង្កនៃប្រទេសកម្ពុជា ។

ដោយមានជំនួយពីប្រជារាស្ត្រខ្មែរនោះ "បូឌីន និងព្រះអង្គដួង" មានគ្រប់សមត្ថភាព បណ្តេញពួកអណ្ណាមរហូតដល់ចូវដុក ។

នៅឧដុង្គ ព្រះបាទ **"អង្គដួង"** ត្រូវបានអបអរសាទរដោយប្រជារាស្ត្រខ្មែរ និងបានកាន់កាប់ជាឧឡារិក នូវការដឹកនាំកិច្ចការទាំងឡាយ ។

នៅក្នុងខណៈដែលពួកអណ្ណាមនិងពួកសៀមបានប្រយុទ្ធប្រឆាំងគ្នា ព្រះបាទអង្គដួងបានរៀបចំកងទ័ពរបស់ព្រះអង្គ ដើម្បីវាយកាន់កាប់ឡើងវិញនូវខេត្តទាំងឡាយនៅកូសាំងស៊ីន ។

លោក Leclère បាននិយាយថា "...ពីឧដុង្គព្រះអង្គដួងទ្រង់យាងទៅកាន់ខេត្តទ្រាំង ជាមួយនឹងកងទ័ពកម្ពុជា ។ កងទ័ពអណ្ណាមដែលទើបនឹងបានបង្ខំឲ្យកងទ័ពសៀមចុះសមុទ្រវិញនោះ បានដើរត្រង់ទៅរកព្រះអង្គដួង និងបានជួបព្រះអង្គ...ៅ ជើងកញ្ចុំ" ។

នៅក្នុងការប្រយុទ្ធបង្ហូរឈាមនេះ (១៨៤១) "ព្រះបាទអង្គដួង" ក្រោយពីបានតស៊ូយ៉ាងស្វិតស្វាញមកព្រះអង្គក៏ដកថយមកឧដុង្គវិញ ។

www.elibraryofcambodia.org

កងទ័ពទាំងពីររបស់សត្រូវ (សៀម និង អណ្ណាម), កងទ័ពនីមួយៗបានស្ថិតនៅលើទឹកដីដែលពួកគេបានច្បាំងដណ្តើមយក ។ A.Leclère បានបញ្ជាក់ថា "តាមពិតសត្រូវនីមួយៗនេះ បានគិតថានឹងកាត់បញ្ចូលជាឧបសម្ព័ន្ធនូវខេត្តខ្លះរបស់ប្រទេសកម្ពុជា បែងចែកប្រទេសនេះ តាមចំណែករបស់ពួកគេ រួចកាន់កាប់ទឹកដីខ្លះតាម តែពួកគេអាចធ្វើទៅបាន" ។ ប៉ុន្តែការតស៊ូរបស់ខ្មែរ ដែលបានរៀបចំជាមួយនឹង ចំណុចយុទ្ធសាស្ត្រទាំងឡាយ បានធ្វើឲ្យមានឧបសគ្គដល់ពួកគេ ។

នៅចំពោះមុខកងទ័ពរបស់ "ព្រះអង្គដួង" និងរបស់ "បូឌីន" ពួកអណ្ណាមបានដកថយ និងស្នើសុំសន្តិភាពជាមួយ "ព្រះអង្គដួង" ។

"ដោយមើលឃើញថា ប្រជាជនកម្ពុជាមិនចេះចាញ់នៅក្នុងជំហររបស់ខ្លួន ហើយដែលថាមពលរបស់ខ្លួនមានសមត្ថភាពល្មមតែត្រឹមកម្លាំងយោធារបស់ខ្លួននោះ (ឧត្តមសេនីយ៍យួនដែលទើបនឹងបានបដិសេធនូវសន្តិភាពនោះ) បានត្រឡប់មកស្នើសុំជានាដោយសន្តិភាពជាមួយខ្មែរវិញ" ។ (H.C.,Leclère ទំព័រ៤៣២) ។

**...ព្រះអង្គដួង បានទាមទារពីឧត្តមសេនីយ៍អណ្ណាមនូវលក្ខខណ្ឌនៃសន្ធិសញ្ញាសន្តិភាពមួយ គឺ : ឲ្យពួកអណ្ណាមប្រគល់មនុស្សនៅក្នុងព្រះរាជវង្សានុវង្ស ប្រជារាស្ត្រ និងមន្ត្រីទាំងអស់មកឲ្យកម្ពុជាវិញ ។**

**សន្ធិសញ្ញាមួយត្រូវបានអនុម័តដោយរដ្ឋាភិបាលសៀម និងរដ្ឋាភិបាលអណ្ណាម ការប្តូរអ្នកទោសបានប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ១៨៤៦ ។ ហើយ "ព្រះបាទ អង្គដួង" បានក្លាយទៅជាព្រះមហាក្សត្រជាទីសក្ការះរបស់ខ្មែរនៅដំណាច់ឆ្នាំ១៨៤៧ ។**

**សន្តិភាពត្រូវបានរកឃើញវិញហើយ ... "ព្រះបាទ អង្គដួង" ព្រះអង្គស្តេចរៀបចំស្រុកទេសឡើងវិញ, ព្រះអង្គរៀបចំកងទ័ព និង កសាងបន្ទាយការពារសឹកសត្រូវច្រើនកន្លែង ដើម្បីច្បាំងយកខេត្តនៅក្រសាំងស៊ីនមកវិញ ពីការកាន់កាប់របស់ពួកអណ្ណាម ។**

www.elibraryofcambodia.org

សេចក្ដីដកស្រង់មួយដែលគេយកចេញពីឯកសាររបស់ក្រសួងសន្តិសុខ នៅក្រោមចំណងជើងថា "ការប៉ុនប៉ងយកមកវិញនូវទឹកដីកម្ពុជានៅវៀតណាមខាងត្បូង" (ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ទំព័រ១) បានបញ្ជាក់អំពី ក្ដីកង្វល់របស់ព្រះករុណា "ព្រះបាទ អង្គដួង" ។

"...ដូចដែលយើងបានឃើញនៅក្នុងជំពូកនៃការប៉ុនប៉ងយកមកវិញនូវទឹកដីកម្ពុជានោះ "ព្រះករុណា ព្រះបាទ អង្គដួង" បានចាប់ផ្ដើមធ្វើយុទ្ធនាការនៅកូសាំងស៊ីនប្រឆាំងពួកអណ្ណាម ដើម្បីព្យាយាមយកមកវិញនូវខេត្តទាំងឡាយរបស់កម្ពុជា ។ ទោះបីព្រះអង្គជាព្រះមហាក្សត្រគួរឲ្យស្រឡាញ់និងគួរឲ្យគោរព "ព្រមទាំងជាក្សត្រស្រឡាញ់សន្តិភាពដោយស្មោះត្រង់ក្ដី" ដោយទ្រង់ព្រះតម្រិះអំពីភាពលំបាកវេទនារបស់ប្រជារាស្ត្ររបស់ព្រះអង្គនោះ, ព្រះមហាក្សត្រដ៏ថ្មើមនេះ មិនអាចទប់បាននូវមនោសញ្ចេតនា និងសមានហឫទ័យ ព្រមទាំងសេចក្ដីអាណិតអាសូរចំពោះប្រជារាស្ត្រ កម្ពុជាដែលត្រូវបានគេជិះជាន់ នៅភាគខាងត្បូងប្រទេសនោះដែរ ។ ព្រះអង្គបាន បាត់ឲ្យកសាងនៅពីមុខខេត្តបូរ៉ាផុក និងហាទៀង នូវបន្ទាយតូចៗ ដែលទុកដូចជាចំណុចចេញដំណើររបស់កងទ័ពខ្មែរ ។ ដោយទទួលការលើកហឫទ័យ ពីការឃើញពួកអណ្ណាមបរាជ័យជាបន្តបន្ទាប់ (ដោយពួកបារាំងកំពុងវាយប្រហារនោះ), ព្រះករុណា "អង្គដួង" បានចាប់អនុវត្តដោយមែនទែន និងយ៉ាងរឹងប៉ឹងជាមួយទ័ពបារាំង ជាសម្ព័ន្ធភាពផងនោះ, ធ្វើការប្រឆាំងអណ្ណាមនៅក្នុងគោលបំណងយកឲ្យបានមកវិញនូវទឹកដីដ៏មានជីវជាតិនេះ ដែលពួកអណ្ណាមបានផ្ដាច់យកដោយអយុត្តិធម៌ពីបុព្វបុរសរបស់ព្រះអង្គ ។ ប្រសិនបើពុំដោយសារមានជំងឺហើយ បន្ទាប់មក ការសោយទិវង្គត មិនត្រូវបានកើតមាននៅក្នុងឆ្នាំ១៨៦០ ដែលធ្វើឲ្យ ចប់នូវគម្រោងការរបស់ព្រះអង្គទេនោះ ។ (ប្រវត្តសាស្ត្រនៃប្រទេសកម្ពុជា, A.Leclère ទំព័រ៤៤៥ ទៅ៤៤៧)" ។

www.elibraryofcambodia.org

**...ប្រជារាស្ត្រខ្មែរមានការសោកស្តាយជាអតិបរមា ចំពោះការសោយទិវង្គត របស់ព្រះករុណាព្រះបាទ"អង្គដួង"នេះ ។ គឺព្រះអង្គនេះហើយ ដែលបានថ្វាយដំណឹង ជាលាយលក្ខណ៍អក្សរទៅ "ព្រះចៅណាប៉ូឡេអុងទី៣" អធិរាជនៃប្រទេសបារាំង អំពីសិទ្ធិ នៃប្រទេសកម្ពុជានៅលើទឹកដី "កូសាំងស៊ីនក្រោម" ។ ព្រះសារលិខិត របស់ព្រះអង្គនៅឆ្នាំ១៨៥៦ ដែលត្រូវបានធ្វើវិភាគច្វាយមកទៀត នៅក្នុងផ្នែក ដែលទុកសម្រាប់និយាយអំពីការតវ៉ានោះ គឺមានតម្លៃខាងគតិយុត្តយ៉ាងខ្ពស់ ។ ព្រះសារលិខិតនេះ បាត់ទុកដូចជា ភស្តុតាងនៃការសរសេរមួយបានបញ្ជាក់ដ៏ ត្រឹមត្រូវបំផុតថា "កូសាំងស៊ីន" គឺជាទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជានោះ ។**

* *
*

**នៅទីបញ្ចប់នៃរជ្ជកាលរបស់ព្រះករុណា "ព្រះអង្គដួង" (១៨៦០), ការប្រយុទ្ធ ដោយអាវុធដើម្បីយក"កម្ពុជាក្រោម"មកវិញ ត្រូវបានជំនួសដោយសកម្មភាព ផ្នែកការទូតវិញ : "គឺការតវ៉ាដោយចំហ និងគ្មានការលាក់លៀម" ។**

នៅពេលនោះ ប្រទេសកម្ពុជា ប្រឈមមុខជាមួយពួកអណ្ណាមផង និងជាមួយ ពួកបារាំងផងដែរ (ដែលពួកគេបានកាន់កាប់ទឹកដីកូសាំងស៊ីន ជំនួសពួក អណ្ណាម និងបានកែប្រែទៅជាអាណានិគមបារាំង ដោយផ្តាច់យកពីដៃស្តេច អណ្ណាមថែម ទៀត) ។

នៅមុនចាប់ផ្តើម កថាខ័ណ្ឌដែលនិយាយអំពីការកាន់កាប់របស់បារាំងនោះ យើងអាចទាញយកការសន្និដ្ឋាន អំពីហេតុការណ៍ប្រវត្តិសាស្ត្រទាំងឡាយដែលបាន រាយការណ៍រួចហើយនោះ ។

ហេតុការណ៍ទាំងនេះ បានបង្ហាញឲ្យឃើញថា "តើទឹកដីខ្មែរត្រូវបានលុកលុយ ដោយវៀតណាមយ៉ាងដូចម្តេចខ្លះ? និងថាតើពួកនេះត្រូវទទួលបរាជ័យដោយឥត

www.elibraryofcambodia.org

ឈប់ឈរយ៉ាងណាខ្លះ? ពីការវាយប្រហាររបស់ប្រជាជនខ្មែរ ដែលជាអតីតម្ចាស់កាន់កាប់ និងជាម្ចាស់ដ៏ត្រឹមត្រូវតាមច្បាប់តែមួយគត់នៃទឹកដីនេះ ដែលនៅក្នុងនោះពួកគេ ចង់ថែរក្សានូវអធិបតេយ្យភាពរបស់ពួកគេនោះ"... ។

* *
*

### III)-ការកាន់កាប់ខុសច្បាប់នូវ "ទឹកដីកម្ពុជាក្រោម" ដោយប្រទេសបារាំង

**ដោយបានធ្វើការតស៊ូប្រយុទ្ធគ្មានឈប់ឈរ ប្រឆាំងនឹងការកាន់កាប់របស់អណ្ណាមលើទឹកដី "កម្ពុជាក្រោម" នោះ, ប្រជារាស្ត្រខ្មែរមិនអាចទុកឲ្យបារាំងកាន់កាប់ទឹកដី "កម្ពុជាក្រោម" ដោយពុំបានធ្វើការតវ៉ាអ្វីសោះនោះទេ ។**

អ្វីដែលមានបន្តទៀតនោះ គឺទាក់ទងតែនឹងការកាន់កាប់ដោយពិតៗប៉ុណ្ណោះ ។ តើការតវ៉ាមានដូចម្ដេចខ្លះ...?

**ក)– ជាបឋម គឺការកត់សម្គាល់ខ្លះៗនៅពេលដំបូង**

បារាំងបានយក ទូរ៉ាន (Tourane) នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ បន្ទាប់មក សាយហ្គន នៅ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៨៥៩ ។

*(លោក Charles Lemire បានពិពណ៌នាអំពីសភាពការណ៍នៃការមកដល់របស់បារាំងនៅកម្ពុជាក្រោមដូចតទៅនេះ)* ....

ឆ្នាំ១៨៧៤..."ដោយចង់បង្ខំឲ្យប្រជាជនកម្ពុជាកែប្រែនូវទំនៀមទម្លាប់រហូតដល់សម្លៀកបំពាក់របស់ខ្លួននោះ, ដោយការការសម្ព័ន្ធភាពវាំងអណ្ណាមនិងស្រីយោរយៅ (ជាពាក្យដែលអ្នកឈ្នះហៅអ្នកចាញ់) ដោយឃើញនៅប្រទេសកម្ពុជាពួកមេបញ្ជាការកងទ័ពអណ្ណាមបានប្រព្រឹត្តអំពើលួចប្លន់ប្រជារាស្ត្រ និងប្រមាថដល់សមាជិកនៃព្រះរាជវង្សានុវង្សនោះ ពួកបារាំងទៅជាមានការមិនចូលចិត្ត ។

www.elibraryofcambodia.org

ហើយការបះបោររបស់ តី សឺន បានបញ្ចប់នូវការទន្ទ្រានយកទឹកដី ។ នៅពេលដែលពួកគេ ចង់បន្តធ្វើជាថ្មី ប្រជាជនកម្ពុជាបានធ្វើការសងសឹក ។ មានការសម្លាប់រង្គាលមួយធ្វើឲ្យពួកអណ្ណាមត្រូវដកថយទាំងមិនពេញចិត្ត នឹងអ្វីដែលពួកគេបានវាតទី រួចមកហើយនោះ ។

នោះគឺជាកាលៈទេសៈមួយ ដែលបារាំងដណ្តើមយក "កូសាំងស៊ិន" បាន ធ្វើឲ្យប្រជាជនកម្ពុជាមានការខកចិត្តយ៉ាងខ្លាំង ហើយបារាំងបានបន្តវេនពីអណ្ណាមនៅក្នុងសិទ្ធរបស់ពួកគេជាអាណាព្យាបាល" ។

លោក Georges Maspéro បានសរសេរនៅក្នុងសៀវភៅរបស់លោកក្រោមចំណងជើងថា ("ចក្រភពខ្មែរ ប្រវត្តិសាស្ត្រនិងឯកសារ") :

**"...ព្រះអង្គដួងជាព្រះមហាក្សត្រនៃប្រទេសមួយ ដែល"កាន់កាប់"ព្រមគ្នាដោយសៀមនិងអណ្ណាម ។ ពួកសៀមទទួលបាននូវខេត្តនៅភាគខាងជើងប្រទេសអំពីបៅហ្វាយខេត្តខ្មែរទាំងឡាយ ប្រគល់ឲ្យដោយគ្មានការយល់ព្រមពីព្រះមហាក្សត្ររបស់ខ្លួន...។ ពួកអណ្ណាមបាន"លុកលុយ"នៅពេលនោះ លើខេត្តទាំងឡាយនៅភាគខាងត្បូងប្រទេសដែលពួកគេដណ្តើមយក ជា"ការធ្វើឲ្យខូចប្រយោជន៍ដល់ប្រជាជនកម្ពុជា" ។**

សូមកត់សម្គាល់នូវពាក្យ : **"កាន់កាប់"** , **"លុកលុយ"** និង **"ការធ្វើឲ្យខូចប្រយោជន៍ដល់ប្រជាជនកម្ពុជា"** ។

គេបានដឹងផងដែរថា បន្ទាប់ពីការឡើងសោយរាជ្យរបស់ស្តេច "យ៉ា ឡុង" លើរាជបល្ល័ង្កអណ្ណាមមក លោក Maspéro បានសរសេរថា "...ប្រទេសបារាំងស្ថិតនៅលើផ្នែកនៃឥណ្ឌូចិននេះ ជាប្រជាជាតិអឺរ៉ុបមួយដែលត្រូវបានទាក់ទាញ...នូវកិត្តិនាមដោយពិតៗ" ។

**ព្រះករុណា "ព្រះអង្គដួង" បានសម្រេចពឹងពាក់ប្រទេសបារាំង មិនមែនដើម្បី**

www.elibraryofcambodia.org

**ប្រគល់កូសាំងស៊ីនទៅឲ្យបារាំងទេ, ប៉ុន្តែគឺដើម្បីស្នើសុំជំនួយឧបត្ថម្ភ និងការជួយផងដែរ ដើម្បីមិនត្រាន់តែឲ្យបេញផុតពីអំណាចរបស់សៀមនិងអណ្ណាមប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីនិងជាពិសេស "ប្រមូលយកមកវិញនូវដីដីមានជីវជាតិផងដែរ និងដែលត្រូវបានដកហូតយកដោយអយុត្តិធម៌ពីដៃបុព្វបុរសរបស់ព្រះអង្គ" ។**

(លោក G.Maspéro បានផ្តល់នូវការបកស្រាយដល់យើង អំពីគោលបំណងរបស់ "ព្រះអង្គដួង" ចំពោះរឿងនេះថា) : ...

**"...យើងជឿហើយអាចធានាបានថា ការស្នើទាំងឡាយដែល "ព្រះបាទ អង្គដួង" បានគិតគូរធ្វើចំពោះទូតបារាំង(នៅសាំងហ្គាពួរ) គឺមានដូចតទៅនេះ គឺរាយការណ៍ ដល់បារាំងជាដំបូងនូវសារទុក្ខរបស់ព្រះអង្គ រឿងរ៉ាវនៃការមិនសប្បាយព្រះរាជហឫទ័យរបស់ព្រះអង្គ ចំពោះប្រទេសជិតខាងដែលគួរឲ្យខ្លាចនេះ, ប្រកាសនូវអនាគតភាពរបស់ព្រះអង្គ ដើម្បីធ្វើការសងសឹក និងនៅទីបញ្ចប់ដើម្បីប្រកាសអំពីការសម្រេចរបស់ព្រះអង្គ ដើម្បីដាក់ឲ្យស្ថិតនៅក្រោមអាណាព្យាបាលបារាំងសែស ដែលនៅក្នុងនោះព្រះអង្គនឹងប្រគល់ឲ្យតាមសន្ធិសញ្ញានូវទឹកដីដែលដណ្តើមយកដោយអណ្ណាមនៅប្រទេសកម្ពុជា ហើយដែលពួកនេះរក្សាទុកជានិច្ច ទោះបីជាគ្មានច្បាប់ធ្វើអនុប្បទាន មិនត្រូវបានធ្វើអន្តរាគមន៍រវាងរដ្ឋទាំងពីរក៏ដោយ ។ ទឹកដីដែលមានបញ្ហានោះ គឺខេត្តទាំង៦បច្ចុប្បន្ននេះ គឺកូសាំងស៊ីន បារាំងសែស" ។**

ការអធិប្បាយរបស់លោក Maspéro នេះ បានធ្វើឲ្យមានការសង្កេតដូចតទៅនេះ គឺ :

១)- ព្រះករុណា "អង្គដួង" ដោយធ្វើសម្ព័ន្ធមិត្តជាមួយប្រទេសបារាំង គ្រាន់តែចង់ឲ្យបារាំងជួយទាមទារឲ្យបានមកវិញនូវខេត្តទាំងឡាយនៅកម្ពុជាក្រោម ក្នុងនោះព្រះអង្គមិនបានគិតទាល់តែសោះថា ត្រូវប្រគល់ទៅឲ្យប្រទេសបារាំង, ដូចដែលបានបញ្ជាក់នៅក្នុងការតវ៉ារបស់ព្រះអង្គជាខាងក្រោយមកទៀត ដែលទាក់ទង

www.elibraryofcambodia.org

ទៅនឹងខេត្តដែលបាននិយាយនេះ ។

២)- ប្រទេសបារាំងបានដឹងច្បាស់ថា · វាពុំមានច្បាប់ធ្វើអនុប្បទានណាមួយរបស់ប្រទេសកម្ពុជាទៅឲ្យអណ្ណាមនោះទេ អំពីខេត្តទាំងឡាយនៅកូសាំងស៊ីន ។ ម្យ៉ាងទៀតលោក Maspéro បានបញ្ជាក់ថា "...មានទឹកដីដែលដណ្តើមយកដោយអណ្ណាមនៅប្រទេសកម្ពុជា និងថាពួកនេះបានរក្សាទុកជានិច្ច ទោះបីជាពុំមានច្បាប់អនុប្បទានណាមួយដែលបានធ្វើអន្តរាគមន៍រវាងរដ្ឋទាំងពីរនេះក៏ដោយ" ។

លោក Maspéro (ទំព័រ៨៣) បាននិយាយអំពីបញ្ហានៃការយកសាយហ្គន :

"...បេសនកម្ម (កិច្ចប្រតិបត្តិការណ៍ក្រៅប្រទេស) ដែលបញ្ជាដោយឧត្តមនាវី Rigault de Genouilly និងកងទ័ព អេស្ប៉ាញ៉ុល ដ៏ធំមួយ បានទម្លាក់គ្រាប់បែកនៅ ទូរ៉ាន នៅខែសីហា ឆ្នាំ១៨៥៨ និងដណ្តើមយកសាយហ្គន នៅខែកុម្ភៈ ឆ្នាំ១៨៥៩ ។ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៨៦២ សន្ធិសញ្ញាមួយដែលតម្រូវពី Tu-Duc ឲ្យធ្វើអនុប្បទានទៅឲ្យបារាំងនូវខេត្ត៣ បំពេញបន្ថែមខេត្តបៀន ហ្វា (សាយហ្គន) និងឌិញទូង (មី ថ) និង ពូឡូ- កុងឌ័រ ។

"...នៅខែមីនា ឆ្នាំ១៨៦១ ឧត្តមនាវី Charner ដែលបញ្ជាអង្គទ័ពកាន់កាប់សាយ ហ្គន បានបញ្ជូននាយទាហានម្នាក់ទៅបង្គំគាល់ "ព្រះបាទ នរោត្តម" ដើម្បីទូល ព្រះអង្គអំពីគោលបំណងរបស់រដ្ឋាភិបាលបារាំង ដើម្បីបង្កើតគ្រឹះស្ថានស្ថិតស្ថេរមួយនៅកូសាំងស៊ីន និងដើម្បីសម្តែងអំពីបំណងរបស់លោក ដើម្បីថែទាំទំនាក់ទំនងមិត្តភាពជាមួយរដ្ឋាភិបាលកម្ពុជា" ។

ការអះអាងពីរចំណុចត្រូវបានធ្វើឡើង ស្របពេលគ្នានឹងអត្ថបទនេះ គឺ :

**ក- អំពើនៃការធ្វើអនុប្បទានរបស់អណ្ណាមទៅឲ្យបារាំង នូវខេត្តទាំងពារបស់ខ្មែរនៅ "កូសាំងស៊ីន" គឺត្រូវបានចាត់ទុកជាមោឃៈដោយពេញច្បាប់ ពីព្រោះថាខេត្តទាំងនេះត្រូវបានកាន់កាប់ដោយកងទ័ព និងដែលត្រូវបានទាមទារជានិច្ចកាល**

www.elibraryofcambodia.org

**ដោយប្រទេសកម្ពុជា ។**

**១– ដោយបានបញ្ជូននាយទាហានម្នាក់ឲ្យមក "ទូលថ្វាយ" ព្រះករុណា នរោត្ដម អំពីបំណងរបស់រដ្ឋាភិបាលបារាំង ដើម្បី "បង្កើតនូវគ្រឹះស្ថានមួយនៅកូសាំងស៊ីន នោះ ឧត្ដមសេនីយ៍ Charner បានទទួលស្គាល់ដោយពិតប្រាកដថា "កូសាំងស៊ីន" គឺជាទឹកដីកម្ពុជា ។**

* *
*

**១)– ការអះអាងជាជិបូងដែលបានធ្វើនេះ គឺការវិភាគនូវព្រឹត្តិការណ៍ទាំងឡាយ បញ្ជាក់អំពីការកាន់កាប់ដោយខុសច្បាប់ "ដែនដីកូសាំងស៊ីន" ដោយប្រទេសបារាំង...**

សៀវភៅមួយចំនួនរបស់បារាំងស្ដីអំពីប្រទេសកម្ពុជា បានលើកឡើងនូវព្រះសារលិខិតលើកដំបូងរបស់ព្រះករុណា "អង្គដួង" ដែលបានផ្ញើទៅថ្វាយអធិរាជបារាំងនៅឆ្នាំ១៨៥៣ ដែលមានអមដោយអំណោយផង, ប៉ុន្តែសៀវភៅទាំងនោះ ភ្លេចធ្វើការវិភាគ និងថែមទាំងមិនបានថែងអំពីព្រះសារលិខិតទី២ ដែលជាព្រះសារលិខិតដ៏សំខាន់បំផុតដែលទាក់ទងទៅនឹងទឹកដី "កូសាំងស៊ីន" នោះទេ ។ ម្យ៉ាងទៀត គោលបំណងរបស់ព្រះករុណា "អង្គដួង" ត្រូវបានគេធ្វើឲ្យប្រែក្លាយខ្លឹមសារដើមដូចយើង ទើបនឹងបានពិនិត្យកត់ត្រាសម្គាល់នៅក្នុងអត្ថបទរបស់លោក G.Maspéro ។

**ព្រះករុណា "អង្គដួង" បង់ "ធ្វើសម្ព័ន្ធភាព" ជាមួយប្រទេសបារាំង នោះគឺជា "សម្ព័ន្ធភាព" ដែលអនុញ្ញាតឲ្យប្រទេសរបស់ព្រះអង្គបានផ្ដាច់ខ្លួនចេញជាបឋមពីអំណាចនៃប្រទេសជិតខាងទាំងពីរ និងបន្ទាប់មកដើម្បីយកមកវិញនូវខេត្តទាំងឡាយដែលត្រូវបានគេផ្ដាច់យកដោយកម្លាំងទ័ពនោះ ។**

A.Leclère (ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ទំព័រ៤៤៣) លោកបានច្បាមយ៉ាងល្អនូវបញ្ហានេះ គឺ "...ព្រះអង្គ (អង្គដួង) ទ្រង់ព្រះតម្រិះថា នឹងស្នើសុំដាក់

www.elibraryofcambodia.org

ប្រទេសកម្ពុជានៅក្រោមអាណាព្យាបាលដូចយើងបានឮនៅពេលបច្ចុប្បន្ននេះ ប៉ុន្តែគឺការ ការពារ..."។

ឯការស្នើសុំការឧបត្ថម្ភនិងជំនួយ ក៏គឺដើម្បីការពារបូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា ។

ចំពោះ Leclère ការ ការពារនេះត្រូវបានស្នើសុំ "នៅក្រោមល័ក្ខខ័ណ្ឌដែលប្រទេសបារាំងនឹងការពារព្រះរាជាណាចក្រកម្ពុជា ពីការលេបដោយប្រទេសជិតខាងទាំងពីរ ឬក៏ប្រជាជាតិអឺរ៉ុបណាមួយផ្សេងទៀតនោះ ។

Leclère បានបញ្ជាក់ទៀតថា "...ព្រះករុណាព្រះ "អង្គដួង" ទ្រង់មានជំនឿចំពោះប្រទេសបារាំង, ពីព្រោះថាប្រទេសបារាំងមានឈ្មោះល្បីថា ជាប្រជាជាតិមួយដែលមានចិត្តល្អ, ពុំមានអ្វីជារបស់ខ្លួននៅចុងបូព៌ាប្រទេសនោះទេ ។ ព្រះមហាក្សត្រ ខ្មែរជឿថា ប្រទេសបារាំងពុំមែនជាប្រទេសអ្នកឈ្លានពាន និងពុំមានបំណងជាអ្នកនិយមបញ្ចូលជាឧបសម្ព័ន្ធនោះទេ" ។

ដោយដាក់ប្រទេសនៅក្រោមអាណាព្យាបាលបារាំងនោះ ព្រះបាទ"អង្គដួង"ទ្រង់ប្រាកដនៅក្នុងព្រះរាជហឫទ័យថា បារាំងនឹងការពារប្រទេសកម្ពុជា នឹងជួយយកមកវិញនូវខេត្តទាំងឡាយនៅកម្ពុជាក្រោម ។

នៅខែវិច្ឆិកា ឆ្នាំ១៨៥៣ "ក្រោយពីព្រះអង្គបានព្រះតម្រិះយ៉ាងម៉ត់ចត់អំពីអ្វីដែលព្រះអង្គបានធ្វើនោះ ព្រះមហាក្សត្រ"អង្គដួង"បានបញ្ជូនជាសម្ងាត់នូវបច្ឆាជនព័រទុយហ្គេពីរនាក់ (មន្ត្រីអ្នកមានឪពុកជាជនជាតិព័រទុយហ្គេ កាន់សាសនាកាតូលិក) ឈ្មោះ "ចៅពញា កុយ និង ពេទ" យក ព្រះរាជសារលិខិតសរសេរជាភាសាបារាំងដោយ"សម្តេច Miche" អេវ៉េក នៅប្រទេសកម្ពុជា តាមការហៅសូត្រឲ្យសរសេររបស់ព្រះមហាក្សត្រ ទៅជូនលោក de Montigny កុងស៊ុលបារាំងនៅសឹង្ហបុរី ដើម្បីផ្ញើទៅថ្វាយ "ព្រះចៅអធិរាជ ណាប៉ូឡេអុងទី៣" ។ ព្រះរាជ

www.elibraryofcambodia.org

សារលិខិតទី១នេះ អមទៅដោយប្រអប់ជង្វាយជាច្រើន ត្រូវបានផ្ញើទៅថ្វាយ "ព្រះចៅអធិរាជណាប៉ូឡេអុងទី៣" ដើម្បី "បង្ហាញព្រះចៅអធិរាជ បារាំងនូវមិត្តភាពរបស់ព្រះអង្គ និងបង្ហាញនូវគោរពភក្ដិរបស់ព្រះអង្គទៀតផង" ។

"ស្ដេចណាប៉ូឡេអុងទី៣" បន្ទាប់ពីបានទទួលព្រះរាជសារលិខិតនេះមក ព្រះអង្គបានចាត់លោក Montigny ឲ្យទទួលបន្ទុកធ្វើការចរចាជាមួយព្រះមហាក្សត្រខ្មែរ ។

នៅពេលនោះមានការញុះញង់ពីស្ដេចសៀមធ្វើឲ្យការចរចាទាំងនេះមិនបានកើតឡើងតាមបំណងឡើយ ។

ព្រះសារលិខិតរបស់ព្រះករុណា "ព្រះអង្គដួង" ក៏ពុំមានឥទ្ធិពលអ្វីឡើយ ។

បារាំងមានការសោកស្ដាយយ៉ាងខ្លាំងចំពោះការបរាជ័យរបស់បេសកកម្ម Montigny ដែលប្រសិនបើបេសកកម្មនេះបានសម្រេចនោះ នឹងជួយសម្រួលដល់ពួកគេនូវការធ្វើសញ្ជ័យនៅលើទឹកដី "កូសាំងស៊ីន" ។

Leclère បានកត់សម្គាល់ (H.C., ទំព័រ៤៤៤) ថា "...ប្រសិនបើនៅក្នុងសម័យនោះ យើងបានមកប្រទេសខ្មែរ និងបានយល់ព្រមជាមួយព្រះមហាក្សត្រខ្មែរនោះ វាច្បាស់ណាស់ថា "កូសាំងស៊ីន" ទាំងមូលត្រូវបានដណ្ដើមយកនៅក្នុងយុទ្ធនាការតែមួយគត់" ។

ដូច្នេះ "ប្រទេសបារាំងបានទទួលស្គាល់" នៅក្នុងសម័យនោះ នូវ "សិទ្ធិ" របស់ប្រទេសកម្ពុជា នៅលើខេត្តទាំងឡាយរបស់ខ្លួននៅ "កម្ពុជាក្រោម" នេះមិនបានរារាំងបារាំងក្នុងការដណ្ដើមយកកូសាំងស៊ីនដោយកងទ័ព និងធ្វើជាអាណានិគម និងថែមទាំង ធ្វើជាខេត្តមួយរបស់បារាំងនោះទៀតផង ។

ដោយមិនទទួលបាននូវការជួយសង្គ្រោះណាមួយពីបារាំងនោះ "ព្រះអង្គដួង" ក៏បានរៀបចំដោយព្រះអង្គឯង នូវការតស៊ូនិងគាំទ្រដោយកងទ័ព ដើម្បីធ្វើការបះបោរប្រឆាំងពួកអណ្ណាម ។

www.elibraryofcambodia.org

តាមលោក Leclère (H.C., ទំព័រ៤៥៥) បានឲ្យដឹងថា "ព្រះអង្គដួង" បានចាត់ឲ្យកសាងបន្ទាយតូចៗនៅលើព្រំដែនខាងត្បូង ។ ព្រះអង្គបានឲ្យលោកឧកញ៉ា "កែប" កសាងកងទ័ពមួយ ដើម្បីប្រយុទ្ធជាមួយពួកអណ្ណាម និងពួកចាមនៅចូវដុក ។

ពួកចាមដែលចូលរួមជាមួយកងទ័ពអណ្ណាម ត្រូវបានបញ្ជូនមកឲ្យប្រឆាំងប្រជាជនកម្ពុជា និងបានតស៊ូទៅតាមសមត្ថភាពរបស់ខ្លួន ប៉ុន្តែពួកគេមិនអាចរារាំងកងទ័ពខ្មែរ មិនឲ្យរុលទៅមុខ ទៅដល់ឯនាយព្រំដែនបានឡើយ ។

ពេលនោះពួកអណ្ណាមពុំមានលក្ខណៈការពារប្រឆាំងនឹងកងទ័ពរបស់កម្ពុជាបានឡើយ ។

ម្យ៉ាងទៀតព្រះករុណា"ព្រះអង្គដួង" មានការព្រួយបារម្ភចំពោះកិច្ចព្រមព្រៀងចាស់ ដែលបានសម្រេចនៅក្រោមរជ្ជកាលស្តេច"យ៉ាឡុង"រវាងបារាំងនិងរាជវាំងអណ្ណាម... នោះគឺ

ស្តេចអណ្ណាមដោយការប្តូរជាមួយនឹង "នាវាចម្បាំង៤គ្រឿង ដែលមានកងទ័ពមួយពាន់ប្រាំមួយរយហាសិបនាក់"ដែលប្រទេសបារាំងបានសន្យា បញ្ជូនទៅថ្វាយនោះ បានយល់ព្រមផ្តល់ឲ្យប្រទេសបារាំងនូវអធិបតេយ្យភាពលើ ទឹកដី ទូរ៉ាន និងកោះពូឡូ កុងឌ័រ ទោះបីជាកោះនេះជាទឹកដីកម្ពុជា ចាប់តាំងពីរាប់សតវត្សរ៍មកហើយក៏ដោយ (ប្រជាជនខ្មែរ A.Migot ទំព័រ២៩៦) ។

នៅក្នុងព្រះសារលិខិតទី២ ផ្ញើថ្វាយអធិរាជ "ណាប៉ូឡេអុងទី៣" និងត្រូវបានប្រថាប់ត្រានៅឧដុង្គនៅថ្ងៃទី១៣ រោច ឆ្នាំ១២១៥ នៃចុល្លសករាជ (១៨៥៦) ព្រះករុណា "ព្រះអង្គដួង" បានឲ្យបារាំងដឹងយ៉ាងច្បាស់នូវសិទ្ធិរបស់ប្រទេសកម្ពុជាលើទឹកដីកូសាំងស៊ីន និងបានស្នើបារាំងកុំឲ្យទទួលស្គាល់អធិបតេយ្យភាពអណ្ណាម និងការផ្តល់នូវទឹកដីណាមួយដែលទាក់ទងទៅនឹងទឹកដីខ្មែរនោះ ។

www.elibraryofcambodia.org

ដូច្នេះថាជា "លិខិតផ្តល់ដំណឹង" នៅក្នុងន័យជាគតិយុត្ត ។

"ស្តេចណាប៉ូឡេអុងទី៣" មិនបានឆ្លើយតបទៅ "ព្រះអង្គដួង" វិញឡើយ ។ ប្រទេសបារាំងបានដណ្តើមយកដោយកង ទ័ពនូវទឹកដីកូសាំងស៊ីនក្រោម ។ "ពួកបារាំងបានយកទឹកចិត្តទុកដាក់ចំពោះតែផលប្រយោជន៍របស់ខ្លួនផ្ទាល់ ("រាជាធិបតេយ្យខ្មែរ") ។

កងទ័ពរបស់ឧត្តមនាវី Rigault de Genouilly បានទម្លាក់គ្រាប់បែកទៅលើទូរ៉ាន នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ ហើយធ្វើដំណើរជាបន្តទៅរកជ្រោយ Saint-Jacque ឡើងតាមទន្លេ និង**ដណ្តើមយកសាយហ្គុននៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៨៥៩** ។

ព្រះករុណា"ព្រះអង្គដួង" ទ្រង់មានការភ្ញាក់ផ្អើល និងព្រួយព្រះទ័យព្រមគ្នាចំពោះដំណើរនៃព្រឹត្តិការណ៍ទាំងឡាយ និងការជាប់ទាក់ទិនចំពោះវាសនាប្រទេសរបស់ព្រះអង្គ ។

A.Leclère បានសរសេរថា "...ព្រះករុណា ព្រះអង្គដួង ចង់ដឹងអំពីគោលបំណងរបស់បារាំង និងចង់ដឹងថាតើប្រសិនជាបារាំងគ្រាន់តែគិតគូរធ្វើការសងសឹកនូវការប្រមាថ ដែលពួកអណ្ណាមបានធ្វើមកលើពួកគេ ដើម្បីរក្សាទុកនូវចំណុចមួយនៃឆ្នេរសមុទ្រតែប៉ុណ្ណោះ ឬក៏ធ្វើសញ្ជ័យលើទឹកដីកូសាំងស៊ីនក្រោម"... ។

ដោយសង្ស័យអំពីបំណងរបស់បារាំង ហើយការសង្ស័យរបស់ព្រះអង្គនឹងត្រូវបានបញ្ជាក់នៅពេលក្រោយបន្តិចមក, ពីព្រោះបារាំងនឹងធ្វើឲ្យកូសាំងស៊ីនក្លាយទៅជាអាណានិគមរបស់ខ្លួនផ្ទាល់ និងថែមទាំងធ្វើជាខេត្តមួយរបស់ខ្លួនទៀតផងនោះ "ព្រះអង្គដួង" បានសម្រេចព្រះទ័យធ្វើការវាយប្រហារមែនទែនទៅលើពួកអណ្ណាម និង ចូលទៅក្នុងកូសាំងស៊ីន ។

ទន្ទឹមនឹងការព្រួយបារម្ភផងនោះ ព្រះអង្គដួងបានធ្វើការវាយ លុកប្រឆាំងពួកអណ្ណាម ។ គឺឱកាសល្អដើម្បីឆ្លៀតពេលដែលពួកគេខ្សោយ វាយយកមកវិញនូវ

www.elibraryofcambodia.org

ខេត្តទាំងឡាយដែលអណ្ណាមបានរំលោភដណ្ដើមយក ។

ដូច្នេះព្រះបាទ "អង្គដួង" ដោយខ្លាចបារាំងដណ្ដើមយកកូសាំងស៊ីនទាំងអស់នោះ បានសម្រេចចូលជ្រៅទៅក្នុងទឹកដីនេះ ដើម្បីដណ្ដើមយកមកវិញមួយផ្នែក ពុំនោះទេទឹកដីកម្ពុជាក្រោមទាំងអស់ នឹងត្រូវបារាំងកាន់កាប់ទាំងអស់ ។

តាមព្រះរាជបញ្ជារបស់ "ព្រះអង្គដួង" ឧកញ៉ា "កែប" ស្ដេចត្រាញ់នៅទឹកដីទាំងជាមួយកងទ័ពកម្ពុជា បានវាយប្រហារពួកអណ្ណាមនៅចូវដុក ។

ជាអកុសល ព្រះបាទ "អង្គដួង" បានធ្លាក់ព្រះកាយប្រឈួន និងសោយទិវង្គតនៅខែវិច្ឆិកា ឆ្នាំ១៨៦០ (ឆ្នាំ១៧៨២ នៃមហាសករាជ ឆ្នាំ១២២២ នៃចុល្លសករាជ នៅខែកត្តិក ថ្ងៃទី៥ កើត) ។

ការសោយទិវង្គតរបស់ព្រះ "អង្គដួង" "បានបញ្ចប់ចលនារបស់កងទ័ពកម្ពុជានៅស្រុកចូវដុក ហើយឧកញ៉ា "កែប" បានត្រឡប់មកប្រទេសកម្ពុជាវិញ" (H.C., Leclère) ។

**ព្រះបាទ "អង្គដួង" សោយទិវង្គតទៅ ការប្រយុទ្ធដោយអាវុធត្រូវបានជំនួសដោយ ដំណើរការគិតគូរ និងតាមលិខិតតវ៉ាប្រឆាំងទៅនឹងការកាន់កាប់របស់បរទេស "ដែលមានការដាក់បន្ទុំ និងមិនត្រឹមត្រូវតាមច្បាប់" នោះ ។**

នៅមុនការចាប់ផ្ដើមនិយាយអំពីអត្ថន័យ ខ្លឹមសារ រូបរាង និងទំហំនៃការតវ៉ាទាំងនេះ យើងសូមរំលឹកពីដំណាក់កាលនៃការធ្វើសញ្ជ័យកូសាំងស៊ីនដោយបារាំង និងការដាក់អាណាព្យាបាលបារាំងនៅលើប្រទេសកម្ពុជា ។

**គ)– ការដាក់អាណាព្យាបាលបារាំងនៅប្រទេសកម្ពុជា**

ស្របទៅតាមការណែនាំរបស់ព្រះករុណាព្រះ "អង្គដួង" ក្រុមប្រឹក្សានៃអ្នកមានបណ្ដាស័ក្តិជាន់ខ្ពស់ បានកោះប្រជុំដោយ "មហាក្សត្រីព្រះមាតា" បានជ្រើសរើសព្រះ "អង្គម្ចាស់វតី" ព្រះរាជបុត្រច្បងរបស់ព្រះមហាក្សត្រ ដែលនៅពេលនោះ

www.elibraryofcambodia.org

មានព្រះជន្ម ២៦ព្រះវស្សាផ្ញើជាព្រះមហាក្សត្រប្រទេសកម្ពុជា ។ នៅក្រោមព្រះនាម "នរោត្តម" ព្រះអង្គវតីត្រូវបានរាជាភិសេកយ៉ាងឆាប់រហ័ស នៅក្នុងឆ្នាំ ១៨៦០ ។ ហើយប្រទេសបារាំងបានកាន់កាប់សាយហ្គន បានមួយឆ្នាំមកហើយ។

នៅខែមីនា ឆ្នាំ១៨៦១ ប្រទេសបារាំងបានទូលថ្វាយព្រះមហាក្សត្រ "នរោត្តម" អំពីបំណងរបស់ខ្លួនដើម្បីបង្កើតនូវ "គ្រឹះស្ថានស្ថិតស្ថេរមួយនៅឥណ្ឌូចិន" ។

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៨៦២ សន្ធិសញ្ញា មួយបានតម្រូវឲ្យ Tu Duc ធ្វើអនុប្បទានទៅឲ្យប្រទេសបារាំងនូវការបេញបន្ថែមខេត្ត៣ គឺខេត្ត បៀងហ្វា (សាយហ្គន) និង ឌិញ ទូង (មីថ) និង ពូឡូ កុងឌ័រ ("ចក្រភពខ្មែរ" G.Maspéro ទំព័រ៨៣៩) ។

នៅចន្លោះពេលនោះ ឧត្តមនាវី Charner (អ្នកបន្តវេនពី Rigault de Genouilly) បានផ្ញើលិខិតមួយទៅថ្វាយព្រះមហាក្សត្រ "នរោត្តម" ដែលគេយល់ថា ជាការប្រើពាក្យដើម្បីបន្ធូរការមិនទុកចិត្តរបស់ហ្លួង "នរោត្តម" តែប៉ុណ្ណោះ ។

"...ព្រឹត្តិការណ៍ចុងក្រោយទាំងឡាយនៅកូសាំងស៊ីនព្រះករុណាពិតជាបានឮហើយ, សូមព្រះអង្គទ្រង់ជ្រាបថា កងទ័ពបារាំង-អេស្ប៉ាញ៉ុល បានដេញពួកអណ្ណាម ដែលនៅសាយហ្គន ចេញ, ហើយកងទ័ពអណ្ណាមដែលបរាជ័យត្រូវបានបែកខ្ញែកគ្នា ។ ប្រជាជននៅជិតៗនោះ និងនៅទីឆ្ងាយបានមកចុះចូលជាមួយពួកយើង និងទទួលយកអាណាព្យាបាលដែលបារាំងបានផ្តល់ឲ្យដល់ពួកគេ ។ បំណងរបស់ប្រទេសបារាំង គឺថែរក្សាការផ្ញើសញ្ញើយរបស់ខ្លួនដើម្បីបង្កើតអាណានិគមនៅកូសាំងស៊ីនក្រោម និងដើម្បីនាំមកនូវគុណប្រយោជន៍ទាំងអស់នៃអារ្យធម៌អឺរ៉ុប" ។

លិខិតនិយាយត្រង់ៗណាស់ លោកឧត្តមនាវី បានបង្ហាញនូវអំណាចរបស់ខ្លួន និង

www.elibraryofcambodia.org

បានគូសបញ្ជាក់អំពីភាពឥតប្រយោជន៍នៃការតស៊ូ (បើអាចកើតមានឡើង) ។ លោកឧត្តមនាវីរូបនោះ បានបញ្ជាក់យ៉ាងនេះចំពោះព្រះមហាក្សត្រប្រទេសកម្ពុជា ដើម្បីថ្វាយព័ត៌មានដល់ព្រះអង្គអំពីបំណងរបស់គាត់សុំកុំឲ្យព្រះអង្គប្រឆាំងតែប៉ុណ្ណោះ ។

លោកឧត្តមនាវីបានបន្ថែមថា "...ទូលបង្គំសូមធានាថ្វាយចំពោះព្រះករុណា នូវបំណងដ៏ល្អរបស់យើងចំពោះប្រទេសកម្ពុជា និងឆ្លើយតបទៅនឹងការផ្ដើមទាក់ទង ដើម្បីសន្តិភាព និងមិត្តភាពដែលព្រះមហាក្សត្រព្រះបិតារបស់ព្រះអង្គទ្រង់បានធ្វើជាញឹកញាប់ជាមួយតំណាងនៃអធិរាជបារាំងដ៏ថ្លៃថ្នូរនៅសាំងហ្គាពួរ ។ ទូលបង្គំក៏មាន កិត្តិយសក្រាបបង្គំទូលថ្វាយព្រះករុណាផងដែរថា ទូលបង្គំ និងគិតគូរនៅក្នុងពេល វេលាមួយមិនយូរប៉ុន្មានដើម្បីនាំកងទ័ពរបស់យើងទៅ "មី ថ" និងដណ្ដើមយក កន្លែងនេះដែលជាកន្លែងការពារចុងក្រោយរបស់ "អណ្ណាម" មកឲ្យប្រទេសកម្ពុជាវិញ" ។

លិខិតនេះសរុបទៅគឺជាការឆ្លើយតបទៅនឹងព្រះសារលិខិតរបស់ព្រះករុណា "អង្គដួង" ។ នៅក្នុងពាក្យគួរសមនៃលិខិតនេះ បានធ្វើឲ្យគេយល់ច្បាស់ថា ឧត្តមនាវី Charner មានការបារម្ភតិចតួចអំពី "សិទ្ធិរបស់ប្រទេសកម្ពុជា" នៅលើទឹកដី "កូសាំងស៊ីន" ដែលគាត់មានបំណង ដើម្បីធ្វើអាណានិគមព្រមជាមួយនឹងការយល់ព្រមពីរដ្ឋាភិបាលបារាំង ។

ការកាន់កាប់កូសាំងស៊ីនត្រូវនាំមក នូវការលូកដៃចូលទៅក្នុងប្រទេសកម្ពុជា, លោក André Migot ("ប្រជាភាស្ត្រខ្មែរ", ទំព័រ ៣០៣) បានផ្ដល់នូវហេតុផលដូចតទៅនេះ...

"ខាងផ្នែកខ្លួន (ប្រទេសបារាំង)បានតាំងនៅកូសាំងស៊ីន អាចយល់ព្រមដោយពិបាកថា ប្រទេសជិតខាងផ្ទាល់របស់ខ្លួនគឺប្រទេសកម្ពុជា បានស្ថិតនៅក្រោមការ

www.elibraryofcambodia.org

ត្រួតត្រារបស់សៀមដែលជាមហាអំណាចមួយគាំទ្រដោយប្រទេសអង់គ្លេស" ។

លោក Paul d' Enjoy (*"ការធ្វើអាណានិគមកូសាំងស៊ីន" ទំព័រ ១០*) បានសរសេរអំពីកាលានុវត្តភាពនៃការធ្វើអាណានិគមនេះថា :

"...ខ្ញុំដឹងច្បាស់ថា គេ (រដ្ឋាភិបាលបារាំង) នឹងយល់ទាស់ ចំពោះការប្រឆាំងរបស់អង់គ្លេស ។ ប៉ុន្តែ ប្រសិនបើយើងត្រូវប្រគល់ឲ្យទៅតាមការទាមទារនីមួយៗរបស់អង់គ្លេសនោះ យើងនឹងបានបណ្តេញចេញពីអាណានិគមរបស់យើងយ៉ាងឆាប់រហ័ស..."

ដូច្នេះ បារាំងមិនអាចទុកប្រទេសមួយដូចជាកម្ពុជានេះ ដែលស្ថិតនៅក្រោមការគំរាមកំហែងដោយផ្ទាល់ពីសៀម ដែលមានប្រទេសអង់គ្លេស ស្ថិតនៅពីក្រោយជាប្រទេសជិតខាងបានទេ ។ ព្រោះហេតុនោះ ទើបបារាំងបានប្រញាប់ប្រញាល់ធ្វើការចរចាជាមួយព្រះករុណា "នរោត្តម" ។ នៅខែមិថុនា ឆ្នាំ១៨៦២ លោក អនុនាវីឯក Doudart de Lagrée ត្រូវបានបញ្ជូនដោយឧត្តមនាវី de La grandière ឲ្យមកបំពេញបេសកកម្ម នៅប្រទេសកម្ពុជាដើម្បីធ្វើការទំនាក់ទំនងជាមួយ "ព្រះបាទ នរោត្តម" ហើយនឹងចុះទៅពិនិត្យភូមិសាស្ត្រ ព្រមទាំងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រទេសនេះផង ហើយឲ្យមានផែនទីបញ្ជាក់ឲ្យបានគ្រប់ទីកន្លែងទៀតផង ។

បេសកកម្មរបស់លោក Doudart de Lagrée មានលក្ខណៈផ្អិតផ្អង់ណាស់ពីព្រោះថា បេសកកម្មនេះត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ដោយពួកចារបុរសសៀម ។ ដើម្បីឲ្យកាន់តែទុកចិត្តអំពីបេសកកម្មនេះ លោកឧត្តមនាវី de Lagrandière បានទៅកាន់ទីក្រុងឧដុង្គផ្ទាល់ខ្លួន និងដោយមានអេវ៉េក Miche ជាអ្នកជួយផងនោះ លោកបានទទួលជោគជ័យក្នុងការបញ្ចុះបញ្ចូលព្រះករុណា "នរោត្តម" ឲ្យឡាយព្រះហស្តលេខានៅឆ្នាំ១៨៦៣ ។ **"គឺជាការពិបាក ("ប្រជាជន**

www.elibraryofcambodia.org

**ខ្មែរ" A.Migot ទំព័រ ៣០៤) ដើម្បីអះអាងថា ព្រះហស្តលេខារបស់ ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ត្រូវបានឡាយដោយស្ម័គ្រព្រះទ័យទាំងស្រុង ឬក៏ដោយសារវត្តមានកាំភ្លើងធំរបស់បារាំងនៅលើផ្ទៃទឹកនៅភ្នំពេញ ។ ហើយក៏ប្រហែលជាមិនមែនជារឿងបម្លែកនោះទេ ដែលព្រះមហាក្សត្រត្រូវតែទទួលយល់ព្រមនោះ" ។**

ក្រោយពីមានការលំបាកជាច្រើនមក សន្ធិសញ្ញានេះ ត្រូវបានផ្តល់សច្ចានុម័តនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៨៦៣ ។ មួយឆ្នាំក្រោយពីការផ្សាយព្រះហស្តលេខាមក ព្រះករុណា "នរោត្តម" បានយាងទៅកាន់ទីក្រុងសាយហ្គន ដើម្បីបំពេញដំណើរការគិតគូរនៅអមអាជ្ញាធរបារាំង ដើម្បីទទួលកាន់កាប់ខេត្តទាំងឡាយរបស់កម្ពុជានៅកូសាំងស៊ីន ។

ព្រះរាជដំណើរគិតគូរនេះ (ដែលត្រូវនិយាយជាខាងក្រោយឆ្ងាយមកទៀតនោះ) គឺនៅតែពុំមានប្រសិទ្ធភាព ។ បារាំងមិនបានយកចិត្តទុកដាក់ឡើយ ហើយផ្ទុយទៅវិញ គេបានប្រញាប់ប្រញាល់ដើម្បីបញ្ចប់ការធ្វើសញ្ញ័យ "ទឹកដីកូសាំងស៊ីននោះ" ។

ថ្ងៃទី២០ ២២ និង ២៤ មិថុនា ១៨៦៧ លោកឧត្តមនាវី de Lagrandière បានដណ្តើមយកដោយមិនបាច់ប្រយុទ្ធនូវខេត្ត វិញឡុង ចូវដុក និងហាទៀង ដែលធ្វើឲ្យគេក្លាយទៅជាម្ចាស់នៃកូសាំងស៊ីនទាំងអស់" (Maspéro) ។

ដោយមិនបានពិគ្រោះយោបល់ ទាំងជាមួយព្រះមហាក្សត្រខ្មែរ ទាំងជាមួយឥស្សរជនបារាំង ដែលជាសមត្ថកិច្ចមូលដ្ឋានផងនោះ, ប្រទេសបារាំងព្រោះតែចង់បានសិទ្ធិពេញបន្ទុកនៅលើប្រទេសកម្ពុជា (នៅក្នុងឆ្នាំដដែលនេះ) បានចុះហត្ថលេខាជាមួយសៀមនូវសន្ធិសញ្ញាឆ្នាំ១៨៦៧ ។ មានន័យថា បារាំងបានយល់ព្រមឲ្យសៀមកាន់កាប់ខេត្តពីររបស់កម្ពុជាគឺខេត្ត បាត់ដំបង និងអង្គរ ជាថ្នូរ និងសេរីភាពដែលសៀមទុកឲ្យបារាំងនៅលើប្រទេសកម្ពុជា ។ **"នោះគឺជាការក្បត់**

www.elibraryofcambodia.org

**ដីដាក់ស្ពែង" ដូចដែលលោក A. Migot បានសរសេរ** ("ប្រជាជនខ្មែរ" ទំព័រ ៣០៨) :

ម្យ៉ាងទៀតព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរមួយបានពង្រឹងផែនការរបស់អ្នកប្រឆាំងទៅលើសន្ធិសញ្ញារបស់អាណាព្យាបាល : **គឺការចុះហត្ថលេខានៅឆ្នាំ១៨៦៧ ដោយប្រទេសបារាំងលើសន្ធិសញ្ញាមួយជាមួយសៀម** ។ ហាក់ដូចជាមិនដឹងចំពោះការព្រមានរាប់មិនអស់ដែលលោក Doudart de Lagrée បានផ្ញើទៅក្រសួងជើងទឹកនៅក្នុងចំណុះឥណ្ឌូចិន ។ ក្រសួងការបរទេសបានសម្រេចចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង–សៀមដែលបានយល់ព្រមឲ្យប្រទេសសៀមកាន់កាប់ខេត្តពីររបស់កម្ពុជា គឺខេត្តបាត់ដំបង និងអង្គរ ។ ម្យ៉ាងទៀតក្រសួងនេះ បានរក្សាសិទ្ធិកាន់កាប់របស់សៀមនៅលើខេត្តម្លូព្រៃ និងទន្លេរពៅ ដែលសៀមបានកាន់កាប់ចាប់តាំងពីច្រើនឆ្នាំមកហើយ ។ **នោះគឺជាការក្បត់ដីដាក់ស្ពែងចំពោះប្រទេសកម្ពុជា គឺប្រទេសបារាំងដែលនៅក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញាអាណាព្យាបាល បានសន្យាដើម្បីការពារប្រឆាំង និងការចង់បានរបស់សៀមនោះ បានប្រគល់ឲ្យប្រទេសនេះដោយមិនរញ្ជរាននូវខេត្តកម្ពុជាដ៏ល្អបំផុតពីរ ដោយពុំបានពិគ្រោះជាមួយព្រះករុណា "នរោត្តម" ឡើយ ។**

ចំពោះសន្ធិសញ្ញាថ្មីព្រះករុណា "នរោត្តម" និងឧត្តមនាវី De La grandière បានតវ៉ាយ៉ាងខ្លាំងក្លា ប៉ុន្តែច្បាប់ត្រូវបានចុះ ហត្ថលេខារួចហើយ "មិនមែនជាបញ្ហាដែលត្រូវវិលមកវិញនោះឡើយ" ។ ទោះជាយ៉ាងណាក៏ដោយ សន្ធិសញ្ញាឆ្នាំ ១៨៦៧ ត្រូវបានចុះហត្ថលេខារួចហើយ ។

ចំពោះការបាត់បង់ខេត្តរបស់ខ្លួននៅភាគខាងកើតប្រទេសនោះ យូរក្រោយមកនឹងបន្ថែមដល់ប្រទេសកម្ពុជានូវការធ្វើឲ្យកាន់តែធ្ងន់ធ្ងរនូវអាណាព្យាបាលដែលបារាំងបានដាក់ទម្ងន់មកលើ ។

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ព្រះករុណា "នរោត្តម" ត្រូវបានបង្ខំឲ្យឡាយព្រះ

ហស្តលេខាលើអនុសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញា ឆ្នាំ១៨៦៣ ។ អនុសញ្ញា នេះ តាមការពិតគឺជា "ការជ្រៀតជ្រែកមួយដែលមិនអាចប្រកែកបានរបស់ប្រទេសបារាំងនៅក្នុងកិច្ចការផ្ទៃក្នុងនៃប្រទេសកម្ពុជា" (A.Migot) ។

នៅឆ្នាំ១៨៩៧ "សន្ធិសញ្ញាមួយទៀត នឹងបំពេញសន្ធិសញ្ញាឆ្នាំ ១៨៦៤ ដាក់បង្ខំដោយកម្លាំងទ័ព និងការគំរាមកំហែងដូចសន្ធិសញ្ញាទី១ដែរ និងបានដកយកពីព្រះមហាក្សត្រនូវអំណាចដែលព្រះអង្គមានបន្តិចបន្តួច និងគំនិតផ្តួចផ្តើមដែលព្រះអង្គនៅសល់ ។ បារាំងបានប្រព្រឹត្តមកលើប្រទេសកម្ពុជា ធ្វើឲ្យគេមើលឃើញក្រោមសេចក្តីសន្និដ្ឋានមួយរបស់អាណាព្យាបាលនូវរបបអាណានិគមផ្តាច់ការដ៏ពិតប្រាកដដោយបានដកហូតពីអាជ្ញាធរកម្ពុជានូវអំណាចទាំងអស់" ។ ("ប្រជាជនខ្មែរ" A.Migot ទំព័រ៣១១) ។

យើងសូមធ្វើសេចក្តីដកស្រង់ខាងក្រោមនេះ នូវនិក្ខេបបទដែលព្រះអង្គម្ចាស់ **"យុគន្ធរ"** ផ្ញើទៅជូនរដ្ឋាភិបាលបារាំង**ដែលអនុញ្ញាតឲ្យវាយតម្លៃបានថា តើនៅក្នុងកាលៈទេសៈ ណាដែលកើតមាននូវការឲ្យសច្ចាប័នលើសន្ធិសញ្ញាទាំងពីរនៃអាណាព្យាបាលឆ្នាំ ១៨៨៤ និងឆ្នាំ១៨៩៧ ។**

***"...ជាការពិតណាស់ថា រដ្ឋាភិបាលបារាំង មិនបានដឹងសោះទេ អំពីសន្ធិសញ្ញាទាំងពីរនេះត្រូវ បានធ្វើឡើងដូចម្តេចនៅក្នុងឆ្នាំ១៨៨៤ និងឆ្នាំ១៨៩៧ ។ សូមកត់សម្គាល់នូវ ដំណាក់កាលសំខាន់ៗស្តីពីការដាក់អំណាចរបស់ព្រះមហាក្សត្រទៅក្នុងដៃរបស់ភ្នាក់ងារអាណាព្យាបាល"... ។***

***"នៅឆ្នាំ១៨៨៤ គឺដោយការធ្វើពលប្រហារលុកលុយព្រះរាជវាំងភ្នំពេញ-កព្រះមហាក្សត្រដោយកាំបិតបំពុះទូង គំរាមកំហែងដកព្រះអង្គ និងនិរទេសព្រះអង្គ ទើបលោក Thompson បានទទួលសន្ធិសញ្ញាដែលព្រះមហាក្សត្របានផ្តល់ឲ្យគាត់នូវអំណាចនយោបាយទាំងអស់នៅប្រទេសកម្ពុជា... ។***

www.elibraryofcambodia.org

**"នៅឆ្នាំ១៨៩៣ គឺដោយសារការគំរាមកំហែង និងដោយការប្រើប្រាស់នូវកម្លាំងទ័ពជើងដែរ, តែលើកនេះមិនសូវឃោរឃៅប៉ុន្មានទេ ។ ប៉ុន្តែ ក៏ក្នុងន័យតែមេត្តាដែរ, ដែល Doumer បានទទួលនូវអ្វីដែលសេសសល់របស់ព្រះមហាក្សត្រ គឺ អំណាចខាងរដ្ឋបាលព្រមជាមួយនិងសិទ្ធិខាងសេដ្ឋកិច្ច និងការកាន់កាប់ទឹកដីរបស់ព្រះរាជាណាចក្រ"... ។**

ចំពោះលោកសាស្ត្រាចារ្យ Marcel Sibert (នៅក្នុងការអធិប្បាយអំពីច្បាប់អន្តរជាតិរបស់ប្រជាជនទំព័រ ១៦៣) បានថ្លែងថា **"តើយកលក្ខខ័ណ្ឌអ្វីដែលអាណាព្យាបាលនេះ បានបញ្ចូលជាឧបសម្ព័ន្ធដោយរបៀបក្លែងបន្លំដូច្នេះ...?" ។**

**ក្រោយពីការដាក់បន្ទុំដោយអាម៉ាស់ចំពោះប្រទេសកម្ពុជានេះ ប្រទេសបារាំងបានខិតខំជាបន្តមកទៀតដើម្បីនាំមកវិញនូវកិត្តិយសរបស់ខ្លួន ។**

**ដោយការប្រើកលល្បិច និងការកៀបសង្កត់ខាងការងារទូតអមដោយការបង្ហាញនូវកម្លាំងទ័ពជើងនោះ, ប្រទេសបារាំងបានទទួលពីប្រទេសសៀមនូវការចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ១៩០២ ដែលនៅក្នុងនោះប្រទេសសៀមបានប្រគល់មកឲ្យបារាំងវិញនូវខេត្តទាំងពីររបស់កម្ពុជា គឺខេត្តម្លូព្រៃ និងទន្លេរពៅ ប៉ុន្តែបានរក្សាទុកខេត្តបាត់ដំបង និងអង្គរ ។**

**តាមរាយការណ៍ជាបន្តមកទៀត "ស្តីពីតម្លៃនៃដង្រួកស្រូវដីជំរេង នៅក្នុងបណ្តាខេត្តដែលបានប្រគល់ឲ្យសៀមនោះ ប្រទេសបារាំងពុំមានមូលហេតុណាមួយសោះ ដែលត្រូវយោគយល់ដល់បាងកក ដែលកំពុងចុះខ្សោយអំណាចយោធានោះ"** (A.Migot) ។

**នៅពេលនោះ បារាំងបានដាក់បន្ទុំដល់ប្រទេសសៀមនៅថ្ងៃទី២៣ ខែមិនាឆ្នាំ១៩០៧ នូវសន្ធិសញ្ញាមួយដែលជាការប្តូរ និងខេត្ត Dan-Sai Kratt និងកោះទាំងឡាយដែលស្ថិតនៅខាងត្បូងជ្រោយ Lam Sing សៀមបានប្រគល់មកឲ្យ**

www.elibraryofcambodia.org

បានាំងនូវខេត្តបាត់ដំបង សៀមរាប និងស៊ីសុផុនវិញ" ។

* ចូរផ្ទៀងស្ដាប់ត្រង់រន្ធសោរ អ្នកនឹងបានឮ
នូវដំណឹងដែលទាក់ទងដល់ខ្លួនអ្នក ។

* រឿងពីពិតប្រាកដនោះ គួរទុកដូចជាបន្ទប់សម្ងាត់ផ្ទាល់ខ្លួន
ប្រើក្នុងកាលមានសេចក្ដីចាំបាច់ ។

* មនុស្សច្រើនណាស់ដែលអត់ធន់ចំពោះគេ ក្ដីទុក្ខលំបាកបាន,
តែមនុស្សតិចណាស់ដែលអត់ធន់ចំពោះការមើលងាយបាន ។

www.elibraryofcambodia.org

# ផ្នែកពីរ

## ប្រទេសកម្ពុជាមិនដែលបោះបង់ចោលនូវសិទ្ធិរបស់ខ្លួននៅលើ ទឹកដី "កម្ពុជាក្រោម" នោះឡើយ ។ ការតវ៉ារបស់ខ្លួនប្រឆាំងការកាន់កាប់ ខុសច្បាប់នូវទឹកដីខ្មែរនេះត្រូវបានធ្វើជាប់ជាប្រចាំ :

ផ្នែកនេះនឹងរំឭកឡើងវិញនូវ :

១- ការជូនដំណឹងជាលាយលក្ខណ៍អក្សររបស់ព្រះករុណា "ព្រះអង្គដួង"

២- ព្រះរាជបេសកកម្មតិតគូររបស់ព្រះករុណា "នរោត្តម"

៣- ដំណើរការតិតគូរ ការតវ៉ា និងការដាក់លក្ខខ័ណ្ឌរបស់ ព្រះរាជាណាចក្រកម្ពុជាចំពោះបញ្ហាកម្ពុជា ចាប់តាំងពីរជ្ជកាល របស់ ព្រះករុណា "នរោត្តម សីហនុ" ។

### ១)- ព្រះករុណា "ព្រះអង្គដួង" បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅប្រទេស បារាំងស្តីអំពីសិទ្ធិលើទឹកដីកម្ពុជាក្រោមនៅមុនពេលដែលបារាំងកាន់ កាប់ដោយខុសច្បាប់លើទឹកដី "កូសាំងស៊ីន" :

យើងបាននិយាយរួចហើយថា ព្រះករុណា "ព្រះអង្គដួង" បានផ្ញើនូវព្រះរាជសារដ៏សំខាន់ពីរច្បាប់ទៅថ្វាយព្រះចៅ "ណាប៉ូឡេអុងទី៣" អធិរាជនៃប្រទេសបារាំង ។

នៅក្នុងព្រះរាជសារទី១ ដែលអមដោយដង្វាយដ៏សំខាន់នោះគឺផ្ញើទៅ នៅខែវិច្ឆិកា ឆ្នាំ១៨៥៣ ។ ព្រះករុណា "ព្រះអង្គដួង" បានបង្ហាញថ្វាយស្តេច "ណាប៉ូឡេអុងទី៣" នូវ មិត្តភាពរបស់ព្រះអង្គ និងស្នើសុំស្តេច "ណាប៉ូឡេអុង" នូវជំនួយឧបត្ថម្ភ និងជំនួយ ដើម្បីការពារព្រះរាជាណាចក្ររបស់ព្រះអង្គ និងលើសពីនេះទៅទៀត គឺដើម្បីយក មកវិញនូវទឹកដីដែលគេបានដកហូតយកពីបុព្វបុរសរបស់ព្រះអង្គ ។

www.elibraryofcambodia.org

ព្រះចៅ "ណាប៉ូឡេអុងទី៣" មិនបានឆ្លើយតបជាមួយព្រះរាជសារនេះទេ ។ នៅក្នុងព្រះរាជសារទី២ ផ្ញើនៅឆ្នាំ១៨៥៦ ព្រះករុណា"ព្រះអង្គដួង" ក្រោយពីព្រះអង្គបានដឹងថា បារាំងបានកាន់កាប់ខេត្តមួយចំនួននៅកូសាំងស៊ីនខាងកើត និងការបរបារកំពុងតែប្រព្រឹត្តិទៅរវាងស្តេច "ទឺ ឌឹក" ប្រទេសអណ្ណាម និងប្រទេសបារាំង ដើម្បីធ្វើអនុប្បទានខេត្តទាំងនេះ ព្រះអង្គបានរាយការណ៍អំពីសិទ្ធិកាន់កាប់ទឹកដីរបស់ "ប្រទេសកម្ពុជា" លើ "កូសាំងស៊ីន" ឲ្យបារាំងដឹង ។

**ព្រះបាទ "អង្គដួង" បានស្នើដល់អធិរាជបារាំងកុំឲ្យទទួលពីស្តេចអណ្ណាម "នូវការផ្តល់ទឹកដីណាមួយដែលត្រូវបានកាត់យកពីប្រទេសខ្មែរនេះ" ។ សេចក្តីនៃព្រះរាជសារនេះមាននៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសថៃ រជ្ជកាលទី៤ ពុទ្ធសករាជ ២៣៩៤ ទៅ ២៤១១ បកប្រែជាភាសាបារាំងនៅក្នុងសៀវភៅ "ព្រះមហាក្សត្រកម្ពុជា" ទំព័រ២ ដែលត្រូវបានបម្លងឡើងវិញនៅខាងក្រោយឆ្ងាយមកទៀត ។**

ព្រះរាជសារនេះត្រូវបានផ្ញើទៅឲ្យអធិរាជបារាំង "ណាប៉ូឡេអុងទី៣" ជាង៧ឆ្នាំនៅមុនការចុះហត្ថលេខា លើសន្ធិសញ្ញាថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៨៦២ ដែលនៅក្នុងនោះ អធិរាជ "ទឺ ឌឹក" បានប្រគល់ទៅឲ្យប្រទេសបារាំងនូវខេត្ត បៀនហ្វា, ឌិនទឿង និង ពូឡូ កុងឌ័រ ។

ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរប្រកបដោយគតិយុត្តិ ស្តីពីសិទ្ធិរបស់ប្រទេសកម្ពុជាទៅលើបណ្តាខេត្តដូចបាននិយាយមកនេះ ព្រះរាជសារលិខិតទាំងនេះបានធ្វើឲ្យក្លាយទៅជាមោឃៈដោយពេញច្បាប់នូវសន្ធិសញ្ញាដែលបានព្រមព្រៀងដោយមិនទទួលស្គាល់នូវសិទ្ធិទាំងនេះ ។ **"ព្រះរាជសារលិខិតរបស់ព្រះករុណាព្រះបាទ សម្តេចព្រះ ហរិរក្សរាមា ឥស្សរាធិបតី ព្រះអង្គដួង ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ថ្វាយព្រះករុណា ណាប៉ូឡេអុងទី៣ អធិរាជនៃប្រទេសបារាំង ។**

www.elibraryofcambodia.org

យើង

ព្រះហរិរក្សរាមា មហាឥស្សរាធិបតី **ព្រះបាទអង្គឌួង** ព្រះមហាក្សត្រនៃប្រទេសកម្ពុជា , សូមសំដែងនូវមិត្តភាពដ៏ស្មោះស្ម័គ្រចំពោះព្រះករុណា អធិរាជណាប៉ូឡេអុងទី៣ អធិរាជនៃប្រទេសបារាំង ។

ដោយមានបំណងដើម្បីបង្ហាញនូវសេចក្តីស្មោះត្រង់របស់ទូលព្រះបង្គំចំពោះព្រះករុណា,

ទូលព្រះបង្គំមានកិត្តិយសសូមថ្វាយព្រះករុណាទ្រង់ជ្រាបថា "ទូលព្រះបង្គំមានហឫទ័យរីករាយចំពោះដំណើរទស្សនកិច្ចដែលបានធ្វើឡើងចំពោះទូលព្រះបង្គំដោយបេសកជនរបស់ព្រះករុណា លោក M.de Montigny ។ ទូលព្រះបង្គំបានបញ្ជាឲ្យមន្ត្រី ថ្នាក់ខ្ពស់របស់ព្រះរាជាណាចក្រកម្ពុជា ៣នាក់ និងមន្ត្រីថ្នាក់បន្ទាប់បន្សំ ១៥នាក់ ទៀតទៅទទួលស្វាគមន៍ លោក M.de Montigny នៅខេត្តកំពតពីព្រោះថា បាប់តាំងពីច្រើនឆ្នាំមកហើយ សាសនទូតបារាំងដែលរស់នៅក្នុងប្រទេសកម្ពុជាបានឲ្យទូលព្រះបង្គំដឹងជាមួយនឹងពាក្យសរសើរជាច្រើនថា អធិរាជបារាំងទ្រង់មានព្រះរាជហឫទ័យអាណិត ករុណាចំពោះប្រជាជាតិទាំងអស់, មិនគ្រាន់តែគិតគូរដល់ផលប្រយោជន៍របស់រដ្ឋវាសី (ជនដែលរស់នៅក្នុងរដ្ឋ) ប៉ុណ្ណោះទេ ព្រះអង្គថែមទាំងការពារដើម្បីធានានូវភាពសុខសាន្ត និងសុខុមាលភាពរបស់ពួកគេថែមទៀតផង ។ ទើបពេលក្រោយមក ព្រះចៅអធិរាជបារាំងគឺជាព្រះមហាក្សត្រដ៏ល្អ និងមិនមានបំណងដូចមហាក្សត្រផ្សេងៗទៀតនៅអឺរ៉ុប ដែលតែងតែស្វែងរកការធ្វើអាជីវកម្ម លើប្រទេសដទៃទៀតនោះទេ ។ ដោយហេតុនេះ ទូលព្រះបង្គំមានហឫទ័យរីករាយខ្លាំងណាស់ ដើម្បីសម្រេចជាមួយព្រះចៅអធិរាជបារាំងនូវសម្ព័ន្ធភាពដ៏ស្ថិតស្ថេរមួយទៅនឹងប្រទេសដ៏ធំ និង មានមួយនេះនូវគុណប្រយោជន៍សម្រាប់ប្រជាជន" ។

www.elibraryofcambodia.org

ដោយហេតុនេះ បានជាទូលព្រះបង្គំ បានឲ្យអ្នកកាន់សាសនា Ridré aviré-madâktâ Miche Posdansera ទទួលបន្ទុកសរសេរនូវលិខិតមួយនេះ ដើម្បីបង្ហាញនូវមិត្តភាពរបស់យើង និងថ្វាយដល់ព្រះករុណាព្រះចៅអធិរាជបារាំងនូវដំរីការពារ ៤ក្បាល ស្នែងរមាស២ ថ្នាំគូរគំនូរពណ៌លឿងចំនួន ៥០ Piculs, ស្ករ ៥ Piculs, ម្រេច ៤ Piculs ។ **(លិខិតនេះបានស្ថិតនៅអស់រយៈពេលជាច្រើនឆ្នាំដោយគ្មានការឆ្លើយតប)** ។ (សេចក្តីព្រះរាជសារលិខិតទី២)... ឥឡូវនេះទូលព្រះបង្គំបានថ្វាយដល់ព្រះអង្គនូវសំពត់ និងដំរីការពារចំនួន ៤ក្បាលដែលជាដង្វាយដ៏ស្តួចស្តើងដែលមានគោលបំណងតែមួយគត់ដើម្បីឲ្យព្រះអង្គបានដឹងអំពីហឫទ័យទូលព្រះបង្គំ ។ តាមការពិត នៅក្នុង ពេលនេះ លោក M. de Montigny ដែលត្រូវអញ្ជើញទៅពិភាក្សាជាមួយអណ្ណាម បន្ទាប់មកលោកបានធ្វើដំណើរហូតទៅដល់ប្រទេសចិនទៀតនោះ គឺមិនអាចចូលទៅប្រទេសបារាំងបានឡើយ ។ ដោយហេតុនេះហើយទូលព្រះបង្គំផ្ញើថ្វាយព្រះអង្គនូវដង្វាយបន្តិចបន្តួចនេះ គឺគ្រាន់តែដើម្បីបង្ហាញនូវមិត្តភាពរបស់ទូលព្រះបង្គំ ហើយព្រមជាមួយនេះទូលព្រះបង្គំក៏សូមថ្វាយដល់ព្រះករុណា ព្រះចៅអធិរាជបារាំងទ្រង់ ជ្រាបដូចតទៅនេះ :

"កាលពីមុនប្រទេសកម្ពុជា គឺជាប្រទេសដ៏ធំទូលាយមួយដែលមានខេត្តធំៗ ។ ក្រោយមកពួកអណ្ណាមដែលជាមនុស្សអសុទ្ធចិត្ត ដែលបានធ្វើសម្ព័ន្ធមិត្តជាមួយប្រទេសកម្ពុជានោះ បានស្វែងរកការផ្តាច់ចេញពីប្រទេសកម្ពុជាជួនកាលស្រុកមួយជួនកាលស្រុកពីរ ។ នៅក្នុងកំឡុងនៃការបះបោររបស់ពួក តីសឺន (TAY SON) ស្តេចយ៉ាឡុង ទ្រង់យាងគេចចេញពីព្រះរាជាណាចក្ររបស់ព្រះអង្គមកសុំការជួយសង្គ្រោះពីព្រះរាជាណាចក្រក្រុងទេព (សៀម), ពេលនោះស្តេចអណ្ណាមបានជួបព្រះបិតាជាទីគោរពរបស់ទូលព្រះបង្គំ ដែលពេលនោះព្រះអង្គជាព្រះមហាក្សត្ររបស់ប្រទេសកម្ពុជា ដែលព្រះអង្គទទួលបាននូវសម្ព័ន្ធភាព ។

www.elibraryofcambodia.org

ក្រោយពីភៀសព្រះកាយមកនៅក្រុងទេព និងក្រោយមកបានមកគង់នៅស្រុកព្រះត្រពាំង (ត្រា វិញ) ដែលជាទឹកដីរបស់កម្ពុជា, ទឹកន្លែងដែលព្រះអង្គបានរៀបចំកងទ័ពដើម្បីប្រយុទ្ធប្រឆាំងពួកតីសឺន ព្រះករុណា ព្រះបិតាជាទីគោរពរបស់ទូលព្រះបង្គំបានបញ្ជូនកងទ័ពទៅជួយព្រះអង្គរហូតដល់ព្រះអង្គទទួលបានជ័យជំនះលើពួក តីសឺន ហើយត្រូវបានឡើងសោយរាជ្យនៅអណ្ណាម ។ ដោយទ្រង់វាយតម្លៃថា ស្រុកព្រះត្រពាំងគឺជាអ្នកធ្វើគុណចំពោះព្រះអង្គ ស្តេច យ៉ា ឡុង បានស្នើសុំដល់ព្រះបិតាជាទីគោរពរបស់ទូលព្រះបង្គំឲ្យស្រុកនេះរួចខ្លួនពីការនាំសួយសារអាករ (ទៅប្រទេសកម្ពុជា) និងកុំប្រើអ្នកស្រុកនេះឲ្យធ្វើការ ។ ព្រះករុណាព្រះបិតារបស់ទូលព្រះបង្គំបានចាត់ទុកថា នេះគឺជាអំពើអាណិតអាសូរមួយចំពោះសម្ព័ន្ធមិត្តនោះ ក៏ទ្រង់យល់ព្រមចំពោះការស្នើនេះ និងមិនបានដាក់អ្នកស្រុកនេះឲ្យស្ថិតនៅក្រោមកំណែនណាមួយឡើយ ។ យូរក្រោយមកស្តេច យ៉ា ឡុង បានធ្វើឲ្យស្រុកនោះក្លាយទៅជាអាណានិគមមួយរបស់អណ្ណាមរហូតដល់រជ្ជកាលព្រះរាមរបស់ទូលព្រះបង្គំ ដែលព្រះអង្គបានបែរទៅរកអធិរាជ យ៉ា ឡុង ដើម្បីស្នើសុំឲ្យអធិរាជ យ៉ា ឡុង គាំទ្រព្រះអង្គ ។ ចំណែកទូលព្រះបង្គំ ក៏បានយាងទៅព្រះរាជាណាចក្រក្រុងទេព ។ ព្រះរាជបុត្ររបស់ព្រះចៅ យ៉ា ឡុង ព្រះនាម មិញ ម៉ាង បានឡើងសោយរាជ្យ និងបានបញ្ជាឲ្យគេជីកព្រែកមួយកាត់ ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីពាមរហូត ដល់ចូវដុកដើម្បីរៀបចំដាក់មន្ត្រី និង ប្រជាជនអណ្ណាម ។ នៅពេលសោយទិវង្គត ព្រះបិតាជាទីគោរពរបស់ទូលព្រះបង្គំ បានបន្សល់ទុកព្រះរាជបុត្រីមួយព្រះអង្គ (មហេសីទី១) ។

អធិរាជ មិញ ម៉ាង ក្នុងការចាត់វិធានការបង្ក្រាប បានបញ្ជាឲ្យនាំខ្លួនព្រះរាជបុត្រីរបស់ព្រះរាមជាទីគោរពរបស់ទូលព្រះបង្គំ ព្រះមាតារបស់ទូលព្រះបង្គំ ព្រះរាជបុត្រផ្ទាល់របស់ទូលព្រះបង្គំ និងបានឲ្យគេធ្វើគតព្រះរាជបុត្រីមួយអង្គរបស់ព្រះ

www.elibraryofcambodia.org

រៀមជាទីគោរពរបស់ទូលព្រះបង្គំ ព្រមទាំងបានបញ្ជាឲ្យមន្ត្រីធំៗ និងអ្នកស្រុកនៃប្រទេសកម្ពុជាឲ្យទៅរស់នៅទីឆ្ងាយ អ្នកខ្លះនៅលើកោះ និងអ្នកខ្លះទៀតទៅដាយដែនគុងកឹង នៅជិតប្រទេសចិន ។ ប្រជាជនកម្ពុជា បានដឹងអំពីបំណងអាក្រក់របស់អធិរាជអណ្ណាម បានងើបបះបោរ និងបានសម្លាប់វគ្គាលប្រជាជនអណ្ណាម ។ ពួកគេបានស្នើសុំឲ្យទូលព្រះបង្គំយាងចេញពីព្រះរាជាណាចក្រក្រុងទេព ដើម្បីសោយរាជ្យ (នៅប្រទេសកម្ពុជា) ។ ព្រះមហាក្សត្រព្រះបាទសាងខ្លែ រចៅយូហួរ ប៉ានបញ្ជាឲ្យ "ចៅពញា បូឌីន តេជះ" ដែលជាឧត្តមសេនីយកងទ័ពម្នាក់ដើម្បីដឹកនាំកងទ័ពដែលមានទាហានជាង ៥ពាន់នាក់ ជាមួយកាំភ្លើងធំ កាំភ្លើងតូច អាវុធ គ្រាប់រំសេវក្រណាត់ របស់របរ ប្រាក់កាស មាស គឺជាទ្រព្យដ៏ច្រើនសម្បើម មកពីឃ្លាំងរបស់ស្តេចដើម្បីជួយទូលព្រះបង្គំក្នុងការប្រយុទ្ធប្រឆាំងជាមួយពួកអណ្ណាម ។ សង្គ្រាមបានប្រព្រឹត្តទៅប្រហែល ១៨ឆ្នាំ នៅប្រទេសកម្ពុជា ។ អធិរាជអណ្ណាម បានស្នើចងសម្ព័ន្ធភាពជាមួយទូលព្រះបង្គំ ដោយយល់ព្រមឲ្យធ្វើមាតុភូមិនិវត្តន៍នៃព្រះមាតាជាទីគោរពរបស់ទូលព្រះបង្គំ ព្រះរាជបុត្រ របស់ទូលព្រះបង្គំព្រះរាជបុត្ររបស់ព្រះរៀមជាទីគោរពរបស់ទូលព្រះបង្គំ និងនាហ្មឺន មន្ត្រីទាំងអស់ក៏ដូចជាប្រជាជនកម្ពុជាដែលត្រូវបានគេ និរទេសឲ្យទៅរស់នៅលើកោះ និងស្រុកផ្សេងៗ ។ ស្តេចអណ្ណាមបានទទួលស្គាល់ព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងបានធ្វើអំណោយនូវត្រាអណ្ណាមពីរ មួយធំមួយតូច ដល់ទូលព្រះបង្គំ និង បានសន្យាប្រគល់មកឲ្យស្រុកខ្មែរវិញនូវទឹកដីកម្ពុជាទាំងអស់ដែលពួកអណ្ណាមបានដណ្តើមយក ។ ឧត្តមសេនីយ "ចៅពញា បូឌីន តេជះ" បានទូលប្រាប់ ទូលព្រះបង្គំថា ព្រះអង្គ បានព្រមព្រៀងទទួលយកសន្តិភាព ពីព្រោះថា ទូលព្រះបង្គំបានទទួលមកវិញនូវព្រះមាតាជាទីគោរពរបស់ទូលព្រះបង្គំនៅចុល្លសករាជ ១២០៩ ឆ្នាំមមែ ទសវត្សរ៍ទី៩ ។

បន្ទាប់ពោះ មិនគ្រាន់តែទឹកដីដែលអណ្ណាមបានសន្យាប្រគល់មកឲ្យ (ប្រទេស

www.elibraryofcambodia.org

កម្ពុជា) ហើយមិនត្រូវបានប្រគល់ឲ្យប៉ុណ្ណោះទេ, ប៉ុន្តែយើងបែរជាបានទទួលនូវការហាមឃាត់មិនឲ្យទទួលនូវសួយសារអាករពីរដី នៅក្នុងចំណុះ និងប្រជារាស្ត្រកម្ពុជា ដែលបានកសាងនាវាធ្វើពាណិជ្ជកម្មជាមួយបរទេសនោះមិនត្រូវបានអនុញ្ញាតឲ្យធ្វើឡើយ ។

បញ្ហាដែលកើតមាននៅប្រទេសកម្ពុជានេះ ព្រះករុណាអធិរាជបារាំងត្រូវព្រះតម្រិះអំពីការបង្កើតការត្រួតត្រារបស់អណ្ណាម ដោយគ្រាន់តែការកាន់កាប់របៀបយ៉ាងសុខសាន្ត ២០០ឆ្នាំមកហើយ ។ ស្រុកដែលពួកអណ្ណាមយកធ្វើជារបស់ខ្លួននៅពេលក្រោយមកគឺ សេកុង លង់ហោរ សាដែក ស្មីធំ បូរដុក ក្រមួនស អូម៉ុនទឹកខ្មៅ ស្រុកពាម និងកោះត្រល់ កោះត្រឡាច ។ អំណោះតទៅប្រសិនបើពួកអណ្ណាមប្រគល់ឲ្យអធិរាជបារាំងនូវទឹកដីទាំងនេះ និងទឹកដីផ្សេងៗទៀតនោះ ទូលព្រះបង្គំសូមអង្វរព្រះករុណា អធិរាជបារាំងសូមមេត្តាកុំព្រមទទួលឲ្យសោះ ពីព្រោះថាទេសភូមិនេះ គឺពិតជាទឹកដីរបស់កម្ពុជា ។ ផ្នែកដែលចេញពីត្រើយខាងលិចនៃទន្លេសេកុង រហូតដល់ពាម (ហាទៀន) ដោយរួមទាំងកោះពីរផងនោះ ត្រូវតែស្ថិតនៅជារបស់កម្ពុជាដូចពេលមុន ។ ចំណែកតំបន់ដែលស្ថិតនៅលើត្រើយខាងកើតនៃទន្លេសេកុង ដែលពួកអណ្ណាម បានកាន់កាប់ចាប់តាំងពីយូរមកហើយ ទូលព្រះបង្គំ មិនតវ៉ាទាមទារទេ ។

មូលហេតុដែលទូលព្រះបង្គំយកបញ្ហាទាំងនោះ ទូលថ្វាយព្រះករុណា អធិរាជបារាំងដើម្បីទ្រង់ជ្រាប់ដ៏ខ្ពង់ខ្ពស់នោះ គឺព្រោះតែទូលព្រះបង្គំ មិនចង់ដោយសារតែទ្រព្យសម្បត្តិរបស់យើង ហើយត្រូវឲ្យយើងទទួលឈឺចាប់ថែមទៀតនោះទេ ។ ដូច្នេះព្រះករុណា អធិរាជបារាំង និងទទួលបាននូវព្រះកិត្តិនាមល្បីល្បាញដ៏ពិតប្រាកដថាជាមហាក្សត្រដែលមានទឹកព្រះទ័យទូលាយ និងដែលបានធ្វើការដើម្បីផលប្រយោជន៍របស់ប្រទេសផ្សេងៗទៀត ហើយប្រជាជនកម្ពុជា និងប្រជាជនបារាំង

www.elibraryofcambodia.org

និងស្រលាញ់គ្នា ហើយនឹងរក្សាឲ្យបានស្ថិតស្ថេរនូវទំនាក់ទំនងដ៏ល្អរបស់ប្រទេសទាំងពីរ ។

ធ្វើនៅព្រះបរមរាជវាំងឧដុង្គ និងប្រថាប់ត្រានៅថ្ងៃអង្គារ ខែកត្តិក ថ្ងៃទី១៣រោជ ចុល្លសករាជ ១២១៥ ឆ្នាំរោង ទសវត្សរ៍ទី៨ ។

ផ្ញើទៅសាំងកាប៉ូ (សឹង្ហបុរី)

ព្រះករុណាទ្រង់ឡាយ ព្រះហស្ថលេខា អង្គដួង

គោលបំណងសំខាន់នៃព្រះរាជសារលិខិតនេះ គឺការសម្រេចចុងក្រោយ ដែលទាក់ទងទៅនឹងបញ្ហាកូសាំងស៊ីន ដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងព្រះរាជសារលិខិតនេះ ។ បន្ទាប់ពីពាក្យពេចន៍គួរសមដែលជាទំនៀមទម្លាប់រវាងព្រះមហាក្សត្រមក **"ព្រះបាទអង្គដួង"** បានសំដែងនូវព្រះទ័យទុកចិត្តចំពោះអធិរាជបារាំង **"ដែលជាមហាក្សត្រល្អ"** ក្នុងពេលដែលមហាក្សត្រផ្សេងៗទៀតនៅអឺរ៉ុបតែងតែស្វែងរកការធ្វើអាជីវកម្មទៅលើបរទេសដទៃឯទៀតនោះ ។

ទោះបីជាការសោយទីវង្គតទៅហើយនេះក៏ដោយ ក៏គេបានឃើញជំហរព្រះករុណា **"ព្រះអង្គដួង"** រក្សានូវព្រះតម្រិះរបស់ព្រះអង្គនូវជំនឿរបស់ព្រះអង្គទៅលើ អធិរាជបារាំង ដែរ ហើយមិនមានពេលណាដែលធ្វើឲ្យខកព្រះទ័យនោះឡើយ ។

កថាខ័ណ្ឌទី២ នៃព្រះរាជសារលិខិតទី២នេះ បានរំលឹកខ្លឹមសាររបស់ព្រះរាជសារលិខិតទី១ និងបានរៀបរាប់អំពីដង្វាយដែលបានថ្វាយដល់អធិរាជបារាំង និងសេចក្តីបញ្ចប់នៃព្រះរាជសារនេះថា **"ហើយនៅក្នុងពេលជាមួយគ្នានេះ ខ្ញុំព្រះបង្គំសូមខ្ញុំថ្វាយព្រះករុណាអធិរាជបារាំងទ្រង់ជ្រាបជូនតទៅនេះ"** ដែលជាផ្នែកសំខាន់នៃលិខិតនេះ ។

ដូច្នេះកថាខ័ណ្ឌទី២ ដំបូង គឺជាផ្នែកនៃសេចក្តីផ្តើម ចំណែកកថា ខ័ណ្ឌ៦ផ្សេង

www.elibraryofcambodia.org

ទៀត គឺចាត់ទុកជាខ្លឹមសារសំខាន់នៃព្រះរាជសារ ។

គេអាចសង្ខេប កថា ខ័ណ្ឌទាំង៦ នេះដូចតទៅ...

**១**- ប្រទេសខ្មែរដីធំទូលាយត្រូវបានកាត់យកគ្មានឈប់ឈរ ដោយពួកអណ្ណាម ជួនកាលមួយស្រុកជួនកាល ២ស្រុក...

**២**- ព្រះមហាក្សត្រខ្មែរបានជួយស្តេច **"យ៉ាឡុង"** បង្ក្រាបអំពើបះបោររបស់ពួកតីសឺន ហើយទីបំផុតស្តេច **"យ៉ាឡុង"** នេះដោយគំនិតទុច្ចរិតបានឆ្លៀតឱកាសដណ្តើមយកខេត្តពីរ គឺ "ព្រះត្រពាំង និង ពាម " ...

**៣**- ប្រជាជនកម្ពុជាបានងើបបះបោរប្រឆាំងពួកអណ្ណាមដែលជាអ្នកជិះជាន់សង្កត់សង្កិន ហើយក្រោយពីសង្គ្រាម ១៨ឆ្នាំ ព្រះមហាក្សត្រកម្ពុជា អាចទាមទារពីស្តេចអណ្ណាមនូវ :

**ក**-ការដោះលែងព្រះរាជវង្សានុវង្សទាំងអស់ និងមន្ត្រីខ្មែរដែលចាប់ឃុំឃាំងដោយពួកអណ្ណាម....

**ខ**-ការយល់ព្រមទទួលយកសន្តិភាពដើម្បីបញ្ចប់សង្គ្រាម ១៨ឆ្នាំនេះ....

**គ**-ការសន្យាពីស្តេចអណ្ណាមដើម្បីផ្តល់ឲ្យស្រុកខ្មែរនូវទឹកដីកម្ពុជាទាំងអស់ ដែលពួកអណ្ណាមបានដណ្តើមយក....

**៤**- ថ្វីបើមានការសន្យាក៏ដោយ ក៏អណ្ណាម មិនបានផ្តល់នូវទឹកដីទាំងនេះឡើយ ហើយលើសពីនេះទៀត ពួកគេបានរារាំងប្រជាជននៅទឹកដីទាំងនេះមិនឲ្យនាំសួយសារអាករមកថ្វាយព្រះមហាក្សត្រខ្មែរថែមទៀត....

ព្រះមហាក្សត្រខ្មែរបានលើកឡើងនៅក្នុងកថាខ័ណ្ឌទាំងនោះថា នៅក្នុងពេល ដែលបារាំងបានមកដល់ ជ័យជំនះរបស់ប្រទេសកម្ពុជាគឺមានច្រើនក្រៃលែង ។ ក្រោយពី ១៨ឆ្នាំនៃសង្គ្រាម ពួកអណ្ណាមបានបង្អោនខ្លួននៅចំពោះមុខព្រះមហាក្សត្រខ្មែរ ដើម្បីស្នើសុំសន្តិភាពពីព្រះអង្គ ដោយសន្យាផ្តល់ឲ្យប្រទេសកម្ពុជា នូវខេត្ត

www.elibraryofcambodia.org

របស់កូសាំងស៊ីនទាំងអស់ដែលពួកគេបានដណ្តើមយក....

**៥–** នៅមុនកថាខ័ណ្ឌចុងក្រោយគេចាត់ទុកជាសេចក្តីសម្រេចនៅទីបញ្ចប់នៃព្រះរាជសារ....

ក្រោយពីបានរាយការណ៍ដូច្នេះថ្វាយអធិរាជ "ណាប៉ូឡេអុងទី៣" អំពីការគស៊ូរបស់ព្រះអង្គជាមួយអណ្ណាម និងការមកដល់ ការទទួលស្គាល់កំហុស និងការកែខ្លួនរបស់អណ្ណាម នេះមក, ព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានឲ្យដំណឹងជាលាយ-លក្ខណ៍អក្សរទៅប្រទេសបារាំងអំពីសិទ្ធិកាន់កាប់ទឹកដីរបស់ព្រះរាជាណាចក្រខ្មែរនៅលើខេត្តទាំងឡាយដូចខាងក្រោមនេះ

១– ខេត្ត សេកុង

២– ខេត្ត លង់ហោរ (ឬ វិញឡុង)

៣– ខេត្ត សាដែក (អតីតខេត្ត អាងយ៉ាង ឬខ្មែរហៅផ្សារដែក)

៤– ខេត្ត ស្មីធូរ (ឬមិថ)—>(មេ-ស)

៥– ខេត្ត ចូវដុក (ឬខ្មែរហៅថា មាត់ជ្រូក)

៦– ខេត្ត ក្រមួន ស (រ៉ាច់យ៉ា)

៧– ខេត្ត អូមុំន (ស្រុក កូវធ្វីង)

៨– ខេត្ត ទឹកខ្មៅ (កាម៉ៅ)

៩– ខេត្ត ពាម (ហាទៀន)

១០ – កោះ ត្រល់ (ភូកុក)

១១ – កោះ ត្រឡាច (ពូឡូកុងឌ័រ)

ព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់ថា "ផ្នែកដែលចេញពីត្រើយខាងលិចទន្លេសេកុងរហូតដល់ពាម (ហាទៀន) ដោយរួមទាំងកោះទាំងពីរជងនោះ ត្រូវតែស្ថិតនៅជារបស់កម្ពុជាដូចពីដើម" ។

www.elibraryofcambodia.org

នៅទីបញ្ចប់ព្រះអង្គទទួលស្គាល់ថា ត្រើយខាងកើតនៃទន្លេសេកុង និងស្រុកដូនណៃ បានក្លាយទៅជារបស់អណ្ណាម ដោយសារតែការកាន់កាប់ដោយសន្តិភាពតែប៉ុណ្ណោះ" ។ ដូច្នេះព្រះអង្គមិនបានទាមទារអធិបតេយ្យភាពប្រទេសកម្ពុជានៅលើទឹកដីទាំងនេះដែលត្រូវបានបោះបង់ឲ្យវៀតណាមដោយស្ងៀមស្ងាត់នោះទេ ។ ផ្ទុយទៅវិញព្រះអង្គបានទាមទារខេត្តផ្សេងៗទៀតដែលខ្មែរយើងបានរស់នៅ និងប្រយុទ្ធជាប់ជាប្រចាំ ប្រឆាំងនឹងការជ្រៀតចូលរបស់ពួកអណ្ណាម....

៦– នៅក្នុងកថាខ័ណ្ឌចុងក្រោយ ព្រះមហាក្សត្របានបញ្ជាប់ថា ព្រះអង្គបានផ្ញើឲ្យអធិរាជបារាំងជ្រាបនូវអ្វីៗដែលមានពីមុន ដើម្បីកុំឲ្យប្រជាជនកម្ពុជាមានការខកចិត្តនៅក្នុងសិទ្ធិរបស់ខ្លួន និងថាបារាំងបានរក្សានូវកេរ្តិ៍ឈ្មោះរបស់ខ្លួនជា ប្រជាជាតិមួយដែលមានចិត្តមេត្តា និងចិត្តល្អទូលាយធ្វើការដើម្បីផលប្រយោជន៍ប្រជារាស្ត្រដទៃ....

ទោះបីជាមានការតវ៉ារបស់"ព្រះអង្គដួង"ក្តី និងទោះបីជាព្រះអង្គបានធ្វើការសន្យាដោយផ្ទាល់ក្តី ក៏ប្រទេសបារាំងបានដណ្តើមយក"កូសាំងស៊ីន"ទាំងអស់ **"ហើយបន្ទាប់ពីវៀតណាម បារាំងបានរំលោភអធិបតេយ្យភាពប្រទេសកម្ពុជានៅលើទឹកដីនេះ" ។**

## II. ការគិតគូររបស់ព្រះករុណា "នរោត្តម" និងព្រះអង្គម្ចាស់ "យុគន្ធរ"

ក្រោយពីព្រះមហាក្សត្រ"អង្គដួង"សោយទិវង្គតបន្តិចមក (ព្រះអង្គសុគតនៅឆ្នាំ ១៨៦០) ប្រទេសបារាំងមិនបានយកចិត្តទុកដាក់គិតគូរបន្តិចសោះ ចំពោះព្រះរាជសាររបស់"ព្រះសពព្រះករុណាអង្គដួង" ដែលបានផ្ញើទៅថ្វាយអធិរាជបារាំងនៅក្នុងឆ្នាំ១៨៥៦ ដែលបានសំដែងនូវព្រះរាជបំណងដើម្បីទាមទារយកខេត្តនៅកម្ពុជាក្រោមមកវិញ ។ យើងបាននិយាយហើយថា នៅខែមិនា ១៨៦១ ឧត្តមនាវី

www.elibraryofcambodia.org

Charner ដែលបានមកតាំងនៅសាយហ្គនជាថ្មី បានទូលថ្វាយនូវបំណង់ទាំងនេះ ចំពោះព្រះករុណា "ព្រះ នរោត្តម" ។

ឆ្នាំបន្ទាប់មកទៀត នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៨៦២ សន្ធិសញ្ញាបារាំង-អណ្ណាម ស្តីអំពីការប្រគល់ខេត្ត បៀនហ្វា និងខេត្ត ឌិញទឿង ព្រមទាំងកោះ ពូឡូកុងឌ័រទៅឲ្យ បារាំងនោះ ត្រូវបានចុះហត្ថលេខា ។

នៅឆ្នាំ១៨៦៣ ព្រះករុណា "នរោត្តម" ទ្រង់ឡាយព្រះហស្តលេខាបង្កើតអាណា ព្យាបាលបារាំងនៅលើប្រទេសកម្ពុជា ។ ដោយសារកម្លាំងនៃអនុសញ្ញានេះ ព្រះអង្គ បានយាងទៅសាយហ្គនទៅឆ្នាំ១៨៦៤ អមព្រះរាជដំណើរដោយលោកអនុនាវីឯក Doudart de Lagrée ដែលនៅអមឧត្តមនាវី de Lagrandière ។

ថ្វីបើកាលប្រវត្តិមិនបានលាតត្រដាងអំពីកម្មវត្ថុនៃព្រះរាជដំណើរទស្សនកិច្ច ទៅជួបឧត្តមនាវី បារាំងនេះក៏ដោយ ក៏គោលបំណងនៃព្រះរាជដំណើររបស់ព្រះ ករុណា "នរោត្តម" គឺច្បាកដជាដើម្បីទទួលបានពីប្រទេសបារាំងនូវការសងសឹក ប្រទេសកម្ពុជាវិញ គឺខេត្ត៣ ដែលអធិរាជ ទឺ ឌឹក បានល្បួងឲ្យឡាយព្រះហស្តលេខា លើសន្ធិសញ្ញាឆ្នាំ១៨៦៣ ។ ខេត្តទាំង៣នេះ រួមមាន :

១- ខេត្ត វិញឡុង (វិញឡុង សាដែក ត្រាវិញ ស្រុកត្រាំង)

២- ចូវដុក (ចូវដុក ឡុងស្បៀង កិនថី)

៣- ហាទៀន (ហាទៀន រ៉ាច់យ៉ា និង បាក់លីវ)

ដែលត្រូវបានរំដោះចេញដោយព្រះករុណា "អង្គដួង" ពីការឈ្លានពានរបស់ អណ្ណាម (សូមមើលពីខាងដើម) ខេត្តទាំង៣នេះ ត្រូវតែស្ថិតនៅជារបស់ខ្មែរ ហើយ ប្រទេសបារាំងមិនត្រូវចាត់ទុកដូចជាអាណានិគមបារាំងនោះឡើយ, ហើយកិច្ច ព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយអធិរាជ ទឺ ឌឹក ដោយគ្មានការយល់ព្រមពី ប្រទេសកម្ពុជានោះ គឺទុកដូចជាគ្មានតម្លៃឡើយ ។

www.elibraryofcambodia.org

ព្រះករុណា "នរោត្តម" ព្រះអង្គទទួលបាននូវការសន្យាមួយចំពោះបញ្ហានេះ ("ព្រះមហាក្សត្រកម្ពុជា" ទំព័រ២) ព្រះអង្គបានយាងចូលប្រទេសកម្ពុជាវិញនៅខែតុលា ឆ្នាំ១៨៦៤ ដោយមានព្រះទ័យជឿជាក់ថា នឹងមានការប្រគល់ឲ្យមាតុភូមិកម្ពុជា នៅពេលខាងមុខនូវខេត្តទាំង៣នោះ ។

ប៉ុន្តែនៅឆ្នាំ១៨៦៧ "ការបះបោររបស់ប្រជាជនកម្ពុជា ដើម្បីទាមទារឯករាជ្យកូសាំងស៊ីន ដែលគាំទ្រដោយព្រះរាជវាំងវ៉េ បាននាំឲ្យបារាំងកាន់កាប់នូវខេត្តទាំង៣នេះ ហើយនិងបានធ្វើឲ្យដាកចេញនូវការសន្យាដែលបារាំងបានធ្វើតាមសំឡេងរបស់ឧត្តមនាវី de Lagrandière ចំពោះព្រះករុណា "នរោត្តម" និងបានធ្វើគ ធ្វើថ្លង់ ចំពោះការតវ៉ាដ៏ឃើចាប់របស់"ព្រះករុណា នរោត្តម" ("ព្រះមហាក្សត្រកម្ពុជា" ទំព័រ ២) ។ ដូច្នេះការកាន់កាប់ខេត្តទាំងនេះ ដោយបារាំង គឺជាការរំលោភ ដ៏ខ្លាំងក្លានិង ដោយចេតនាទៅលើអធិបតេយ្យភាព បូរណភាពទឹកដីនៃប្រទេសកម្ពុជា ។

ព្រះករុណា "ព្រះ នរោត្តម" ក្រោយពីព្រះរាជបេសកកម្មគិតគូរដោយផ្ទាល់ព្រះអង្គនោះមក ទ្រង់បានបញ្ជូនព្រះរាជបុត្ររបស់ព្រះអង្គ ព្រះនាម "យុគន្ធរ" ឲ្យទៅប្រទេសបារាំង ដើម្បីធ្វើការតវ៉ា ប្រឆាំង និងការរំលោភរបស់របបដែលក្លែងខ្លួន ធ្វើជាអ្នកអាណាព្យាបាលផង, ហើយតវ៉ាប្រឆាំង និងការដាក់បញ្ចូល ជាឧបសម្ព័ន្ធទៅប្រទេសបារាំងនូវខេត្តខ្មែរទាំងឡាយទៅកូសាំងស៊ីន ។

នៅក្នុងនិក្ខេបបទរបស់ព្រះអង្គដែលបានជូនទៅរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ព្រះអង្គម្ចាស់ "យុគន្ធរ" ដោយរំលឹកអំពីកាលៈទេសៈនៃសន្ធិសញ្ញាឆ្នាំ១៨៨៤ និងឆ្នាំ១៨៩៧នោះ បានតវ៉ាយ៉ាងខ្លាំងក្លាប្រឆាំងនឹងការរំលោភអំណាចរបស់អាណានិគម :

"...M.Doumer បានអញ្ជើញមក និងសង្គ្រោះព្រះមហាក្សត្រ... ដោយប្រើសេចក្តីបង្គាប់ឆ្នាំ១៨៩៧, បានធ្វើឲ្យព្រះមហាក្សត្រ និងប្រជារាស្ត្រខ្មែរស្ថិតនៅក្នុង

www.elibraryofcambodia.org

ដៃរបស់វៀតណាមដ៏ជាន់ខ្ពស់ ដោយពុំមានការធានាណាមួយឡើយ, ហើយបណ្តោយឲ្យពួកគេ (ខ្មែរ) ទទួលរងឈឺចាប់ និងត្អូញត្អែរមកដល់សព្វថ្ងៃនេះ" ។

ការធ្វើតាមអំណាចចិត្តរបស់ប្រជាជាតិជាអ្នកការពារនេះ ក៏បានសំដែងចេញផងដែរចំពោះប្រជាជននៅកូសាំងស៊ីន ដែលពួកបារាំងបានបន្តកាន់កាប់រហូតដល់ឆ្នាំ១៩៥៤ ហើយពួកគេបានចាកចេញទៅ ។ ព្រះមហាក្សត្រ "នរោត្តម" និងមហាក្សត្រដែលស្នងរាជ្យបន្តអំពីព្រះអង្គ បានតវ៉ាដោយទទួលបានការប្រឆាំង និងការប៉ះពាល់ដល់អធិបតេយ្យភាពនៃប្រទេសកម្ពុជានៅលើទឹកដីនេះ ។

## III. ការតវ៉ា និងលក្ខខ័ណ្ឌរបស់ប្រទេសកម្ពុជា នៅក្នុងរជ្ជកាលរបស់ព្រះករុណា "នរោត្តម សីហនុ" និងនៅក្នុងឱកាសនៃឯករាជ្យជាតិ

ភាពជាក់លាក់ អំពីការតវ៉ារបស់ប្រទេសកម្ពុជាចំពោះការកាន់កាប់ "កម្ពុជាក្រោម" ដោយបារាំងបានបន្តធ្វើពីរជ្ជកាល "ព្រះបាទ នរោត្តម" មកដល់រជ្ជកាលព្រះករុណា "នរោត្តម សីហនុ" ។ ព្រះមហាក្សត្រខ្មែរ មិនបានភ្លេចទាល់តែសោះអំពីកាលៈទេសៈដែលបានបណ្តាលឲ្យកើតមានកូសាំងស៊ីន បារាំង និងកាលៈទេសៈដែលបានអនុញ្ញាតឲ្យបង្កើតអាណាព្យាបាលនៅលើទឹកដីកម្ពុជា ។ ព្រះអង្គអាចដឹងនិងរំឭកឡើងវិញក្នុងពេលដែលឱកាសទាំងឡាយបានលេចឡើង បង្ហាញនោះ ។

ព្រឹត្តិការណ៍ទាំងឡាយដែលបានបន្តពីការផ្ទុះឡើងនូវសង្គ្រាមលោកលើកទី២ បានធ្វើឲ្យព្រះករុណា "នរោត្តម សីហនុ" ធ្វើការអះអាងឡើងវិញ ជាមួយនិងកម្លាំងថ្មី នៃអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាលើទឹកដីកម្ពុជាក្រោម ។

**១– នៅក្រោមការកាន់កាប់របស់ជប៉ុន :** ព្រះករុណា "នរោត្តម សីហនុ" តាមសេចក្តីប្រកាសថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៤៥ បានដាក់លក្ខខ័ណ្ឌដោយច្រាកជប្រជានៅលើសិទ្ធិរបស់វៀតណាមដែលបានប៉ះពាល់ទឹកដីកូសាំងស៊ីន ហើយនៅចំពោះមុខគោលបំណងរបស់វៀតណាម ដើម្បីធ្វើឲ្យបានសម្រេចនូវការឯកភាពរបស់ខ្លួន

www.elibraryofcambodia.org

ដោយដាក់បញ្ចូលកូសាំងស៊ីនទៅក្នុងទឹកដីរបស់ខ្លួននោះ ព្រះអង្គបានលើកការស្នើ បង្កើតគណៈកម្មការចម្រុះមួយ ដើម្បីកំណត់ព្រំដែនខ្មែរ–វៀតណាម ។

សេចក្តីស្នើនេះមិនត្រូវបានគេអើពើឡើយ, អាជ្ញាធរបារាំងមានបំណងរក្សាទុក កូសាំងស៊ីន ធ្វើជាទឹកដីបារាំង ព្រំដែនដែលបានគូសជាឯកតោភាគី ដោយពួកគេ (បារាំង) ត្រូវបានរក្សាទុក, ហើយគឺដោយសារព្រំដែនដែលត្រូវបានគូសតាម អំណាចចិត្តនេះ ហើយដែលបានបែងចែករហូតមកដល់សព្វថ្ងៃនូវប្រទេស វៀតណាម និង ប្រទេសកម្ពុជា ។

**២– ព្រះរាជសាររបស់ព្រះករុណា "នរោត្តម សីហនុ" ចុះថ្ងៃទី២០ មករា ១៩៤៨**

ដោយព្រះអង្គបានដឹងថា ប្រទេសបារាំងនឹងប្រគល់ទៅតាមការស្នើរបស់អធិរាជ បាវដាយ ដែលមានបំណងបង្រួបបង្រួមនូវ Ky ទាំង៣ (តុងកឹង, អណ្ណាម, កូសាំង ស៊ីន) នោះ ព្រះករុណា "នរោត្តម សីហនុ" នៅក្នុងព្រះរាជសារ ចុះថ្ងៃទី២០ មករា ឆ្នាំ១៩៤៨ (ដែលត្រូវបានចម្លងឡើងវិញដូចខាងក្រោមនេះ) បានស្នើដល់ស្នងការ ជាន់ ខ្ពស់បារាំងនៅឥណ្ឌូចិន ដើម្បីឲ្យបានដឹងអំពីការចរចាទាំងឡាយដែលបារាំង នឹងផ្តើមធ្វើជាមួយវៀតណាម ។...

## ព្រះរាជសារចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៤៨
## របស់ព្រះករុណា ព្រះមហាក្សត្រនៃ ប្រទេសកម្ពុជា

លោកស្នងការជាន់ខ្ពស់,

ខ្ញុំមានកិត្តិយសផ្ញើជូនលោក នូវព្រះរាជសារនេះ ដើម្បីសំដែងជូនលោកនូវ បំណងដែលស្ថិតនៅក្នុងហឫទ័យរបស់ខ្ញុំជានិច្ច ហើយដែលខ្ញុំស្នើសុំលោកជួយ បំពេញឲ្យបានសម្រេច ។

www.elibraryofcambodia.org

ខ្ញុំជឿថា ខ្ញុំមានការខ្វះខាតចំពោះករណីកិច្ចរបស់ខ្ញុំក្នុងការ ការពារដែលខ្ញុំត្រូវធ្វើចំពោះប្រជារាស្ត្រខ្ញុំ ។ ប្រសិនបើខ្ញុំស្ថិតនៅមិនអើពើចំពោះព្រឹត្តិការណ៍ទាំងឡាយដែលបានប្រព្រឹត្តទៅនៅក្នុងរដ្ឋជិតខាង នៅក្នុងពេលបច្ចុប្បន្ននេះ និងជាពិសេសនៅកូសាំងស៊ីន, ជាព្រឹត្តិការណ៍ដែលប្រជារាស្ត្រកម្ពុជា មួយភាគធំដែលបានរស់នៅ ចាប់តាំងពីយូរណាស់មកហើយ នៅក្នុងផ្នែកនៃតំណបិននេះ មានការចាប់អារម្មណ៍ ហើយដែលវាអាចនឹងមានផលអាក្រក់មិនអាចចៀសវាងបាននៅលើវាសនាអនាគតរបស់ខ្លួនគេ ។

ដោយបានដឹងរហូតមកដល់ថ្ងៃនេះថា .: តើអ្វីទៅជាផលវិបាកនៃនយោបាយដែលនឹងកើតមាននៅក្នុងទេសភូមិជិតខាងនេះ? ចាប់ពីពេលនេះទៅ ខ្ញុំ យល់ឃើញថា ខ្ញុំត្រូវតែមានធ្វើលក្ខខ័ណ្ឌស្តីអំពីការវិវត្តន៍នយោបាយនៅតាមបណ្តាខេត្តនៅកូសាំងស៊ីន ដែលប្រជាជនខ្មែរជាអ្នកមានចំនួនគ្របដណ្តប់ ឬយ៉ាងហោចណាស់ក៏មានបំណងចង់ដឹងនូវអ្វីដែលនឹងមកដល់នោះដែរ ។

អាណិកជនខ្មែរនៅកូសាំងស៊ីន បានប្រមូលគ្នាដើម្បីការពារផលប្រយោជន៍របស់ខ្លួន ថែមទាំងនៅក្នុងក្របខ័ណ្ឌរដ្ឋាភិបាលកូសាំងស៊ីនបណ្តោះអាសន្នទៀតផង និងម្យ៉ាងទៀតពួកគេហាក់ដូចជាបានបំពេញភាពត្រឹមត្រូវតាមច្បាប់របស់ពួក គេ និងបំណងប្រាថ្នារបស់ពួកគេទៀតផង ។

ចំពោះរឿងហេតុបែបនេះ ខ្ញុំធ្លាប់បានគិតថា មិនត្រូវធ្វើអន្តរាគមន៍នោះទេ, គឺទុកឲ្យ ប្រទេសបារាំងបន្តតួនាទីរបស់ខ្លួនជាអ្នកអាណាព្យាបាលចុះ ។ ហើយពីកាលណោះ គេមានជំនឿថា បើសិនជាខ្ញុំធ្វើអន្តរាគមន៍ និងធ្វើឲ្យជម្លោះនេះកាន់តែទុកព្រួយ, ប៉ុន្តែខ្ញុំមិនបានចាត់ទុកថា ការអនុប្បវាទរបស់ខ្ញុំ ត្រូវបានបកស្រាយថា ជាការបោះបង់របស់ខ្ញុំនោះទេ ។ នៅក្នុងពេលព្រឹត្តិការណ៍ប្រកបដោយសោកនាដកម្មបានប្រព្រឹត្តិទៅនៅក្នុងប្រទេសកម្ពុជា នៅក្នុងអំឡុងខែមិនា ឆ្នាំ១៩៤៥ និងនៅក្នុង

www.elibraryofcambodia.org

ពេលដែលកិត្យានុភាពរបស់ប្រទេសបារាំង ទទួលរងនូវការបញ្ឈប់មួយពេលនោះ ខ្ញុំបានមានឱកាសដើម្បីប្រកាសថា នៅក្នុងភាពជា យថាហេតុ សូមឲ្យប្រជាជាតិដ៏ធំជាមិត្ត នេះបញ្ឈប់ទាំងស្រុង និងបានទាមទារនូវសិទ្ធិដ៏ពិសិដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា ខ្មែរនៅលើបណ្តាខេត្តកូសាំងស៊ីនទាំងនេះ ដែលជនជាតិភាគតិចខ្មែរមិនដែលឈប់មានសិទ្ធិជាពលរដ្ឋនោះទេ ។

ប្រសិនបើនៅក្នុងអត្ថបទផ្សេងៗត្រឹមត្រូវតាមបទបញ្ញា ទាំងខាងច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណី និងជាពិសេសនៅក្នុងមាត្រាមួយនៃសេចក្តីប្រកាសចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៣៤ ស្តីអំពីសញ្ជាតិខ្មែរ មាត្រាដែលត្រូវបានចម្លងឡើងវិញ នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាត្រង់ជំពូកស្តីពីសញ្ជាតិ មហាក្សត្រអង្គមុនជាទីគោរពរបស់ខ្ញុំ បានអនុញ្ញាតឲ្យប្រទេសបារាំងមាននៅក្នុងក្រុមសមាគមទាំងនេះ ហើយស្ថិតនៅក្នុងមហាគ្រួសារកម្ពុជាដែលគឺជាសិទ្ធិមួយស្ទើរតែដាច់ខាតនោះ ។ ព្រះអង្គបានធ្វើនៅក្នុងសេចក្តីស្នេហាដ៏ជ្រាលជ្រៅចំពោះប្រជាជាតិដ៏ធំជាអ្នកការពារនេះ ហើយនៅក្នុងការជឿជាក់ថា ប្រជាជាតិដ៏ធំនេះ មិនរំលោភនូវបុព្វសិទ្ធិណាមួយឡើយ ។ ព្រះអង្គបានដឹងថា ប្រជារាស្ត្ររបស់ព្រះអង្គ ថ្វីបើនៅឆ្ងាយពីទឹកដីកំណើត ក៏ដោយ ក៏មិនអាចរីករាយសប្បាយចិត្តក្នុងការរស់នៅក្រោមអាណាព្យាបាល និង ការឧបត្ថម្ភគាំទ្ររបស់បារាំងបានដែរ ។

ប៉ុន្តែ ប្រសិនបើប្រជារាស្ត្រទាំងនេះត្រូវបានហៅនៅក្នុងអនាគតថាជាអ្នកទទួលរងដោយសារព្រឹត្តិការណ៍ទាំងឡាយមកលើវាសនារបស់ខ្លួនឬក៏ផ្សេងទៀតនោះ ខ្ញុំនឹងប្រកាន់យកនូវ សិទ្ធិនៅក្នុងទេសកាលដូចគ្នានេះ ដើម្បីដឹងចំពោះការអភិវឌ្ឍន៍នៃបទបញ្ញាដើម្បីធ្វើអន្តរាគម ។

ខ្ញុំសូមលោកស្នងការជាន់ខ្ពស់នៃសាធារណរដ្ឋជាទីគោរព មេត្តាពិនិត្យពិចារណាចំពោះលិខិតនេះដែលមិនមែនជាការអំពាវនាវដោយឥតវិន័យ នោះទេ

www.elibraryofcambodia.org

ប៉ុន្តែ គឺជាបំណងដ៏ក្លៀវក្លា និងស្រួចស្រាល់ ដើម្បីការការពារផលប្រយោជន៍នៃប្រជារាស្ត្ររបស់ខ្ញុំទាំងមូល"។

**លិខិតនេះមានចំណុចកត់សម្គាល់ដូចតទៅនេះ**

**ក)-** ព្រះករុណា "នរោត្តម សីហនុ" បានបញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើនៅក្នុងពេលនោះ ព្រះអង្គ មិនអាចដាក់លក្ខខ័ណ្ឌចំពោះបញ្ហាខេត្តនៅកូសាំងស៊ីនដែលសមាសភាពខ្មែរជាអ្នកគ្រប់ដណ្តប់ទេនោះ ព្រះអង្គត្រូវតែដឹងអំពីការចរចាទាំងឡាយដែលបារាំងកំពុងតែចាប់ផ្តើមជាមួយវៀតណាម ហើយដែលបារាំងពុំមានសិទ្ធិចាត់ចែងទឹកដីរបស់ប្រទេសផ្សេងទៀតនោះទេ ។

**ខ)-** ក្នុងនាមព្រះអង្គជាព្រះមហាក្សត្ររបស់ប្រជាជនកម្ពុជាទាំងអស់ ព្រះករុណា"នរោត្តម សីហនុ" ត្រូវទាមទារសិទ្ធិដ៏ពិសិដ្ឋរបស់ព្រះរាជាណាចក្រខ្មែរនៅលើបណ្តាខេត្តរបស់ព្រះអង្គនៅកូសាំងស៊ីន ដែលអាណិកជនខ្មែរជាអ្នកមានសិទ្ធិត្រឹមត្រូវតាមច្បាប់នៅលើទឹកដីនេះ មិនដែលបាត់បង់សិទ្ធិជាពលរដ្ឋនោះឡើយ ។

**គ)-** ព្រះករុណា "នរោត្តម សីហនុ" ចាត់ទុកប្រទេសបារាំងថាជាអ្នកអាណាព្យាបាល លើប្រទេសកម្ពុជាទាំងមូល ដោយរួមទាំងទឹកដី កូសាំងស៊ីន ដែលបារាំងត្រូវការពារប្រជារាស្ត្រខ្មែរ និងផលប្រយោជន៍របស់ពួកគេនៅ កូសាំងស៊ីន ។ បារាំងមិនត្រូវរំលោភនូវ "បុព្វសិទ្ធិ" ទាំងនេះទេ ។

**ឃ)-** នៅទីបញ្ចប់ គេត្រូវតែកត់សម្គាល់ថា នៅក្នុងសម័យនោះ អំណាចរបស់អាជ្ញាធរបារាំងនៅលើប្រទេសកម្ពុជា គឺប្រើអំណាចផ្តាច់ការ ទាំងលើរាស្ត្រ និងលើស្តេច ពីព្រោះនៅក្នុងពាក្យដែលប្រើនៅលើព្រះលិខិតរបស់ព្រះករុណា នរោត្តម សីហនុ គឺមានលក្ខណៈសុភាពរមទម្យ ។

ប្រទេសបារាំង ក្រៅពីការជាប់អំពល់ជាមួយកម្ពុជា បានចុះហត្ថលេខាជាមួយ

www.elibraryofcambodia.org

ស្តេច បាវដាយ នូវកិច្ចព្រមព្រៀងឆកសមុទ្រហាឡុង (d'Along Baie) នៅឆ្នាំ ១៩៤៩ ដោយទទួលស្គាល់គោលការណ៍សហភាពរបស់ Ky ទាំង៣ (តុងកឹង, អណ្ណាម, កូសាំងស៊ីន)។

ព្រះករុណា "នរោត្តម សីហនុ" បានតវ៉ាប្រឆាំងនឹងកិច្ចព្រមព្រៀងទាំងនេះ ដោយចាត់ទុកជាមោឃៈនៅក្នុងព្រះរាជសារមួយចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៤៨។

**៣- ព្រះករុណា "នរោត្តម សីហនុ" តវ៉ាប្រឆាំង និងកិច្ចព្រមព្រៀងនៃឆកសមុទ្រហាឡុង (d'Along Baie)**

ព្រះអង្គបានបញ្ជូនគណៈប្រតិភូមួយទៅតាមសង្កេតមើល, ម្យ៉ាងគឺចំពោះការពិភាក្សាដេញដោលរបស់សភាបារាំង ស្តីអំពីច្បាប់ដែលទាក់ទងទៅនឹងការកែប្រែលក្ខន្តិកៈ កូសាំងស៊ីន និងការកាត់បញ្ចូលទៅឲ្យអណ្ណាម ម្យ៉ាងទៀតគឺដើម្បីតវ៉ាប្រឆាំងការបញ្ចូលទឹកដីកម្ពុជា នៅកូសាំងស៊ីនទៅឲ្យអណ្ណាម ។

**៤- នៅក្នុងពេលចុះហត្ថលេខាលើសន្ធិសញ្ញា បារាំង-ខ្មែរ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩**

ព្រះមហាក្សត្រកម្ពុជាបានប្រកាសយ៉ាងដាច់ខាតថា សន្ធិសញ្ញា នេះ មិនបានការអ្វីឡើយ ភាគីកម្ពុជា មិនព្រមលះបង់នូវ"សិទ្ធិ និងផលប្រយោជន៍របស់ខ្លួននៅលើ កូសាំងស៊ីន" នោះទេ ។

**៥- លិក្ខិតណ្ឌទាំងឡាយ និងការតវ៉ានៅចំពោះមុខ ក្រុមប្រឹក្សាជាន់ខ្ពស់ របស់សហភាពបារាំង**

នៅចំពោះមុខ ក្រុមប្រឹក្សាជាន់ ខ្ពស់របស់សហភាពបារាំង (សម័យប្រជុំថ្ងៃទី២៩ និងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៥១) លោក "សឺន សាន" តំណាងនៃប្រទេសកម្ពុជាបានធ្វើអន្តរាគមន៍ដូចតទៅនេះ...

ក- លោក "សឺន សាន" បានរំលឹកនៅចំពោះមុខនៃសន្និបាតនេះ អំពីបញ្ហា

www.elibraryofcambodia.org

ដែលស្ថិតនៅមិនទាន់ដាច់ស្រេច ហើយដែលប្រមុខរដ្ឋនៃប្រទេសកម្ពុជាមានការចាប់អារម្មណ៍នោះ ពីទឹកដីកម្ពុជានៅ កូសាំងស៊ីន ។ លោក "សឺន សាន" បានទទួលអំពីលីក្ខខ័ណ្ឌទាំងឡាយដែលបានសំដែង និងធ្វើឡើងជាឧឡារិក ដោយព្រះករុណា ព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងរដ្ឋាភិបាលរបស់ខ្លួនស្តីអំពី "សិទ្ធិត្រឹមត្រូវតាម ច្បាប់របស់ប្រទេសកម្ពុជានៅលើទឹកដី កម្ពុជាក្រោម"។

ខ- លោក "សឺន សាន" បានទទួលអំពីភាពចាំបាច់នៃគំនូសព្រំដែនមួយ ដែលមានការព្រមព្រៀងពីភាគីទាំងឡាយ គឺព្រំដែនរួម និង"សិទ្ធិរបស់ខ្មែរនៅលើកូសាំងស៊ីន" ព្រមទាំងលក្ខន្តិកៈរបស់ប្រជាជនកម្ពុជានៅ "កម្ពុជាក្រោម" ។ ព្រំដែនបច្ចុប្បន្ន ត្រូវបានកំណត់ដោយបំពាន និងជាឯកតោភាគី ដោយប្រទេសបារាំង ដែលជាមហាអំណាចអាណានិគមនៅក្នុងសម័យនោះ ។

គ- នៅទីបញ្ចប់លោក "សឺន សាន" បានរំឭកថា ប្រទេសបារាំងបានចូលរួមក្នុងសន្ធិសញ្ញា បារាំង-ខ្មែរ មួយតាមអត្ថន័យនៃញត្តិរបស់លោកឯកឧត្តម "Deferre" និងដែលបោះឆ្នោតដោយសភាជាតិបារាំងនៅឆ្នាំ១៩៤៩ ដើម្បីផ្តល់ការសម្រុះសម្រួលរបស់ខ្លួនក្នុងដោះស្រាយនូវបញ្ហាទាំងនេះបំពេញចិត្តប្រទេសកម្ពុជា ។

**៦- នៅសន្និសីទ ក្រុងហ្សឺណែវ ឆ្នាំ១៩៥៤**

ការតវ៉ារបស់ខ្មែរត្រូវបានសរសេរនៅក្នុងកថាខ័ណ្ឌ ៧-១១ និង១២ នៃច្បាប់បញ្ចប់ដែលបានចែងអំពីការគោរពបូរណភាពទឹកដីវៀតណាម ។

គណៈប្រតិភូខ្មែរបានស្នើយ៉ាងច្បាស់ចំពោះ សន្និសីទ ដើម្បីពិចារណាថា **១ ទាំងឡាយខាងលើនេះ មិនបានរួមបញ្ចូលនូវការបោះបង់បោលនូវ សិទ្ធិ និងផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់ដែលប្រទេសកម្ពុជា នឹងអាចធ្វើឲ្យមានផលចំពោះខេត្តមួយចំនួននៅវៀតណាមខាងត្បូង ហើយដែលនៅក្នុងនោះ ប្រទេសកម្ពុជា បានដាក់តែង**

www.elibraryofcambodia.org

**និងបានសរសេរនូវលិខិតមួយ ដ៏ជាក់លាក់ ជាពិសេសនៅក្នុងពេលនៃការចុះហត្ថលេខាសន្ធិសញ្ញា បារាំង-ខ្មែរ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ និងនៅក្នុងអំឡុងពេលនៃការបោះឆ្នោតលើច្បាប់បារាំងដែលបានបញ្ចូល កូសាំងស៊ីន ទៅឲ្យវៀតណាម ។**

ដូច្នេះចាប់តាំងពីការលុកលុយ កូសាំងស៊ីន ដោយពួកអណ្ណាម និងរហូតដល់ការកាន់កាប់របស់បារាំង និងចាប់ពីនោះមក រហូតដល់កិច្ចព្រមព្រៀង ក្រុងហ្សឺណែវ បានបញ្ចប់នូវការកាន់កាប់នេះ ប្រទេសកម្ពុជា មិនបានឈប់ក្នុងការតវ៉ាប្រឆាំងនឹងការរំលោភអធិបតេយ្យភាពកម្ពុជានៅលើទឹកដីនេះ ។

ពុំមានសកម្មភាព ឬក៏អំពើណាមួយត្រូវបានបង្ហាញអំពីការបោះបង់របស់ប្រទេសកម្ពុជាចំពោះសិទ្ធិរបស់ខ្លួននោះទេ ។ សិទ្ធិទាំងនេះនៅតែស្ថិតនៅជានិច្ច ទោះបីជាមានការកែប្រែនូវលក្ខន្តិកៈកូសាំងស៊ីន ដោយមហាអំណាចបរទេសក៏ដោយ ។

អធិបតេយ្យភាពរបស់ប្រទេសកម្ពុជានៅលើទឹកដី កូសាំងស៊ីន របស់ខ្លួន បានស្ថិតនៅពេញលេញ និងទាំងស្រុង (cf. 391 "កម្រងសំណួរទូទៅស្តីពីសិទ្ធិអន្តរជាតិ ដាក់តម្កល់នៅចំពោះមុខសមាគមនៃប្រជាជាតិ") ។

*

* *

ប្រទេសបារាំង ទោះបីមានការតវ៉ារបស់ប្រទេសកម្ពុជាក៏ដោយ ក៏ (តាមច្បាប់ផ្ទៃក្នុង) បារាំងបានប្រគល់ទៅឲ្យវៀតណាម ជាឯកតោភាគីនូវ ទឹកដីខ្មែរ នៅកូសាំងស៊ីន ដែលបានដណ្តើមយកពីប្រទេសកម្ពុជាដោយកម្លាំងទិព រួចបង្កើតទៅជាអាណានិគម ។ ច្បាប់នេះគឺគ្មានតម្លៃឡើយ ទាំងចំពោះប្រទេសកម្ពុជា ក៏ដូចជាចំពោះវៀតណាម ។ ប្រទេសបារាំងជាប្រទេសទី៣ មិនត្រូវចាត់ចែងទឹកដីរបស់ប្រទេសផ្សេងៗទៀតនោះទេ ។ ច្បាប់បារាំងនៅក្នុងវិស័យនេះ មិនមែនប្រឆាំង

www.elibraryofcambodia.org

ប្រទេសកម្ពុជា ដែលបានរក្សាទុវអធិបតេយ្យភាពរបស់ខ្លួនជានិច្ចនៅលើ ទឹកដីខ្មែរ នៅ កូសាំងស៊ីនឡើយ ។

ច្បាប់បារាំងស្ដីពីបញ្ហានេះ គឺជាច្បាប់មួយដែលទន្ទឹមនឹងការគ្មានតម្លៃនោះ ក៏បានបណ្ដាលឲ្យមានការរំលោភបូរណភាពទឹកដីនៃ ប្រទេស កម្ពុជា ផងដែរ ។ ដោយហេតុនេះ ច្បាប់នេះត្រូវបានផ្ដន្ទាទោសដោយច្បាប់អន្តរជាតិ ។

នៅក្នុងសម័យ មហាសន្និបាត របស់ អង្គការសហប្រជាជាតិ លើកទីដប់ពីរ នៅឆ្នាំ១៩៥៧ និក្ខេបបទដែលមានចំណងជើងថា "និក្ខេបបទនៃប្រទេសកម្ពុជាស្ដីអំពីទឹកដីរបស់ខ្លួននៅវៀតណាមខាងត្បូង" ត្រូវបានប្រគល់ទៅឲ្យគណៈប្រតិភូរបស់បណ្ដាប្រទេសជាសមាជិក ។

នៅទីបញ្ចប់ព្រះអង្គម្ចាស់ "នរោត្តម សីហនុ" ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជាបាន លើកឡើងបញ្ហានេះ នៅក្នុងកំឡុងនៃ មហាសន្និបាត លើកទីដប់ពីរ ទីដប់ប្រាំនិងទី ដប់ប្រាំមួយរបស់ អង្គការសហប្រជាតិ ។

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៦១ (សម័យប្រជុំលើកទី ១៦) ព្រះអង្គបានប្រកាសដូចតទៅនេះ គឺ :

"...កូសាំងស៊ីន បច្ចុប្បន្នវៀតណាមខាងត្បូង គឺជាទឹកដីមួយរបស់ប្រទេសកម្ពុជា ជាផ្នែកដែលកាន់កាប់ដោយអណ្ណាម នៅក្នុងសម័យនៃការមកដល់ របស់បារាំងនៅពាក់កណ្ដាលនៃសតវត្សរ៍ទី១៩ ។ ពេលនោះប្រទេសបារាំង បានដាក់បញ្ចូលជាឧបសម្ព័ន្ធយ៉ាងខ្លីនូវទឹកដីនេះដោយរួមទាំងខេត្តដែលមានវិវាទរវាងប្រទេសកម្ពុជា និងប្រទេសអណ្ណាម និងបានយកធ្វើជាអាណានិគមមួយ បន្ទាប់មកធ្វើជាខេត្តមួយរបស់បារាំង ជាមួយនិងតំណាងរាស្ដ្រ ជ្រើសតាំងនៅក្នុងរដ្ឋសភាបារាំង ។

www.elibraryofcambodia.org

"នៅឆ្នាំ១៩៤៦-១៩៤៧ ប្រទេសបារាំង មានការប្រយុទ្ធប្រឆាំងអំពើបះបោររបស់វៀតណាម ជាពិសេសមានសភាពខ្លាំងនៅភាគខាងជើងនោះ បានបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយ នៅវៀតណាមខាងត្បូង បន្ទាប់មកនៅឆ្នាំ១៩៤៨ ១៩៤៩ បានយាង**បាវដាយ** ជាអតីតអធិរាជ ដែលបានដាក់រាជ្យនៅក្នុងឆ្នាំ១៩៤៥ មកវិញ និងបានប្រកាសឲ្យធ្វើជាប្រមុខរដ្ឋ និងបានផ្ទេរទឹកដី កូសាំងស៊ីន ដែលបារាំងកំពុងកាន់កាប់ទៅឲ្យ**បាវដាយ** ដោយមានការយល់ព្រមពីរដ្ឋសភាបារាំងផង ។

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានតវ៉ាជាផ្លូវការប្រឆាំងនឹងការផ្ទេរទឹកដីនេះ ដែលនៅក្នុងនោះតាមគតិយុត្តិប្រទេសរបស់យើងនៅតែមានសិទ្ធិនៅលើទឹកដីនោះ (ប៉ុន្តែ ជាការឥតប្រយោជន៍) ។

*** ផលបាបមិនទាន់មកដល់ អ្នកបាបនៅជាសុខ,**
**ផលបុណ្យមិនទាន់មកដល់ អ្នកបុណ្យនៅជាទុក្ខ**
**"សេចក្ដីសុខមាននៅក្នុងសេចក្ដីទុក្ខ" ។**

*** អ្នករៀនដើម្បីប្រជាជាតិ ត្រូវយកផ្ទះប្រជាជាតិជាសាលារៀន ។**

*** ពិភពលោករមែងបើកផ្លូវ ឲ្យមនុស្សទាំងអស់គ្នា**
**ដែលមានបំណងចង់ទៅផ្លូវណា។ តាមសេចក្ដីសម្រេចរបស់ខ្លួន ។**

www.elibraryofcambodia.org

# ជំពូកបី

## ភស្តុតាងនានាដែលបញ្ជាក់ថា កូសាំងស៊ីន ជារបស់ព្រះរាជាណាចក្រកម្ពុជា

នៅភាគខាងត្បូងបំផុតបង្អស់នៃឧបទ្វីបឥណ្ឌូចិន មានភស្តុតាងយ៉ាងច្រើនក្រៃលែង ស្តីពីកំណើតនៃប្រទេសខ្មែរ អំពីជីវិតរបស់ប្រជាជនកម្ពុជានៅកូសាំងស៊ីនអំពីអតីតកាលរបស់ប្រជាជននេះ ជាមួយនឹងប្រាសាទជាប្រវត្តិសាស្ត្រ វត្តអារាម ឈ្មោះរបស់អតីតខេត្តទាំងឡាយ និងឈ្មោះរបស់ភូមិទាំងឡាយដែលប្រមូលចងក្រង ជូនកាលដោយអ្នកប្រវត្តិសាស្ត្រ ជូនកាលដោយផ្នែកការងារផ្លូវការនានា បានបន្ថែមទៅលើទឡ្ហីករណ៍ប្រវត្តិសាស្ត្រ និងគតិយុត្តិ ដើម្បីបញ្ជាក់អះអាងអំពីអធិបតីភាពរបស់ប្រទេសកម្ពុជានៅលើខេត្តទាំងឡាយនៅកម្ពុជាក្រោម ។

ការរៀបរាប់របស់អ្នកដំណើរបរទេសដំបូងៗដែលមកប្រទេសកម្ពុជា និងគំនូរផែនទីជាច្រើនរបស់អតីតប្រទេសខ្មែរ ក៏ស្របគ្នាទៅនឹងភស្តុតាងទាំងឡាយដែលមិនអាចប្រកែកបានថា កូសាំងស៊ីន គឺជាទឹកដីរបស់កម្ពុជានោះ ។

សូមមើលភស្តុតាងជាបន្តបន្ទាប់ដូចតទៅនេះ

១- ភស្តុតាងទាំងឡាយដែលប្រមូលបានដោយអ្នកដំណើរអឺរ៉ុបលើកដំបូង និងអតីតផែនទីភូមិសាស្ត្រ

២- ប្រជាជនខ្មែរនៅកម្ពុជាក្រោម

www.elibraryofcambodia.org

# ផ្នែកទី១

## តស្តុតាងនានាដែលប្រមូលបានដោយពួកអ្នកដំណើរទី១ និងអតីត ផែនទីភូមិសាស្ត្រនៃអាស៊ីអាគ្នេយ៍

ប្រវត្តិសាស្ត្រដែលបានសិក្សានៅជំពូកទី១ បានឲ្យដឹងថា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជ ប្រជារាស្ត្រខ្មែរបានតាំងទីលំនៅ នៅទឹកដីកម្ពុជាក្រោម (វៀតណាមខាងត្បូង បច្ចុប្បន្ននេះ) ដែលនៅក្នុងសម័យនោះ ហៅថា "ហ៊្វូណន" ។ កេរដំណែលនៃទីក្រុងសមុទ្រ អូកអែវ (Oc. Eo) គឺជាសក្ខីភាពបង្ហាញស្រាប់ ។

ហ៊្វូណន បានយកឈ្មោះជាបន្តមកទៀតថា "កម្ពុជាក្រោម" និងរក្សារហូតមកដល់បច្ចុប្បន្ននេះ ដោយសារមូលហេតុនៃភូមិសាស្ត្រ និងជាតិពន្ធុ និងប្រហែលជាត្រូវបានបកប្រែតាមអត្ថបទដោយពាក្យបារាំងថា "Bas-Cambodge" (កម្ពុជាក្រោម) ។ អត្ថបទចាស់ៗរបស់ចិន គឺមានសភាពជាក់លាក់ដែលបង្ហាញថា ទឹកដីទាំងនេះគឺជារបស់ព្រះមហាក្សត្រអង្គរ ជាពិសេសឯកសារនិក្ខេបបទដ៏ល្បីល្បាញរបស់អ្នកដំណើរចិន "ជៀវតាក្វាន់" (Tchéou Ta Kouan) ។

កំណត់ត្រារបស់ "ជៀវតាក្វាន់" ត្រូវបានបញ្ជាក់ និងអះអាងដោយការរៀបរាប់របស់ជនជាតិ អេស្ប៉ាញ៉ុល និងជនជាតិ ព័រទុយហ្គេ ដែលជាជនអឺរ៉ុបដំបូងបំផុតបានមកដល់ប្រទេសកម្ពុជា ។

នៅទីបុងក្រោយគឺផែនទីអាស៊ីអាគ្នេយ៍ជាច្រើនដែលបានរៀបចំឡើងនៅសតវត្សរ៍ទី១៦ ទី១៧ និងទី១៨ បានធ្វើឲ្យលេចឡើងដោយឥតសង្ស័យនូវព្រះរាជាណាចក្រ "Camboja" នៅក្នុងភាគដីធំបំផុត និងនៅខាងត្បូងបំផុត (នៅមាត់សមុទ្រទាំងអស់) នៃឧបទ្វីបឥណ្ឌូចិន ។ ដែលនៅក្នុងសម័យនោះទឹកដីវៀតណាមហៅថា "តុង កឹង" មានព្រំប្រទល់រហូតដល់ទន្លេក្រហម ។

www.elibraryofcambodia.org

## I. ផែនទីចាស់ៗ និងដើមកំណើតនៃពាក្យកូសាំងស៊ីន

គេបានបកស្រាយដោយរបៀបផ្សេងៗគ្នានូវពាក្យ "កូសាំងស៊ីន" អ្នកខ្លះនិយាយថា ពាក្យនេះ គឺជាពាក្យអណ្ណាម និងអាចត្រូវបានបកប្រែថា "អ្នកស្រី ជិន សុំ" "Madame Chin demande" (Cô Chin Xin) ដោយរំលឹកអំពីការសុំរបស់ម្ចាស់ក្សត្រីអណ្ណាម មហេសីរបស់ព្រះបាទ ជ័យជេដ្ឋាទី២ ដើម្បីឲ្យទទួលបានពីស្តេចអង្គនេះនូវការអនុញ្ញាតដើម្បីបង្កើតគ្រឹះស្ថានជំនួញនៅខាងត្បូងប្រទេសកម្ពុជា ជាពិសេសគឺនៅសាយហ្គន ។

ការបកស្រាយនេះ គឺជាការភាន់ច្រឡំ ។ ពាក្យថា "កូសាំងស៊ីន" បានកើតមាននៅមុនការបង្កើត អាណាចក្រ អណ្ណាម ។ ពាក្យនេះមិនមានន័យថា កម្ពុជាក្រោមនោះទេ ។ ពាក្យនេះបានចង្អុលបង្ហាញនូវទឹកដីមួយដែលស្ថិតនៅចន្លោះប្រទេសចំប៉ាខាងត្បូង ជួរភ្នំអណ្ណាមនៅខាងលិច និងតុងកឹងនៅខាងជើង ដែលបើប្រមាណទៅគឺមួយផ្នែកនៃតុងកឹង និងមួយផ្នែកនៃ វៀតណាមកណ្តាល (អណ្ណាម) ។

ផែនទីចាស់ៗខ្លះ បញ្ជាក់ថា "កូសាំងស៊ីន" គឺជាដែនដីសណ្តទាំងអស់នៃតុងកឹង អ្នកផ្សេងៗទៀតជាច្រើនបានបង្ហាញថា "កូសាំងស៊ីន" ឬ Cochin Chine មិនគ្រាន់តែស្ថិតនៅទីកន្លែងកម្ពុជាក្រោមប៉ុណ្ណោះទេ ប៉ុន្តែស្ថិតនៅមួយផ្នែកនៃឆ្នេរសមុទ្រអណ្ណាម (ចាប់តាំងពីដីសណ្តនៃតុងកឹងរហូតដល់ វ៉េ គឺថា រហូតដល់ព្រំប្រទល់នៃអតីត ចំប៉ា) ។

ផែនទីទាំងនេះ ត្រូវបានគេចម្លងឡើងវិញនៅក្នុង "អាណាចក្រអាណានិគមបារាំង" (E.C.F) សៀវភៅបោះពុម្ពផ្សាយនៅឆ្នាំ១៩២៩ នៅក្រោមការដឹកនាំរបស់លោក Georges Maspéro ។ ភាគច្រើនបានបែងឈ្មោះតែមួយ គឺ "Camboja" នៅអាស៊ីអាគ្នេយ៍ ។

១- ផែនទីឥណ្ឌូចិន គូរដោយជនជាតិ ព័រទុយហ្គេ ម្នាក់ បានចេញនៅឆ្នាំ ១៥៨០

www.elibraryofcambodia.org

(E.C.F ទំព័រ១២២ រូប ៧១) ។ គេបានឃើញ:

-"កូសាំងស៊ីណា" (Cochin china) នៅទីកន្លែងដីសណ្ដទន្លេកុងកឹង

- "Camboja" នៅក្នុងភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ។

២- ផែនទីឥណ្ឌូចិន ឥណ្ឌាខាងកើត ដកស្រង់ពីសៀវភៅផែនទីភូមិសាស្ត្រ Urtelina នៅឆ្នាំ១៥៩៣ (ជំនួយស្មារតីឯកសាររបស់ក្រសួងការបរទេសនៃប្រទេសកម្ពុជាស្ដីអំពីជនជាតិភាគតិចកម្ពុជា) (A.M. Minaf) ។

៣- ផែនទីឥណ្ឌាខាងកើត ដកស្រង់ពីសៀវភៅផែនទីភូមិសាស្ត្រ Morentôr, ឆ្នាំ១៦២៨ (A.M. Minaf) ។

៤- ផែនទីឥណ្ឌូចិន បោះពុម្ពផ្សាយនៅឆ្នាំ១៦៣៨ ហើយលោក Jean Jeanson នៅក្នុង "Nieu Wen Atlas Ost Verelt beschryvinge" (ទំព័រ ១២៧ រូប៧៣ E.C.F) ។

៥- ផែនទីរបស់ Père Alexandre de Rhodes, 1650 (A.M. Minaf)

៦- ផែនទី "ព្រះរាជាណាចក្រសៀម" បោះពុម្ពផ្សាយនៅឆ្នាំ១៧១៤ ដោយ Père Placide (E.C.F ទំព័រ១១៦) ។

គេបានឃើញ :

-"ឈូងសមុទ្រកូសាំងស៊ីន" នៅកន្លែងឈូងសមុទ្រ កុងកឹង បច្ចុប្បន្ន

-"កូសាំងស៊ីន ព្រះរាជាណាចក្រ" ឆ្នេរសមុទ្រអណ្ដាមទាំងអស់ និង "កុងកឹង" ខាងជើង

-"ព្រះរាជាណាចក្រកម្ពុជា" នៅភាគខាងត្បូងទាំងអស់ និង "ចំប៉ា" ខាងកើត ។

៧- ផែនទីឥណ្ឌូចិន ដកស្រង់ពីសៀវភៅផែនទីប្រវត្តិសាស្ត្ររបស់ Guendeville (1713-1719) (E.C.F) ។

- ការបង្កលបង្ហាញដូចគ្នា

www.elibraryofcambodia.org

៨- ផែនទីឥណ្ឌូចិនដោយ Robert 1717 (E.C.F ទំព័រ១១៦) ។

៩- ផែនទីឥណ្ឌូចិន បោះពុម្ពផ្សាយដោយ Durville នៅឆ្នាំ 1755 (ជាភាសាអង់គ្លេស) (E.C.F) ។

គេបានឃើញ :

- "ព្រះរាជណាចក្រកម្ពុជា" មួយភាគធំនៅភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន និងយ៉ាងទូលាយនៅភាគខាងជើង ។

- "Ciampa" មួយភាគតូចនៅខាងកើតកម្ពុជាក្រោម ។

- "Cakinchina" ជួរភ្នំអណ្ណាមទាំងអស់ ។

១០-ផែនទី "ប្រទេសឥណ្ឌានៅខាងនាយទន្លេ Gange" រៀបចំគូរឡើងសម្រាប់ប្រវត្តិសាស្ត្រទូទៅរបស់អ្នកដំណើររបស់ La Harpe ។

- "ព្រះរាជាណាចក្រកម្ពុជា" ភាគខាងត្បូងទាំងអស់នៃឥណ្ឌូចិន, "កូសាំងស៊ិន" ស្ថិតនៅខាងជើង ។

១១-"ផែនទីឥណ្ឌូចិន" បោះពុម្ពផ្សាយនៅឆ្នាំ១៨៥០ នៅក្នុងសៀវភៅ "L' Univers ,ជប៉ុន - ឥណ្ឌូចិន - ស្រីលង្កា" នៅ Firmin Didot នៅក្រោមបំណងដើង "អាណាចក្រភូមា" កែតម្រូវនៅតូរូបចម្លាក់ ។

- គេបានរកឃើញជាលើកទី១ នូវពាក្យ "ឥណ្ឌូចិន" ប៉ុន្តែពាក្យ "CAMBODJE" កាន់កាប់នៅភាគខាងត្បូងនៃឥណ្ឌូចិន ។

- កូសាំងស៊ិន បានលាតសន្ធឹងនៅលើឆ្នេរសមុទ្រ អណ្ណាម ដែនដីសណ្តុតុងកឹងនៅវៀ ។ វាបានបង្ហាញឲ្យឃើញច្បាស់នៅក្នុងផែនទីទាំងនេះ និងផែនទីជាច្រើនដទៃទៀតថា រហូតដល់ឆ្នាំ១៨៥០ គេបានស្គាល់ឈ្មោះ តែមួយគត់ គឺឈ្មោះ "Camboia"ឬ "Camboje" "Camboja" កម្ពុជាភាសាខ្មែរដើម្បីកំណត់ប្រទេសដីធំមួយនៅអាស៊ីអាគ្នេយ៍គឺ "ព្រះរាជាណាចក្រខ្មែរ" ។

www.elibraryofcambodia.org

ចំណែក "កូសាំងស៊ីន" វិញ គឺវាជំណាងឲ្យរដ្ឋដីតូចមួយ ស្ថិតនៅចន្លោះ តុងកឹង ខាងជើង ចំប៉ា នៅខាងត្បូង និងជួរភ្នំ អណ្ណាម នៅខាងលិច គឺថានៅតាមបណ្ដោយ នៃឆ្នេរសមុទ្រ អណ្ណាម ។

ដូច្នេះ វាច្បាស់ណាស់ថា គឺពួកបារាំងដែលបានផ្លាស់កន្លែង "កូសាំងស៊ីន" ពី ជើងទៅត្បូង នៅកន្លែង "កម្ពុជាក្រោម" ។

ដែនទឹកឥណ្ឌូចិនចុងក្រោយ ដែលបានចុះឈ្មោះដ៏ត្រឹមត្រូវនៃប្រទេស "Camboja" និង "កូសាំងស៊ីន" នៅកន្លែងពិតប្រាកដរបស់ខ្លួនដែលមានកាលបរិច្ឆេទនៅ ឆ្នាំ១៨៥០ គឺថានៅមុនការតាំងនៅរបស់បារាំងនៅឥណ្ឌូចិនដែលបានចាប់ផ្ដើម នៅក្នុងឆ្នាំ ១៨៥៨ ។

គឺប្រទេសបារាំងដែលបានបង្កើតការបែងចែកជា ៣ផ្នែកនៃអាណាចក្រ អណ្ណាម គឺ តុងកឹង អណ្ណាម និង កូសាំងស៊ីន ។ ដោយបន្ថែមទៅលើឈ្មោះទាំង៣ ទៅលើ ប្រទេសពីរផ្សេងទៀត គឺប្រទេសកម្ពុជា និងឡាវ នោះ បារាំងបង្កើតបាននូវ "ឥណ្ឌូចិន បារាំង" ។

បារាំង បានពង្រួញ "Camboja" ដែលមានប្រទេសកម្ពុជាបច្ចុប្បន្ន និងកម្ពុជា ក្រោមទៅជាប្រទេសដ៏តូចមួយដែលមានផ្ទៃដី ១៨១.០៣៥គម$^2$ ដោយលុបចោល កម្ពុជាក្រោមនៅខាងត្បូង ធ្វើដូច្នេះបារាំងបង្កើតបាននូវគ្រប់ផ្នែកទាំងអស់នៃ"កូសាំង ស៊ីន មួយទៀតដែលជារបស់បារាំង ។ ក្នុងពេលជាមួយគ្នានេះ បារាំង បានលុប បំបាត់ឈ្មោះ "កូសាំងស៊ីន" នៅទិសឦសាន ដើម្បីដាក់ជំនួសឈ្មោះតែមួយគត់គឺ "អណ្ណាម" ។ ដូច្នេះប្រទេសបារាំងបានកែប្រែនូវរូបសណ្ឋាននយោបាយ របស់អាស៊ី អាគ្នេយ៍ដែលត្រូវបានរស់នៅដោយពូជសាសន៍ មន-ខ្មែរ ភាគច្រើន ចំណែកប្រជា ជន អណ្ណាម និងប្រជាជនផ្សេងៗទៀត គឺគ្រាន់តែជាជនអន្តោ ប្រវេសន៍តែប៉ុណ្ណោះ ។

លោក Henri Aurillac បានបញ្ជាក់អះអាងនូវយោបល់នេះ ហើយនៅក្នុងឆ្នាំ

www.elibraryofcambodia.org

១៨៧០ នៅក្រោយពេលការកាន់កាប់ដោយ អណ្ណាម និងភាគខាងកើតកូសាំងស៊ីន នោះមក លោកបានសរសេរនៅក្នុងសៀវភៅ "កូសាំងស៊ីន អណ្ណាម ម៉យ កម្ពុជា" (បណ្ណាល័យជាតិ Côté 4695) :

"អាណាចក្រអណ្ណាម មានចំណែកធម្មជាតិធំៗបីស្ថិតនៅចន្លោះ ៩ និង ២២ អង្សានៃរយៈទទឹងខាងជើងគឺ កម្ពុជា និង អណ្ណាម បច្ចុប្បន្នហៅថា កូសាំងស៊ីនបារាំង កូសាំងស៊ីន ពិតប្រាកដហៅថា តុងកឹង" ។

ដូច្នេះលោក H.Aurillac បានបញ្ជាក់ មាន កូសាំងស៊ីនពីរ គឺ កូសាំងស៊ីនបារាំង ដែលគាត់ហៅថា "កម្ពុជា អណ្ណាម" និង "កូសាំងស៊ីន ពិតប្រាកដ" ។ ចំពោះផ្នែកទាំងពីរនេះ គាត់បានបន្ថែម តុងកឹង ដើម្បីចង្អុលបង្ហាញអាណាចក្រអណ្ណាម ។

ដូច្នេះ វាច្បាស់ណាស់ ចំពោះលោក H. Aurillac ដែលថា "កូសាំងស៊ីន" ពិតប្រាកដនេះ គឺ អណ្ណាម ដែលគាត់បានចង្អុលបង្ហាញថា ជាទឹកដីមួយដែលស្ថិតនៅចន្លោះ តុងកឹងខាងជើង និង កម្ពុជាក្រោម... នៅលើឆ្នេរសមុទ្រ អណ្ណាមទាំងអស់ ។ ចំណែក កម្ពុជា-អណ្ណាម ដែលគាត់បានចង្អុលបង្ហាញនៅក្រោមឈ្មោះ "កូសាំងស៊ីន បារាំង" នោះ គឺគ្មានអ្វីក្រៅពី "កម្ពុជាក្រោម" នោះទេ ។

ហេតុអ្វីបានជាមានឈ្មោះ "កម្ពុជា អណ្ណាម" ?

ពីព្រោះថា លោក H. Aurillac ក៏ដូចជាបារាំងដទៃឯទៀតដែរ នៅក្នុងសម័យនោះ បានស្គាល់ថា "កម្ពុជា អណ្ណាម" នេះ គឺជារបស់ព្រះរាជាណាចក្រខ្មែរ ។ លោក Aurillac ថែមទាំងបានបញ្ជាក់ថា "ខេត្ត ហៀនហ្វា" ត្រូវបានប្រគល់ដោយខុសច្បាប់ទៅឲ្យប្រទេសបារាំងដោយអធិរាជ "ទឺ ឌឹក" តាមសន្ធិសញ្ញាចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៨៦២ ដែលជា "ខេត្តដីល្អបំផុតរបស់ប្រទេស កម្ពុជា អណ្ណាម" ។

www.elibraryofcambodia.org

## II. ភស្តុតាងទាំងឡាយដែលប្រមូលបានដោយជនជាតិ អេស្ប៉ាញ៉ុល និង ព័រទុយហ្គេ

ការចង្អុលបង្ហាញដែលមាននៅក្នុងផែនទីដែលបាននិយាយនៅក្នុងកថាខ័ណ្ឌទី១ នៃផ្នែកនេះ គឺដូចគ្នាបេះបិទទៅនឹងការរៀបរាប់នូវហេតុការណ៍ទាំងឡាយដោយជនជាតិ ព័រទុយហ្គេ និង អេស្ប៉ាញ៉ុល ដែលជាអ្នកដំណើរអឺរ៉ុបមកដល់កម្ពុជាដំបូងបំផុត ។

បើតាមលោក Charles Lemire បានឲ្យដឹង នៅក្នុង "របាយការណ៍កាលប្បវត្តិ..." លោកបានឲ្យដឹងថា គឺ ពួកព័រទុយហ្គេ ដែលបាននាំយកទៅនូវប្រវត្តិសាស្ត្ររបស់ប្រទេស កម្ពុជា" ។

ប្រវត្តិសាស្ត្រទាំងនេះត្រូវបានបំផ្លាញដោយពួក សៀម ។ នៅឆ្នាំ ១៥៩៣ លោក Charles Lemire (របាយការណ៍ទំព័រ ៨) បាននិយាយថា "ប្រវត្តិសាស្ត្រនៃទំនាក់ទំនង ខ្មែរ–ថៃ បានពន្យល់អំពីមូលហេតុដែលឯកសារប្រវត្តិសាស្ត្រទាំងនោះត្រូវបានបំផ្លាញ ។ បញ្ហា "ខេត្ត បាត់ដំបង", "អង្គរ" ហើយថ្មីបំផុតនេះ "ព្រះវិហារ" ដែលនៅក្នុងនោះ តុលាការអន្តរជាតិនៃយុត្តិធម៌បានផ្តល់យុត្តិធម៌ដល់ព្រះរាជាណាចក្រកម្ពុជា (សាលដីកាចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២) បញ្ជាក់នូវយោបល់ដែលនៅក្នុងនោះថាប្រទេសថៃ មិនបានគោរពតាមភស្តុតាងពីអតីតកាលឡើយ ។

ជនជាតិ ព័រទុយហ្គេ ដំបូងបានមកដល់ ប្រទេស កម្ពុជា នៅក្នុងឆ្នាំ ១៥១១ ។ លោក B.P.Groslier បានរាយការណ៍អំពីព្រឹត្តិការណ៍នៅ "អង្គរ និងប្រទេសកម្ពុជាក្នុងសតវត្សរ៍ទី១៦ ។ តាមប្រភពរបស់ជនជាតិ ព័រទុយហ្គេ និង អេស្ប៉ាញ៉ុល" នៅឆ្នាំ ១៥១១–១៥១២ ឯកអគ្គរដ្ឋទូត ព័រទុយហ្គេ បានរាយការណ៍អំពីបេសកកម្មរបស់ខ្លួនទៅឲ្យព្រះមហាក្សត្រ ព័រទុយហ្គេ, គេបានរៀបរាប់អំពីប្រទេស "Camboja" នៅក្នុងចំណោមប្រទេសទាំងឡាយដែលពួកគេទើបនឹងបានចូលទៅដោយចេញពី

www.elibraryofcambodia.org

ម៉ាឡាកា ។ គឺជាលើកទី១ហើយ ដែលគេបាននិយាយអំពី ប្រទេស កម្ពុជា នៅអឺរ៉ុប។

ការនិយាយបន្ត បានស្ថិតនៅក្នុងលិខិតមួយចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៥១៣ របស់ លោក Emmanuel ទៅឲ្យ Pope Leon ទី១០ បោះពុម្ពផ្សាយនៅទីក្រុងរ៉ូម (*អង្គរ និងប្រទេសកម្ពុជានៅសតវត្សរ៍ទី១៦ ទំព័រ ១៤២*) ។ លិខិតនេះបានថែងថា "... បេសកជនរបស់ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ដែលជាព្រះមហាក្សត្រដ៏ខ្លាំងបំផុតមួយអង្គ រវាងជនជាតិម៉ូន (*ប្រជាជនប្រទេសម៉ូនីតានិ*) នៅលើដី និងនៅលើសមុទ្រ..." ។

សៀវភៅ "le Suma Orientale" របស់លោក Tomé Pires គឺជាសៀវភៅអេស្ប៉ាញ លើកដំបូងដែលបានផ្តល់នូវការកត់សម្គាល់មួយស្តីអំពីប្រទេសកម្ពុជា ។ B.P. Groslier (*ទំព័រ ១៤៣ និងទំព័របន្តបន្ទាប់*) បានផ្តល់នូវការបកប្រែដូចតទៅ

"f° 138 r° ព្រះរាជាណាចក្រ Camboja ។

**"ដោយចាកចេញពីសៀម (Syam) ឆ្ពោះទៅចិន (Chyna) នៅតាមមាត់សមុទ្រ គេឃើញមានព្រះរាជាណាចក្រ Camboja ដែល (*ដោយដើរតាម*) ទិសដៅដូចគ្នានេះ គេបានទៅដល់ចំចាំ ។ ព្រះមហាក្សត្រអង្គនេះ គឺជាអ្នកមិនជឿគ្រិស្តសាសនា និងជាអ្នកចំបាំង ។ ប្រទេសរបស់ព្រះ អង្គ (*មានលាតសន្ធឹង*) ទៅឆ្ងាយពីខាងក្នុងទឹកដីរបស់ប្រទេសទៅទៀត ។ ព្រះអង្គកំពុងធ្វើសង្គ្រាមជាមួយពួក Brema និងជាមួយពួកសៀម និងជួនកាលជាមួយប្រទេសចំប៉ាផងដែរ ហើយព្រះអង្គមិនស្ថិតនៅក្រោមអំណាចរបស់អ្នកណាម្នាក់ឡើយ ។ ប្រជារាស្ត្រ Camboja គឺជាអ្នកចំបាំង" ។**

ការពិពណ៌នានេះ គឺត្រឹមត្រូវណាស់ ។ គឺវាស្របទៅតាមការចង្អុលបង្ហាញដែលមាននៅក្នុងដែនទីផ្សេងៗដែលបានរៀបរាប់មកហើយនេះ ។ ដោយបានអាននូវរឿងនិទានពិតរបស់ជនជាតិ អេស្ប៉ាញ៉ុល នេះ គេឃើញថា ឆ្នេរសមុទ្រទាំងអស់

www.elibraryofcambodia.org

(ចាប់ពី ឈូងសមុទ្រសៀមទៅដល់ប្រទេសចំប៉ា ផ្នែកខាងត្បូងប្រទេសអណ្ណាម) គឺស្ថិតនៅក្នុងទឹកដីខ្មែរ ។ អ្នកនិពន្ធបានបញ្ជាក់ថា ដោយចាកចេញពីប្រទេសសៀមក្នុងទិសដៅឆ្ពោះទៅប្រទេសចិន នៅតាមបណ្ដោយឆ្នេរសមុទ្រ គេបានទៅដល់ប្រទេសកម្ពុជា ។ អ្នកនិពន្ធបានបន្ថែមថា ហើយនៅក្នុងទិសដៅតែមួយនេះ គេបានទៅដល់ប្រទេសចំប៉ា ។

វាច្បាស់ណាស់ថា ផ្លូវដែលធ្វើដំណើរដោយអ្នកដំណើរជនជាតិ អេស្ប៉ាញ៉ុលម្នាក់នេះ បានឆ្លងកាត់តាមឆ្នេរសមុទ្ររបស់ខ្មែរទាំងអស់គឺថា ទៅជិតដល់ កម្ពុជាក្រោម ។

ដូច្នេះគឺខុសទាំងស្រុងក្នុងការអះអាងថា ឆ្នេរសមុទ្រទាំងអស់នៃ កម្ពុជាក្រោមគ្មានមនុស្សនៅនោះ ។ នៅសតវត្សរ៍ទី១៦ រាជអាណាចក្រកម្ពុជា កាន់កាប់ទឹកដីកម្ពុជាក្រោមដែលប្រជាជនភាគច្រើន គឺជាប្រជាជនខ្មែរ ។ **"ព្រះមហាក្សត្រមិននៅក្រោមអំណាចអ្នកណាទាំងអស់ ហើយប្រជារាស្ត្រកម្ពុជា គឺជាអ្នកចំបាំង" ។ នេះជាការសរសើររបស់អ្នកដំណើរ អេស្ប៉ាញ៉ុល ។**

អ្នកដំណើរម្នាក់ទៀតឈ្មោះ "Pinto" បានទៅដល់ឆ្នេរសមុទ្រខាងកើតនៃឧបទ្វីបឥណ្ឌូចិន និងមាត់ទន្លេមេគង្គនៅក្នុងឆ្នាំ ១៥៤០ និង ១៥៥៣ ។ អ្នកដំណើររូបនេះបានកំណត់ឈ្មោះមាត់ទន្លេមេគង្គថា ជា "របាំងនៃប្រទេស Camboja" ។

តាមលោក Georges Maspéro (អាណាចក្រខ្មែរទំព័រ ៦០) បានឲ្យដឹងថា ព្រះមហាក្សត្រខ្មែរ "ព្រះបាទ ពញាតន់ ១៥៩៥" ថែមទាំងបានប្រទានរង្វាន់ដល់ជនជាតិ អេស្ប៉ាញ៉ុល ពីរនាក់គឺលោក Blaz Ruiz Castilla និងលោក Diégo Beloso ដែលបានជួយព្រះអង្គឲ្យដណ្ដើមរាជបល្ល័ង្កពីស្ដេចដណ្ដើមរាជ្យបល្ល័ង្កមួយអង្គរបស់ប្រទេសកម្ពុជា (ស្ដេចរាមាជើងព្រៃ) ។ ព្រះមហាក្សត្រ "ពញាតន់" បានតែងតាំងលោក Blaz Ruiz Costilla ជាចៅហ្វាយខេត្តទ្រាំង (សុកត្រាំង) ហើយ

www.elibraryofcambodia.org

លោក Diégo Beloso ជាចៅហ្វាយខេត្តបាភ្នំ ។

មានជនជាតិ ព័រទុយហ្គេ ជាច្រើននាក់ បានរស់នៅជាស្ថាពរនៅប្រទេសកម្ពុជា។ មានជនជាតិ ព័រទុយហ្គេ មួយចំនួនមានកូនចៅរក្សាឈ្មោះឪពុកជាឈ្មោះ ព័រទុយ–ហ្គេ ជានិច្ច ។ លោក Charles Le mire បានសរសេរនៅក្នុង "សេចក្ដីរាយការណ៍កាលប្បវត្តិ" របស់លោកទំព័រ៨ បានផ្ដល់កូនចៅរបស់ពួកគេ និងបានរក្សាឈ្មោះឪពុកជាឈ្មោះ ព័រទុយហ្គេ ដូចជាឈ្មោះ Kol de Monteiro (អ្នកបកប្រែរបស់ព្រះមហាក្សត្រនៃប្រទេសកម្ពុជា) លោក Le mire បានបន្ថែមថា កូនកាត់ ព័រទុយហ្គេ ដែលមានប្រពន្ធ កម្ពុជា មិនមែនជាតួយ៉ាងដូចជាកូនកាត់ ព័រទុយហ្គេ ជាមួយចិន ដែលអាក្រក់មើលនោះទេ" ។

ពួកអ្នកដំណើរ ព័រទុយហ្គេ បានគូរផែនទីរបស់ ប្រទេស កម្ពុជា ពីដើម ។

លោក B. P. Groslier បានសរសេរអំពីផែនទីទាំងនេះ (ផ្ទាំងផែនទីពិភពលោករបស់ Diogo Ribeiro ឆ្នាំ ១៥២៧ រក្សាទុកនៅ Weimar និងឆ្នាំ ១៥២៩ រក្សាទុកនៅសារមន្ទីរនៃការផ្សាយនូវជំនឿសាសនានៅទីក្រុងរ៉ូម) ដែលឯកសារនីមួយៗនៃឯកសារទាំងនេះបានផ្ដល់នូវគំនូរបំព្រួញនៃឆ្នេរសមុទ្រឥណ្ឌូចិនជាមួយនិងឈ្មោះ Comboja និងឈ្មោះ Ia Codor (Isla Codor) តែមួយគត់" ។

ផែនទីដែលចាស់ៗបំផុតត្រូវបានគូរដោយពួក អេស្ប៉ាញ៉ុល និងពួក ព័រទុយហ្គេ ហើយគេបានឃើញឈ្មោះទាំងឡាយរបស់ប្រទេស និងកោះទាំងឡាយ ឬក្រុងទាំងឡាយដែលបានចុះជាភាសា ព័រទុយហ្គេ ។

ដូច្នេះនៅក្នុងផែនទីមួយដែលមានកាលបរិច្ឆេទនៅឆ្នាំ ១៥៥០ ដែលបើតាមលោក Lopa Homen ដែលមានឋានទាមវិទ្យាមួយដីសម្បូរណ៍ផែនទីនោះ ឥឡូវនេះ ត្រូវបានរក្សាទុកនៅបណ្ណាល័យជាតិនៅទីក្រុងប៉ារីស ។

ឋានទាមវិទ្យានេះ មានឈ្មោះជាពិសេសគឺ

www.elibraryofcambodia.org

- Pulo Coroz (Poulo Condor)

- Coroll (នៅកំពស់ខេត្តកំពត)

- Punta Recaroa ( ជ្រោយ Camau)

លោក Groslier បានផ្តល់នូវការពន្យល់ដូចខាងក្រោមនេះ :

"La Punta Recartoa ភាសា ព័រទុយហ្គ មានន័យថា : ចំណុចដែលត្រូវចៀសវាង ឬចូលចតដោយប្រុងប្រយ័ត្ន ។ ចំណុចនេះអាចមានន័យថា Camau ដូចជា ជ្រោយ Saint - Jacque ដែរ ។

"Coroll គឺប្រែកដជាកោះត្រល់ កោះដែលមានរាងដូចជាត្រល់ ដែលបច្ចុប្បន្នហៅថា ភូ ក្វុក" ។

**ផែនទីមួយទៀតរបស់ជនជាតិ ព័រទុយហ្គ នៅឆ្នាំ១៥៨០ បានបង្ហួលបង្ហាញទីក្រុង Conboa នៅកន្លែងដែកនិញ ។ ចំណែកជ្រោយ Camau ត្រូវបានគេហៅថា "ជ្រោយ Cambodia" ។ គឺចេញពីជ្រោយ Cambodia នេះហើយដែលពួកអណ្ណាម បានហៅថា "ជ្រោយ Camau" នោះ ។**

ផែនទីធ្វើដោយដៃរបស់ Godinho de Eredia បង្កើតឡើងនៅ Malacca ឆ្នាំ ១៦១៣ ("អក្សរ និងកម្ពុជា" ឧបសម្ព័ន្ធ) បានចុះប្រទេស "Cambodia និង Promentorium notium របស់ខ្លួនគឺថា ជ្រោយ Saint- Jacques"។

ឈ្មោះចុងក្រោយនេះ បើតាមលោក Groslier គឺជាការធ្វើឲ្យក្លាយនូវសំនៀងខ្លះ គឺអ្នកបើកបរយន្តហោះរបស់លោក Blaz Ruiz បានដាក់ឈ្មោះឲ្យតំបន់នេះថា "Cincas Chagas" គឺជាទីក្រុងនៅព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសចំប៉ាដែលបានចេញឈ្មោះថា "Jacques" (នៃ Chagas) ដោយសារមូលហេតុនៃភ្នំ ៥ ដែលត្រូវបានរកឃើញ និងជាអនុស្សាវរីយនៃសេចក្តីវិនាស ៥យ៉ាងរបស់ព្រះយេស៊ូ (១៥៨៥)។

www.elibraryofcambodia.org

បើតាមលោក Groslier ឈ្មោះរបស់ខេត្តនៅកម្ពុជាក្រោម ដែលរក្សាទុកដោយពួក អេស្ប៉ាញ៉ុល គឺ :

- Barara ឬ Bararan (បារៀឈ្មោះបច្ចុប្បន្ន និងជាខ្មែរបារីយ៉ា (Pâriyâ) ។
- Pratarpan ជាភាសាខ្មែរព្រះត្រពាំង (ត្រាវិញ) ។
- Tran (Treang)

ចំពោះលោក "San Antonio et Jacques" បានរៀបរាប់ទីក្រុង "Milon" ថា ជា វិញឡុង ប៉ុន្តែជាភាសាខ្មែរគឺ "ពញាហោរ" ។ អ្វីដែលបាននិយាយពីមុន គឺ ច្បាស់ជាទឹកដីខ្មែរពិតប្រាកដដែលបានស្គាល់ដោយអ្នកធ្វើដំណើរតាមនាវាជនជាតិព័រទុយហ្គេ ឬ អេស្ប៉ាញ៉ុល ។

## ផ្នែកទី២
## អតីតកាល និងជីវិតរបស់ខ្មែរកម្ពុជាក្រោម

ជីវិតរបស់ប្រជាជនកូសាំងស៊ីន គឺជីវិត ខ្មែរក្រោម បង្កើតបានជាមួយនិងកេរដំណែលពីអតីតកាលរបស់ពួកគេ នូវភស្តុតាងទាំងឡាយដោយត្រឹមត្រូវពិតប្រាកដថា កម្ពុជាក្រោម គឺជារបស់ខ្មែរ ។

នៅក្នុងកំឡុងពេលជាង ១៧សតវត្សរ៍ កម្ពុជាក្រោមត្រូវបានរស់នៅដោយប្រជាជនខ្មែរដោយសុទ្ធសាធ ។ មានតែដល់ដើមសតវត្សរ៍ទី១៨ នោះទេ ទើបមានជនជាតិចិន និងជនជាតិអណ្ណាមបានមកដល់ ដូចដែលយើងបានឃើញនៅក្នុងជំពូកទី២ នៃអត្ថបទសៀវភៅនេះរួចហើយ ។

**គឺប្រជាជនខ្មែរដែលបានកែប្រែទឹកដី កម្ពុជាក្រោម ទៅជាទឹកដីមានជីវជាតិ**

www.elibraryofcambodia.org

**ដោយសារការផ្ដាច់ៗ...មានការបញ្ចូលទឹកទៅក្នុងស្រែជាដើម... ។**

**កុំមានមជ្ឈមណ្ឌលណាមួយ ខេត្តណាមួយ ព្រែកណាមួយ ព្រែកជីកណាមួយ ប្រាសាទណាមួយ វិហារ៉ាមណាមួយ ឬភូមិណាមួយ នៅមានឈ្មោះជាខ្មែរតាមផ្លូវការទេ, បណ្ដាកន្លែងទាំងនោះ ត្រូវបានកែប្រែឈ្មោះដោយពួកអណ្ណាមអស់ហើយ ។**

**គឺជីវិតទំនៀមទម្លាប់ អគ្គការដ្ឋបាល និងសង្គមរបស់ខ្មែរត្រូវតែមានអំណាចពិតប្រាកដណាស់ លើអាផ្ដាររបាំងក៏ដូចជាអណ្ណាមដែលបានកាន់កាប់ប្រទេសនេះ និងដែលត្រូវទទួលស្គាល់នូវលក្ខន្តិកៈជាពិសេសរបស់ កម្ពុជាក្រោម ។**

នៅក្នុងពេលដែលពួកគេចូលមកដល់ទឹកដីខ្មែរ ពួកវៀតណាមបានខិតខំបំបាត់នូវភាពដើមនៃជាតិពន្ធុរបស់អតីតអ្នកកាន់កាប់ ជួនកាលដោយការបង្ខិតបង្ខំធ្វើឲ្យដូចពួកគេ ជួនកាលដោយការវាយរុញច្រាន ។ ប៉ុន្តែនៅចំពោះមុខនៃការតស៊ូរបស់ជនជាតិដើម ពួកគេបានវាយរុញច្រាននៅក្នុងលក្ខណៈផ្សេងៗ ជួនកាលដោយការកម្ទេចទាំងស្រុងនោះ គឺការប្រល័យពូជសាសន៍ ។ គឺដោយសារមធ្យោបាយទាំងនេះហើយ បានជាសាសន៍ចាមត្រូវបានបំផ្លាញឲ្យសាបសូន្យ ។

ពួកគេបានបំបាត់ស្លាកស្នាមនៃវប្បធម៌ និងអារ្យធម៌ខ្មែរ នៅលើទឹកដីទាំងឡាយរបស់កម្ពុជាក្រោម ដើម្បីធ្វើឲ្យក្លាយទៅជាទឹកដីវៀតណាម ។ បញ្ហានេះនៅតែមាននៅឡើយ ។

លក្ខណៈពិសេសរបស់ខ្មែរកម្ពុជាក្រោម គឺមិនអាចលុបបំបាត់បានឡើយ និងអតីតភាពរបស់ខ្លួនត្រូវបានបញ្ជាក់ដោយភស្តុតាងជាច្រើនរាប់មិនអស់ ។

យើងសូមលើកយកនូវភស្តុតាងមួយចំនួននៅក្រោមចំណងជើងដូចតទៅ :

I- ខ្មែរក្រោម ដើមកំណើត, ការចាត់ចែងរដ្ឋបាល ព្រឹត្តិការណ៍សំខាន់ៗ ដែលទាក់ទងពិសតវត្សរ៍ទី១ មកដល់ឆ្នាំ ១៨៤៩ ។

II- ខ្មែរក្រោម នៅក្រោមអាណានិគមវៀតណាម (១៨៤៩-១៨៦២) ។

www.elibraryofcambodia.org

III-ខ្មែរក្រោម នៅក្រោមអាណានិគមបារាំង (១៨៦២-១៩៤៨) ។

IV-ខ្មែរក្រោម នៅក្នុងសម័យបច្ចុប្បន្ន

V- កេរដំណែលពីអតីតកាល និងបុរាណវត្ថុវិទ្យានៃ កម្ពុជាក្រោម (ដីសណ្តទន្លេមេគង្គ) ។

## I. ខ្មែរក្រោម ដើមកំណើត, ការបាត់បង់រដ្ឋបាល ព្រឹត្តិការណ៍សំខាន់ៗដែលទាក់ទង (ពីសតវត្សរ៍ទី១ ដល់ឆ្នាំ ១៨៤៩)

លោក Adhémard Leclère ("សៀវភៅប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" ទំព័រ៩ និង១០ "Historie du Cambodge" p. 9 et 10 ) បានសរសេរថា ប្រជារាស្ត្រដែលបានជួយបង្កើតប្រជាជាតិខ្មែរ បានរស់នៅលើទឹកដីដែលយើងបានហៅនៅពេលបច្ចុប្បន្ន នេះថា "កូសាំងស៊ីន" ។

ប្រសិនបើគេជឿទៅលើរឿងព្រេងដែលទាក់ទងទៅនឹងស្រុកបាសាក់ដែលរៀបរាប់ដោយព្រះតេជគុណ ថាច់ ចាំង (ព្រះសង្ឃខ្មែរក្រោមមួយអង្គ ជាសមាជិកនៃពុទ្ធសាសនបណ្ឌិតរង នៅកូសាំងស៊ីន) នៅក្នុងសៀវភៅរបស់ព្រះអង្គ "ប្រវត្តិសាស្ត្រនៃកូសាំងស៊ីន" (សរសេរដៃជាភាសាខ្មែរ សរសេរចប់នៅថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៤៤ សរសេរជាមួយនឹងកិច្ចសហការរបស់ គណៈកម្មការទំនៀមទម្លាប់របស់ប្រទេសកម្ពុជានៃស្ថាប័នដដែលនេះ និងជាមួយសមាគមនៃវិទ្យាល័យខេត្តឃ្លាំង ការសរសេរដោយដៃដែលបានបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មាន "Le Dépêche du Cambodge" លេខ ១៥៦៥, ១៥៧២ ដែល បានចេញផ្សាយ នៅថ្ងៃទី១៨ និងទី២៨ ខែធ្នូ ឆ្នាំ១៩៦២ និងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ១៩៦៣ ដើមកំណើតរបស់ខ្មែរក្រោមមានឫសគល់តាំងពីយូរណាស់មកហើយ គឺ ដូចលោក Dauphin Meunier បាននិយាយថា "ប្រហែល ២០សតវត្សរ៍ មុន គ្រិស្តសករាជ ពីព្រោះថារឿងព្រេងនេះ ទាក់ទងទៅនឹងប្រទេសគោកធ្លក ។

www.elibraryofcambodia.org

យើងនឹងដកស្រង់នូវអត្ថបទសរសេរដែទាំងនេះ ដែលសរសេរអំពីដើមកំណើត របស់កូសាំងស៊ីន ការចាត់ចែងកិច្ចការរដ្ឋបាលរបស់ខេត្តមួយចំនួន ការពន្យល់ អំពីប៉ាននាមវិទ្ទារបស់កន្លែងមួយចំនួន និងអំពីសកម្មភាព ឬការងាររបស់ចៅហ្វាយខេត្តខ្មែរនៅ កូសាំងស៊ីន ។

**ក)– ដើមកំណើតនៃស្រុកបាសាក់**

ប្រវត្តិសាស្ត្របានប្រព្រឹត្តិទៅនៅក្នុងសម័យព្រះមហាក្សត្រគោកធ្លក ។ នៅខាងត្បូងប្រទេសនៅពេលនោះ គឺមានតែកោះមួយចំនួនដែលបានបាក់បង់នៅក្នុងសមុទ្រ ។

ព្រះអង្គម្ចាស់មួយអង្គ ជាព្រះមហាក្សត្រគោកធ្លក និងបានរៀបអភិសេកជាមួយម្ចាស់ក្សត្រិយាវ ម្នាក់នៅចំប៉ាសាក់ បន្ទាប់ពីការប្រើល្បិចកលមួយដែលដឹកនាំដោយព្រះមហាក្សត្រយានីទី២ នៃប្រទេសចំប៉ាសាក់ ត្រូវបាននិរទេសព្រះកាយ និងនាំទៅជាមួយព្រះអង្គ នូវមនុស្សប្រុសស្រីដែលគេមិនចង់ឃើញមុខចំនួន ៥០០ នាក់ និងទាហាន ៥០០នាក់ក្នុងសំពៅមួយគ្រឿង និងក្បូនពីរដែលហៅថា "ពោងពាយ" បានចុះទឹកទន្លេមេគង្គ ទៅទិសខាងត្បូង ។

មកដល់ជិតកោះមួយដែលកាន់កាប់ដោយអ្នកនេសាទពោងពាយទាំងពីរនេះ និងសំពៅដែលមានព្រះអង្គម្ចាស់ គោកធ្លក និងព្រះអង្គម្ចាស់ក្សត្រិយាវ គង់នៅក្នុងនោះ ក៏បានបែកគ្នាបន្ទាប់ពីមានខ្យល់ព្យុះមួយ ។

ពោងពាយទាំងពីរនេះ និងសំពៅនីមួយៗបានទៅប៉ះកោះខុសគ្នារៀងៗខ្លួន និងស្ថិតនៅឆ្ងាយពីកោះអ្នកនេសាទដែលសំពៅរបស់ព្រះអង្គម្ចាស់បានចូលចត ។ ក្រោយពីធ្វើដំណើរអស់រយះពេលជាច្រើន និងដោយមានជំនួយពីអ្នកនេសាទផងនោះ ព្រះអង្គម្ចាស់អង្គនេះ បានរកឃើញទាហានរបស់ព្រះអង្គ និងមនុស្សផ្សេងៗទៀត ។ កោះទាំង៣ នេះ ត្រូវបានក្លាយទៅជាទឹកដីមានតម្លៃដោយគេបានដាំស្រូវ

www.elibraryofcambodia.org

លូ សវណ្ណក ជាមួយពូជ ដែលព្រះមហាក្សត្រនៅចំប៉ាសាក់ បានដាក់មកឲ្យតាមក្បួន ។

ដោយមានពួកនេសាទនាំផ្លូវនោះ ព្រះអង្គម្ចាស់ បានយាងមកព្រះរាជាណាចក្រគោកធ្លក ជាមួយនឹងមហេសីរបស់ព្រះអង្គ ។ ព្រះបិតារបស់ព្រះអង្គព្រះមហាក្សត្រគោកធ្លក ត្រូវបានគេថ្វាយដំណឹងឲ្យព្រះអង្គជ្រាបអំពីការនិរទេសខ្លួនរបស់ព្រះរាជបុត្ររបស់ព្រះអង្គផង និងអំពីអត្ថិភាពនៃកោះទាំងឡាយ នៅភាគខាងត្បូងដែលមិនទាន់មានមនុស្សរស់នៅ នៅឡើយ ។ ព្រះមហាក្សត្របានជួយព្រះ រាជបុត្ររបស់ព្រះអង្គដើម្បីបង្កើតរដ្ឋធានីមួយដែលព្រះអង្គបានបញ្ជូនប្រជារាស្ត្ររបស់ព្រះអង្គដើម្បីឲ្យទៅរស់នៅទីនោះ ។ តាមការណែនាំរបស់ "ព្រាហ្មបុរោហិត" (ព្រាហ្មដែលចេះវិជ្ជាអាថ៌កំបាំងខាងផ្លូវងងឹត) នោះ ព្រះមហាក្សត្របានដាក់ឈ្មោះឲ្យកោះនិមួយៗនៅក្នុងចំណោមកោះទាំង៣ នេះគឺ

– កោះដែលព្រះអង្គម្ចាស់នៅគោកធ្លក និងព្រះអង្គម្ចាស់ក្សត្រីនៅចំប៉ាសាក់ គង់នៅបានក្លាយទៅជា "កោះចាំសាក់ ឬស្រុកបាសាក់" ។

– កោះទី២ ដែលរស់នៅដោយទាហានលាវចំនួន ៥០០នាក់ មកពីចំប៉ាសាក់ ត្រូវបានហៅថា "ពលលាវ" (ឧទាហរណ៍) វៀតណាមហៅថា "បាក់លីវ" (លោក Malleret បានរាយការណ៍ចំពោះបញ្ហានោះ នូវរឿងនិទានមួយទៀតដែលត្រូវបានរៀបរាប់ ក្រោយពីនេះឆ្ងាយទៅទៀត នៅក្នុងបុរាណវត្ថុវិទ្យា (កម្ពុជាក្រោម) ។

– ទីបញ្ចប់ កោះទី៣ ដែលរស់នៅដោយពួកមនុស្សដែលគេមិនចង់ឃើញមុខ បានទទួលឈ្មោះថា "គ្រួលាវ" បច្ចុប្បន្នហៅភូមិព្រែកកុយ (ខេត្តឃ្លាំង) ។

កោះចាំសាក់ បានតាំងនៅកណ្តាលនៃខេត្ត សុកត្រាំងបច្ចុប្បន្ន ។ រឿងនិទាននេះទាក់ទងទៅនឹងសម័យមួយ (ពីរសហស្សវត្សរ៍ មុនគ្រិស្តសករាជ) ដែលកូសាំងស៊ីន គ្រាន់តែជាឈូងសមុទ្រមួយនោះក៏ដោយ គឺសមជាការពិតណាស់ ។

www.elibraryofcambodia.org

**១)– ដើមកំណើតនៃទីកន្លែងផ្សេងៗ និងវត្តអារាមដែលមានទំនាក់ទំនងជាមួយ និងការកកើតស្រុកបាសាក់**

**១– វត្តប្រាសាទគង់**

នៅលើកោះ "ចាំសាក់" ឬ "បាសាក់" ព្រះអង្គម្ចាស់បានបញ្ជាឲ្យគេកសាងនូវប្រាសាទមួយដែលបច្ចុប្បន្ននេះ មាននៅសល់តែផ្នែខ្លះនៅលើភ្នំដីតូចមួយនៅស្រុកឃ្លាំង ។ ឥឡូវនេះព្រះអង្គបានស្ថាបនាវត្តមួយនៅកន្លែងនេះ ដែលហៅថា "វត្តប្រាសាទគង់" (ឃុំថាមដូង ស្រុកបាយឆៅ ខេត្តឃ្លាំង) ។

ព្រះអង្គម្ចាស់ក៏បានបញ្ជាផងដែរឲ្យកសាងវត្តមួយនៅខាងជើង "ប្រាសាទ"នេះ, ដែលនៅគង់វង្សមកទល់សព្វថ្ងៃនេះ គឺវត្តដែលមានឈ្មោះថា "វត្តហ្លុងបាសាក់" (វត្តរបស់ព្រះមហាក្សត្រនៅបាសាក់ ភូមិបាយឆៅ ខេត្តឃ្លាំង (រ៉ៃសាវ) ។

**២– វត្តបួន ព្រះភ័ក្រ្ត ឬវត្តព្រះនរាយណ៍, របតិយ អ្នកតាសំពៅផ្លាយ, ស្រះប្រុស ស្រះស្រី** (នៅឆ្ងាយទៅទៀតនៅចំណាំងជើង "បុរាណវត្ថុវិទ្យានៃកម្ពុជាក្រោម" មានការបង្កុលបង្ហាញជាច្រើន ដែលបានធ្វើឲ្យលេចចេញនូវរឿងនិទានដែលរៀបរាប់ដោយព្រះតេជគុណ ថាច់ ចាំង និងដែលទាក់ទងទៅនឹងដើមកំណើតនៃខេត្តទាំងឡាយ ឬកន្លែងនានា ឬក៏វត្តអារាមនៅកម្ពុជាក្រោម ត្រូវបានបញ្ជាក់ដោយការរកឃើញរបស់លោក L.Melleret )

តាមរឿងនិទាននេះ "...ព្រះមហាក្សត្រគោកធ្លកទ្រង់បានដឹងថា ព្រះរាជបុត្ររបស់ព្រះអង្គបានកសាងប្រាសាទមួយនៅកោះបាសាក់នោះ ព្រះអង្គបានបញ្ជូននូវរូបបដិមាមួយដែលមានព្រះភក្រ្ត ៤ ដែលព្រះភ័ក្រ្តនីមួយៗតំណាងឲ្យនិមិត្តរូបរបស់ព្រះទាំង៥ ព្រះអង្គ (តាម"ព្រះពុទ្ធ" គេត្រូវតែស្តាប់អាទិទេព ហើយឈ្មោះរបស់ព្រះពុទ្ធសក្យមុនី បានកើតមានបន្ទាប់ពីសម័យដែលមានការទាក់ទងនឹងរឿងនេះ) និងបដិមា ២ ព្រះអង្គគឺ"ទេវរូបព្រះនរាយណ៍" និង"នាង ឧម៉ា ភគវតី"។

www.elibraryofcambodia.org

ចំណែកឯសំពៅវិញ បន្ទាប់ពីខ្យល់ព្យុះមួយបក់បោកក៏បានទៅបះទង្គិចនឹងថ្មនៅឆ្នេរសមុទ្រ និង បានកឿងនៅទីនោះ ។

ដំណឹងនេះបានឮទៅដល់ព្រះអង្គម្ចាស់នៅបាសាក់ ហើយព្រះអង្គបានយាងចាកចេញតាមនាវាមួយគ្រឿងដើម្បីតាមរកសំពៅនេះ ។ ព្រះអង្គបានរកឃើញសំពៅនេះ ហើយបានបញ្ជាឲ្យគេសាងនៅទីកន្លែងនេះ នូវ"វត្តព្រះនរាយណ៍ចេតិយ" បច្ចុប្បន្ននេះហៅថា "វត្ត ព្រះភ័ក្ត្រ ៤" គឺជា "វត្តនៃព្រះភ័ក្ត្រទាំង ៤ របស់ព្រះ" ។ ព្រះអង្គក៏បានឲ្យគេកសាងផងដែរ នូវប្រាសាទមួយ ដើម្បីដាក់តម្កល់ទេវរូបទាំងពីរ គឺព្រះនរាយណ៍ និងឧមាភគវតី ប្រាសាទដែលព្រះអង្គឲ្យឈ្មោះថា "អ្នកតាដូនរាយ" បច្ចុប្បន្នហៅថា "អ្នកតាសំពៅធ្លាយ" ។ នៅជិតប្រាសាទចុងក្រោយនេះ ព្រះអង្គបានឲ្យគេកសាងនូវអាងទឹកពីរ គឺស្រះម្ចាស់ក្សត្រា និងស្រះម្ចាស់ក្សត្របច្ចុប្បន្នហៅថា "ស្រះប្រុស ស្រះស្រី" (L.Malleret រៀបរាប់រឿងមួយផ្សេងទៀតដែលនឹងនិយាយនៅខាងក្រោយទៀត) ។

ប្រវត្តិសាស្ត្ររបស់កុសាំងស៊ីនដែលរាយការណ៍ដោយព្រះតេជគុណ ថាច់ ប៉ាង បានចាប់ផ្ដើមទៅទៀត ចាប់ពីព្រឹត្តិការណ៍របស់ព្រះមហាក្សត្រ សូរិយវង្សទី២ គឺប្រហែលជា ៣០សតវត្សរ៍ ក្រោយពីរឿងនិទានដែលត្រូវបានរៀបរាប់នៅដើមដំបូងនៃសៀវភៅនេះ ។

ប្រសិនបើគេយកតាមលោក Malleret នោះរឿងនិទានដែលទាក់ទងទៅនឹងការបង្កើតស្រុកបាសាក់ គឺស្ថិតនៅក្នុងសម័យ Néolithique (យុគថ្មរលីង) មុនសម័យ "ហ៊្វូណន" ។

**គ)– ការកែប្រែផ្លាស់ប្ដូរ កុសាំងស៊ីន នៅក្រោមរជ្ជកាលព្រះបាទសូរិយាវង្សទី២ (១១១២–១១៦២)**

**បន្ទាយប្រាការ ៤ជំបូង (បន្ទាយដែលមានបាំមយាមមាំមួន, ពលរេហ៍យប់ថ្ងៃ)**

www.elibraryofcambodia.org

តាមសៀវភៅសរសេរដោយដៃរបស់ព្រះតេជគុណ ថាច់ ចាំង ដែលត្រូវយកមកផ្សាយឡើងវិញដោយ (កាសែត La Dépêche du Cambodge 19-12-1962) បានឲ្យដឹងថា តាមបញ្ជារបស់ព្រះបាទសូរិយាវង្សទី ២ ចៅហ្វាយខេត្តបាសាក់ លោកពញាតេជោ បានបង្កើតនូវបន្ទាយប្រាការ ៤ ដែលបន្ទាយនិមួយៗគ្រប់គ្រងដោយមន្ត្រីខ្មែរម្នាក់ គឺ

១- នៅពាម (ហាទៀន) "បន្ទាយពាម" ត្រូវបានគ្រប់គ្រង ដោយ "ពញាមាស" (ដែលក្រោយមកក្លាយទៅជា "បន្ទាយមាស" ឬ "បន្ទាយតាមាស" ដែលពួកអ្នកដំណើរអឺរ៉ុបនៅពាក់កណ្ដាលសតវត្សរ៍ទី១៨ ដែលលោក Pierre Poivre បានកំណត់ដាក់ឈ្មោះថា "ស្ពានតាមាស" (Pontamias) (បុរាណវត្ថុវិទ្យា នៅដីសណ្ដទន្លេមេគង្គ ទំព័រ១៤) ។ នៅសងខាងពាម ដែលមានព្រៃទ្រាំង លោក ពញាមាស បានសាងសង់នូវបន្ទាយប្រាការមួយនៅខាងជើងនៃមាត់ពាមនេះ ។ ចាប់ពីនោះមកកន្លែងដែលហៅថា "ពាមបន្ទាយមាស" និងកន្លែងដែលស្ថិតនៅខាងត្បូងមាត់ពាមនេះ ត្រូវបានហៅថា "ទ្រាំងត្រើយត្បូង" (Latanier au bord sud) ។

២- នៅមាត់ពាមទន្លេបាសាក់ បន្ទាយប្រាការមួយត្រូវបានគ្រប់គ្រងដោយ "ពញាមោះ" ។ អាងទឹកទាំងពីរនេះ ដែលកសាងដោយ ពញាមាស នៅមាននៅឡើយ ។ ចំណែកអាងទឹកនៅខាងត្បូងដែលហៅថា "ស្រះពញាមោះ" បានក្លាយទៅជា "ត្រពាំងតាមោះ" រីឯអាងទឹកនៅទិសខាងជើង ដែលយកតាមឈ្មោះរបស់ភរិយា លោកគឺ "ស្រះជំទាវអុង" បានក្លាយទៅជា "ត្រពាំងដូនអុង" ។

កន្លែងនៃអតីតបន្ទាយប្រាការនេះ បានស្ថិតនៅចម្ងាយ ៣គ.ម ពីខេត្ត "ឃ្លាំង" (សុកទ្រាំង) នៅក្នុងឃុំ ញ៉ាមឡាង (ខេត្តឃ្លាំង) ។

៣- បន្ទាយប្រាការទី៣ នៅខាងកើតបាសាក់នៅក្នុងតំបន់ "ព្រៃ គ" (ព្រៃនៃដើម-គ) គ្រប់គ្រងដោយពញាឱន ។ ព្រះបាទសូរិយាវង្សទី២ បានបញ្ជាឲ្យសាង

www.elibraryofcambodia.org

សង់សាលាសម្រាកមួយ (ពន្លាជ័យ) ។ បន្ទាយដែលមានមុនដំបូងហៅថា "ព្រែក" បានក្លាយទៅជា "ព្រែនគរ" ។

ចំពោះ ពញាឱន លោកបានចុះរហូតដល់មាត់ពាមដូនណៃ ដើម្បីឲ្យសាងសង់នូវបន្ទាយមួយទៀតដែលត្រូវបានដាក់ឈ្មោះរបស់លោកគឺ "បន្ទាយពញាឱន" ដែលក្រោយពីការកាន់កាប់របស់ពួកអណ្ណាមបានឲ្យឈ្មោះថា "យ៉ាំ ឱញ" (យ៉ាំអាចស្របគ្នានឹងពាក្យតា ហើយឱញ គឺជាការអានក្លាយមកពីពាក្យឱន) ។

៤- បន្ទាយទី៤ ស្ថិតនៅលើកោះមួយនៅពាមមេគង្គ គ្រប់គ្រងដោយ "ពញាប្រែង" (ឥឡូវកោះនេះមានឈ្មោះថា កោះតាប្រែង) នៅជិតពាមមេគង្គនៅជិត "ជ្រោយឫស្សីកំពង់លួង" (បេន ថ្រែ ហ្គុងលួង) មានកោះមួយឈ្មោះ "កោះគង" (ពួកវៀតណាមឲ្យឈ្មោះកោះនេះថា ហ្គ័រកុង (Go Cong) មានរបស់បុរាណវត្ថុវិទូ ។

លោក ជុំ ជាតិ (ឈុំ ឈៀក?) នៃកាសែត La Dépêche du Cambodge បានសរសេរថា "បន្ទាយទាំង៤នេះ បានគ្រប ដណ្តប់តំបន់ទាំងអស់ដែលស្ថិតក្នុងតំបន់របស់ពួកគេរៀងៗខ្លួន យូរក្រោយមកបាន ក្លាយទៅជាទីតាំងរបស់ខេត្តទាំង៤ ដែលរួមជាមួយខេត្តបាសាក់ផងនោះ វាបង្កើត បាន ៥ខេត្ត របស់អតីតកូសាំងស៊ីន" ។

### ឃ)- ការរៀបចំឡើងវិញនៅក្រោមរជ្ជកាលរបស់ព្រះអង្គចន្ទទី១

### ព្រះបាទអង្គចន្ទទី១ បានរៀបចំឡើងវិញ នូវទឹកដី កម្ពុជាក្រោម

### ក)- ចៅហ្វាយខេត្តបាសាក់ទាំងពីរ ទេន និង តាត

នៅឆ្នាំ១៥២៨ ព្រះបាទអង្គចន្ទទី១ (ចន្ទដារាជ (Chan darach) បានតែងតាំងពញាទេន ធ្វើជាចៅហ្វាយស្រុកបាសាក់ជាមួយនឹងងារជា "ពញា អាធិករង្ស ទេន" (ការចម្លងត្រឹមត្រូវតាមព្រះតេជគុណ ថាច់ប៉ាង គឺ អាធិករង្ស) ។ ចៅហ្វាយស្រុក

www.elibraryofcambodia.org

បាសាក់បានទទួលមរណភាពនៅឆ្នាំ ១៥៥១ នៅក្នុងអាយុ ៧៣ឆ្នាំ ។

ព្រះអង្គចន្ទ បានតែងតាំង ពញាតាត ឲ្យបន្តវេនពី ពញាទែន និងបានទទួលងារជា "ស្ថិទ្ធភូបាលតាត" ។ នៅក្នុងពេលនោះ ចៅហ្វាយខេត្តថ្មីៗ បានសាងសង់នូវបន្ទាយទាំងឡាយ និងបានរៀបចំស្រុកបាសាក់ឡើងវិញ និងខេត្តទាំងអស់នៅកម្ពុជាក្រោម ។

**១)– ការងាររបស់ ពញាតាត**

នៅក្នុងស្រុកទ្រាំង ពញាតាត បានកសាងបន្ទាយមួយដូចបន្ទាយលង្វែក ដោយមានស្នាមភ្លោះ និងដាំផ្កាំងធ្វើអំពីឫស្សី ។ ក្រោយពីមានទឹកជំនន់មួយមក ស្ថិទ្ធភូបាលតាតបានបញ្ជាដល់ទាហានរបស់លោកដើម្បីកសាងនៅក្នុងទីក្រុងនៃ "ស្រុកទ្រាំង" នូវ "ជង្រុកស្រូវមួយដើម្បីដុក ស្រូវចាំបាច់សម្រាប់ការទទួលទានរបស់អ្នកស្រុកនៅទីងកន្លែង ក្នុងករណីដែលមានការរាំងស្ងួត ឬគ្រោះទុរ្ភិក្ស" ។ គឺ ចាប់ពីសម័យនោះហើយដែលអ្នកស្រុកបានហៅស្រុករបស់ពួកគេថា "ស្រុកឃ្លាំង" ។

នៅឆ្នាំ ១៥៣៣ ស្ថិទ្ធភូបាលតាត បានបង្កើត "វត្តឃ្លាំង" ជាកន្លែងដែលគាត់បានរក្សាទុកនូវអ្វីទាំងអស់ដែលគាត់បានសរសេរ ឬកត់ត្រាទុកអំពីសមិទ្ធផលនានារបស់គាត់ដែលរួមមាន :

- ការកែប្រែស្រុកទ្រាំងទៅជាស្រុកឃ្លាំង
- ការបែងចែកស្រុកឃ្លាំង (កម្ពុជាក្រោម) ទៅជា ៥ខេត្ត ។
- ការរៀបចំកងទ័ពជើងគោក និងកងទ័ពជើងទឹក ។
- ការកំណត់បញ្ជារដ្ឋបាល និងគ្រឿងសញ្ញាវុធរបស់ទាហាន ។
- ទំនៀមទម្លាប់នៃចូលឆ្នាំថ្មី
- ពិធីច្រត់ព្រះនង្គ័លសម្រាប់ដំណាំនៅក្នុងរដូវក្តៅ
- ល្បែងរបស់អ្នកចំបាំង

www.elibraryofcambodia.org

– ពិធីបុណ្យអុំទូក

**គ)– ការរៀបចំកិច្ចការរដ្ឋបាល និងការបែងចែកស្រុកឃ្លាំងទៅជា ៥មណ្ឌលរដ្ឋបាល**

ស្និទ្ធភូបាលតាត បានបែងចែកស្រុកឃ្លាំង (កម្ពុជាក្រោម) ទៅជា ៥ខេត្ត គឺ

១– នៅកណ្ដាល ខេត្តឃ្លាំងជាមួយទីជុំទីក្រុងនៃស្រុកទ្រាំង ឬឃ្លាំងធ្វើជាទីរួមខេត្ត និងទឹកដីទាំងអស់នៃស្រុកឃ្លាំង ។

២– ខេត្តព្រះត្រពាំង បច្ចុប្បន្នខេត្តត្រាវិញ ដោយមានចៅហ្វាយស្រុកម្នាក់ (ប្រធានមណ្ឌល) បានទទួលងារជា "មន្ត្រីសេនា បូរីក្សទេស" ។ ទឹកដីរបស់លោកលាតសន្ធឹងពីទន្លេបាសាក់ទៅដល់ព្រៃដែនអណ្ណាម ។

៣– ខេត្តពលលាវ (តាមលោក Malleret ហៅថា "ប៉ូលាវ") បច្ចុប្បន្នខេត្តបាក់លីវ ដោយមានចៅហ្វាយស្រុកម្នាក់មានងារជា "មន្ត្រីអាជិកសេនា" ។ ខេត្តនេះបានលាតសន្ធឹងពីទន្លេបាសាក់ទៅដល់ "ជ្រោយខ្មែរ" ឬ "ទឹកខ្មៅ" ពួកអតីតអ្នកដំណើរព័រទុយហ្គេបានដាក់ឈ្មោះថា "ជ្រោយ Camboia" នៅក្នុងផែនទីរបស់ពួកគេ ។

៤– ខេត្តក្រមួន ស ដោយមានចៅហ្វាយស្រុកម្នាក់ ដោយមានងារជា "មន្ត្រីពិជិតសេនា" ។ ខេត្តនេះបានលាតសន្ធឹងពី "ជ្រោយខ្មែរ" ទៅដល់បន្ទាយមាស ។

៥– ខេត្តបារ៉ាច ដោយមានចៅហ្វាយស្រុកម្នាក់មានងារជា "មន្ត្រី សេនាពិជ័យសង្គ្រាម" ។ គឺជាខេត្តនៅទិសឧត្តរ ដែលលាតសន្ធឹងរហូតដល់ "អង្គរបូរី" ។

ស្និទ្ធភូបាលបានទទួលមរណភាពនៅក្នុងអាយុ ៩៨ឆ្នាំ ។

កូនប្រុសរបស់លោកឈ្មោះ ឧកញ៉ា អាជិកវង្សា ឡុង បានបន្តវេនពីលោក (ការបន្តវេនបានធ្វើពីឪពុកមកកូនដោយមានការយល់ព្រមពីព្រះមហាក្សត្រ) ។

**ង)– ការគ្រប់គ្រង កម្ពុជាក្រោម ក្រោយរជ្ជកាលរបស់ព្រះអង្គចន្ទទី១**

ព្រះតេជគុណ ថាច់ ចាំង បាន ផ្ដោតទៅលើ "ប្រវត្តិសាស្ត្ររបស់ក្រុងកម្ពុជា"

www.elibraryofcambodia.org

ដែលបានតម្កល់ទុកនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ (ព្រះរាជពង្សាវតាក្រុងកម្ពុជា ច្បាប់ស្លឹករឹតនៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ) បានរៀបរាប់ឡើងវិញនូវហេតុការណ៍ជាប្រវត្តិសាស្ត្ររបស់កម្ពុជាក្រោមដោយបានផ្តល់នូវភាពត្រឹមត្រូវទាក់ទងទៅនឹងចៅហ្វាយខេត្ត ឬក៏អនុក្សត្រជាអ្នកបន្តវេនពញាតាត ហើយនិងឧបាយកលរបស់អណ្តាម ដើម្បីកាន់កាប់កម្ពុជាក្រោមរហូតទល់នឹងការមកដល់របស់បារាំង ។

## ១–នៅក្រោមអំណាចរបស់ឧកញ៉ា អាធិករវង្សា ឡុង

នៅឆ្នាំ ១៥៥៦ នៅក្រោមរជ្ជកាលរបស់ព្រះបរមឥន្ទ្ររាជា (១៥៥៦–១៥៦៧) "ឡុង" ជាកូនប្រុសរបស់ស្និទ្ធភូបាលតាត ត្រូវបានតែងតាំងជាចៅហ្វាយខេត្ត (ឬអនុក្សត្រ) នៅកម្ពុជាក្រោមដោយបានទទួលងារជា "ឧកញ៉ា អាធិករវង្សា ឡុង" ។ ងាររបស់ចៅហ្វាយខេត្តកម្ពុជាក្រោមនេះ បានស្ថិតនៅរហូតដល់អ្នកបន្តវេនផ្សេងៗ ទៀតរបស់ឧកញ៉ាឡុង ដោយរាប់តាំងពីសម័យនោះមក ។ នៅក្រោមអំណាចរបស់គាត់ កម្ពុជាក្រោមបានស្គាល់សន្តិភាព និងសេចក្តីរុងរឿង ។

លោកឧកញ៉ា ឡុង បានទទួលមរណភាពនៅក្នុង អាយុ ៨៩ឆ្នាំនៅក្រោមរជ្ជកាលរបស់ព្រះជ័យជេដ្ឋាទី២ (១៦២០) លោកពុំមានកូនប្រុសបន្តវេនបទ ។

## ២– នៅក្រោមអាជ្ញាធរ ម៉ឺនជ័យ

ម៉ឺនជ័យ ត្រូវបានតែងតាំងជា "ចៅហ្វាយស្រុក ស្រុកបាសាក់" (នៅពេលនោះបាសាក់ ដំណាងឲ្យ កម្ពុជាក្រោម ទាំងអស់) នៅក្រោមងារជា "ឧកញ៉ា ទេសវង្សា" តែងតាំងដោយព្រះបាទ ជ័យជេដ្ឋាទី២ ដើម្បីជំនួសឧកញ៉ា ឡុង ។

ឧកញ៉ា ទេសវង្សាជ្យ បានទៅកាន់ពលលាវ (បាក់លីវ) ជាកន្លែងដែលគាត់បានកសាងបន្ទាយមួយ (បន្ទាយសីមា) នៅភូមិ "ខ្វែងខ្សាច់" និងបានកត់ត្រានៅលើ Olles នូវហេតុការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៃរដ្ឋាភិបាលរបស់លោក ។

www.elibraryofcambodia.org

-"នៅឆ្នាំ១៦២៣ ព្រះចៅក្រុងវេ ព្រះនាម "ង្វៀង សាយវឿង" បានស្នើសុំព្រះមហាក្សត្រកម្ពុជានូវភាគខ្លះនៃទឹកដីព្រៃនគរ ដើម្បីធ្វើការហ្វឹកហាត់ទាហាននៅក្នុងរយៈពេល ៥ឆ្នាំដើម្បីត្រៀមវាយចិន" ។

- នៅក្រោមរជ្ជកាលរបស់ព្រះជ័យជេដ្ឋាទី២ (១៦១៨-១៦២៦) គេបានសង្កេតឃើញថា នៅក្នុងខេត្តនីមួយៗរបស់កម្ពុជាក្រោមនូវ "ជនជាតិអណ្ណាមមួយចំនួន" ។ ព្រះមហាក្សត្របានរៀបអភិសេកព្រះអង្គម្ចាស់ក្សត្រីរបស់ព្រះមហាក្សត្រក្រុងវេ ហើយបានផ្តល់កិត្តិយសតម្លើងឋានៈជា "សម្តេចព្រះភគវតី វរក្សត្រី" (ឆ្នាំ១៦១៨) ។

- ព្រះបាទជ័យជេដ្ឋាទី២ បានឆ្លើយយល់ព្រមចំពោះ "ស្តេចក្រុងវេ" ដើម្បីអនុញ្ញាតឲ្យធ្វើការហ្វឹកហាត់ទាហាននៅកោះក្របី (ព្រៃនគរ) នៅក្នុងរយៈពេល ៥ឆ្នាំ ។

- ពីឆ្នាំ ១៦៤៥ ដល់ឆ្នាំ ១៦៥៦ មន្ត្រីជាន់ខ្ពស់ទាំងឡាយ និងព្រះមហាក្សត្រចៅពញាចន្ទ ស្តេចបន្ទវេនទី៤ (ពីព្រះបាទជ័យជេដ្ឋាទី២ បានតវ៉ាចំពោះ "ព្រះចៅក្រុងវេ អណ្ណាមក្នុក" នូវដីកោះក្របីដែលព្រះជ័យជេដ្ឋាទី២ បានឲ្យខ្ចី ។ ដោយល្បិចកលរបស់មហាក្សត្រិយអណ្ណាម "ព្រះភគវតី វរក្សត្រីយ៍" នោះ, ការតវ៉ានេះបានក្លាយទៅជាអសារឥតការ ។

នៅឆ្នាំ ១៦៥៦ នៅក្នុងឱកាសនៃការជ្រួលច្របល់កើតឡើងនៅព្រៃនគរ មហាក្សត្រិយ៍អង្គនេះ បានទទួលការអន្តរាគមន៍ដោយកងទ័ពរបស់ "ព្រះចៅក្រុងអណ្ណាមក្នុក" នោះ ពួកវៀតណាមបានដណ្តើមយកដោយកម្លាំងទ័ព ។ មុនដំបូងដណ្តើមបានមួយផ្នែក នៃទឹកដីព្រៃនគរ និងក្រោយមកដណ្តើមបានខេត្តផ្សេងៗទៀតនៃទឹកដីកម្ពុជាក្រោម ។ ការប្រយុទ្ធតស៊ូរបស់កម្ពុជាប្រឆាំងនឹងពួកឈ្លានពានវៀតណាមបានចាប់ផ្តើមតាំងពីសម័យនោះមក ។

www.elibraryofcambodia.org

នៅឆ្នាំ ១៦៥៦ ព្រះមហាក្សត្រអណ្ណាម បានត្រួតត្រាតែផ្នែកខ្លះនៃទឹកដីសាយហ្គន ។ ប្រជាជនកម្ពុជានៅតែបន្តគ្រប់គ្រងខេត្តកូសាំងស៊ីននៅឡើយ ហើយដែលព្រះមហាក្សត្រខ្មែរ បានបន្តតែងតាំងចៅហ្វាយខេត្ត ។

ចំពោះបញ្ហានេះ គេត្រូវតែកត់សម្គាល់លំនាំតាមលោក Moura និងលោក Leclère បានឲ្យដឹងថា ស្តេចអណ្ណាមបានស្នើសុំព្រះ ជ័យជេដ្ឋាទី២ ឲ្យអនុញ្ញាតបង្កើតគ្រឹះស្ថានពាណិជ្ជកម្មនៅ ព្រៃនគរ នៅក្នុងពេលនោះ បើតាម "ពង្សាវតារបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ" គឺជាការអនុញ្ញាតឲ្យធ្វើការហ៊ឹកហ្វឺនកងទ័ពនៅកោះក្របីដែលស្តេចអណ្ណាមបានស្នើសុំ ។

ទោះជាយ៉ាងណាក៏ដោយ លោក Moura បានគូសបញ្ជាក់ថា "គ្មានការអនុញ្ញាតជាផ្លូវការណាមួយ និងគ្មានសន្ធិសញ្ញាត្រឹមត្រូវតាមច្បាប់ណាដោយបានធ្វើអន្តរាគមន៍ ដើម្បីដោះស្រាយឲ្យបានត្រឹមត្រូវតាមច្បាប់នូវការកាន់កាប់ជាមួយខ្លួនដោយពួកអណ្ណាមនូវប្រទេសដីធំទូលាយ និងមាននេះទេ" ។

ព្រះតេជគុណ "ថាច់ ថាំង" បានបញ្ជាក់ថា "ម៉ឺនជ័យ ឧកញ៉ា ទេសវង្សា" បានទទួលមរណភាពនៅក្នុងជន្មាយុ ៨៣ឆ្នាំ នៅក្រោមរជ្ជកាលរបស់ "ព្រះអង្គច័ន្ទ" ជាស្តេចចូលសាសនាជ្វា (រាមាធិបតីចន្ទ)(១៦៤២-១៦៥៩)។ ម៉ឺនជ័យបានតែងតាំងប្អូនប្រុសរបស់ខ្លួន ចៅពញាពេជ្រ ធ្វើជាចៅហ្វាយខេត្តបាសាក់នៅក្នុងឆ្នាំ ១៦៥៥ ។

ចៅពញាពេជ្រ បានរស់នៅឯ "វ៉ុងខ្សាច់" ដែរ នៅក្នុងខេត្តពលលាវ ។ លោកបានទទួលមរណភាពនៅក្នុងអាយុ ៧៥ឆ្នាំ ។

**៣- ចៅពញា ម៉ៅ**

"ពញាម៉ៅ" បានបន្តវេនពីឪពុករបស់ខ្លួន ចៅពញាពេជ្រ នៅក្រោម រជ្ជកាលរបស់ព្រះបាទ បរមរាជាទី៣ (១៦៦០-១៦៧២) ។ "ពញាម៉ៅ" បានទទួលមុខងារជា "ឧកញ៉ា អាធិកវង្សា" និងបានកសាងនូវបន្ទាយសីមាមួយទៀតនៅ "ពុតឆ្វេ"

www.elibraryofcambodia.org

នៅ ក្នុងខេត្តពលលាវ ដែលលោកបានទទួលមរណភាពនៅក្នុងអាយុ ៩៨ឆ្នាំ ដោយបាន បន្សល់ទុកកូនប្រុសម្នាក់ឈ្មោះ "ម៉ឺនតាត" ។

### ៤- ម៉ឺនតាត

នៅឆ្នាំ ១៧១៦ នៅក្រោមរជ្ជកាលរបស់ "ព្រះបាទស្រី ធម្មារាជា" នៅក្រោមការគំរាមកំហែងរបស់ពួកអ្នកលុកលុយអណ្ណាម "ម៉ឺនតាត" ដែលត្រូវបានតែងតាំងជាចៅហ្វាយខេត្ត បន្ទាប់ពីឪពុករបស់ខ្លួននោះ បានបង្ខំចិត្តផ្លាស់រដ្ឋធានីរបស់ខ្លួននៅ "ពុតថ្លៃ" (ពលលាវ) ទៅនៅឃ្លាំងវិញ ដែលជាអតីតទីក្រុងរបស់ "ស្ដិទ្ធកុបាលតាត", ទីនេះមានយុទ្ធសាស្ត្រល្អជាង ។

"ម៉ឺនតាត" បន្ទាប់ពីបានទៅតាំងនៅខេត្តឃ្លាំងរួចហើយ បានប្រឈមមុខនឹងឧក្ខាមកម្មរបស់មនុស្សម្នាក់ឈ្មោះ "ស្នងលិន" ប្រហែល ១០ឆ្នាំ (នេះបើតាម) ព្រះចៅ អធិការវត្ត ពានសិរីទ្ធិ (ឬសំបូទ្ធិ (ខេត្តឃ្លាំង) ។

"ម៉ឺនតាត" បានធ្វើឲ្យប្រទេសមានសន្តិភាព យកចិត្តទុកដាក់និងការងារសង្គម និងសាសនា និងការរៀបចំទឹកដី ។ លោកបានអញ្ជើញទៅ កម្ពុជាណាចក្រដើម្បីនិមន្តព្រះសង្ឃដែលមានការចេះដឹងជ្រៅជ្រះ ដើម្បីមកបង្រៀន "ធម្មវិន័យ" ដល់ព្រះពុទ្ធសាសនិកជននៅកម្ពុជាក្រោម ។

"ម៉ឺនតាត" បានទទួលមរណភាពនៅក្នុងអាយុ ៩០ឆ្នាំ បន្សល់ទុកកូនប្រុសម្នាក់ឈ្មោះ សូរ ។

### ៥- ពី ម៉ឺនសូរ ទៅ ម៉ឺនណែម

ម៉ឺនសូរ ជំនួសឪពុករបស់លោកនៅឆ្នាំ ១៧៥៨ នៅក្រោមរជ្ជកាលរបស់ព្រះស្រីសុរិយោពណ៌ (ព្រះឧទ័យទី២ ១៧៥៨-១៧៧៥) ។ ម៉ឺនសូរបានតវ៉ាប្រឆាំងការលុកលុយរបស់អណ្ណាមនៅក្នុងតំបន់ស្រាម (បាយឆៅ) និងបានផ្ញើរបាយការណ៍ទៅថ្វាយព្រះមហាក្សត្រនៃប្រទេសកម្ពុជាដើម្បីទទួលបាននូវកម្លាំងបន្ថែមដើម្បីប្រយុទ្ធ

www.elibraryofcambodia.org

ជាមួយពួកអណ្ណាម ។

គឺជាការចាប់ផ្ដើមនៃសង្គ្រាមដែលប្រទេសកម្ពុជាត្រូវទ្រាំទ្រប្រឆាំងនឹងប្រទេសជិតខាងទាំងពីររបស់ខ្លួន សៀមនៅទិសខាងជើង និងទិសខាងលិច អណ្ណាមនៅទិសខាងត្បូងដែលបានវាយប្រហារនៅក្នុងពេលជាមួយគ្នា ។

"ម៉ឺនសួរ" មិនបានទទួលនូវកម្លាំងបន្ថែមគ្រប់គ្រាន់ដើម្បីបណ្ដេញពួកអ្នកលុកលុយនៅកម្ពុជាក្រោមនោះឡើយ។ លោកបានទទួលមរណភាពនៅក្នុងអាយុ ៧១ឆ្នាំ ។

កូនប្រុសរបស់លោក ឈ្មោះ "ម៉ឺនណៃម" បានជំនួសលោកនៅក្នុងឆ្នាំ ១៧៩៦ នៅពេលព្រះបាទ "អង្គអេង" បានសោយទិវង្គត ។ ពេលនោះប្រទេសកម្ពុជាបានឆ្លងកាត់នូវដំណាក់កាលដ៏លំបាក ដែលបានបន្តនៅក្នុងអន្តររជ្ជកាល (១៧៩៦-១៨០៦) នៅក្រោមរជ្ជកាលរបស់ព្រះបាទអង្គច័ន្ទ (ទី២) (១៨០៦-១៨៣៤) និងនៅក្រោមរជ្ជកាលរបស់ "ម្ចាស់ក្សត្រីយអង្គម៉ី" (១៨៣៤-១៨៤១) ។

ពួកវៀតណាមបានឆ្លៀតឱកាសនៃការវឹកវរផ្ទៃក្នុងនៃប្រទេសកម្ពុជា និងសង្គ្រាមដែលប្រទេសកម្ពុជាបានធ្វើជាមួយសៀម និងភាពទន់ខ្សោយរបស់ព្រះមហាក្សត្រីយក្មេងនោះ ដើម្បីវាយប្រហារកម្ពុជាក្រោម និងបានលុកលុយកម្ពុជា ក្រោម ។

ថ្វីបើទាំងនៅប្រទេសកម្ពុជាក្រោមក៏ដោយ ក៏ពួកវៀតណាមមិនបានសម្រេចការដាក់បង្ខំចាប់អាជ្ញាធរកម្ពុជានោះឡើយ គឺអាជ្ញាធរកម្ពុជាបានបន្តគ្រប់គ្រងជនរួមជាតិរបស់ខ្លួនដដែល ។

"ម៉ឺនណៃម" ដែលបានរក្សាការតស៊ូទល់នឹងកងទ័ពអណ្ណាមនោះ បានទទួលមរណភាពនៅក្នុងអាយុ ៨៩ឆ្នាំ ។

**ខ)- ព្រឹត្តិការណ៍របស់ព្រះអង្គដួង ចៅហ្វាយសុខ និងការធ្វើអាណានិគមនិយមវៀតណាម**

www.elibraryofcambodia.org

"ម៉ឺនសុខ" បានជំនួសឪពុករបស់ខ្លួននៅដើមរជ្ជកាល "ព្រះអង្គដួង" នៅក្នុងឆ្នាំ ១៨៤១ ។

ព្រះមហាក្សត្រ "អង្គដួង" (តាមការស្នើសុំពីចៅហ្វាយស្រុក) ព្រះអង្គបានច្រាប់ដាច់ចៅហ្វាយស្រុករូបនេះថា "មិនមានសន្ធិសញ្ញាណាមួយ ពុំមានអនុសញ្ញាណាមួយត្រូវបានសម្រេចដោយព្រះមហាក្សត្រខ្មែរអង្គណាមួយ ដើម្បីប្រគល់ទឹកដីកម្ពុជាក្រោមទៅឲ្យអណ្ណាមនោះឡើយ ។ ប្រសិនបើមានសន្ធិសញ្ញា ឬក៏អនុសញ្ញានោះ គឺសុទ្ធតែក្លែងក្លាយ" ។

សេចក្តីប្រកាសទាំងនេះរបស់ "ព្រះអង្គដួង" ត្រូវបានកត់ត្រាទុកដោយចៅហ្វាយសុខនៅក្នុងជីវប្រវត្តិរបស់ខ្លួនដែលសរសេរនៅលើ Olles ប៉ុន្តែជាអកុសលសំណេរ នេះត្រូវបានចេះនៅក្នុងសង្គ្រាមឆ្នាំ ១៩៤៥ ។

នៅក្រោមរដ្ឋាភិបាលរបស់ចៅហ្វាយសុខ ប្រជាជនកម្ពុជានៅកូសាំងស៊ីន បានប្រមូលផ្តុំគ្នាបានរៀបចំដើម្បី បណ្តេញពួកអ្នកលុកលុយពីទឹកដីរបស់ពួកគេ ។ ព្រះតេជគុណ ថាច់ ចាំង បានរៀបរាប់ការប្រយុទ្ធកសិនេះដូច្នេះថា :

**ង)– ការហ៊ុំព័ទ្ធនិវេសនដ្ឋានរបស់ចៅហ្វាយខេត្ត ឃ្លាំង ដោយកងទ័ពអណ្ណាមរបស់ឧត្តមសេនីយ៍ ប៊ិញប៊ីយ និង ឡាញ់ស៊ីម :**

នៅឆ្នាំ ១៨៤១ ឧកញ៉ា "អាធិកវង្សា សុខ" បានទទួលនូវការណែនាំទាំងអស់ដើម្បីរៀបចំការ ការពារកម្ពុជាក្រោម ។

ពីរ ឬបីឆ្នាំក្រោយពីការវិលត្រឡប់របស់លោកមកពីឧត្តុង្គមានជ័យវិញ កងទ័ពអណ្ណាមដែលបញ្ជាដោយឧត្តមសេនីយ៍ ប៊ិញប៊ីយ និង ឡាញ់ស៊ីម បានឡោមព័ទ្ធលំនៅស្ថានចៅហ្វាយខេត្តនៅឃ្លាំងបង្ខំឲ្យលោកចៅហ្វាយខេត្តចូលរួមអនុវត្តន៍និងគោរពតាមច្បាប់អណ្ណាម ហើយដើម្បីឲ្យសម្រេចបាននូវគោលបំណងនេះឧត្តមសេនីយ៍អណ្ណាមបានផ្ញើសារាចរទៅឲ្យប្រមុខខេត្តទាំងអស់នៅកម្ពុជាក្រោម ។

www.elibraryofcambodia.org

អាជ្ញាធរ និងប្រជាជនកម្ពុជាក្រោមបានបដិសេធ មិនព្រមស្តាប់បង្គាប់តាម ឡើយ ហើយបានរៀបចំការតស៊ូឡើង ។

**១- សឺកសេនាទា**

បានដឹកនាំការប្រយុទ្ធប្រឆាំងពួកវៀតណាមក្នុងរយៈពេល ៣ឆ្នាំ ។

នៅឆ្នាំ ១៨៤៦ បុរសម្នាក់នៅ "ខេត្តទ្រាំង ត្រើយជើង" ដោយបានដឹងអំពីការ ឡោមព័ទ្ធនិវេសនដ្ឋានរបស់ចៅហ្វាយខេត្ត សុខ បានទៅកាន់ព្រែកតាកូន ប្រមូល ពួកអ្នកស្ម័គ្រចិត្ត និងហ្វឹកហ្វឺនពួកគេ ដើម្បីប្រយុទ្ធជាមួយពួកអណ្ណាម ។ ឧត្តម សេនីយ៍ វៀតណាមទាំងពីរនាក់បានទទួលជោគជ័យពីព្រោះមានជំនួយពី "Ong Tong Doc" នៅមាត់ជ្រូកនូវកងទ័ពបន្ថែមដែលមានទាហានអណ្ណាម និង ទាហាន ផ្សារនៅ លង់ហោរ ផ្សារដែក និង មីថ ។

នៅក្នុងអំឡុងពេល ៣ឆ្នាំនៃការតស៊ូ "សេនាទា "បានទៅកាន់ពាមទឹកសាប និង ព្រែកពលលាវ ដើម្បីជ្រើសរើសកងទ័ព លោកបានធ្លាក់ទៅក្នុងការពួនស្ទាក់មួយ របស់អណ្ណាម ដែលនៅក្នុងអំឡុងពេលនោះ លោកបានពលីជីវិត ទាហានរបស់ លោកបានយកលោកទៅបូជានៅវត្ត ខ្វែងបវែល (ខេត្តពលលាវ បាក់លីវ) ។

**២- សេនា សួស**

ក្រោយពីមរណភាពរបស់ "សេនាទា" បងលោកឈ្មោះ សេនា ម៉ាន (មាន់) បានកាន់កាប់ជាមេបញ្ជាការនៃកងទ័ពតស៊ូ ។ "សេនា សួស" បានទៅចូលរួម ជាមួយលោក ។

បើតាមព្រះតេជគុណ ថាច់ ប៉ាង ថា: "លោក សួស" មានដើមកំណើតនៅបាភ្នំ ជាអតីតសត្រូវរបស់ពួក "ផ្វា" គាត់មានដាវមួយគួរឲ្យខ្លាច ឈ្មោះ "ដាវ ទូលព្រះ ធរណី" (ដែលមានបណ្តោយមួយម៉ែត្រកន្លះ ហើយដែលមនុស្សពីរនាក់លើក ដោយលំបាក) ។ "លោក សួស" បានប្រមូលមនុស្សរបស់គាត់ និងជាមួយកងទ័ព

www.elibraryofcambodia.org

របស់ លោក មាន់ បានសម្លាប់វគ្គិលទាហានអណ្ណាម និងទាហានផ្សា ដែលស្ថិតនៅក្នុងសំពៅចំនួន ១០នៅ "ព្រែកអំពៅយារ " នៅមុខខេត្តឃ្លាំង ។

សេនា សួស បានសម្លាប់ អុងបិញប៊ីយ នៅមាត់ព្រែកអំពៅយារ និងបានធ្វើដំណើរទៅកាន់ឃ្លាំង ។ នៅចម្ងាយ ២គីឡូម៉ែត្រពីមជ្ឈមណ្ឌលនេះ គាត់បានផ្ញើលិខិតមួយច្បាប់ជាសម្ងាត់ទៅឲ្យឧកញ៉ា "អាធិកវង្សាសុខ" ដែលនៅជាអ្នកទោសរបស់អណ្ណាមនៅឡើយនោះ ។ ឧត្តមសេនីយ៍ អណ្ណាម ចាប់បានលិខិតនេះ និងបានបញ្ជូនកងទ័ពមួយទៀតទៅប្រចាំងលោក សួស ដែលកងទ័ពនោះរួមមានទាហាន អណ្ណាម និងទាហានផ្សា បញ្ជាដោយ "សេនាផ្សា" ទូន អេក, ទូន ជូ, ទូន ម៉ាច និង ទូន ឡូ ។ សេនា សួស បានបង្វែងដានកងទ័ពនេះ និងបានសម្លាប់សេនាផ្សាទាំង ៤ នាក់នេះ ។

ឧត្តមសេនីយ៍អណ្ណាមម្នាក់ទៀត "អុងឡាញ់កាង" បានជួយ អុងឡាញ់ស៊ីម ដើម្បីប្រមូលកងទ័ពថ្មីប្រយុទ្ធជាមួយ "សេនាសួស" ដោយមានកលយុទ្ធដ៏ប៉ិនប្រសប់ "សួស" បានបញ្ជាដល់មនុស្សរបស់គាត់ឲ្យពួននៅត្រើយខាងត្បូងនៃ "ព្រែកអំពៅយារ" ចំណែកគាត់បានឆ្លងព្រែកជាមួយ "សេនាឯក" ទាំងពីរនាក់របស់គាត់ គឺមេរយ "ស៊ីវ" និងមេពាន់ "សុខ" ដើម្បីទៅកាន់ទិសខាងជើង ។ ពួកអ្នកស្រុកបានរៀបរាប់ថា ពួកគេបានឃើញ "សេនាសួស" ស្លៀកសំពត់ហូល និងអាវតេជះ "មេរយស៊ីវ" និង "មេពាន់សុខ" បានស្លៀកខោជើងខ្លី ជាមួយ និងអាវតេជះពណ៌ក្រហម ។ "សេនាសួស" បាន់ទទួលជោគជ័យក្នុងការសម្លាប់ជនជាតិអណ្ណាមមួយចំនួនធំ និងកាប់ឧត្តមសេនីយ អុងឡាញ់ស៊ីម ជាពីរកំណាត់ ។

### ៣– សេនាសួស វីរបុរសជាតិ ស្លាប់នៅលើសមរភូមិ

ជនជាតិផ្សា ម្នាក់ជាទាហានរបស់ អុងឡាញ់កាង ដែលភ័យតក្កមា ក្រោយពីការស្លាប់របស់អុង ឡាញ់ស៊ីម បានស្នើឧត្តមសេនីយ៍អណ្ណាម "បំពុលសេនាសួស" ។ អុងឡាញ់កាង បានយល់ព្រម ហើយជនជាតិផ្សារូបនេះឈ្មោះ "ត្រូ ទូន ម៉ាត់" ក្លែង

www.elibraryofcambodia.org

ខ្លួនធ្វើជាអ្នកស្រុកបាសាក់ ចូលធ្វើទាហាននៅក្នុងកងទ័ពលោក "សេនាសួស" និង បានទទួលជោគជ័យក្នុងការដាក់ថ្នាំបំពុលឲ្យ "សេនាសួស" ផឹក ។

ដោយវៀតបានព័ត៌មាននេះ អុងឡាញ់កាង បានមកដល់ជាមួយនិងកងទ័ពដ៏ខ្លាំងដែលបញ្ជូនមកដោយព្រះមហាក្សត្រអណ្ណាម ។

"សេនា សួស" បានផ្លាក់ខ្លួនឈឺជាទម្ងន់ មានឈាមហូរចេញតាមមាត់ និងតាមច្រមុះ គាត់បានផ្តល់ការណែនាំជាចុងក្រោយដល់សេនាឯកទាំងពីរ និងកងទ័ពរបស់គាត់ ហើយឲ្យគេដឹកគាត់ទៅសមរភូមិប្រយុទ្ធ "ព្រោះសេនាម្នាក់ដែលសមនឹងទទួលបាននូវគោរមងារនេះ ត្រូវតែស្លាប់នៅក្នុងការប្រយុទ្ធ" គាត់បាននិយាយដូច្នេះ ទៅកាន់កងទ័ពរបស់គាត់ដែលត្រូវតែចងចាំ ។ លោក "សេនាសួស" បានបន្ថែមទៀតថា **"ខ្ញុំមិនស្តាយទេជីវិត ប៉ុន្តែខ្ញុំស្តាយមាតុភូមិរបស់ខ្ញុំ ហើយខ្ញុំត្រូវតែស្លាប់ ជាជាងស្ថិតនៅក្រោមការត្រួតត្រារបស់ពួកបរទេស"...** ។

តាំងពីពេលព្រឹកព្រលឹមរហូតដល់ថ្ងៃត្រង់ "សេនាសួស" និងកងទ័ពរបស់លោកបានប្រយុទ្ធ និងបានសម្លាប់ទាហានអណ្ណាម និងទាហានជ្វាយ៉ាងវគ្គលហាលផ្សៀត ។ ជាអកុសលមានភ្លៀងមួយមេធំបានធ្លាក់លើសមរភូមិដែលបានធ្វើឲ្យស្ថានភាពរបស់ "សេនាសួស" កាន់តែធ្ងន់ធ្ងរឡើង ហើយលោកក៏បានស្លាប់ទៅ ។

លោក សួស ទទួលមរណភាព ។ ការប្រយុទ្ធគ្នាបានបញ្ចប់ប្រជាជនកម្ពុជា បានដឹកសពវីរបុរសជាទីស្រឡាញ់របស់ពួកគេ ដើម្បីយកទៅបូជានៅមាត់ព្រែកមួយនៅក្នុងកន្លែងមួយដែលអ្នកស្រុកបានហៅ ថា ភូមិ "ដៃតាសួស" ស្ថិតនៅក្នុងឃុំភូមិ (ខេត្ត ឃ្លាំង បច្ចុប្បន្ន សុកទ្រាំង) ។

នៅពេលនោះ ពួកវៀតណាមបានកាន់កាប់ស្ទើរទាំងអស់លើកូសាំងស៊ីន ។ ឧត្តមសេនីយ៍ អុងឡាញ់កាង បានដោះលែង "អាធិកវង្សាសុខ" និងបានតែងតាំងជា "អុងភូ" (Ong Phou) ដើម្បីឲ្យគាត់បន្តគ្រប់គ្រងប្រជាជនកម្ពុជានៅបាសាក់ ។

www.elibraryofcambodia.org

ចំណែក "មន្ត្រី" នៅតាមខេត្តផ្សេងៗទៀត គេបានចាត់តាំងជា "កាយតុង" (Kay Tong) ហើយកម្ពុជាក្រោមបានទទួលឈ្មោះថា "ណាមគី" (ប្រទេសខាងត្បូង) ។ ដូច្នេះពួកវៀតណាម បានដាក់បង្ខំរបបអាណានិគមរបស់ពួកគេចាប់តាំងពីសម័យនោះមក បើតាមព្រះតេជគុណ ប៉ាង គឺចាប់តាំងពីឆ្នាំ ១៨៤៩ ។

រឿងនិទានរបស់ព្រះតេជគុណ ថាច់ ប៉ាង ប្រមូលចងក្រងពីប្រភពដ៏ល្អៗពីព្រោះថា អ្នកនិពន្ធគឺជាអ្នកស្រុករបស់ប្រទេសដែលបានរាយការណ៍ពីប្រវត្តិសាស្ត្របញ្ជាក់ពីសាក្សីដែលប្រមូលបានពីអ្នកប្រវត្តិសាស្ត្រផ្សេងៗទៀត ។ **គេបានបញ្ជាក់ដូចអ្នកទាំងនេះដែរថា : កូសាំងស៊ីន គឺជារបស់ព្រះរាជាណាចក្រកម្ពុជា ។**

II- **ខ្មែរក្រោម នៅក្រោមអាណានិគមនិយមវៀតណាម (១៨៤៩-១៨៦២)**

កាលបរិច្ឆេទឆ្នាំ ១៨៤៩ ដែលផ្តល់ដោយព្រះតេជគុណ ថាច់ ប៉ាង ដែលជាចំណុចចេញដំណើរនៃរបបអាណានិគមអណ្ណាមនៅកម្ពុជាក្រោមនោះ គឺស្របទៅតាមសេចក្តីរាយការណ៍របស់សៀវភៅ "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជារបស់លោក d'Adhémard Leclère (ទំព័រ ៤៣៤ និងទំព័របន្តបន្ទាប់) ។ ពួកវៀតណាមមិនបានសម្រេចការដាក់បង្ខំអំណាចរបស់ពួកគេទៅលើខ្មែរក្រោមនៅមុនឆ្នាំ ១៨៤៧ នោះទេ ។

មុនកាលបរិច្ឆេទនេះ អណ្ណាម និងសៀម បានចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ ១៨៤៦ ដែលបាននាំទៅដល់ការបញ្ចប់នូវភាពជាសត្រូវរវាងសៀម និងអណ្ណាម ។ នៅលើទឹកដីខ្មែរ ពួកអាជ្ញាធរអណ្ណាម បានចាប់ផ្តើមអនុវត្តវិធានការបញ្ចូលវប្បធម៌ឲ្យការប្រព្រឹត្តិរបស់ខ្មែរឲ្យដូចប្រជាជនវៀតណាម ឬការរើសអើងចំពោះខ្មែរក្រោម ។

កាលបរិច្ឆេទឆ្នាំ ១៨៦២ គឺជាកាលបរិច្ឆេទនៃការចុះសន្ធិសញ្ញា បារាំង អណ្ណាម ដែលនៅក្នុងនោះ អធិរាជ ទឺ ឌឹក បានប្រគល់ឲ្យប្រទេសបារាំងនូវខេត្តខ្មែរមួយចំនួន

www.elibraryofcambodia.org

នៅកូសាំងស៊ីន ។

ដូច្នេះ នៅឆ្នាំ ១៨៤៩ ពួកវៀតណាម បានព្យាយាមដាក់បង្ខំរបបរបស់ពួកគេនៅកម្ពុជាក្រោម ។ A.Leclère (H.C ទំព័រ ៤៣៥) បានរាយការណ៍ថា វាពុំមានយុត្តិធម៌ចំពោះម្ចាស់ដើមនៃទឹកដីនោះទេ ហើយការដណ្តើមទាំងអស់របស់អណ្ណាម ត្រូវបានឲ្យសច្ចាប័នដោយតុលាការ ។

**ការសង់សឹកមានលក្ខណៈខ្លាំងក្លា ពីខាងភាគីខ្មែរ ។**

ពួកអាជ្ញាធរអណ្ណាម ជាពិសេសពួកចៅក្រមក៏បានរងការសង់សឹកដែរ ។ លោក Leclère បានសរសេរថា ប្រសិនបើពិរុទ្ធជនមិនត្រូវបានរកឃើញទេ ហើយគាត់មិនមែនជាពិរុទ្ធជននោះ ភូមិទាំងមូលត្រូវបានផ្តល់ឲ្យទទួលខុសត្រូវ ។ "ចាប់ប្រធានភូមិអ្នកមានមុខមានមាត់ និងអ្នកស្រុកធម្មតា ហើយនៅពេលនោះ គឺមានការដាក់ពិន័យដ៏ធ្ងន់ធ្ងរ និងការស្លាប់នៅក្រោមដំបង និងផ្តៅ" ។

ទាំងអស់នេះបានផ្តល់ឲ្យជីវិតរបស់ប្រជាជនកម្ពុជាស្ទើរតែមិនអាចប្រព្រឹត្តិទៅបាន មានប្រជាជនមួយចំនួនត្រូវបោះបង់ដីធ្លីរបស់ពួកគេទៅឲ្យយួន" ។

ពួកអណ្ណាមបានកែប្រែឈ្មោះភូមិ ស្រុកទាំងអស់របស់ខ្មែរនៅពេលដែលពួកគេបានមកដល់ ។ Leclère បានគូសបញ្ជាក់ថា ពួកអណ្ណាមបានធ្វើឲ្យប្រែក្លាយ ឈ្មោះរបស់កម្ពុជាដែលជាញឹកញាប់គេពិបាកនឹងរកឃើញណាស់ក្នុងពេលបច្ចុប្បន្ននេះ"។

លោក L. Malleret បានរៀបរាប់នូវហេតុការណ៍នេះដូចគ្នា "នៅក្នុងបុរាណវត្ថុវិទ្យា នៃដីសណ្តទន្លេមេគង្គដែលនឹងត្រូវសិក្សានៅខាងមុខឆ្ងាយទៀត ។

"ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា" (A.Leclère ទំព័រ ៤៣៥ និង ៤៣៦) បានកត់សម្គាល់នូវការប្រែក្លាយឈ្មោះភូមិ ស្រុក ខេត្ត ភាគច្រើនរបស់ខ្មែរដោយពួកអណ្ណាម ជួនកាលដោយការបកប្រែ ជួនកាលដោយការប្រែក្លាយនៃ សំឡេង" ។

"ពីពេលមុន ពួកអណ្ណាម បានបកប្រែទៅជាភាសាអណ្ណាម ដូរឈ្មោះកម្ពុជានៅ

www.elibraryofcambodia.org

ពេលដែលគេស្គាល់ន័យរបស់វាហើយ ហើយចំពោះអ្នកកាន់កាប់ទឹកដីចាស់ឈ្មោះក៏បានបាត់បង់ដែរ ដូច្នេះ :

– ខេត្តព្រៃនគរ ចាប់តាំងពីការកាន់កាប់មក បានក្លាយទៅជាខេត្ត យ៉ាឌិញ

– ចំពោះខេត្តកំពង់ស្រកាត្រី បានក្លាយទៅជាខេត្ត បៀនហ្វា

– ខេត្ត បារីយ៉ា ( La Barira ជាអេស្ប៉ាញ៉ុល និងជារបស់ ពីរទុយហ្គេ ដែលបានចុះពីនាវ៉ា Beloso នៅឆ្នាំ១៥៩៧ នៅពេលដែលគាត់ត្រឡប់មកពីក្រុងម៉ានីលនៅមុនពេលបន្តិចនៃការធ្វើគត់ ព្រះចៅ រាមាហៅជើងព្រៃ) បានក្លាយទៅជា បារៀ ។

– ផ្សារដែក បានក្លាយទៅជាសាដែក នៅមុនពេលមានឈ្មោះថា អានយ៉ាង ។

– ពោរ លើ (ពលលាវ តាមព្រះតេជគុណ ចាច់ចាំង ។ លោកបានរក្សាការហៅថា ពោរ លើ ដដែល) បានក្លាយទៅជា បាក់លីវ ។

– ទឹកខ្មៅ (ជ្រោយខ្មែរ) បានក្លាយទៅជា ការម៉ៅ ។

– បាយឆៅ (បាយមិនទាន់ឆ្អិន) បានក្លាយទៅជា បាយសៅ ។

– ពាមមានជ័យ បានក្លាយទៅជា មីថាំង ។

– ស្រុកទ្រាំង បានក្លាយទៅជា សុកត្រាំង ។

– ពាម មេសែន (បាននាមវីឡានៃឈ្មោះនេះ និងបង្ហាញនៅខាងក្រោយទៀត) បានក្លាយទៅជា ដូនណាយ ង៉ាយ (ដាយង៉ាយ) ។

– ក្រមួន ស (ក្រមួន ស) បានក្លាយទៅជា រ៉ាច់យ៉ា ។

– ព្រែកឫស្សី បានក្លាយទៅជា កិនធី ។

– អូរម៉ី បានក្លាយទៅជា អូម៉ុន នៅស្រុក កិនធី

– កំពូលមាស បានក្លាយទៅជា ប៊ិញធ្វៃ ។

– មាត់ជ្រូក បានក្លាយទៅជា ចូវដុក និងភ្នំស្វំ របស់ខេត្តនេះ បានក្លាយទៅជាភ្នំសាម របស់អណ្ណាម ។

www.elibraryofcambodia.org

- ចារ៉ាច បានក្លាយទៅជា ឡុង ស្វៀង និង ភ្នំបាជី របស់ខេត្ត បានក្លាយទៅជាភ្នំបាជី ។

- ខេត្ត មួងខាំ បានក្លាយទៅជាខេត្ត ហាទៀន

- ពាម ដែលគេហៅថា មួងខាំ ដែរនោះបានក្លាយទៅជា ហាទៀន

- ព្រះត្រពាំង បានក្លាយទៅជា ត្រាវិញ

- កំពង់ឫស្សី បានក្លាយទៅជា បេនត្រែ

- លង់ហោរ បានក្លាយទៅជា វិញឡុង

- មេ ស (ស្មិធរ) បានក្លាយទៅជា មីថ

- កោះគង់ បានក្លាយទៅជា ហ្គុំកុង (ប៉ាននាមវិទ្យា នៃឈ្មោះនេះត្រូវបានបញ្ជាក់នៅក្នុងសំណេរដៃរបស់ព្រះតេជគុណ ថាច់ចាំង)

- កំពង់គោ បានក្លាយទៅជា ឡៀង អាន បច្ចុប្បន្ន តិនអាន ។

- រោងដំរី បានក្លាយទៅជា តីនិញ

- បន្ទិច បានក្លាយទៅជា បេន លុន

- ភ្នំតីនិញ ពេលនោះមានឈ្មោះថា ភ្នំដើង ម៉ែដែង

- កោះត្រល់ (លោក Malleret ហៅថា កោះត្រល់ ឬកោះស្រល់) បានក្លាយទៅជា ភូគ្កុក ។

- ភ្នំយក់ បានក្លាយទៅជាភ្នំ កាវូស

- ពាមដើងកញ្ចើ បានក្លាយទៅជា កីងយើ (ជ្រោយ Saint-Jacques)

- ឈើទាលមួយដើម បានក្លាយទៅជា ធូយ៉ូវម៉ុត ។

- បន្ទាយកោះក្របី បានក្លាយទៅជា ហុង ង្វៀន

- កំពង់កោះក្របី បានក្លាយទៅជា បេន ថែ (សាយហ្គុន) (តាមព្រះតេជគុណ ថាច់ ចាំង គឺកោះក្របី នេះហើយ ដែលស្តេចអណ្ណាម បានស្នើសុំខ្ចីរយៈពេល ៥ឆ្នាំ

www.elibraryofcambodia.org

ដើម្បីហ៊ីកហ្វឺនទាហាន ។

ចំណែកខេត្ត មានខេត្តចំនួន ៦ :

- ខេត្ត យ៉ាឌិញ មានទីរួមខេត្ត សាយហ្គន
- ខេត្ត ឌិញទឿង មានទីរួមខេត្ត មីថ
- ខេត្ត បៀន ហូ មានទីរួមខេត្ត បៀនហ្វា
- ខេត្ត លង់ហោរ មានទីរួមខេត្ត វិញឡុង
- អានយ៉ាង មានទីរួមខេត្ត ចូវដុក
- ហាទៀន មានទីរួមខេត្ត ហាទៀន

តាមលោក H. Aurillac បានឲ្យដឹងថា "ការច្បាំងដណ្ដើមយករបស់បារាំងពុំមានការផ្លាស់ប្ដូរឡើយនូវការបែងចែកដូចខាងលើនេះ" ។

## III. ខ្មែរក្រោម នៅក្រោយរបបអាណានិគមបារាំង (១៨៦២–១៩៥៤)

### ក– ប្រជាជនខ្មែរនៅ កូសាំងស៊ីន នៅពេលបារាំងមកដល់

ចាប់តាំងពីឆ្នាំ ១៨៦៧ កូសាំងស៊ីនបានធ្លាក់ទាំងស្រុងទៅក្នុងដៃរបស់អាជ្ញាធរបារាំង ។ ការធ្វើជំរឿននៅឆ្នាំ ១៨៨៨ នៅក្នុងភូមិទាំងឡាយដែលរស់នៅដោយប្រជាជនសុទ្ធសាធ នោះ មានចំនួនដូចខាងក្រោមនេះ:

- ១០.៦៧៣ នាក់ នៅ បាក់លីវ (ពោរ លើ)
- ១១.៨០៨ នាក់ នៅ កិនថឺ (ព្រែកឫស្សី)
- ១៦.០៨០ នាក់ នៅ ចូវដុក (មាត់ជ្រូក)
- ១៨.០៨០ នាក់ នៅ រាច់យ៉ា (ក្រមួន ស)
- ៣៧.៣១៧ នាក់ នៅ សុកត្រាំង (ស្រុកឃ្លាំង)
- ៥១.០៥០ នាក់ នៅ ត្រាវីញ (ព្រះត្រពាំង)
- ៣.២៥០ នាក់ នៅ តីនិញ (រោងដំរី)

www.elibraryofcambodia.org

- ១.៧២៦ នាក់ នៅ ហាទៀន (ពាម)

- ៩២ នាក់ នៅ សាយហ្គន (ព្រៃ នគរ)

គិតសរុបនៅក្នុងឆ្នាំ ១៨៨៨ ប្រជាជនខ្មែរមានទាំងអស់ ១៥១.២៣៨នាក់ ។ នៅក្នុងឆ្នាំ ១៨៩៨ លោក Paul d'Enjoy បានធ្វើការសិក្សាអំពីការប្រមូលផ្តុំឡើងវិញនៃខ្មែរកម្ពុជាក្រោម ។ លោកបានផ្តល់នៅក្នុងសៀវភៅ "Manuel du colon" (សៀវភៅនិយាយអំពីអាណានិគមជន) នៃសមាគមបោះពុម្ពផ្សាយនៃវិទ្យាសាស្ត្រ នៅទីក្រុង ប៉ារីស) នូវឈ្មោះរបស់ឃុំដែលមានតែប្រជាជនកម្ពុជារស់នៅដូចជា :

*. នៅក្នុងស្រុក តីនិញ (ឈ្មោះជាភាសាខ្មែរ គឺរោងដំរី) ទំព័រ ២៥៩

១) ឃុំ បាងជ្រិម (ឈ្មោះកម្ពុជា) ស្ថិតនៅ ៤០គ.ម ពីតីនិញ មាន៣ឃុំគឺ

- បាងជ្រិមស្រី
- ព្រៃតូច
- កន្ទ្រាង

២) សង្កាត់ ចុន បាដែន (ឈ្មោះកម្ពុជា) ស្ថិតនៅ ៤០ គ.ម ពីតីនិញមាន ៥ឃុំគឺ

- អំពិល
- កាញុន
- កេដុល
- រុង
- ធុង

} ទំព័រ ២៦០

៣) សង្កាត់ខាងស្មៀន (ឈ្មោះកម្ពុជា) ស្ថិតនៅចម្ងាយ ៤៥គ.ម ពីតីនិញ មាន ១១ឃុំ គឺ :

www.elibraryofcambodia.org

- កំពង់ញា
- កាខុប
- ដែស្វាយ
- ដាតបូ
- ព្រៃចេក
- ប្រហារមិត្ត
- ភូមិស្វាយ
- តាញី
- ត្រពាំង
- របុន

} ទំព័រ ១៦១

១០) សង្កាត់ខ្សែងយោល (ឈ្មោះកម្ពុជា) ស្ថិតនៅ ៣៩គ.ម ពីតីនិញ ។ មាន ៧ឃុំ គឺ

- បូចិត្ត
- មិត្តមល
- តា ឡុក តាឌុង
- តា ណោត
- តា នុប
- តា ប៉ាង ប្រៃ
- តា ប៉ាង ប្រ-សុខ

*. **ស្រុកបៀនហ្វា (កម្ពុជា)**

១៧) សង្កាត់ប៊ិញកាច់ (កម្ពុជា) ស្ថិតនៅ ១០០គ.ម ពីបៀនហ្វា មាន ៧ឃុំ គឺ

www.elibraryofcambodia.org

– អូរ ប៊ិញ

– អូត្រាង

– ឡៀម គ្រឹង

– ហៀង ម៉ាក

– ថាញ់ កុង

– ទី កូង

គឺនៅទីនោះហើយដែលភូមិទាំងឡាយ ឬឃុំទាំងឡាយដែលមានតែប្រជាជនខ្មែររស់នៅ ។ ប៉ុន្តែប្រជាជនទាំងនេះ ក៏បានរស់នៅគ្រប់ទីកន្លែងនៅក្នុងស្រុកផ្សេងៗទៀតដូចជា :

– ធូ យ៉ូវម៉ុត ( ឈើទាលមួយដើម )

– វីញ ឡុង (លង់ហោរ )

– សា ដែក ( ផ្សារដែក)

– បេនត្រែ ( កំពង់ឫស្សី )

– តាន់អាន ( កំពង់គោ )

– កាម៉ៅ (ទឹកខ្មៅ )

– ចាយសៅ ( ចាយចៅ )

– ភូ ក្កុក ( កោះត្រល់ )

និងស្រុកផ្សេងៗទៀត ។

ប្រជាជនខ្មែរបានរស់នៅលាយឡំជាមួយនឹងជនអន្តោប្រវេសន៍អណ្ណាមនិងចិន។

**១– ជនជាតិភាគតិចខ្មែរនៅ កូសាំងស៊ីន តាមលោក** Malleret **(១៩៤៦)**

នៅក្នុងសន្និសីទ សារព័ត៌មានមួយដែលប្រព្រឹត្តទៅនៅសាយហ្គននៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៤៦ នៅក្រោមការឧបត្ថម្ភរបស់ការិយាល័យទទួលបន្ទុកកិច្ចការ

www.elibraryofcambodia.org

វប្បធម៌របស់ផ្នែកសហព័ន្ធនៃការសិក្សាសាធារណៈ , សន្និសីទដែលត្រូវបានចម្លង ដាក់នៅក្នុងលេខចេញផ្សាយមួយច្បាប់របស់ព្រឹត្តិបត្រនៃសមាគមការសិក្សា ឥណ្ឌូចិន លោក Louis Malleret អតីតចាងហ្វាងសាលាបារាំងនៅចុងបូព៌ា ប្រទេសបានធ្វើអត្ថាធិប្បាយនៅចំពោះមុខនាយទាហាន និងមន្ត្រីអង្គបញ្ជូននៅ ឥណ្ឌូចិនស្ដីអំពីជនជាតិភាគតិចកម្ពុជា ។

ដោយរំលឹកឡើងវិញអំពីចរិតខ្មែរនៅទឹកដី កូសាំងស៊ីន លោក Malleret បាន ផ្ដល់ព័ត៌មានដ៏មានប្រយោជន៍ស្ដីអំពីខ្មែរ កម្ពុជាក្រោម ហើយលោកបានធ្វើការ វិភាគដោយល្អិតល្អន់អំពីជីវិតរបស់ប្រជាជនកម្ពុជានៅ កូសាំងស៊ីនផងដែរ ។

ដោយទាញការយកចិត្តទុកដាក់លើការងាររបស់អាជ្ញាធរបារាំងនៅក្នុងសម័យ នោះស្ដីអំពីអំពើអយុត្តិធម៌ដែលបានប្រព្រឹត្តធ្វើចំពោះសហគមន៍ កម្ពុជា នោះ លោក Malleret បានលើកឡើងនូវការកែទម្រង់ដែលត្រូវអនុវត្តស្ដីអំពីទ្រព្យ សម្បត្តិរបស់ខ្មែរដើម្បីជា កិត្តិយសដល់ប្រទេសបារាំង ។

បើតាមលោក Malleret បានឲ្យដឹងថា សហគមន៍នេះតំណាងឲ្យមនុស្ស ប្រហែល ៣៥០.០០០នាក់ ។

លោក Malleret បាននិយាយថា "គេត្រូវពិនិត្យពិចារណាអំពីច្បាប់ស្ដីពីជន ជាតិភាគតិច ជាពិសេសនៅពេលដែលពួកនេះតំណាងឲ្យផ្នែកទាំងឡាយនៃប្រជា ភិវឌ្ឍន៍ដែលគេអាចដើរតាមនិរន្តរភាពដ៏គួរឲ្យចាប់អារម្មណ៍ចាប់តាំងពីសតវត្សរ៍ ទី១ នៃគ្រិស្តសាសនា រហូតមកដល់បច្ចុប្បន្ននេះ" ។

មួយភាគនៃសន្និសីទនេះ ត្រូវបានទុកសម្រាប់កន្លែងតំបន់ដែលគេឃើញមាន ប្រជាជន កម្ពុជា គឺ :

"ប្រជាជនកម្ពុជាទាំងនេះ គេបានជួបជាពិសេសនៅឯនាយទន្លេធំ និងទន្លេ បាសាក់ ។ នៅក្នុងខេត្តត្រាវិញ នៅក្នុងឆ្នាំ ១៩៣៧ ពួកគេតំណាងឲ្យការប្រមូលផ្ដុំ

www.elibraryofcambodia.org

ប្រជាជនដីណែនណាន់តាន់តាប់ចំនួន ៨២.០០០នាក់ ទល់នឹងជនជាតិអណ្ណាម ចំនួន ១៥៦.០០០នាក់ ។ នៅសុកត្រាំង សមាមាត្រមានសភាពដូចគ្នាគឺ ខ្មែរ ៥០.០០០នាក់ទល់នឹងអណ្ណាម ១០៧.០០០នាក់ ។ នៅបាក់លីវ ប្រជាជនខ្មែរមាន មួយភាគ ៦ ហើយនៅកិនថឺ មានមួយភាគ ១០ ។ ប៉ុន្តែនៅរាច់យ៉ា បានឡើងខ្ពស់ ទៀត រហូតដល់មួយភាគបី គឺចំនួន ៦៥.០០០នាក់ទល់នឹង ១៩២.០០០នាក់ ។ សមាមាត្រនេះ មានសភាពដូចគ្នានៅ ហាទៀន ជាខេត្តដ៏តូចមួយដែលមាន ប្រជាជនរស់នៅតិច ហើយនៅចូវដុក មានមួយភាគបួន គឺប្រជាជនកម្ពុជា ៤០.០០០នាក់ទល់នឹងប្រជាជនអណ្ណាម ១៦៨.០០០នាក់ ។ ប្រសិនបើគេមិនគិត ដល់ខេត្តត្រាវិញទេនោះ គេសង្កេតឃើញថា នៅក្នុងស្រុកបាសាក់ តែមួយជន ជាតិភាគតិច កម្ពុជាបានកើនឡើងដល់ ១៦ភាគរយនៃប្រជាជនទាំងអស់ ។

"នៅក្នុងខេត្តត្រាវិញ និងខេត្តសុកត្រាំង ប្រជាជនដើមទាំងនេះ បង្កើតបាននូវ ក្រុមមួយដ៏ណែនតាន់តាប់ ។ នៅក្នុងឆ្នាំ ១៩៣៩ នៅក្នុងខេត្តត្រាវិញ សមាសភាព ខ្មែរបានរក្សានូវទីតាំងគ្របសង្កត់នៅក្នុងភូមិចំនួន ៥០ និងមានចំនួនភាគច្រើន នៅក្នុងខេត្ត ២០ផ្សេងទៀត ។ ពួកគេបានប្រមូលផ្តុំនៅជុំវិញវត្តចំនួន ១០៩ ដែល មានលោកសង្ឃជាង ១៣០០អង្គបានបង្ហាត់បង្រៀនខាងផ្នែកព្រះពុទ្ធសាសនា ។ នៅ សុកត្រាំង គេបានរាប់ឃើញមានវត្តមិនតិចជាង ៥៤វត្តទេ ហើយបុគ្គលិកលក្ខណៈ នៃពូជសាសន៍ត្រូវបានថែរក្សាដោយរឹងប៉ឹងដែលកើតចេញមកពីសមាគម ដើម្បី អប់រំអំពីសីលធម៌ បញ្ញា និងសម្បទារបស់ប្រជាជនកម្ពុជានៅកូសាំងស៊ីន ដឹកនាំ ដោយលោក **ញឹម ឯម** ។ នៅក្នុងតំបន់អន្តរការីទាំងឡាយនៃស្រុកបាសាក់ ភូមិ របស់កម្ពុជាត្រូវបានប្រមូលផ្តុំនៅជុំវិញ អូម៉ុន និង ធូត ណូត ។ នៅរ៉ាច់យ៉ា ភូមិ ទាំងឡាយបានបង្កើតទៅជាក្រុមផ្ទះនៅរាយប៉ាយនៅខាងត្បូង និងខាងជើងនៃទីរួម ខេត្ត ។ ប៉ុន្តែនៅចូវដុក នៅជួរភ្នំ ទ្រិតូង ភូមិទាំងឡាយត្រូវបានប្រមូលផ្តុំយ៉ាង

www.elibraryofcambodia.org

ច្រើនណែនណាន់តាន់តាប់ ដោយចេះរក្សាបាននូវប្រពៃណីដ៏ល្អ ។

"គេបានជួបសមាសភាពនៅដាច់ពីគ្នានៅក្នុងភូមិ ឡុងស្វៀន, វិញ ឡុង, តាន់ អាន និងថៃមទាំងនៅបីឡឹងផង ចំណែកនៅឯនាយវាលភក់ គេបានឃើញការបង្កើតដោយមានស្ថិរភាពនៅជិតប្រទេសកម្ពុជានៅក្នុងតំបន់ គីនិញ ។ ប្រជាជនកម្ពុជាត្រូវបានបាត់បង់ទាំងស្រុងនូវខេត្តនានានៅភាគកណ្តាលដូចជា មីថ, បេនត្រែ, ហ្គកុង ក៏ដូចជាខេត្តបាស់ ។នៅភាគខាងកើតដូចជាខេត្ត បារៀ ប៉ុន្តែគេអាចនៅរាប់បានថា មានចំនួនប៉ុន្មានពាន់នាក់ទៀតនៅក្នុងខេត្តបៀនហ្វា និងធូយ៉ូវម៉ូតដែលជាដំណែលចុងក្រោយនៅភាគខាងកើតនៃការពង្រីកកាលពីពេលដើមរបស់ពួកគេ" ។

"ប្រសិនបើប្រជាជនទាំងនេះ បានបាត់បង់មួយភាគធំនៃទឹកដីរបស់ខ្លួននោះ អនុស្សាវរីយ៍ នៃអធិបតេយ្យភាពបានស្ថិតនៅក្នុងឋាមនាមវិទ្យានៅក្នុងស្រុក ។ មានឈ្មោះមួយចំនួននៃទីកន្លែង គឺគ្រាន់តែជាការធ្វើឲ្យក្លាយដោយសុទ្ធសាធពីអតីតពាក្យជាភាសាខ្មែរតែប៉ុណ្ណោះ" ។

ហេតុដូច្នេះហើយ ខេត្តសាឌែក វាមានលក្ខណៈងាយស្រួលណាស់ដើម្បីស្គាល់ថា ជាផ្សារដែក ។ សុកត្រាំងគឺស្រុកទ្រាំង, ត្រាវិញ គឺព្រះត្រពាំង, បាក់លិវគឺពោរលើ, កាម៉ៅ គឺទឹកខ្មៅ, មីថ គឺ មេ ស ឬ ស្មឹធរ ។

ទីកន្លែងផ្សេងៗទៀត គឺជាការបកប្រែភាសាអណ្តាមពីឋាននាមវិទ្យាចាស់របស់កម្ពុជា ។ ដូច្នេះ បេនត្រែ គឺត្រូវគ្នានឹងកំពង់ឫស្សីចាស់ ហើយនៅក្នុង បេន ង៉េ គឺជាឈ្មោះចាស់របស់ផ្នែកមួយនៃសាយហ្គន ដែលគេស្គាល់យ៉ាងងាយថា ជា កំពង់ក្របីចាស់ ។ ម្យ៉ាងទៀតឈ្មោះចាស់ បានក្លាយទៅជា មើលស្ទើរតែមិនស្គាល់ ប៉ុន្តែជាញឹកញាប់ វាបានស្ថិតនៅយូរនៅក្នុងការប្រើប្រាស់របស់ប្រជាជន ហើយគេបានឮគេនិយាយថា "រោងដំរី" ដើម្បី បង្ហាញគីនិញ ខេត្ត លង់ហោរ សម្រាប់ វិញ

www.elibraryofcambodia.org

ខ្មុង, មាត់ផ្អែក សម្រាប់ ចូវដុក, ក្រមួនស សម្រាប់ រ៉ាច់យ៉ា, ពាម សម្រាប់ ហាទៀន និងជាពិសេស ព្រៃនគរ ភាសាសំស្ក្រឹត "ណាហ្គារ៉ា" ដើម្បីចង្អុលបង្ហាញថា សាយហ្គន ចឹឡឹង គឺថា ជាអតីតទីក្រុងរបស់ខ្មែរ ដែលបានកាន់កាប់មួយភាគនៃវ៉ាលកប់សព ។ លោក Malleret បានផ្តល់នៅក្នុងសន្និសីទបន្តរបស់លោកអំពីលក្ខណៈនៃអ្វីៗដែលជារបស់ខ្មែរនៅកូសាំងស៊ីន ចាប់តាំងពីរូបរាងនៃផ្ទះសម្បែង រហូតដល់ជំនឿផ្សេងៗដូចជាការជឿអ្នកតាជាដើម ។

បើតាមលោក "ភូមិរបស់កម្ពុជាត្រូវបានបែងចែកនៅក្នុងកូនភ្នំខ្សាច់ទាំងឡាយ និងនៅក្នុងទេសភាពមួយនៃសួនច្បារ ហើយគេបានស្គាល់នៅទីឆ្ងាយទៅទៀត នូវការប្រមូលផ្តុំរបស់ខ្មែរ ជាមួយនឹងព្រៃដើមគគីរ ដែលកត់សម្គាល់ថា មានវត្តមានរបស់ខ្មែរ ។

លោក Malleret បាននិយាយថា "វត្តនៅកូសាំងស៊ីនទាំងនេះ គឺជាវត្តដែលគេស្គាល់ថា ជាវត្តរបស់កម្ពុជា"

នៅគ្រប់ទីកន្លែង គេឃើញមានរោងសិប្បកម្មខ្មែរ ។ នៅទ្រាំតូង គេឃើញមានរោងសិប្បកម្មប្រចាំគ្រួសារដែលគេធ្វើសំពត់សម្រាប់យកទៅតុបតែងទីអារ៉ាមបានយ៉ាងល្អ" ។ ហើយលោក Malleret បានទទួលនៅអមអាជ្ញាធរបារាំងអំពីការបង្កើតសាលារៀនសិល្បៈសម្រាប់ប្រជាជនខ្មែរដូចដែលគេបានបង្កើតនៅ "បៀនហ្វា និងនៅ ធូយ៉ូវម៉ុត និងនៅយ៉ាឌិញ សម្រាប់ប្រជាជនអណ្ណាម ។

និយាយពីសាសនាវិញ លោក Melleret បានគូសបញ្ជាក់ថា ព្រះពុទ្ធសាសនារបស់ប្រជាជនកម្ពុជា ទោះជានៅកូសាំងស៊ីនក្តី ឬក៏នៅប្រទេសកម្ពុជាក្តី ក៏គេគោរពសាសនាព្រះពុទ្ធ "ហិនយាន" ។ ព្រហ្មញ្ញសាសនា ត្រូវបានគោរពលាយឡំជាមួយនឹងព្រះពុទ្ធសាសនា ឧទាហរណ៍គេឃើញមានកន្លែង "អ្នកតា" ដូចគ្នាបេះបិទនៅប្រទេសកម្ពុជា។

www.elibraryofcambodia.org

លោក Malleret ក៏បានរៀបរាប់ផងដែរអំពីបញ្ហាមួយដែលមានលក្ខណៈធ្ងន់ធ្ងរចំពោះជនជាតិភាគតិចខ្មែរនៅកូសាំងស៊ីន គឺបញ្ហាសិក្សាអប់រំ ។

ជនជាតិភាគតិចខ្មែរបង្កើតបាន "នូវសភាពដូចគ្នារួមមួយខាងភាសា សាសនា ទំនៀមទម្លាប់ និងប្រពៃណីរបស់ខ្លួន" ។ ភ្ជាប់ជាមួយនិងទំនៀមទម្លាប់ទាំងនេះ ប្រជាជនខ្មែរមានការស្អប់ខ្ពើមក្នុងការបញ្ជូនកូនចៅរបស់ពួកគេឲ្យទៅនៅសាលាបារាំង អណ្ណាម ។

ប្រាកដហើយ គឺមានសាលាបារាំង-ខ្មែរ តិចតួចណាស់ ។ អាជ្ញាធរបារាំងបានបង្កើតសាលារៀនជាប្រពៃណីនៅតាមវត្តដើម្បីជំនួសសាលាទាំងនេះ គឺ

- ឆ្នាំ ១៩៤៤ មាន ៩៤សាលា និង សិស្ស ១.០៣៨ នាក់
- ឆ្នាំ ១៩៤៥ មាន ២០សាលា ដែលត្រូវផ្តល់ប្រាក់ជំនួយ និងសិស្ស ៥៧១នាក់

មានសាលា "ផ្លាស់ប្តូរទម្រង់ថ្មី" ផងដែរ ដូចជានៅប្រទេសកម្ពុជាចាប់ពីក្នុងកំឡុងឆ្នាំ ១៩៤០ ទៅឆ្នាំ ១៩៤៥ ។ ការសិក្សាត្រូវបានបង្រៀនដោយព្រះសង្ឃ ។ ចំនួន សាលារៀននេះ បានកើតឡើងពី ៣៧ នៅក្នុង ១៩៣០ ទៅដល់ចំនួន ៩០ នៅក្នុងឆ្នាំ ១៩៣៥ និងទៅដល់ចំនួន ២០៩ នៅក្នុងឆ្នាំ ១៩៤៤ ជាមួយនឹងចំនួនសិស្សបាន កើនឡើងពីឆ្នាំ ១៩២៤ ទៅដល់ឆ្នាំ ១៩៣០ ចំនួន ៧.២៣៤នាក់ ដែលនៅក្នុងនោះ មានសិស្សស្រីចំនួន ១០៩៣នាក់ នៅក្នុងឆ្នាំ ១៩៤៤ ។

ចំពោះសាលារៀនបារាំងខ្មែរចំនួនរបស់វាបានកើនឡើងដល់ ១៩សាលាជាមួយនឹងគ្រូបង្រៀនតែ ៣០នាក់ប៉ុណ្ណោះ ។

លោក Malleret បានសន្និដ្ឋានថា ទោះបីជាយ៉ាងណាក៏ដោយ ក៏ការងារជាបន្ទាន់ ការងារជាចាំបាច់ គឺត្រូវផ្តល់ឲ្យជនជាតិភាគតិច កម្ពុជា នៅ កូសាំងស៊ីន នូវមធ្យោបាយទាំងឡាយ ដើម្បីការពារបុគ្គលិកលក្ខណៈរបស់ខ្លួន ដោយបង្កើតសម្រាប់ពួកគេ ឲ្យមានសាលារៀន ។

www.elibraryofcambodia.org

ស្ដីពីការងាររដ្ឋបាលវិញ លោក Malleret បានប្រកាសថា នៅក្នុងឆ្នាំ ១៩៤៦ គេឃើញមាននៅសល់ "ស្លាកស្នាមពីអតីតកាល ដែលគួរឲ្យស្រងេះស្រងោចនៅឡើយ ដែលទាក់ទងទៅនឹងការជិះជាន់សង្កត់សង្កិនរបស់អណ្ណាម ការរំលាយបញ្ចូលគ្នានូវភូមិ កម្ពុជា ជាមួយភូមិ អណ្ណាម វិធានការ ដែលសម្រេចឡើងដោយគ្មាន ការប្រុងប្រយ័ត្នដោយអាជ្ញាធរបារាំងដែលសំដៅដកហូតទាំងស្រុងពីអ្នកទី១ នូវទឹក ដីភូមិឋានរបស់ខ្លួនដើម្បីជាផលប្រយោជន៍សម្រាប់អ្នកទី២..." ។

លោក Malleret ក៏បានសង្កត់ធ្ងន់ដែរអំពីការតែងតាំង "មន្ត្រីជំនួយម្នាក់ទទួលបន្ទុកខាងអគ្រានុកូលដ្ឋាននៅក្នុងភូមិទាំងឡាយដែលមានប្រជាជនកម្ពុជាភាគច្រើន" ។

លោក Malleret បានបន្ថែមថា វាក៏សំខាន់ផងដែរថា "សមាសភាពកម្ពុជាមានកន្លែងដែលសមស្របសម្រាប់ខ្លួននៅគ្រប់អង្គភាពទាំងឡាយដែលត្រូវបានគេជ្រើសតាំងនៅក្នុងលំដាប់ថ្នាក់មួយចំនួនដែលត្រូវបានគេបង្កើតឡើង" ។

លោក Malleret បាននិយាយថា ភាសាកម្ពុជាត្រូវបានគេទទួលស្គាល់ជាផ្លូវការនៅក្នុងការតាក់តែងនូវពាក្យស្នើទាំងឡាយ ឬក៏នៅក្នុងការឆ្លើយឆ្លងកិច្ចការរដ្ឋបាល គេត្រូវពង្រីកការិយាល័យទទួលបន្ទុកកិច្ចការកម្ពុជានៅអមខុទ្ទកាល័យរបស់ចៅហ្វាយខេត្ត ។

លោក Malleret បានផ្ដល់នូវតួលេខប្រជាជនខ្មែរនៅ កូសាំងស៊ីន ដូចតទៅនេះ :

នៅឆ្នាំ ១៨៨០ : មានចំនួន ១៥០.០០០នាក់

នៅឆ្នាំ ១៩២៥ : មានពី ៣០០.០០០ ទៅ ៣៥០.០០០នាក់ "ប្រជាជនកម្ពុជានៅ កូសាំងស៊ីន មានចំនួនដ៏សំខាន់ ហើយចំនួនរបស់ពួកគេនេះបានកើនឡើងនៅរាល់ពេលធ្វើជំរឿនម្ដងៗ" ។

**ប្រទេសបារាំងត្រូវបង្ហាញនូវដំណោះស្រាយប្រកបដោយយុត្តិធម៌ ។**

www.elibraryofcambodia.org

លោក Malleret បានបញ្ចប់សន្និសិទរបស់លោកដោយថ្លែងទៅកាន់នាយទាហាន និងមន្ត្រីទាំងឡាយនៃអគ្គបញ្ជូនទៅឥណ្ឌូចិន នូវពាក្យដ៏គួរឲ្យរំជួលចិត្តដូចតទៅនេះ :

**"ប្រសិនបើខ្ញុំបានយល់ព្រមនៅយប់នេះ ដើម្បីសន្ទនាជាមួយអ្នកអំពីជនជាតិភាគតិចនេះ ដែលគួរតែត្រូវបានការពារដោយមិនអាចជៀសរួច នោះ គឺច្បាស់ជាខ្ញុំស្ថិតនៅទីនេះ ដើម្បីជជែកតវ៉ា និងធ្វើជាមេធាវី សម្រាប់អ្នកដែលខ្សោយ ។ ហើយគឺដោយសារតែ កូសាំងស៊ីន ជាប្រទេសមួយដែលដាក់ផ្ទុក ប្រវត្តិសាស្ត្របញ្ជាក់ពីការបានរស់នៅដោយត្រឹមត្រូវ របស់កូនចៅអ្នកកសាង ប្រាសាទអង្គរដោយពិតប្រាកដ" ។**

**គ- របបដែលត្រូវអនុវត្តចំពោះ ខ្មែរក្រោម នៅក្រោមការកាន់កាប់របស់ បារាំង :**

សិទ្ធិដូចតទៅនេះ ត្រូវបានខ្មែរនៅ កម្ពុជាក្រោម ទទួលស្គាល់ (និក្ខេបបទរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីអំពីជនជាតិភាគតិចកម្ពុជានៅកូសាំងស៊ីន) :

ក)- សិទ្ធិរបស់ប្រជាជនកម្ពុជាក្នុងការចូលរួមក្នុងកិច្ចការសាធារណៈអ្នកមានមុខ មានមាត់កម្ពុជា ត្រូវបានចាត់តាំង ឬក៏ជ្រើសរើសតាមសមាមាត្រប្រជាជនកម្ពុជាដែលចុះក្នុងបញ្ជីនៅក្នុងសង្កាត់ និងឃុំទាំងឡាយ ។

នៅស្រុកស្វាយទង (ទ្រាវិញ) ជាឧទាហរណ៍មានឥស្សរជនខ្មែរពីរនាក់ ត្រូវបានតែងតាំងជាប្រតិភូរដ្ឋបាល ។

ខ)- សិទ្ធិខាងការបូជា និងគោរពសាសនា

បុណ្យស៊ិរីល និងសាសនាត្រូវបានរៀបចំធ្វើដោយសេរីដោយប្រជាជនកម្ពុជាតាមទំនៀមទម្លាប់ខ្មែរ និងគម្ពីរព្រះពុទ្ធសាសនា ។ ឧទាហរណ៍ បុណ្យចូលឆ្នាំខ្មែរត្រូវបានប្រារព្ធធ្វើជាផ្លូវការ ។ វិទ្យាស្ថានព្រះពុទ្ធសាសនា មួយត្រូវបានបង្កើតនៅសុកត្រាំង និងឋានានុក្រមព្រះពុទ្ធសាសនា ត្រូវបានទទួលស្គាល់ជាផ្លូវការដោយ

www.elibraryofcambodia.org

អាជ្ញាធរ អាណានិគម (ពុទ្ធសាសនបណ្ឌិត្យរង) ។

ព្រះសង្ឃខ្មែរនៅកូសាំងស៊ីន ស្ថិតនៅក្រោមឱវាទគណៈសង្ឃជាន់ខ្ពស់នៅភ្នំពេញ ។

សាលាបឋមសិក្សា បួងខាងភាសាបាលីនៅកូសាំងស៊ីន ដែលជាសាខានៃសាលានៅកម្ពុជាបានបង្ហាញសិស្សរបស់ខ្លួននៅសាលាជាន់ខ្ពស់ខាងភាសាបាលីនៅភ្នំពេញ ។

គ)– សិទ្ធិខាងការសិក្សារបស់ប្រជាជនកម្ពុជានៅក្នុងសាលាវត្តដែលត្រូវបានរៀបចំកែប្រែថ្មី និងនៅក្នុងសាលាបារាំងខ្មែរ ។

ឃ)– សិទ្ធិខាងព្យាបាលជំងឺដោយឥតគិតថ្លៃនៅក្នុងមន្ទីរពេទ្យ ។

ម្យ៉ាងទៀតនៅក្នុងអំឡុងពេលកាន់កាប់របស់បារាំង ពួក "ចៅហ្វាយស្រុកឃ្លាំង" បានបន្តទទួលការតែងតាំងជាផ្លូវការមុខងាររបស់ខ្លួនពីព្រះមហាក្សត្រកម្ពុជាដូចនៅក្នុងអតីតកាល គឺ

១)– នៅឆ្នាំ ១៨៦៨ ម៉ឺនអួង ដោយទទួលបាននូវការតែងតាំងពីអាជ្ញាធរបារាំងជា "Ong Phou" នៃស្រុកឃ្លាំង ឋានៈវៀតណាមជា Ong Phou Lam Vong បានមកកាន់ទីក្រុងភ្នំពេញដែលព្រះករុណា "ព្រះបាទ នរោត្តម" បានប្រទានឋានៈជា "អាធិកវង្សា រាជប្រតិភូនៅខេត្តឃ្លាំង" ។ ប៉ុន្តែឋានៈវៀតណាម "Ong Phou Lam Vong" របស់លោកស្ថិតនៅដដែល ហើយដែលព្រះតេជគុណ ថាច់ ចាំង បានមាន ព្រះថេរៈដិកាថា ពួកបារាំងក៏បានធ្វើវៀតណាមភាវូបនីយកម្មប្រជាជនខ្មែរ និងមុខងារដែលប្រគល់ឲ្យដោយអាជ្ញាធរខ្មែរ ។

បារាំងបានបង្ខំ ខ្មែរក្រោម ឲ្យដាក់ឈ្មោះជីតាជាឈ្មោះវៀតណាម ដើម្បីងាយស្រួលក្នុងការចុះបញ្ជីទារពន្ធ ។

ចៅហ្វាយខេត្តខ្មែរនៅខេត្ត កូសាំងស៊ីន ត្រូវមានមុខងារជា "តុង" (Tong)

www.elibraryofcambodia.org

ហើយនៅតាមខេត្តនីមួយៗពួកមន្ត្រីស្រុកទទួលមុខងារជា "ឡាង"។

ដូច្នេះ "គេបានតែងតាំង "តុង" ៥នាក់ ដើម្បីទារពន្ធ :

– នៅខេត្តឃ្លាំង : តុង ឱញខាញ់

– ខេត្តខាងកើត : តុង ឱញជី

– ខេត្តខាងត្បូង : តុង ញ៉ីវហា

– ខេត្តខាងលិច : តុង ឱញអាង

– ខេត្តខាងជើង : តុង ឱញខាញ់

តាមព្រះតេជគុណ ថាច់ ចាង បានឲ្យដឹងថា "ម៉ឺន អួង" ស្ថិតនៅក្រោមអំណាចដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា"ព្រះបាទ នរោត្តម" ចំពោះអ្វីៗទាំងអស់ដែលទាក់ទងទៅនឹងប្រជាជនកម្ពុជា ។

**២)– នៅឆ្នាំ ១៨៨០ នៅពេល ម៉ឺនអួង បានទទួលមរណភាពទៅបងប្រុសរបស់គាត់ឈ្មោះ ម៉ឺនអួរ បន្តវេន**

ក្រោយពីបានទទួលនូវការតែងតាំងពីអាជ្ញាធរបារាំងមក ស្របទៅតាមប្រពៃណីបានមកកាន់ទីក្រុងភ្នំពេញដើម្បីចូលគាល់ព្រះករុណា "ព្រះបាទ នរោត្តម" ដែលព្រះអង្គបានប្រទានឋានៈឲ្យគាត់ជា "ឧកញ៉ាអាធិកវង្សា" ។

**៣)– នៅឆ្នាំ ១៨៨៨ ស៊ិន ឡេីប បានជំនួស ម៉ឺនអួរ**

គាត់ត្រូវបានព្រះករុណា "ព្រះបាទ ស៊ីសុវត្ថិ" ហៅមកធ្វើជាលេខាធិការផ្ទាល់របស់ព្រះអង្គនៅភ្នំពេញនៅក្នុងឆ្នាំ ១៩០៤។

**៤)– ឧត្តមមន្ត្រី ឡឹម ឯម**

នៅឆ្នាំ ១៩២៣ លោក "ឡឹម ឯម" ក្រោយពីបានទទួលជ័យជំនះដ៏ត្រចះត្រចង់នៅក្នុងការប្រឡងប្រជែងកិច្ចការរដ្ឋបាលនោះ ត្រូវបានតែងតាំងជា "Ong Vieng Ong Phou Doc Phou Soe" ដោយអនុវត្តអំណាចរបស់ខ្លួនទៅលើប្រជាជនខ្មែរ

www.elibraryofcambodia.org

ចិន និងវៀតណាម ។

លោក "ឡឹម ឯម" បានខិតខំប្រឹងប្រែងដើម្បីលើកមនោសញ្ចេតនា ស្នេហាជាតិរបស់ ខ្មែរក្រោម ក្នុងការអភិវឌ្ឍន៍ការសិក្សា អក្សរសាស្ត្រខ្មែរ ។

លោក "ឡឹម ឯម" បានបង្កើតនៅក្នុងវត្តនីមួយៗនូវ "សាលារៀនទម្រង់ថ្មី" មួយ ។ នៅឆ្នាំ១៩២៧ គាត់បានទទួលពីអាជ្ញាធរបារាំងនូវការអនុញ្ញាតដើម្បីបង្កើតសាលាបឋមសិក្សាខ្មែរ ។

ដើម្បីជួយដល់សិស្សានុសិស្ស គាត់បានបង្កើតនៅក្នុងឆ្នាំ១៩៣៥ នូវ "សមាគមសិក្សា វិទ្យាល័យ" នៅកូសាំងស៊ីន ។

នៅឆ្នាំ ១៩៤០ សមាគមបានបញ្ជូនសិស្សទៅបន្តការសិក្សាផ្នែកមធ្យមសិក្សា នៅទីក្រុងភ្នំពេញ សាយហ្គន យ៉ាឌិញ និងព្រែកឫស្សី ជារៀងរាល់ឆ្នាំ ។ នៅឆ្នាំ ១៩៤៣ ឡឹមឯម ដុក ភូសួ ប្រធានសមាគមសិក្សាវិទ្យាល័យបានទទួលការអនុញ្ញាតិដើម្បីបង្កើតផ្នែកមួយ នៃវិទ្យាស្ថានព្រះពុទ្ធសាសនា នៅ កូសាំងស៊ីន គាត់បានបង្កើតសាលាបឋមសិក្សាភាសាបាលីនៅក្នុងវត្តនីមួយៗនៅកូសាំងស៊ីន ។ សិស្សដែលបានចេញពីសាលាជាមួយនឹងវិញ្ញាបនប័ត្របឋមសិក្សាភាសាបាលី ត្រូវបានបញ្ជូនទៅទីក្រុងភ្នំពេញ ដើម្បីបន្តការសិក្សាមធ្យម និងផ្នែកឧត្តមសិក្សារបស់ពួកគេ ។

នៅទីបញ្ចប់សូមបង្ហាញក្នុងស្ថានភាពជាឯកសារថា គាត់បានសហការក្នុងការស្រាវជ្រាវខាងបុរាណវត្ថុរបស់លោក Louis Malleret ។

## IV. ខ្មែរក្រោម ក្នុងសម័យ ទសវត្សរ៍ ១៩៥០-១៩៦០

កម្មវិធីធ្វើដូចគ្នាបេះបិទ ការគាបសង្កត់ ឬការបំបាត់ពូជសាសន៍កម្ពុជានៅកូសាំងស៊ីន ។ ក្រោយមកគេបានស្គាល់ពេលវេលាបញ្ចប់មួយនៅក្នុងអំឡុងពេលការកាន់កាប់របស់បារាំង និងរហូតដល់បារាំងបានចាកចេញពីកូសាំងស៊ីន ។ ប៉ុន្តែ

www.elibraryofcambodia.org

បន្ទាប់ពីការចាកចេញ របស់បារាំងទៅវៀតណាមក៏បានចាប់ផ្ដើមអនុវត្តយ៉ាង ធ្ងន់ធ្ងរឡើងវិញជាងពេលណាៗទាំងអស់ ។

ពួកបារាំងបានប្រគល់ប្រជាជនកម្ពុជាទាំងនេះទៅឲ្យវៀតណាមដោយធ្វើរំលង ការទាមទារតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជា ។ ការចុះហត្ថលេខានៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៥៥ នូវអនុសញ្ញាបារាំង-វៀតណាមដែលបានដាក់បង្ខំសញ្ជាតិ វៀតណាមដល់ប្រជាជនកម្ពុជានៅកូសាំងស៊ីន គឺជាអំពើរំលោភដោយចំពោះលើ សិទ្ធិមនុស្សជាតិ ។

**"នៅក្នុងការបំបាត់ពូជសាសន៍ខ្មែរនៅកូសាំងស៊ីន ជាការទទួលខុសត្រូវដ៏ធ្ងន់ធ្ងរ មួយបានធ្លាក់ទៅលើបារាំងដែលបានប្រកាសខ្លួនឯងថា ជាមហាអំណាចការពារ ប្រទេសកម្ពុជា" ។**

រដ្ឋាភិបាលសាយហ្គន ដោយធ្វើតាមនយោបាយរបស់អតីតអធិរាជអណ្ណាម បានប្រកាន់យកវិធានការដែលជាការរំលោភប្រឆាំងនិងប្រជាជនកម្ពុជា, គឺការធ្វើ វៀតណាមូបនីយកម្ម ប្រជាជនខ្មែរទាំងអស់ដែលបានកើតនៅកូសាំងស៊ីន ។ ការធ្វើ វៀតណាមូបនីយកម្មលើឈ្មោះរបស់ប្រជាជនខ្មែរទាំងអស់ (ក្រិត្យចុះថ្ងៃទី ២៩-៨-១៩៥៦ ការរឹតត្បិតនូវការសិក្សារបស់ប្រជាជនកម្ពុជា ។ ចំពោះវិធានការទាំងនេះ គឺបានបន្ថែមនូវការចាប់ខ្លួនដោយរំលោភ និងថែមទាំងការសម្លាប់ទៀតផង (ឯកសារជំនួយស្មារតីរបស់រដ្ឋាភិបាលខ្មែរទំព័រ ១០ ទៅទំព័រ ១៤) ។

ដោយការភ័យខ្លាច និងការរំលោភទាំងនេះ ប្រជាជនខ្មែររាប់ពាន់នាក់នៅ កូសាំងស៊ីន បានមកប្រទេសកម្ពុជាដើម្បីស្នើសុំវិធានការការពារ ។

នៅខែមីនា ឆ្នាំ១៩៦១ ការចាកចេញទាំងហ្វូងៗចំនួនខ្មែរក្រោមមកស្នាក់នៅ ក្នុងកម្ពុជាមានតួលេខដូចតទៅនេះ គឺ :

- ខេត្តតាកែវ ១៤៣២ នាក់

www.elibraryofcambodia.org

- ខេត្តកំពត ៥១៧ នាក់
- ខេត្តកំពង់ចាម ១៤២ នាក់
- ខេត្តស្វាយរៀង ១២៤ នាក់

សរុប ២.២១៥ នាក់

នៅខែសីហា ឆ្នាំ១៩៦១ ចំនួននេះបានឡើងដល់ ២.៨៤៦ និងបានកើនឡើងចាប់តាំងពីពេលនោះមក ។

ដោយរក្សាទុកនូវលក្ខខ័ណ្ឌទាំងឡាយរបស់ខ្លួនចំពោះសិទ្ធិនៅវៀតណាមនៅលើទឹកដីខ្មែរនៅកូសាំងស៊ីន ប្រទេសកម្ពុជាបានស្នើបទបញ្ហាបណ្តោះអាសន្នមួយចំពោះវាសនារបស់ប្រជាជនកម្ពុជានៅអតីតកូសាំងស៊ីន ដោយស្នើការផ្ញើអន្តរាគម ពីស្ថាប័នរបស់អង្គការសហប្រជាជាតិ ជាពិសេសគឺស្ថាប័នឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួន ដើម្បីឲ្យមានការចរចាប្រព្រឹត្តទៅដោយចំហជាមួយរដ្ឋាភិបាលវៀតណាមខាងត្បូង ដើម្បីកំណត់លក្ខន្តិកៈសហគមន៍ខ្មែរដែលរស់នៅលើទឹកដីរបស់ខ្លួនចាប់តាំងពីរាប់សហស្សវត្សមកហើយនោះ ។

## រឿងដីខ្មោចផ្សានៃជនជាតិខ្មែរក្រោម ដែលសម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជាទ្រង់បានលើកនៅចំពោះមុខអង្គការសហប្រជាជាតិ (កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៦១)

### ព្រះបន្ទូលថ្លែងការណ៍នៃសម្តេចព្រះប្រមុខរដ្ឋកម្ពុជា

### សម្រែកដង្ហោយហៅរបស់ជនជាតិខ្មែរ

"ដោយហេតុថា បញ្ហានេះប៉ះពាល់ផ្ទាល់ដល់សាច់ និងឈាមរបស់យើងយ៉ាងផ្ទាល់តែម្តង" ដោគវាសនាដ៏អភ័ព្វដែលបងប្អូនរួមជាតិខ្មែរយើងបានទទួលនៅ ឯ

www.elibraryofcambodia.org

ទាយព្រំប្រទល់ដែនផ្នែកខាងកើត បញ្ហាទាំងនេះធ្វើឲ្យយើងក្រៀមក្រំយ៉ាងក្រៃលែង។

ដោយត្រូវគេបង្ខំទុកដូចជា ជនបរទេសនៅលើទឹកដីដែលជាកេរមរតករបស់ខ្លួននឹងដោយត្រូវរដ្ឋាភិបាលយៀកណាមខាងត្បូងចាត់ទុកជា ជនជាតិយៀកណាមនោះ ។ បងប្អូនរួមជាតិខ្មែរទាំងនេះ បានត្រូវទទួលនូវទារុណកម្មគ្រប់យ៉ាង បើកាលណាខ្លួនចង់រក្សាទុកនូវបុគ្គលិកលក្ខណៈរបស់ខ្លួន និងកាលបើខ្លួនចង់នៅមានស្មាមីភក្តិចំពោះភាសារបស់ខ្លួន, ចំពោះទំនៀមទម្លាប់របស់ខ្លួន, ចំពោះទម្រង់ការនៃព្រះពុទ្ធសាសនាដែលខ្លួនត្រូវគោរពប្រតិបត្តិ ។ ជនរួមជាតិខ្មែរទាំងនេះ ក៏មិនបានទទួលការអនុគ្រោះពី "ពួកឧទ្ទាម" ដែលកំពុងប្រឆាំងនឹងរដ្ឋាភិបាលព្រៃនគរ ហើយដែលទទួលការគាំទ្រពីរដឹកការហាណូយនោះដែរ ។

ដើម្បីនាំគ្នាគេចឲ្យផុតពីការប្រល័យជីវិតនេះ បងប្អូនរួមជាតិយើងជាច្រើនរយនាក់បានរិះរកផ្លូវគេចរត់ឆ្លងព្រំដែនមកជ្រកកោននៅលើទឹកដីជាតិខ្មែរ ។ ក៏ប៉ុន្តែបងប្អូនរួមជាតិទាំងនេះពុំអាចភៀសខ្លួនបានទាំងអស់គ្នាទេ ។ ដោយមានការតាមដេញប្រកិត, ការចាប់ចងបណ្តាជនរួមជាតិយើងទាំងនេះ បានខូចបង់នូវជីវិតជាញឹកញាប់ក្នុង ការរត់ភៀសខ្លួនពុំបានសម្រេចផលនេះ ។

"សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ទ្រង់បានយកព្រះទ័យទុកដាក់ចំពោះទុក្ខលំបាកទាំងនោះ ដោយទ្រង់បានដាក់ជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិលើកទី១៦ នូវបញ្ហានៃអានិតិជនខ្មែរនៅវៀតណាមខាងត្បូង ។ ហើយទ្រង់បានសុំនៅឱកាសនោះ ឲ្យគេទទួលធានាអះអាងចំពោះសិទ្ធិនៃអានិតិជនទាំងអស់ដែលនៅក្នុងតំបន់ផ្សេងៗក្នុងសាកលលោកផង" ។

"អន្តរាគមន៍នេះមាននៅក្នុងសេចក្តីថ្លែងការណ៍របស់សម្តេច ដែលទ្រង់បានថ្លែងកាលពីថ្ងៃទី២២ កញ្ញា ១៩៦១ នៅលើវេទិកានៃមហាសន្និបាត ។ សេចក្តីរបស់ទ្រង់ទាំងបីផ្នែកដែលទាក់ទងនឹង "ខ្មែរក្រោម" យើងសូមដកស្រង់យកមកផ្សាយជូន

www.elibraryofcambodia.org

ដូចតទៅ ...."

ការផ្ទេរដែនដីនៃ រដ្ឋកូសាំងស៊ីន ពីដើមឲ្យដល់រដ្ឋាភិបាលវៀតណាម ហើយដែល បាននាំមក ដំណាលក្នុងរឿងដោះស្រាយដោយសន្តិវិធីដល់បញ្ហាអាល់ហ្សេរី ។ ការផ្ទេរនេះកំណត់ អំពីឫសកំណើតនៃបញ្ហាដ៏ក្ដុកក្ដួលរបស់ពួក "ខ្មែរក្រោម" ដែលជាកម្មវត្ថុរបស់ សេចក្ដីថ្លែងការណ៍នាពេលនេះ... ។

ប្រទេស កូសាំងស៊ីន ដែលជាវៀតណាមខាងត្បូងសព្វថ្ងៃនោះ ជាទឹកដីរបស់កម្ពុជា ដែលប្រទេសអណ្ណាម បានកាន់កាប់មួយភាគនៅពេលដែលជនជាតិបារាំងបានមកដល់កាលពីពាក់កណ្ដាលសតវត្សរ៍ទី១៩ ។ កាលនោះប្រទេសបារាំង បានទុកអាណាខេត្រទាំងនេះឲ្យស្ថិតនៅក្រោមអំណាចចក្ររបស់ខ្លួនតែម្ដង ព្រមទាំងខេត្រទាំងឡាយដែលនៅកើតរីវ៉ាទរវាងប្រទេសកម្ពុជា និងប្រទេសអណ្ណាម ហើយបារាំងក៏យកដែនដីនិងខេត្រទាំងនោះធ្វើឲ្យអាណានិគមមួយ រួចធ្វើជាខេត្រមួយរបស់បារាំង ដោយជ្រើសតាំងអ្នកដំណាងរាស្ត្រ ឲ្យទៅនៅប្រជុំក្នុងសភារបស់បារាំង ។

កាលពីឆ្នាំ ១៩៤៦-៤៧ ដោយហេតុប្រទេសបារាំង ត្រូវគស៊ូបង្ក្រាបការបះបោររបស់វៀតណាម ដែលមានកម្លាំងជាពិសេសនៅប៉ែកខាងជើងនោះ ប្រទេសបារាំងក៏បង្កើតឲ្យមាន រដ្ឋាភិបាលបណ្ដោះអាសន្នមួយនៅវៀតណាមខាងត្បូង ។ រួចកាលពីឆ្នាំ ១៩៤៨-៤៩ ប្រទេសបារាំងបានហៅ បាវដាយ ជាអតីតព្រះមហាក្សត្រ ដែលត្រូវដាក់រាជ្យកាលពីឆ្នាំ ១៩៤៥ នោះឲ្យមកវិញ ។ បារាំងបានប្រកាសតាំង បាវដាយ ឲ្យធ្វើជាប្រមុខរដ្ឋ ហើយផ្ទេរកូសាំងស៊ីនជាដីរបស់បារាំងមកឲ្យ បាវដាយ ដោយមានសេចក្ដីយល់ព្រមរបស់រដ្ឋសភាបារាំងផង ។ ព្រះមហាក្សត្រនៃប្រទេស កម្ពុជា ព្រះអង្គទ្រង់ក៏បានតវ៉ាជាផ្លូវការជំទាស់នឹងការផ្ទេរដែនដីនេះ, ដែលប្រទេសរបស់យើងបានរក្សាសិទ្ធិរបស់ខ្លួនត្រឹមត្រូវតាមច្បាប់នៅលើដែនដីនោះ តែការតវ៉ានេះ

www.elibraryofcambodia.org

ជាការផុតអំពើ ។

ម្យ៉ាងទៀតប្រទេសបារាំង បានទទួចពោលពីករណីយកិច្ចរបស់ខ្លួនចំពោះជនជាតិបារាំងរាប់លាននាក់ដែលរស់នៅប្រទេស អាល់ហ្សេរី ។ សេចក្តីប្រែសប្រណីនេះត្រឹមត្រូវនឹងអាចឲ្យគេយោគយល់បានណាស់ ។ ប៉ុន្តែ បណ្តាលឲ្យខ្ញុំ ត្រូវរំលឹកដល់វាសនានៃសហគមន៍ខ្មែរចំនួន ៦០០.០០០នាក់ ដែលរស់នៅដោយគ្មានការធានាអះអាងបន្តិចបន្តួចណា ពីរដ្ឋាភិបាលវៀតណាមខាងត្បូងទេ ។ ម្យ៉ាងទៀតជនរួមជាតិ ៦០០.០០០នាក់ នេះពិតជាអ្នកកាន់កាប់ទឹកដីនោះមុនគេទៀតផង ។ គឺមិនមែនជាករណីត្រូវគ្នា នឹងករណីនៃជនជាតិបារាំងនៅប្រទេស អាល់ហ្សេរី ទេ ។ ក៏ប៉ុន្តែខ្ញុំមានជំនឿថា មេដឹកនាំ អាល់ហ្សេរីទាំងឡាយមុខជានឹងបើកឲ្យមានការធានាអះអាង ចំពោះជនជាតិបារាំងទាំងនោះ ដែលយើងមិនហ៊ានសង្ឃឹមថា គេព្រមធានារ៉ាប់រង ចំពោះជនរួមជាតិទាំងឡាយរបស់យើង ដែលស្ថិតនៅក្រោមនីតិកម្មរបស់វៀតណាម ខាងត្បូងឬទេ...? ។

...នៅពេលនេះ ខ្ញុំសូមអភ័យទោសដល់ប្រតិភូដ៏ជាទីគោរពទាំងឡាយចំពោះសន្ទរកថាដ៏វែងនេះ ហើយខ្ញុំសូមស្នើចំពោះអង្គការរបស់យើងមេត្តាគិតដល់ **បញ្ហា មនុស្សធម៌** ដែលតាមយោបល់របស់ខ្ញុំ ត្រូវតែធ្វើឲ្យអង្គការនេះយកចិត្តទុកដាក់គិតឲ្យបានដិតដល់ ។ បញ្ហានេះគឺជាបញ្ហា **អោនិតិជន** ហើយជាពិសេសបញ្ហាសហគមន៍ ដែលរស់នៅក្នុងប្រទេសដទៃ ។

បញ្ហានេះប៉ះពាល់ផ្ទាល់ដល់យើង ព្រោះថា ជនរួមជាតិរបស់យើងចំនួន ៦០០.០០០នាក់ បានរស់នៅក្នុងវៀតណាមខាងត្បូងកំពុងរងនូវលក្ខណៈដ៏លំបាកក្រៃលែង ហើយគ្មានអ្វីជាទីពឹងទាល់តែសោះ ដើម្បីតទល់នឹងវិធានការ ជាពិសេសដែលគេកំពុងរំលោភមកលើនោះទេ ។ សហគមន៍ខ្មែរ នៅវៀតណាមខាងត្បូង គឺជាម្ចាស់ទឹកដីពីដំបូងមក ដែលការលុកលុយរបស់ជនជាតិវៀតណាម បានមក

www.elibraryofcambodia.org

គ្របសង្កត់បាត់អស់ទៅនោះ, ប៉ុន្តែនៅតែរក្សាឯកភាព ដ៏ពេញលេញខាងសាសនា ខាងភាសា ខាងទំនៀមទម្លាប់និងប្រពៃណី ។ ដោយមានសេចក្តីសម្រេចរំលោភរបស់រដ្ឋាភិបាលយៀកណាមខាងត្បូងនោះ, សហគមន៍ខ្មែរនេះ បានទទួលនូវការបង្ខំឲ្យចូលជាតិជាយៀកណាម ហើយគេពុំព្រមបើកឲ្យមានសិទ្ធិ រក្សាទុកនូវទំនៀមទម្លាប់របស់ខ្លួន ភាសារបស់ខ្លួនព្រមទាំងទម្រង់ការនៃព្រះពុទ្ធសាសនា (ការហាមមិនឲ្យមានសំដែងធម៌ទេសនាជាខ្មែរ មិនឲ្យមានសៀវភៅធម៌ខ្មែរ) ។ល។ ការរំលោភប៉ះពាល់ដល់សិទ្ធិដ៏ថ្លៃថ្នូរ នៃមនុស្សទាំងនេះ កាន់តែមានថែមច្រើនឡើងទៀត ក្នុងឱកាសប៉ុន្មានខែចុងក្រោយនេះ ដោយមានវិធានការជាពិសេសយ៉ាងសាហាវ ហើយអាក្រក់បំផុត ដែលមិនមែនជាអំពើផ្តាច់មុខតែខាងអ្នករដ្ឋការដ៏ត្រឹមត្រូវតាមច្បាប់យៀកណាមខាងត្បូងតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាអំពើមកពីខាងពួកឧទ្ទាមដែលប្រយុទ្ធប្រឆាំង នឹងរដ្ឋាភិបាលនៅព្រៃនគរថែមទៀត ។ ជនរួមជាតិខ្មែរជីអភ័ព្វទាំងនេះជាច្រើនរយនាក់ បានប៉ុនប៉ងរត់ពីការជិះជាន់សង្កត់សង្កិននេះ ដើម្បីមករកជ្រកកូននៅក្នុងទឹកដីកម្ពុជា ។ ជនរួមជាតិទាំងនេះបានត្រូវគេ ដេញតាមចាប់ ឃុំឃាំង ធ្វើទារុណកម្មដល់រូបកាយ បាញ់រះសម្លាប់ចោល... ។

ចំណែកខាងខ្លួនវិញ ប្រទេសកម្ពុជាក៏មានអាទីតិជនយៀកណាមរស់នៅក្នុងប្រទេសដោយសេរី ក្នុងចំណោមនៃប្រជាពលរដ្ឋរបស់យើងដែរ ។ ហើយបានរក្សាទុកនូវសញ្ជាតិរបស់ខ្លួន ភាសារបស់ខ្លួន ទំនៀមទម្លាប់របស់ខ្លួន ។ លក្ខន្តិកៈនៃជនជាតិយៀកណាមទាំង ៤០០.០០០នាក់នេះ គឺជាលក្ខន្តិកៈនៃជនជាតិបរទេសទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា ទុកជាជនជាតិនៃប្រទេសខាងលិច ឬជនជាតិប្រទេសអាស៊ីក៏ដោយ ។

យើងពុំអាចនៅជា គ-ថ្លង់ ចំពោះសេចក្តីអំពាវនាវដ៏ អស់សង្ឃឹម នៃជនរួមជាតិយើង ដែលកំពុងរស់នៅក្នុងយៀកណាមខាងត្បូង នោះបានឡើយ ។ គឺហេតុនេះ

www.elibraryofcambodia.org

ហើយ ទើបយើងបានប៉ុនប៉ងជាច្រើនលើកច្រើនគ្រា ក្នុងកិច្ចចរចាគ្នាជាមួយរដ្ឋាភិបាល វៀតនាម ដើម្បីសុំឲ្យបានមានការសើរើរៀបចំលក្ខន្តិកៈរបស់ខ្លួននេះឡើងវិញ, ឬក៏យ៉ាងហោចណាស់ឲ្យបានដល់នូវការបន្ធូរបន្ថយខ្លះ ចំពោះជោគវាសនារបស់ ខ្មែរក្រោម យើង ។ តែគេបានប្រឆាំងមិនព្រមទទួលតាមយើងសុំនេះទេ ។ យើងក៏បានសុំចំពោះទៅស្នងការដ្ឋាន សម្រាប់អ្នកភៀសខ្លួននៃអង្គការសហប្រជាជាតិទៀត, អ្នកធ្វើអង្កេតទាំងឡាយបានមក ហើយបានសួរចម្លើយដល់អ្នកដំណាងនៃអ្នកភៀសខ្លួន មកពីសហគមន៍ខ្មែរទាំងនោះ, ហើយបានធ្វើសេចក្ដីរាយការណ៍មួយ ។ តែគ្មានបានលទ្ធផលអ្វីសោះ ។

ការពុំព្រមរបស់រដ្ឋាភិបាលវៀតនាម ក្នុងការពិនិត្យរួមជាមួយយើងនូវបញ្ហាដែលកើតមានឡើងពីអានីតិជនទាំង ៦០០.០០០នាក់នោះ, ពុំមែនមានដូចជានៅក្នុងសាកលលោកនេះទេ ។ យើងមានឧទាហរណ៍ក្នុងរឿងនេះនៅប្រទេស "អូទ្រិស" និងនៅប្រទេស "អ៊ីតាលី", ដែលបានរិះរករួមជាមួយគ្នា នូវការដោះស្រាយមួយចំពោះបញ្ហាប្រជាជននៅតំបន់ទន្លេ "អាឌីស" ខាងលើ ។ ប៉ុន្តែវៀតណាមខាងត្បូងគេសំអាងហេតុថា គេមិនមែនជាសមាជិកនៃ អ.ស.ប. ទេ, ដើម្បីមិនព្រមជជែកពិភាក្សាអ្វីទាំងអស់, ជាហេតុធ្វើឲ្យឃើញនូវការគ្មានផលប្រយោជន៍ដែលទុកប្រទេសខ្លះ និងប្រជាពលរដ្ឋខ្លះឲ្យនៅក្រៅអង្គការរបស់យើង ។ ការឥតផលប្រយោជន៍នេះ បានកើតមានឡើងមួយចំណែកទៀត នៅក្នុងការលំបាកទាំងឡាយដែលអាចធ្វើឲ្យឃើញរូបរាងឡើង បើកាលណាគេគិតគួរនឹងយករឿងប្រទេសលាវទៅជូន អ.ស.ប. ដែលគ្មានទាំងវៀតណាមខាងជើង និងគ្មានទាំងប្រទេសចិនពិនិត្យផងនោះ... ។

បញ្ហាអានីតិជនខ្មែរ នៅវៀតណាមខាងត្បូង មិនមែនកើតមានតែម្នាក់ឯងក៏ទេដែរ នៅក្នុងសកលលោក ។ គឺដោយហេតុនេះហើយ ដែលខ្ញុំជឿថា សហប្រជាជាតិ

www.elibraryofcambodia.org

ត្រូវតែយកចិត្តជាចាំបាច់ គិតដល់ឲ្យបានខ្លាំងឡើង ចំពោះកិច្ច ការពារសិទ្ធិរបស់មនុស្ស ដែលត្រូវគេបង់ដៃចង់ជើង បណ្តោយឲ្យអ្នករំលោភ ជិះជាន់នោះ ....

## សេចក្តីថ្លែងការណ៍នៃប្រទេសកម្ពុជា អំពីទឹកដីរបស់ខ្លួននៅវៀតណាមខាងត្បូង (កូសាំងស៊ីន) ចំពោះសន្និសីទហ្សឺណែវ ឆ្នាំ ១៩៥៤

មានបញ្ហាពីរប្រការដែលប្រទេសកម្ពុជាត្រូវបានកិច្ចប្រជុំនៅទីក្រុងហ្សឺណែវយកចិត្តទុកដាក់នោះ ។ ម្យ៉ាងគឺទឹកដីនោះបានផ្សារភ្ជាប់ទៅនឹងការប្រឆាំងចំពោះកម្លាំងទ័ពវៀតមិញ ដែលតែងតែបានសាបព្រួសនូវអសន្តិសុខ នៅលើទឹកដីកម្ពុជាកាលពីពេលថ្មីៗនេះ ។ ថែមទាំងបានធ្វើការឈ្លានពាន ទៅលើខេត្តមួយចំនួននៅភាគខាងជើង នៃប្រទេសនេះទៀតផង ។ ប្រទេសកម្ពុជា ក៏ដូចជា ប្រជាជាតិទាំងឡាយតែងមានសំណូមពរចង់ឲ្យសន្តិភាព វិលត្រឡប់មកកាន់ឥណ្ឌូចិនវិញ ។ ម្យ៉ាងទៀតប្រទេសកម្ពុជាសុខចិត្តបៀសវាង មិនទទួលយកសន្តិភាពដែលស្ថាបនារួមគ្នាក្រោមការឧបត្ថម្ភនៃប្រទេសមហាអំណាចធំៗ ដោយគ្មានបានទទួលអ្វីក្រៅអំពីផលវិបាកនៃការបាត់បង់ទឹកដី ដែលខ្លួនកាន់កាប់នៅវៀតណាមខាងត្បូង (គឺកូសាំងស៊ីន) នោះឡើយ ។ គឺបញ្ហាទី២ នេះហើយដែលជាគោលបំណងនៃការធ្វើនិក្ខេបបទខាងលើនោះនេះ បន្ទាប់ពីបង្ហាញនូវប្រវត្តិសាស្ត្រដ៏ខ្លីមួយ និងបង្ហាញឲ្យឃើញនូវតឹកតាងជាច្រើនបញ្ជាក់ពីបញ្ហារាប់មិនអស់របស់ទឹកដីកម្ពុជានៅវៀតណាមខាងត្បូង ហើយចង់លើកជាទិសដៅនៃដំណោះស្រាយមួយចំនួន ។

*****

www.elibraryofcambodia.org

**១-ប្រវត្តិសាស្ត្រដីខ្មែរមួយដែលបង្ហាញថា ហេតុអ្វីបានជាទឹកដី កូសាំងស៊ីន របស់ប្រទេសកម្ពុជា ស្រាប់តែត្រូវស្ថិតនៅក្នុងកណ្តាប់ដៃ របស់ពួកវៀតណាម**

មុននឹងសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់ ទឹកដីឥណ្ឌូចិនរបស់បារាំង រួមមាន ៥ប្រទេសផ្សេងៗពីគ្នាគឺ : ទឹកដីតុងកឹង, អណ្ណាម, កូសាំងស៊ីន, លាវ និងកម្ពុជា ។ ប្រទេសទាំងបី នៅខាងដេម មានប្រជាជាតិទាំងឡាយដែលមានឈ្មោះរួមគ្នាថា "ជនជាតិអណ្ណាម" (បច្ចុប្បន្នគឺវៀតណាម) ដែលមានអារ្យធម៌ មានប្រភពដើមមកពីប្រទេសចិន ។ ចំណែកប្រទេសកម្ពុជាវិញ ប្រជាជាតិមានអារ្យធម៌ ។ តាមបែបហិណ្ឌូ មានភាពខុសគ្នាដាច់ស្រឡះតែម្តងជាមួយប្រជាជាតិនៃបណ្តាប្រទេសទាំងបីខាងដើមនោះ ។

ពួកជនជាតិអណ្ណាម ដែលមានពូជអម្បូរដើមជា "វៀត" ដែលស្ថិតនៅក្នុងអម្បូរពួកកុលសម្ព័ន្ធមួយ ស្ថិតនៅក្នុងប្រទេសចិនភាគខាងត្បូងនោះ បាននាំគ្នាធ្វើអន្តោប្រវេសន៍ទាំងហ្វូងៗសំដៅទៅទិសខាងត្បូង ហើយក៏បាននាំគ្នាពង្រាយសាយភាយលាតសន្ធឹងពាសពេញ ប្រៀបបានទៅនឹង "ទឹករលកក្នុងទឹកជំនន់ ឬក៏ដូចជាស្រទាប់ជាតិប្រេង ដែលកំពប់អណ្តែតលើផ្ទៃទឹក តាំងពីទន្លេក្រហមអណ្តែតបាចសាចមកដល់ទន្លេមេគង្គខាងក្រោម តាំងពីព្រំដែននៃប្រទេសចិន និងឈូងសមុទ្រកុងកឹងរហូតមកជ្រោយទឹកខ្មៅ (Camau) និងឈូងសមុទ្រសៀម (ប្រយោគខាងលើនេះបានដកស្រង់ចេញពី សៀវភៅប្រវត្តិសាស្ត្រ ស្តីអំពីបណ្តាប្រទេសក្នុងសហភាពឥណ្ឌូចិន របស់លោក ង្វៀន ម៉ាញ់គ្វេ (Nguyên Manh Quê) ជាជនជាតិវៀតណាមផ្ទាល់តែម្តង ។ ទំព័រទី២៤) ។ ពួកជនជាតិអណ្ណាមទាំងនោះ បានធ្វើការបំផ្លិចបំផ្លាញរាជាណាចក្រចម្ប៉ា ទាល់តែវិនាសអស់ (គឺជាប្រទេសដែលជនជាតិចាមបានរស់នៅ) ហើយបន្ទាប់មកក៏បានកាន់កាប់នូវចំណែកមួយ នៃទឹកដីរបស់ប្រទេសកម្ពុជា នៅក្នុងពេលដែលបារាំងបានចូលមកដាក់នឹមអាណានិគម នៅ

www.elibraryofcambodia.org

ឥណ្ឌូចិន កាលពីខែកុម្ភៈ ឆ្នាំ ១៨៥៩ (កាលបរិច្ឆេទនៃការដណ្ដើម យករបស់ក្រុងសៃហ្គន) នោះ ។ មូលហេតុដែលបណ្ដាលឲ្យវៀតណាម អាចកាន់កាប់ដែនដីមួយផ្នែករបស់កម្ពុជានេះ គឺបណ្ដាលមកពី ជួនកាលអំពីការបេះទឹកដី ម្ដងម្កាលពីសំណាក់ពួករាជវង្សបះបោរកម្ពុជា ឬជួនកាលបណ្ដាលពីចិត្តសប្បុរសផ្សេងៗ ពីសំណាក់ព្រះរាជានៃប្រទេសកម្ពុជា ។ ឧទាហរណ៍ដូចជាស្រុកព្រះត្រពាំង (ឬត្រាវិញ) ដែលបានប្រគល់ទៅឲ្យព្រះចៅអធិរាជ យ៉ា ឡុង (Gia long) សម្រាប់ស្នាក់អាស្រ័យដោយសារតែត្រូវពួកបះបោរ Tây Son (អានថា តី សឺន) "បានន័យថា ពួកអ្នកមកពីជួរភ្នំខាងលិច" ដេញចេញពីរាជបល្ល័ង្ក ។ ព្រះចៅអធិរាជ យ៉ាឡុង ក៏បានយកទីកន្លែងស្នាក់ អាស្រ័យនោះ បង្កបង្កើនទ័ពនៅទីនោះ និងទទួលបានកម្លាំងទ័ពជំនួយពីសំណាក់ព្រះ បាទអង្គអេង ព្រះចៅក្រុងកម្ពុជា (១៧៧៩-១៧៩៦)។ ក្រោយការបង្ក្រាបពួកបះបោរ តីសឺន និងការវិលត្រឡប់ទៅសោយរាជ្យ នៅប្រទេសអណ្ណាមវិញ ព្រះចៅ យ៉ា ឡុង ក៏បាននឹកឃើញដល់គុណនៃការទទួលឲ្យស្នាក់អាស្រ័យដីសែនកក់ក្ដៅ នៅស្រុកត្រាវិញ ហើយបានស្នើសុំទៅ ព្រះបាទអង្គអេង ឲ្យស្រុកនោះបានរួចចាកផុតពីគ្រប់ការគ្រប់គ្រង ហើយឲ្យប្រជាជនរស់នៅទីនោះ បានរួចចាកផុតពីការបង់ពន្ធដារ និងកំណែនផ្សេងៗ ។ ព្រះបាទអង្គអេង ក៏បានយល់ព្រមដោយសារតែដើម្បីចំណងមិត្តភាព ។ បន្ទាប់ពីពេលនោះមកព្រះចៅយ៉ាឡុង ក៏បានប្រើអំណាចត្រួតត្រាស្រុកនោះ ឲ្យនៅក្រោមអាណានិគមរបស់ពួកអណ្ណាមតែម្ដងទៅ (យោងតាមព្រះសារលិខិតរបស់ ព្រះបាទ អង្គឌួង ទៅកាន់ព្រះចៅអធិរាជ ណាប៉ូឡេអុងទីបី ដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រប្រទេសថៃ)។

ជាមួយគ្នានោះដែរ តំបន់ទាំងឡាយនៅក្បែរក្រុងសៃហ្គន មាន កំពង់ស្រកាត្រី (Bien- Hoa), ព្រះសួគ៌ា (Baria), សុទ្ធតែត្រូវបើកឲ្យជនអន្តោប្រវេសន៍ អណ្ណាមចូលមកជ្រកកោន ដោយទទួលបានការអនុញ្ញាតយ៉ាងកក់ក្ដៅពីព្រះបាទជ័យជេដ្ឋាទី

www.elibraryofcambodia.org

២ កាលពីឆ្នាំ ១៦៦៣ ។ ព្រះអង្គម្ចាស់អណ្ណាមឈ្មោះ ង្វៀន សៃវឿង (Nguyên Sai Vuong) បានស្នើសុំឲ្យជនអន្តោប្រវេសន៍របស់ទ្រង់មានសិទ្ធិប្រកបរបរដាំដុះនៅលើទឹកដីនោះ ព្រមទាំងធ្វើមុខជំនួញផ្សេងៗទៀត ដោយបង់ពន្ធជូនរដ្ឋ ។ ព្រះបាទជ័យជេដ្ឋាទី២ ដែលបានរៀបអភិសេកជាមួយនឹងម្ចាស់ក្សត្រីយ៍អណ្ណាមមួយព្រះអង្គត្រូវជាបុត្រីរបស់ ង្វៀន សៃវឿង ក៏បានយល់ព្រមតាមការស្នើសុំ ។ ពីព្រោះតាមទំនៀមទម្លាប់នៃចក្រភពខ្មែរ ព្រះមហាក្សត្រយានី, ព្រះអតីតមហាក្សត្រីយានី ព្រះឧបយុវរាជ គឺព្រះអង្គទាំងអស់នោះ ពិតជាបានទទួលចំណែកស្តីអំពីគោរម្យងារនិងឯកសិទ្ធិ អស់មួយជីវិត ទៅលើខេត្តមួយចំនួន នៃចក្រភព ។ ខេត្តទាំងអស់នោះនឹងស្ថិតនៅជាកម្មសិទ្ធិរបស់ព្រះចៅអធិរាជ ជារៀងរហូត ។ ក៏ប៉ុន្តែ ម្ចាស់កម្មសិទ្ធិនៃខេត្តទាំងអស់នោះ នឹងទទួលបានសារប្រយោជន៍ ដោយច្បាប់ឯកសិទ្ធិមួយចំនួនលើកលែងតែការគ្រប់គ្រងអាជ្ញាធរដែនដី ត្រូវស្ថិតនៅក្រោមឱវាទនៃព្រះចៅអធិរាជ (ទាំងការបង់ពន្ធដារទាំងភ្នាក់ប៉ូលិស... ។ល។

នៅចំពោះមុខ ការវាតពង្រីកយកទឹកដី កម្ពុជា ពីសំណាក់ពួកជនជាតិអណ្ណាម ព្រមទាំងការភ័យព្រួយចំពោះការព្រមព្រៀងគ្នារវាងពួកសៀម និងពួកអណ្ណាមក្នុងការបែងចែកទឹកដីកម្ពុជានៅថ្ងៃអនាគតនោះ, នៅឆ្នាំ ១៨៥៣ "ព្រះបាទអង្គដួង" ក៏បានបញ្ជូនជាសម្ងាត់នូវជំនូនជាច្រើនមុខទៅកាន់កុងស៊ុលបារាំង នៅសាំងហ្គាពួរ ព្រមទាំងសារលិខិតមួយច្បាប់ ទៅថ្វាយព្រះចៅអធិរាជ ណាប៉ូឡេអុងទីបី សំណូមពរចង់ឲ្យមានអាណាព្យាបាលអំពីប្រទេសបារាំងមកលើប្រទេសកម្ពុជា (សៀវភៅប្រវត្តិសាស្ត្រនៃបណ្តាប្រទេសនៅសហភាពឥណ្ឌូចិន ដោយលោក ង្វៀន ម៉ាញ់ក្វេ ទំព័រ២៨០, ...សៀវភៅប្រវត្តិសាស្ត្រសង្ខេបនៃព្រះរាជាណាចក្រកម្ពុជា ដោយលោក ហង់រី រូសស្យេ Henri Russier ទំព័រទី៨៣) ។ ព្រះសារលិខិតនោះ ពុំបានទទួលការឆ្លើយតបទេ, ព្រះបាទអង្គដួងក៏បានសម្រេចព្រះទ័យ ជូនបណ្តឹងទៅកាន់

www.elibraryofcambodia.org

ប្រទេសបារាំងជាមួយ និងព្រះសារលិខិតមួយថ្មីទៀតព្រមទាំងជំនូនជាច្រើនផង, ហើយស្នើសុំឲ្យប្រទេសបារាំង ធ្វើសេចក្តីសម្រេចស្តីអំពីសម្ព័ន្ធមេត្រីភាព ជាមួយនឹងប្រទេសកម្ពុជា ។ ហើយក៏បានអង្វរករសុំឲ្យព្រះចៅអធិរាជបារាំង កុំឲ្យយល់ព្រមទទួលនូវទឹកដីមួយចំនួន ដែលបានរាយនាមនៅក្នុងសារលិខិតនោះ, ប្រសិនបើពួកអណ្ណាមសុខចិត្តប្រគល់ទឹកដីទាំងនោះ ទៅឲ្យប្រទេសបារាំង, ពីព្រោះថាទឹកដីទាំងអស់នោះ ជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា (យោងតាមព្រះសារលិខិតរបស់ព្រះបាទ អង្គដួង ដកស្រង់ ចេញពីសៀវភៅប្រវត្តិសាស្ត្រនៃប្រទេសថៃ) ។

អនុវត្តតាមយុទ្ធវិធីច្រើនយ៉ាង ក្នុងការពង្វាតយកទឹកដីនៅសតវត្សរ៍ទី១៩ ហើយជាពិសេស ដោយសារតែមានការបង្ហាញនូវសមានចិត្ត និងការជឿជាក់របស់កម្ពុជាផង, ប្រទេសបារាំង ក៏បានធ្វើអន្តរាគមន៍ នៅកូសាំងស៊ីន (ក្នុងន័យថាវាយវៀតណាម យកដីមកធ្វើអាណាព្យាបាល តាមសំណូមពររបស់ខ្មែរ) ។ ការប្រយុទ្ធគ្នានៅទីក្រុងសៃហ្គនកាលពីឆ្នាំ ១៨៥៩ កងទ័ពកម្ពុជា បានគាំទ្រកងទ័ពបារាំង ធ្វើដំណើរព្រមគ្នា ឆ្ពោះទៅកាន់ខេត្តមាត់ជ្រូក (Chau doc), ខេត្តក្រមួនស (Rach Gia), ខេត្តស្រុកឃ្លាំង (Soc Trang) និងខេត្តព្រះត្រពាំង (Tra Vinh) ។

យោងតាមសន្ធិសញ្ញាសន្តិភាព និងមិត្តភាពនៅទីក្រុងសៃហ្គន កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ ១៨៦២, ប្រទេសអណ្ណាម ក៏បានយល់ព្រមទទួលយកគោលការណ៍សំខាន់ៗទាំងឡាយ ដែលទាក់ទិននៅនឹងការប្រតិបត្តិការដោយសេរី តាមសាសនាកាតូលិក នៅលើទឹកដីរបស់ខ្លួន ការប្រកាន់តាមកិច្ចសន្យាមិនយល់ព្រមលះបង់ចំណែកណាមួយ នៃទឹកដីរបស់ខ្លួនទៅឲ្យនរណាទាំងអស់ ដោយមិនបានពិភាក្សាជាមួយនឹងប្រទេសបារាំង ។ ការបើកឲ្យធ្វើពាណិជ្ជកម្ម បារាំង អេស្ប៉ាញ នៅតាមកំពង់ផែមួយចំនួន សំណងថ្លៃខូចខាតក្នុងការធ្វើសង្គ្រាម ។ "ខ" សំខាន់មួយគួរឲ្យចាប់អារម្មណ៍ ជាពិសេសចំពោះប្រទេសកម្ពុជា ដោយអាស្រ័យលើអំណាចនោះ

www.elibraryofcambodia.org

ប្រទេសវៀតណាម ត្រូវលះបង់ខេត្តចំនួនបីរបស់កម្ពុជា ដែលខ្លួនបានកាន់កាប់នោះ ទៅឲ្យប្រទេសបារាំងកាន់កាប់ជំនួស គឺ : កំពង់ស្រកាត្រី (Bien Hoa) , យ៉ាឌិញ (Gia dinh) និងមេ ស (My Tho) ។ "នេះហើយគឺជា "ខ" ដីសំខាន់មួយ ដែលគ្មានតម្លៃទាល់តែសោះ ។ ដោយសារតែពួកអណ្ណាមបានយល់ព្រមលះបង់អស់តែមួយភាគបីប៉ុណ្ណោះ នូវទឹកដីដែលមិនមែនជាកម្មសិទ្ធិរបស់ពួកគេទាល់តែសោះនោះ ។

ក្រោយមកទៀតនៅឆ្នាំ ១៨៦៧ ដោយយកលេសថា សន្ធិសញ្ញានៅទីក្រុងសៃហ្គន ត្រូវទទួលការគំរាមបំពារបំពានអំពីជនជាតិអណ្ណាម (ក្នុងន័យថា ជួយការពារទឹកដីឲ្យខ្មែរកុំឲ្យយួនធ្វើបាប) ប្រទេសបារាំងក៏បានដកហូតយកទឹកដីនៅលើខេត្តបីទៀត ដែលជាទឹកដីរបស់ប្រទេសកម្ពុជា យកទៅកាន់កាប់បន្ថែមទៀត គឺខេត្តលង់ហោរ (Vinh long), ខេត្តមាត់ជ្រូក (Chau doc), និងខេត្តពាម (Ha tien) (តាមរយៈអ្នកតំណាងរបស់ខេត្តលោកឧត្តមនាវី ឡាក្រង់ឌីយែរ Lagrandière) បន្ទាប់មកគឺប្រទេសបារាំង បានមកត្រួតត្រាកាន់កាប់ទឹកដីកូសាំងស៊ីន ប៉ែកខាងលិចទាំងអស់តែម្តង ។ ប្រទេសបារាំងក៏បានដណ្តើមយក កោះត្រល់ (Phu quôc) ដែលជាទឹកដីរបស់ប្រទេសកម្ពុជាទៀត, ហើយនៅទីបំផុត បារាំងក៏បានដណ្តើមកាន់កាប់ទឹកដី កូសាំងស៊ីន ទាំងមូលតែម្តង (បច្ចុប្បន្នជាវៀតណាមខាងត្បូង) ។ ធ្វើឲ្យក្លាយទៅជាទឹកដីចំណុះឲ្យអាណានិគមបារាំងដោយសារតែសន្ធិសញ្ញា បារាំង-អណ្ណាម កាលពីឆ្នាំ ១៨៧៤ (ដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រនៃបណ្តាប្រទេសសហភាពឥណ្ឌូចិន ដោយលោក ង្វៀន ម៉ាញ់ក្វេ ត្រង់ទំព័រទី១៦៤ ដល់ ១៦៧) ។

## ២- ភស្តុតាងបញ្ជាក់បង្ហាញថា ទឹកដីមួយចំនួននៅកូសាំងស៊ីន គឺជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា

នៅមានសល់ភស្តុតាងជាច្រើន ដែលអាច បញ្ជាក់យកជាកសិណបានថា ទឹកដី

www.elibraryofcambodia.org

ទាំងអស់នោះពិតជារបស់ប្រទេសកម្ពុជាពិតមែន ។

-បើនិយាយអំពីបុរាណវត្ថុវិទ្យាវិញ ប្រាសាទទាំងឡាយ, រូបចម្លាក់ធ្វើអំពីស្ពាន់និងថ្ម, សិលាចារិក, បូជនិយដ្ឋានសាសនា, ព្រះវិហារធ្វើអំពីឥដ្ឋ, សសរស្តម្ភទាំងអស់នោះ, សុទ្ធសឹងបានបញ្ជាក់អំពីវត្តមានរបស់បុព្វបុរសកម្ពុជានៅក្នុងតំបន់ទាំងនោះ ។

- បន្ថែមពីលើភស្តុតាងខាងផ្នែកបុរាណវត្ថុវិទ្យា ក៏នៅមានសល់ផែនទី កូសាំងស៊ីនចាស់ៗ, ផែនទីកាលពីសតវត្សរ៍ទី៧, ទី៨, ផែនទីដែលបានគូសវាសកាលពីឆ្នាំ ១៥៩៣, ផែនទីកាលពីឆ្នាំ ១៦៣៨, ផែនទីគូសដោយ"លោកឪពុក" រូដ (Rhodes) កាលពីឆ្នាំ ១៦៥០, ផែនទីឥណ្ឌូចិន បោះពុម្ពផ្សាយដោយលោកឌូវីល (Durville) កាលពីឆ្នាំ ១៧៥៥ ។ល។ ក្រៅអំពីនោះនៅមានសេសសល់អត្ថបទចម្រុះផ្សេងៗជាច្រើនទៀត ដែលសរសេរជាភាសាខ្មែរ, អណ្ណាម និងបារាំង ដែលបានអះអាងបញ្ជាក់បន្ថែម ស្តីអំពីអធិបតេយ្យភាពរបស់កម្ពុជា នៅលើទឹកដីមួយចំនួននៅកូសាំងស៊ីន ។

-បើផ្អែកទៅតាមផ្លូវច្បាប់វិញ វាពិតជាមិនអាចទៅរួចទេ ចំពោះការដែលអះអាងថា ប្រទេសកម្ពុជាឈប់ធ្វើជាម្ចាស់កម្មសិទ្ធិនៃទឹកដីទាំងនោះហើយ

-ច្បាប់អន្តរជាតិបានចាត់ទុកជាត្រឹមត្រូវចំពោះរបៀប ៦បែបនៃលទ្ធកម្មមកពីប្រភពដើម

- ការកាន់កាប់ដែនដីមួយដែលទំនេររួចផុតអំពីការគ្រប់គ្រងគ្រប់បែបយ៉ាងព្រមទាំងធ្វើតាមស្ថានភាពជាប្រក្រតីទាំងឡាយ ។

- ការប្រើអំណាចយោធាលើទឹកដីនោះ ។

- ការដេញថ្លៃបាន

- កំណត់ដោយផ្លូវច្បាប់មួយចំណែកទៀតសម្រាប់លទ្ធកម្មដែលក្លាយមកអំពី

www.elibraryofcambodia.org

ដែនដីផ្សេងៗដទៃទៀត ។

– ការបានមកដោយអនុប្បទាន (ដោយការប្រគល់ឲ្យ) ។

– ការពង្រីកដោយសារតែការលុកលុយផ្នែកយោធា ។

ហេតុដូច្នេះហើយ ការកាន់កាប់ដោយពួកអណ្ណាមពិតជាមិនប្រក្រតីឡើយ ដោយហេតុថា ពួកគេបានកាន់កាប់លើទឹកដីមួយ ដែលមិនមែននៅទំនេរនោះទេ ។ ហើយក៏មិនអាច ធ្វើឲ្យក្លាយទៅជាការពិតបានដោយផ្នែកតាមលក្ខណៈសម្បត្តិ ដែលកំណត់នៅក្នុងកតិកាសញ្ញា នៅទីក្រុងប៊ែរឡាំងកាលពីឆ្នាំ ១៨៨៥ ជាពិសេសតាមរបៀបជាអចិន្ត្រៃយ៍ ព្រមទាំងការឲ្យដំណឹងដោយលាយលក្ខណ៍អក្សរ ជាផ្លូវការផ្ញើទៅកាន់ប្រទេសមហាអំណាចទាំងបី ។

ពិតជាមិនដែលមានលទ្ធកម្មឯណា ដែលកើតមកដោយសារអំណាចយោធាឡើយ ។ ពីព្រោះថា អំណាចរបស់រដ្ឋដែលមាននៅលើដែនដី ដែលត្រូវគេកាន់កាប់នោះ ពិតជាមិនធ្លាប់ត្រូវបានផ្តួលរំលំទាំងស្រុងនោះទេ ហើយរដ្ឋាភិបាលកម្ពុជាក៏តែងតែគ្រប់គ្រងដែនដីនោះ តែរហូតមក ។

ពួកអណ្ណាមមិនត្រឹមតែមិនបាន ទទួលលទ្ធកម្មដែនដីនៅ កូសាំងស៊ីន ដោយសារ តែការដេញថ្លៃបាន (កុំមានរដ្ឋសហគមន៍ទាល់តែសោះ) (កិច្ចប្រ... សង្គមប្រជាជាតិ (Société de Nations...) យុត្តាធិការអន្តរជាតិ (Juridiction Internationale) ពិតជាមិនបានកំណត់ឲ្យដែនដីទាំង... ទៅឲ្យពួកអណ្ណាមទេ ។

ការកំណត់តាមផ្លូវច្បាប់ នៃដែនដីនោះ ពិតជាមិនអាចយកមកធ្វើជាសំអាងបានឡើយ ។ គេមិនអាចយកទឡ្ហីករណ៍នោះ មកប្រើប្រាស់ដោយផ្អែកលើសកម្មភាព ដែលស្តែងចេញដោយព្រះរាជា នៃកម្ពុជា នៅក្នុងកាលសម័យវិបត្តិផ្ទៃក្នុងប្រទេសព្រមទាំងរយៈកាលស្ថិតនៅក្រោមអាណានិគមបារាំងនោះឡើយ ។ គ្រប់សម័យកាលទាំងអស់ ព្រះរាជាខ្មែរគ្រប់អង្គ តែងតែសំដែងឲ្យឃើញដោយធ្វើការ

www.elibraryofcambodia.org

ទាមទារតវ៉ា ឬក៏ដោយធ្វើបទអន្តរាគមន៍ ឬដោយអាវុធដែលបង្ហាញពីការប្តេជ្ញាចិត្តមិន ព្រមបោះបង់ចោលដែនដី ដែលកាន់កាប់ដោយពួកអណ្ណាម ។ កាលពីឆ្នាំ ១៧៣៨ ព្រះបាទអង្គសួរ ក៏បណ្តេញពួកគេចេញពីខេត្តពាម ។ នៅឆ្នាំ ១៧៧៨ ព្រះអង្គនន់ក៏បានដណ្តើមយកខេត្តកំពង់ស្រកាត្រី និងមេ ស ដោយចក់ឱកាសមានការបះបោរនៅប៉ែកខាងក្រោមកូសាំងស៊ីន, ក្នុងពេលដែលពួកតីសឹន ងើបឡើងបះបោរដែរ ។ នៅឆ្នាំ ១៨៥៩, ព្រះបាទអង្គដួង ក៏បានបញ្ជាទ័ពទៅកាន់ខេត្តមាត់ជ្រូក នៅពេលពួកបារាំងបានមកដល់, ហើយការប្រយុទ្ធក៏នៅតែបន្តមិនឈប់ ។

ចំពោះការតវ៉ាផ្សេងៗទៀត ក៏កាន់តែកើនឡើងជាញឹកញាប់, ព្រះបាទអង្គឌួ បានធ្វើការទាមទារនោះ, ហើយបានធ្វើបន្តទៀត ដោយព្រះបាទអង្គច័ន្ទ នៅឆ្នាំ ១៦៥៣ ។ ដោយមិននិយាយដល់ "ព្រះបាទអង្គដួង" ដែលបានស្នើសុំឲ្យមានបទអន្តរាគមន៍ពីប្រទេសបារាំង ជាចម្បងសម្រាប់ការទាមទារយកវិញនូវខេត្តទាំងឡាយរបស់ខ្មែរនៅកូសាំងស៊ីននោះផង ។ នៅក្នុងឱកាសយាងទៅកាន់ទីក្រុងសៃហ្គនកាលពីខែតុលា ឆ្នាំ ១៨៦៤ (មួយឆ្នាំក្រោយការចុះហត្ថលេខាលើសិទ្ធិសញ្ញាក្រោមអាណានិគមបារាំង), "ព្រះបាទ នរោត្តម" ក៏បានជំរុញឲ្យមានដំណើរការទាមទារយ៉ាងតឹងតែង ទៅកាន់ពួកអាជ្ញាធរបារាំង ដើម្បីបានធ្វើជាម្ចាស់កម្មសិទ្ធិ នៃបណ្តាខេត្តនៅ កូសាំងស៊ីន ឡើងវិញ ។

ក្រោមការកាន់កាប់របស់ពួកជប៉ុន, ដោយសារតែការប្រកាសរបស់ព្រះបាទសម្តេចព្រះ "នរោត្តម សីហនុ" កាលពីថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៤៥, ដែលប្រឆាំងទៅនឹងការប៉ុនប៉ង របស់ពួកវៀតណាមក្នុងការធ្វើឲ្យបានសម្រេចដោយភាពស្រុះស្រួលគ្នា ដើម្បីលាយបញ្ចូលគ្នាទឹកដី កូសាំងស៊ីន ទាំងមូល, ឲ្យក្លាយទៅជាទឹកដីរបស់ខ្លួននោះ, ព្រះអង្គបានថ្លែងយ៉ាងជាក់លាក់ ដោយប្រុងប្រយ័ត្ន ស្តីអំពីសិទ្ធិរបស់កម្ពុជា នៅលើដែនដីកូសាំងស៊ីន, ព្រមទាំងណែនាំឲ្យមានការតែងតាំង

www.elibraryofcambodia.org

គណៈកម្មការចម្រុះមួយ ស្តីអំពីការកំណត់ព្រំដែនរវាងខ្មែរ និងវៀតណាម ។ រដ្ឋាភិបាល ណាមបូ (រដ្ឋាភិបាលហូជីមិញ), បានយល់ព្រមឯកភាពនៅឆ្នាំ ១៩៤៥ ស្តីអំពីគោលការណ៍កែប្រែការកំណត់ព្រំដែន ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា ។

បន្ទាប់ពីការបែកបាក់គ្នា នៅក្នុងរដ្ឋាភិបាលហូជីមិញរួចមក, (ដែលនេះជាបញ្ហាចោទចំពោះប្រទេសបារាំង) ដោយយល់ព្រមតាមការស្នើសុំរបស់រដ្ឋាភិបាលព្រះចៅ ចៅដាយ, ដែលលំអៀងទៅរកការបង្រួបបង្រួមប្រទេសទាំងបី (ការរួមបញ្ចូលគ្នានៃដែនដីតុងកឹង អណ្ណាម និងកូសាំងស៊ីន ឲ្យក្លាយទៅជាទឹកដីតែមួយរបស់វៀតណាម) ព្រះបាទសម្តេចព្រះ "នរោត្តម សីហនុ" ក៏បានស្នើសុំតាមសារលិខិតចុះថ្ងៃទី២០ ខែ មករា ឆ្នាំ១៩៤៨, ទៅកាន់អគ្គស្នងការជាន់ខ្ពស់បារាំងនៅឥណ្ឌូចិន។ ដើម្បីឲ្យបានជ្រាបជាដំណឹង ស្តីអំពីកិច្ចចរចាដែលបារាំងនឹងចាប់ផ្តើមធ្វើជាមួយវៀតណាម ។ ក្រៅអំពីការជាប់មមាញឹកក្នុងរឿងរ៉ាវនៅកម្ពុជា ប្រទេសបារាំងក៏បានចុះហត្ថលេខា ជាមួយព្រះចៅចៅដាយ ស្តីអំពីកិច្ចព្រមព្រៀងនៅឆកសមុទ្រ ហាឡុងនៅឆ្នាំ ១៩៤៨ ។ ក្នុងនោះមានការយល់ព្រមទទួលស្គាល់ជាគោលការណ៍ នៃការរួមបញ្ចូលតែមួយរបស់ ប្រទេសទាំងបី ។ ព្រះបាទសម្តេចព្រះ "នរោត្តម សីហនុ", បានប្រឆាំងនឹងកិច្ចព្រមព្រៀងនោះ ដោយព្រះសារលិខិតចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៤៨, ហើយនៅឆ្នាំ ១៩៤៩ ព្រះអង្គបានបញ្ជូនគណៈប្រតិភូកម្ពុជាមួយក្រុម ដើម្បីតាមដានការពិភាក្សាតទល់នៅឯរដ្ឋសភាបារាំង ស្តីអំពីច្បាប់ទាក់ទិនទៅនឹងការផ្លាស់ប្តូរលក្ខន្តិកៈនៅកូសាំងស៊ីន, ហើយនឹងការផ្សារភ្ជាប់ កូសាំងស៊ីន ជាមួយប្រទេសវៀតណាមនោះ, ដើម្បីថ្លែងការណ៍ប្រឆាំងទៅនឹងសមាហរណកម្ម នៃទឹកដីដែលជារបស់កម្ពុជា នៅ កូសាំងស៊ីន ទៅឲ្យប្រទេសវៀតណាម ។

ថ្វីបើកម្ពុជា មានការតវ៉ាប្រឆាំងយ៉ាងខ្លាំងក្លាក្តី ក៏ប្រទេសបារាំង នៅតែធ្វើអនុប្បទានទឹកដី កូសាំងស៊ីន ឲ្យទៅវៀតណាមដែរ, ដោយសារតែបារាំងគោរពតាម

www.elibraryofcambodia.org

ច្បាប់ផ្ទៃក្នុងរបស់ខ្លួន, ហើយវៀតណាមក៏បានទទួលលទ្ធកម្មដោយមិនប្រក្រតីមួយ, នោះ គឺ ការបានទទួលសម្បត្តិទ្រព្យមួយអំពីបុគ្គលម្នាក់ ដែលមិនមែនជាម្ចាស់កម្មសិទ្ធិពិតប្រាកដ ។

**ទីបំផុតនៅក្នុងឱកាសបញ្ចប់សេចក្តីនៃ សន្ធិសញ្ញា បារាំង-ខ្មែរ កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ ១៩៤៩ ព្រះមហាក្សត្រកម្ពុជាបានប្រកាសយ៉ាងដាច់ខាតថា "សន្ធិសញ្ញានោះ ពុំបានធ្វើឲតំរូវប័ន្ធីស្ថូបន្តិចទាល់តែសោះ ចំពោះភាគីកម្ពុជា ដោយតម្រូវឲ្យកម្ពុជា បោះបង់សិទ្ធិ និងផលប្រយោជន៍ នៅលើទឹកដីកូសាំងស៊ីន"** ។

ម្យ៉ាងវិញទៀត ទឹកដីកម្ពុជានៅ កូសាំងស៊ីន ពុំបានធ្វើជាកម្មវត្ថុនៃអនុប្បទានប្រក្រតីនោះទេ ។ គ្មានសន្ធិសញ្ញាណាមួយក៏ដូចជាអនុសញ្ញាឯទៀត ពុំបានចែងល័ក្ខខ័ណ្ឌអំពីអនុប្បទាននោះទេ ។ ទឹកដី កូសាំងស៊ីន (វៀតណាមខាងត្បូង) ពិតជាពុំអាចប្រៀបធៀបទៅនឹង **រដ្ឋល្វីស៊ីយ៉ាណា** ដែលពួក បារាំង លះបង់ទៅឲ្យពួក អាមេរិក កាលពីឆ្នាំ១៨០៣ ឬក៏ដូចទៅនឹង **រដ្ឋអាឡាស្កា** ដែល សូវៀត លះបង់ទៅឲ្យ អាមេរិក នៅឆ្នាំ ១៨៦៧ ឬក៏ប្រៀបទៅនឹង **រដ្ឋការ៉ូលីន** ដែលពួក អេស្ប៉ាញ លះបង់ឲ្យ ពួក អាល្លឺម៉ង់ នៅ ឆ្នាំ ១៨៩៩ នោះក៏ទេដែរ ។

ពិតជាពុំដែលមានការពង្រឹងឲ្យមានការកាន់កាប់ផ្នែកយោធាតទៅទៀតនោះទេ។ ប្រទេសអណ្ណាមពុំបានធ្វើសង្គ្រាមដណ្តើមយកដី កូសាំងស៊ីននេះ ជាមួយនឹងកម្ពុជាទេ ។ **"ការធ្វើអន្តរាគមន៍ដោយអាវុធកន្លងមកជាច្រើនដងរបស់ពួកអណ្ណាម គឺសុទ្ធសឹងតែធ្វើឡើងតាមសំណូមពារព្រះអង្គម្ចាស់ខ្មែរម្នាក់ទៀត ដើម្បីប្រឆាំងនឹងព្រះអង្គម្ចាស់ ខ្មែរម្នាក់ទៀត ដែលយកលេសក្នុងការដណ្តើមរាជបល្ល័ង្គ ឬក៏ដើម្បីប្រឆាំងនឹងពួកសៀម ហើយនឹងយោងតាមសំណូមពារ ពួកបះបោរតែប៉ុណ្ណោះ"** ។

ទីបំផុត ផ្ទុយទៅនឹងទឡ្ហីករណ៍មួយចំនួននោះ ក៏នៅពុំទាន់មានការកំណត់ព្រំដែនណាមួយដែលត្រូវបានធ្វើអន្តរាគមន៍ដើម្បីធ្វើការបែងចែកឲ្យដាច់ស្រេចជាស្ថាពរ

www.elibraryofcambodia.org

នូវទឹកដីកម្ពុជាដែលកាន់កាប់ដោយពួកអណ្ណាមដែរ ។ សេចក្តីសម្រេចកាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ១៨៧០ និងការផ្សះផ្សារសម្រុះសម្រួលកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៨៧៣ ដែលទាក់ទិនទៅនឹងការកំណត់ព្រំដែនរវាង កូសាំងស៊ីន និងកម្ពុជា ក៏បាន ធ្វើបតិដ្ឋាប័ននូវកតិកាសញ្ញាដាឯកតោភាគីជាមួយនឹងប្រទេស បារាំង ដែលកាល ណោះគឺជា "អ្នកអភិបាលដោយផ្ទាល់នៅលើទឹកដី កូសាំងស៊ីន" ។ ក្នុងនាមជាប្រទេស ចំណុះ ហើយប្រទេសកម្ពុជាក៏ស្ថិតនៅក្នុងនាមជាប្រទេសដែលនៅក្រោមអាណា ព្យាបាលដែរ ។ គឺជាសារលិខិតរដ្ឋបាលដែលបានសម្រេចដោយប្រទេសមហា អំណាចដដែលមួយនោះ ដែលមានភាពលំអៀងគួរឲ្យយល់បានចំពោះការពង្រីកឲ្យ ទូលាយនូវដែនដីកម្មសិទ្ធិចំណុះខ្លួន ។ **ប្រទេសកម្ពុជាដែលបានស្នើសុំឲ្យមាន អាណាព្យាបាលពី ប្រទេសបារាំង ព្រមទាំងបានប្រគល់កិច្ចការអធិបតេយ្យក្រៅ ប្រទេសឲ្យទៅបារាំងថែមទៀតផង ហើយនៅទីបំផុតក៏មិនអាចបត្តិក្តិតវាប្រឆាំង នឹងការកំណត់ព្រំដែន នោះឡើយ ។**

### ៣- បញ្ហាទាំងឡាយដែលត្រូវបោទឡើង

ទឹកដីមួយចំណែករបស់ប្រទេសកម្ពុជាដែលត្រូវពួកអណ្ណាមដណ្តើមកាន់កាប់ ដោយមិនប្រក្រតីនោះ ត្រូវបានផ្ទេរទៅឲ្យបារាំង បន្ទាប់មកក៏ត្រូវបារាំងធ្វើបដិទាន ទៅឲ្យវៀតណាមវិញ ដោយឆ្លងតាមច្បាប់នៅប្រទេសបារាំងកាលពីឆ្នាំ១៩៤៩ ។ គួរ ជ្រួតជ្រាបថា ទឹកដីមួយចំណែកនោះ មានផលប្រយោជន៍ជាមូលដ្ឋានសម្រាប់ ប្រទេសកម្ពុជាក្រៅអំពីផលប្រយោជន៍ដែលមាននៅក្នុងប្រវត្តិសាស្ត្រ និងផ្នែក បុរាណវត្ថុវិទ្យា ។ **ម្យ៉ាងទៀតបើពិនិត្យទៅតាមប្រជាសាស្ត្រទឹកដីមួយចំណែកដែល ជាកូសាំងស៊ីននោះ មានផ្នែកប្រជាជនកម្ពុជាដែលស្នេហាមាតុភូមិដ៏ខ្លាំងក្លាបំផុត និង រក្សាយ៉ាងខ្ជាប់ខ្ជួននូវជំនឿទៅលើព្រះពុទ្ធសាសនា ដោយរស់នៅជុំវិញវត្ត អារាមរាប់រយ ដែលជាទីស្នាក់អាស្រ័យរបស់ព្រះសង្ឃ ដើម្បីអនុវត្តតាមគោល**

www.elibraryofcambodia.org

**ការណ៍នៃសាសនាព្រះពុទ្ធផ្នែកហិនយាន ដូចជានៅប្រទេសកម្ពុជាដែរ ថែមទាំងជាអ្នកអភិរក្សប្រកបដោយភក្តីភាព និងយ៉ាងខ្ជាប់ខ្ជួនចំពោះទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ ។**

ម្យ៉ាងវិញទៀតបើផ្អែកទៅតាមវិស័យសេដ្ឋកិច្ចវិញ ទឹកដីនៅវៀតណាមខាងត្បូងទាំងនោះដែលមានក្រឡាផ្ទៃប្រមាណជា ៦៧.៧០០គីឡូម៉ែត្រក្រឡា ដែលមានវិសាលភាពធំជាងប្រទេសស្វីសទៅទៀតនោះ គឺជាទឹកដីប្រកបទៅដោយទីវាលទំនាប មានជីវជាតិដោយសារជីរធម្មជាតិដែលទន្លេមេគង្គបានពាំនាំយកដីល្បាប់ហូរស្រោចស្រពអស់រយៈពេលរាប់សតវត្សរ៍មកហើយ ។ ទឹកដីមួយចំណែកនោះស្ថិតនៅអមសងខាងតាមបណ្តោយមាត់ពាមនៃទន្លេមេគង្គ ព្រមទាំងបានធ្វើជាមាត់ច្រកចេញទៅកាន់សមុទ្រនៃប្រទេសកម្ពុជាផងដែរ ។ ទឹកដីនោះបានបង្កើតជាប្រព័ន្ធ ធារាសាស្ត្រដ៏ធំមួយសម្រាប់ធ្វើពាណិជ្ជកម្មផ្លូវទឹករបស់ប្រទេសកម្ពុជា ។

មានបញ្ហាតាមលំដាប់លំដោយបីយ៉ាងដែលត្រូវចោទឡើង

– បញ្ហាបែងចែកទឹកដីគ្នា

– បញ្ហាគាំពារដល់ជនជាតិភាគតិចដែលជាម្ចាស់ស្រុកដើម

– និងបញ្ហាបើកមាត់ច្រកទៅកាន់សមុទ្រទាំងអស់នេះសុទ្ធសឹងជាបញ្ហា ដែលមិនត្រឹមតែមានសារៈសំខាន់ចំពោះប្រទេសកម្ពុជា និងវៀតណាមតែប៉ុណ្ណោះនោះទេ តែក៏មានសារៈសំខាន់ចំពោះប្រទេសបារាំងដែរ ក្នុងនាមជារដ្ឋមួយដែលបានជម្រះបញ្ជីអស់នូវរបបឥណ្ឌូចិនពីអតីតកាល ហើយនឹងរដ្ឋនិយមសន្តិភាពជាច្រើនទៀតដែលទាមទារចង់បាន និងថែរក្សាសន្តិភាពឲ្យនៅស្ថិតស្ថេរ ព្រមទាំងមានវិបុលភាពនៅក្នុងសហគមន៍អន្តរជាតិ ។ ទាំងអស់នេះសុទ្ធសឹងជាប្រភេទបញ្ហាដែលធ្លាប់បានជៀងទៅរកបណ្តាប្រទេសមហាអំណាច នាសង្គមប្រជាជាតិ, អង្គការសហប្រជាជាតិ ចាប់តាំងពីក្រោយការបញ្ចប់នៃសង្គ្រាមលោកលើកទី១មកម្ល៉េះ ។

www.elibraryofcambodia.org

ចំពោះបញ្ហាវែងចែកទឹកដីគ្នានោះ បណ្ដារដ្ឋទាំងឡាយតែងតែបានខិតខំព្យាយាមស្វែងរកដំណោះស្រាយជានិច្ច ដូចជាករណីដែលទាក់ទងទៅនឹងតំបន់ឡាសារ La Sarre, អាល់ សាស់ឡូវ៉ែន Alsace-Lorraine , (ដែលជាតំបន់ប្រទាញប្រទង់គ្នា ធ្វើការទាមទាររវាងបារាំង និងអាល្លឺម៉ង់) ខេត្តវីលណូ Vilno (ដែលទាមទារដោយប្រទេស លីទុយអានី និងប៉ូឡូញ, តំបន់រុស្ស៊ី Russie Blanche (ទាមទារដោយប្រទេស ប៉ូឡូញ និង រុស្ស៊ី) តំបន់ បេសារ៉ាប៊ី Bessarabie (ដែលទាមទារដោយប្រទេស រ៉ូម៉ានី និង រុស្ស៊ី) តំបន់ខ្ពង់រាប ស៊ីលេស៊ី Haute Silesie (ដែលទាមទារដោយ ប៉ូឡូញ និង អាល្លឺម៉ង់) តំបន់ តេសចេន Teschen (ដែលទាមទារដោយ ប៉ូឡូញ និង ឆេកូស្លូវ៉ាគី) , តំបន់ ទីរ៉ុល ខាងត្បូង Tyrol Meridional ឬ តំបន់ ខ្ពង់រាប អាឌីន Haute Adige (ដែលទាមទារដោយ អូទ្រីស និង អ៊ីតាលី) តំបន់ ហ្វីយូម Fiume (ដែលទាមទារដោយ អ៊ីតាលី និង យូហ្គោស្លាវី) ។

- អ្វីៗដែលទាក់ទងទៅនឹងការគាំពារជនជាតិភាគតិច បណ្ដាសម្ព័ន្ធមិត្តដែលឈ្នះសង្គ្រាមលោកលើកទី១ បានដាក់លក្ខខ័ណ្ឌតឹងរ៉ឹង ចំពោះសញ្ញាប័ណ្ណពិសេសមានឈ្មោះថា ផ្នែកលើភាគតិចទៅលើបណ្ដារដ្ឋមួយចំនួននៅ ប៉ូឡូញ, ឆេកូស្លូវ៉ាគី, អូទ្រីស, ហុងគ្រី, បណ្ដារដ្ឋនៅតំបន់ បាល់គ័ Baltes, បណ្ដារដ្ឋនៅតំបន់ បាល់កង់ ដោយតម្រូវឲ្យធ្វើបរិវិសកម្ម (ការបរិចាគដោយរៀអផ្លាស) ទៅតាមសន្ធិសញ្ញា ។

ប្រជាពលរដ្ឋជនជាតិភាគតិចបានទទួលគុណប្រយោជន៍ក្នុងការគាំពារដ៏ពិសេសមួយដែលមានលក្ខណៈជាអន្តរជាតិ ដោយថែរក្សាការពារពួកគេឲ្យរួចចាកផុតអំពីការរំលោភដោយអំណាចហួសប្រមាណពីសំណាក់រដ្ឋអំណាចទៅលើទឹកដីដែលពួកគេបានរស់នៅ ឧទាហរណ៍ដូចជាពួកជនជាតិ អាល្លឺម៉ង់ ដែលរស់នៅតំបន់ ស៊ីលេស៊ី ដែលត្រូវក្លាយជាជនជាតិ ប៉ូឡូញ ។

- ចំពោះបញ្ហាបើកច្រកចេញទៅកាន់សមុទ្រ គេក៏បានរកឃើញដំណោះស្រាយ

www.elibraryofcambodia.org

តាមបែបអន្តរជាតិជាច្រើនយ៉ាង ដែលទាក់ទិនទៅនឹងច្រកសមុទ្រ ប៉ូឡូញ និងកំពង់ផែ ដង់ហ្សិក Dantzig នេះគឺជាដំណោះស្រាយម្យ៉ាង ចំណែកឯដំណោះស្រាយម្យ៉ាងទៀត គឺបណ្តាទឹកដីនៅតំបន់ មេម៉េត Memet និងកំពង់ផែ មេម៉េត ។

ក៏ដូចគ្នាទៅនឹងរបៀបច្រកសមុទ្រប៉ូឡូញ និងទឹកដីនៅតំបន់ មេម៉េត ដែលត្រូវបានគោរពជាចាំបាច់ចំពោះជីវិតសេដ្ឋកិច្ចនៃប្រទេស ប៉ូឡូញ និងប្រទេសលីទុយអានី ហើយក៏ដូចគ្នាទៅនឹងទឹកដីទាំងឡាយនៅ កូសាំងស៊ីន ដែលធ្វើបតិដ្ឋាបនចំពោះប្រទេសកម្ពុជា ប្រៀបបានទៅនឹងសួតសម្រាប់ដកដង្ហើមយ៉ាងពិតប្រាកដ ។

ប្រសិនបើគេគិតចង់ធ្វើការទាមទារយកមកវិញទាំងស្រុងនូវដំណោះស្រាយដែលអាចយកជាការបានកាលពីមុន និងបទពិសោធន៍ដែលគេបានធ្វើឲ្យលេចចេញឡើងនូវផលវិបាកតិច ឬច្រើនក្តីនោះ គឺមិនមែនជាការស្នើសុំគួរឲ្យចង់បានចំពោះប្រទេសមួយដោយត្រូវបំភ្លេចឲ្យអស់នូវទឹកដីល្អៗដ៏មានជីវជាតិ សុខចិត្តអត់ទ្រាំក្នុងការបើកច្រកទៅកាន់សមុទ្រដែលមានតែមួយគត់ ព្រមទាំងយល់ព្រមបោះបង់ចោលនូវជោគវាសនាប្រជានុរាស្ត្រជិតមួយលាននាក់(១៩៦១)នោះទេ ។ នេះគឺជាពលិកម្មដ៏ធ្ងន់ធ្ងរខ្លាំងពេកណាស់ ដើម្បីអាចត្រូវធ្វើឲ្យប្រទេសមួយនោះ ទោះបីជាការបរិច្ចាគ និងមិត្តភាពនោះប្រកបទៅដោយសមានចិត្តបរិសុទ្ធយ៉ាងណាក្តី ។

នៅក្នុងចំណោមដំណោះស្រាយសន្តិភាពទាំងឡាយដែលអាចប្រមើលមើលនៅកណ្តាលកិច្ចប្រជុំនៅទីក្រុងហ្សឺណែវ ក៏នៅមានដំណោះស្រាយមួយ ដែលគេបានទទួលស្គាល់អធិបតេយ្យភាពរបស់ពួកវៀតមិញនៅលើ ចំណែកមួយនៃទឹកដីជាតិរបស់វៀតណាមដែរ ។ ដំណោះស្រាយនោះបានត្រឡប់ក្លាយទៅជាការបែងចែកទឹកដីមួយរបស់វៀតណាមដែលត្រូវបានឲ្យសច្ចាប័នទទួលស្គាល់ដោយបណ្តារដ្ឋទាំងឡាយដែលជាសមាជិកនៅក្នុងកិច្ចប្រជុំនោះ ហើយជួនកាល ក៏អាចនៅពេលក្រោយមក ត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិដែរ ។ ការបែងចែកនេះហាក់

www.elibraryofcambodia.org

ដូចជាការសម្រេចប្រគល់ឲ្យវៀតណាមជាស្ថាពរ នូវបណ្ដាទឹកដីមួយចំនួនរបស់កម្ពុជាដែលត្រូវបានកាត់ផ្ដាច់ចេញពីកម្ពុជា ដោយមិនប្រក្រតីនោះដែរ ។ គឺដោយសារតែ កាត់ផ្ដាច់ជា យថាហេតុ នេះហើយ ដែលប្រទេសកម្ពុជាបានប្រកែកតវ៉ាដោយ សំណូមពរដល់ប្រជាជាតិទាំងឡាយដែលជាសមាជិកនៅក្នុងកិច្ចប្រជុំនោះ (សន្និសីទ ហ្សឺណែវ) ឲ្យពិនិត្យមើលដំណោះស្រាយមួយដែលមានសមធម៌ព្រមទាំងពោរពេញ ដោយសិទ្ធិជាប្រវត្តិសាស្ត្រទាំងផលប្រយោជន៍ខាងសេដ្ឋកិច្ច ក៏ដូចជាផលប្រយោជន៍ខាងនយោបាយសម្រាប់ប្រទេសកម្ពុជាដែរ ។

**៤– ដំណោះស្រាយទាំងឡាយ (ដែល កម្ពុជា បានលើកឡើងកាលណោះ)**

មានសម្មតិកម្មពីរយ៉ាងដែលអាចយកមកបង្ហាញ

– ឬមួយក៏កិច្ចប្រជុំនៅទីក្រុងហ្សឺណែវពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការជម្រះបញ្ហានោះ ដែលបានចោទឡើងរវាងប្រទេសកម្ពុជា, ប្រទេសបារាំង និងប្រទេសវៀតណាម ហើយធ្វើការសន្និដ្ឋានថា បញ្ហានោះនឹងត្រូវលើកឡើងតាមក្រោយដល់ថ្នាក់ អង្គការសហប្រជាជាតិ ។ នៅក្នុងករណីនោះ ប្រសិនបើកិច្ចប្រជុំត្រូវធ្វើការសម្រេចចិត្តស្ដីអំពីសន្តិភាពនៅឥណ្ឌូចិន ប្រទេសកម្ពុជា ក៏បានសំណូមពរទៅកាន់កិច្ចប្រជុំឲ្យសម្រេចយកកតិកាសញ្ញាបម្រុងទុកមួយ ដែលប្រទេសកម្ពុជា បានបង្កើតឡើងសម្រាប់ការរក្សាសិទ្ធិរបស់ខ្លួនដែលទាក់ទិនទៅនឹងទឹកដីនៅកូសាំងស៊ីនព្រមទាំង បញ្ជូនក្ដីវិវាទនោះ ទៅកាន់អង្គការសហប្រជាជាតិ ។

– ឬមួយយកសម្មតិកម្មទីពីរ ដែលសមាជិកទាំងអស់ក្នុងកិច្ចប្រជុំបានធ្វើការសន្និដ្ឋានថា ត្រូវតែធ្វើការបញ្ចប់គ្រប់បញ្ហាទាំងអស់នៅឥណ្ឌូចិន ដោយចាំបាច់នឹងទូទាត់គ្រប់បញ្ហាចោទ ដែលអាចទទួលរ៉ាប់រងបានឲ្យមានសន្តិភាពឲ្យរួចស្រេចតែម្ដងនោះ ។ នៅក្នុងសម្មតិកម្មនោះប្រទេសកម្ពុជា ក៏បានសុំណូមពរដល់កិច្ចប្រជុំឲ្យយល់ព្រមចំពោះការឲ្យប្រទេសកម្ពុជា បានធ្វើជាបរិបាលកិច្ចជាន់ខ្ពស់នៅក្នុងគណៈ

www.elibraryofcambodia.org

កម្មការពិសេសមួយ ដែលរៀបចំដោយតំណាងប្រទេសបារាំង, វៀតណាម និង កម្ពុជា ហើយដែលត្រូវទទួលបេសកកម្មក្នុងការសាកល្បងទូទាត់ជម្រះ ដោយស្រុះស្រួលគ្នាស្ដីអំពីបញ្ហានៅវៀតណាមខាងត្បូង (កូសាំងស៊ីន) ។

ក្នុងករណីមានការខ្វែងគំនិតគ្នារវាងប្រទេសទាំងបីនោះ កិច្ចប្រជុំអាចនឹងធ្វើឲ្យដូចទៅនឹង សន្ធិសញ្ញា ទីក្រុងវែរសាយ (Versailles), ដែលបានធ្វើចំពោះរដ្ឋនៅតំបន់ ដង់ហ្ស៊ិក ហើយនិងសន្ធិសញ្ញារវាងពួកសម្ព័ន្ធមិត្ត និងប្រទេសអ៊ីតាលី កាលពីថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ១៩៤៧ នៅក្នុងការទាមទារទីក្រុងទ្រីយែស Trieste **ដោយប្រមើល មើលជាអន្តរជាតិនូវទឹកដី កូសាំងស៊ីន និងត្រូវដាក់ឲ្យស្ថិតនៅក្រោមការដោនាំប៉ះរងរបស់អង្គការសហប្រជាជាតិ ។**

រដ្ឋាភិបាលកម្ពុជា ដឹងខ្លួនថា ត្រូវរងការលំបាកដោយបានលើកឡើងនូវបញ្ហាមួយដែលមានលក្ខណៈស្មុគស្មាញដល់កិច្ចប្រជុំដែលកំពុងតែមានជាច្រើន ដែលពិបាកស្មុគស្មាញរួចមកហើយ ក្នុងការធ្វើឲ្យមានសន្តិភាពដូចដើមឡើងវិញនៅឥណ្ឌូចិននោះ ។ ប៉ុន្តែ ការធ្វើដូច្នេះ មកពីរដ្ឋាភិបាលកម្ពុជាមានជំនឿស៊ប់ មិនមែនដោយសារតែបានបម្រើឲ្យផលប្រយោជន៍ផ្ទាល់ខ្លួនតែម្យ៉ាងនោះទេ ។ ផ្ទុយទៅវិញ គឺចូលរួមវិភាគទានទៅដល់កិច្ចខិតខំប្រឹងប្រែង ដែលបង្កើតឲ្យមាននូវសន្តិភាពមួយដ៏មានប្រសិទ្ធភាព និងរឹងមាំនៅលើពិភពលោកផងដែរ ។ សហប្រជាជាតិ ក៏ដូចជាប្រជាជាតិទាំងឡាយ ដែលបានមកប្រមូលផ្តុំប្រជុំគ្នា នៅទីក្រុងហ្សឺណែវ, ដោយជាប់ជំពាក់ក្នុងគំនិតស្វែងរកសុខុមាលភាពជូនមនុស្សជាតិ ដោយមិនត្រឹមតែសាកល្បងបង្កើតឲ្យមានសន្តិភាពដ៏ចាប់រហ័សតែមួយមុខនោះទេ, ប៉ុន្តែ ថែមទាំងបំបិទចោលគ្រប់មូលហេតុនៃការវិវាទទាំងអស់នៅថ្ងៃអនាគតព្រមទាំងស្ថាបនានូវភាពចម្រើនរុងរឿងសុខុមាលភាពនៅលើពិភពលោក ដោយផ្អែកទៅលើមូលដ្ឋានដ៏រឹងមាំបំផុត ។ គឺនៅក្នុងគំនិតលំដាប់ទីពីរនេះហើយ ដែលប្រទេសកម្ពុជា បានចូល

www.elibraryofcambodia.org

រួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងអន្តរជាតិ, ដោយសាកល្បងស្វែងរកដំណោះស្រាយបញ្ហានោះ ។ ដែលមានរូបភាពដូចជាពិសេសដោយឡែក, ក៏ប៉ុន្តែ ក៏គិតទៅជាលក្ខណៈមួយជាបែបផែនអន្តរជាតិដែរ ។ គេក៏មិនអាចចាត់ទុក បញ្ហាជោគទៅតំបន់ ដង់ហ្សិក ថាជាបញ្ហាតែមួយគត់របស់ប្រទេស ប៉ូឡូញ និង អាល្លឺម៉ង់ ឬក៏តំបន់ ទ្រីយ៉េស ជាបញ្ហាតែមួយ គត់របាំង យូហ្គោស្លាវី និង អ៊ីតាលី ។ ទាំងអស់នោះគឺសុទ្ធសឹងជាបញ្ហាដែលប្រជាជាតិទាំងអស់ត្រូវចាប់អារម្មណ៍ដោះស្រាយនៅក្នុងគំនិតជឿជាក់ និងយោគយល់គ្នា ទៅវិញទៅមក ។ រដ្ឋាភិបាលកម្ពុជា ហ៊ានសង្ឃឹមយ៉ាងដូច្នេះថា ប្រជាជាតិទាំងអស់ដែលបានមកចូលរួម នៅក្នុងកិច្ចប្រជុំទីក្រុងហ្សឺណែវពិតជាបាននាំនាំនូវការប្រណាំង ប្រជែងរបស់ពួកគេ ដើម្បីធ្វើឲ្យសន្តិភាពដ៏យូរអង្វែងមួយ មានជីវិតសាជាថ្មីឡើងវិញ ព្រមទាំងធ្វើឲ្យយុត្តិធម៌ គ្របដណ្តប់ទៅលើអាស៊ីអាគ្នេយ៍ និងនៅពាសពេញពិភពលោក ។

ភ្នំពេញថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៤

នាយករដ្ឋមន្ត្រី

## V. បុរាណវត្ថុវិទ្យានៃដីសណ្តទន្លេមេគង្គបញ្ជាក់ថា កូសាំងស៊ីន គឺជារបស់ប្រទេសកម្ពុជា

"បុរាណវត្ថុវិទ្យានៃដីសណ្តទន្លេមេគង្គ" ធ្វើជាកម្មវត្ថុនៃសៀវភៅមួយរបស់លោក Louis Malleret ដែលជា អាជ្ញាអ្នកនិពន្ធ បានគូសបញ្ជាក់នៅក្នុងសៀវភៅរបស់លោកដូចតទៅនេះ :

១) នៅប្រទេសកម្ពុជា ឋាននាមវិទ្យា គឺជាជំនួយដ៏មានប្រយោជន៍មួយសម្រាប់យើង ។ វាបានស្ថិតនៅជារឿយ ៗប្រកបដោយសារៈសំខាន់យ៉ាងខ្លាំងជាង

www.elibraryofcambodia.org

ឋាននាមវិទ្យារបស់វៀតណាមដែលជាធម្មតា វាបានបោះគោលដើម្បីផ្សព្វផ្សាយនូវ... ("ការរុករកនៃបុរាណវត្ថុវិទ្យា" ភាគ១ ទំព័រ១) ។

២) "ដីសណ្តទន្លេមេគង្គ មកសម័យថ្មីៗបំផុតគឺជាទឹកដីចាស់របស់ប្រជាជនខ្មែរ (Paul Vial "បណ្តាឆ្នាំដំបូងនៃកូសាំងស៊ីន ក្នុងអាណានិគមបារាំង" ប៉ារីស ១៨៧៤ ទំព័រ ១៧២) បាននិយាយថា "គេបានប៉ាន់ស្មានថា មានប្រជាជនកម្ពុជាប្រមាណ ២០០.០០០នាក់ នៅពេលស្រុកបាសាក់មានការផ្លាស់ប្តូរក្នុងឆ្នាំ ១៨៦០" ។

ចំណែកប្រពៃណីរបស់វៀតណាម គឺមានកាលបរិច្ឆេទថ្មីបំផុតនៅក្នុងតំបន់ទាំងនេះ ដើម្បីឲ្យគេអាចរកឃើញនៅទីនេះនូវការគាំទ្រ ។ ដូច្នេះភស្តុតាងទាំងឡាយខាងបុរាណវត្ថុវិទ្យា គឺទាក់ទងទៅនឹងសិល្បៈខ្មែរ ឯពួកអណ្ណាមគឺជាជនបរទេស ។ ("បុរាណវត្ថុវិទ្យា..." ទំព័រ ៤) ។

សៀវភៅនេះបានផ្តល់ដល់ការផ្លាស់ប្តូរស្រុកបាសាក់នូវលក្ខណៈដូចតទៅនេះ គឺ

គេបានកាប់គាស់ឆ្នេរសមុទ្រសៀម ជាមួយនឹងទីប្រជុំកោះរបស់ខ្លួន ភ្នំតូចៗ ដែលមានជាតិកំបោរ ឬថ្មភក់នៅទិសខាងលិច និងផ្លូវឆ្លងកាត់ ។ ដែលបើកទ្វារទៅរកច្រកចូលកំពង់ផែនៅពាម (ហាទៀន) ភ្នំស្វាម ជារាងសាជីមូលស្ថិតនៅតែឯងនៅទិសខាងជើងទីប្រជុំភ្នំ "ប្រាំពីរ" ដែលប្រជាជនខ្មែរហៅថា "ភ្នំ ពពាហ៍" ។ វាលដែលបាននាំត្រង់ទៅដល់ បាថេ ("បា" =បុព្វបុរសភេទប្រុស) ជាទីកន្លែងធ្វើសក្ការៈបូជាដ៏ខ្ពស់ ដែលគេបានឃើញពីភ្នំជីសូរ ដែលស្ថិតនៅចម្ងាយ ១០០គ.មពីទីនោះ ។ នៅជើងភ្នំនេះ មានលាតសន្ធឹងជួរភ្នំ "អូកែវ" ដែលប្រជាជនចិន និងអណ្ណាមបានធ្វើជាទីក្រុង "Oc. Eo" ជាមួយនឹងព្រែកជីកចាស់ៗ របស់ខ្លួននៅពីមុខកំពង់ផែ ។ ទំនងជាកំពង់ផែតាកែវ និងទីកន្លែងចាស់ៗរបស់ប្រជាជន ហ្វ៊ូណន, ដែលបានលាតសន្ធឹង ពីជើងទៅត្បូង នៅសងខាងព្រែកជីក Mac Câu Dung (អតីត Brah Sdisi តភ្ជាប់បាសាក់ទៅ Triton) ។ នៅឯនាយ ទៅទិសខាងកើត មានតំបន់

www.elibraryofcambodia.org

ខ្សាច់នៅព្រែកត្រពាំង, សុកត្រាំង ។ លោក Malleret បានរកឃើញនៅក្នុងតំបន់នេះ ក្រៅពីចំណុចបុរាណវត្ថុចំនួន ១៧ដែលត្រូវបានរកឃើញនៅក្នុងឆ្នាំ ១៩៤៥ គឺមានចំណុចថ្មីចំនួន ១២៦ទៀត ដែលមានរូបសំណាកជាផ្នែកៗជាច្រើន ។

អ្នកនិពន្ធបានបង្ហាញនូវការលំបាកធំៗ ដែលបានជួបនៅក្នុងការស្រាវជ្រាវទាំងនេះ ដែលបានបង្កឡើងដោយការកែប្រែឈ្មោះ ដែលសុំឡើងដោយវៀតណាម ។ គេត្រូវប្រឈមមុខនូវព័ត៌មាននៅនឹងកន្លែង នៅអមប្រជាជនកម្ពុជា និងបានប្រើប្រាស់នូវសេចក្តីកំណត់សរសេរដោយដៃ របស់ Pétrus Truong - Ving Ky ដើម្បីធ្វើឲ្យបានដូចដើមវិញ នូវឋាននាមវិទូចាស់ ។

**រូបសំណាក និងឋាននាមវិទ្យា ដែលជាការងាររបស់លោក Malleret បានប្រមូលផ្តុំធ្វើឲ្យដូចដើមវិញ ។ បានបញ្ជាក់នៅក្នុងរបៀបដែលមិនអាចប្រកែកបាននូវការរៀបចំរបស់ប្រជាជនខ្មែរ នៅក្នុងតំបន់ កូសាំងស៊ីន នេះ ចាប់តាំងពីបុរាណកាលមកម្ល៉េះ ។ បាននាំមកនូវភស្តុតាងថ្មីថា តំបន់ដែលបាននិយាយខាងលើគឺជារបស់កម្ពុជា, ដោយមើលឃើញនូវសារៈសំខាន់នេះ ការដកស្រង់ពីសៀវភៅរបស់លោក L.Malleret នឹងផ្តល់ជូននៅក្នុង ឧបសម្ព័ន្ធ... ។**

**********

*** អនាគត ត្រូវពិញបានដោយបច្ចុប្បន្ន ។**
*** កែខៃទាន់កាល រមែងការពារភ័យវិបត្តិបានច្រើនយ៉ាង ។**
*** កុំទុកចោលដល់ព្រឹក បើអ្នកអាចធ្វើក្នុងថ្ងៃនេះបាន ។**
*** បើសេចក្តីពេញចិត្តមាននៅដរាបណា ការតស៊ូក៏មាននៅដរាបនោះ, បើសេចក្តីពេញចិត្តអស់ហើយ ការតស៊ូក៏ចប់ត្រឹមប៉ុណ្ណោះ ។**
*** ឫសគល់របស់រដ្ឋ គឺទំនុកបំរុងយុវជនឲ្យមានការសិក្សា ។**

www.elibraryofcambodia.org

# បច្ចឹមកថា

ប្រវត្តិសាស្ត្រនៃ កម្ពុជាក្រោម ដែលពីដើមហៅថា កូសាំងស៊ីន ត្រូវបានបញ្ជាក់ ដោយរមណីយដ្ឋានទាំងឡាយ ដោយប្រាសាទ ឋាននាមវិទ្យា អសាធារណនាម រឿងព្រេង ប្រពៃណី និងអត្ថបទចាស់ៗ ។

ប្រវត្តិសាស្ត្រនេះ ដែលប្រភពសំខាន់ៗត្រូវការរំលឹកនៅក្នុងនិក្ខេបទនេះ ដែលត្រូវបានបង្កើតឡើងមួយផ្នែកនៅក្នុងសករាជ ហ្វ៊ុណន នៅមុនការចាប់ផ្ដើមនៃគ្រិស្តសករាជ និងរហូតដល់ការគាបសង្កត់របស់វៀតណាមដែរ ដែលបានបញ្ចេញឲ្យឃើញនៅក្នុងសតវត្សរ៍ទី១៨ ។ កូសាំងស៊ីន ត្រូវបានកាន់កាប់ដោយប្រជាជនខ្មែរ និងបង្កបង្កើតនូវផ្នែកខាងកើត នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងខណៈដែលទឹកដីនេះត្រូវបានបង្កើតឡើងជាស្ថាពរដោយព្រះបាទជ័យវរ្ម័នទី២ នៅដើមសតវត្សរ៍ទី៩ ។

ប្រវត្តិសាស្ត្រក៏បានរៀបរាប់ផងដែរថា វត្តមានរបស់ប្រជាជនខ្មែរ គឺមិនប្រែប្រួល និងត្រូវបានបញ្ជាក់អះអាងដោយការតស៊ូចំពោះការលុកលុយរបស់វៀតណាមបានស្វែងរកពង្រីកការគ្រប់គ្រងរបស់ពួកគេ ដោយធ្វើឲ្យខូចប្រយោជន៍ដល់ព្រះរាជាណាចក្រខ្មែរ ។

បន្ទាប់ពីការលុកលុយនេះមក ការកាន់កាប់របស់វៀតណាម នៅតែស្ថិតនៅមិនទៀងជានិច្ច ហើយព្រះមហាក្សត្រខ្មែរ មិនដែលយល់ព្រម ប្រគល់ឲ្យស្ដេចអណ្ណាមនូវទឹកដីមួយចំរៀកណាមួយដែលវៀតណាមលុកលុយនោះឡើយ ។ កិច្ចព្រមព្រៀង តែមួយគត់ ដែលត្រូវបានសម្រេចឡើងរវាងព្រះមហាក្សត្រ គឺការអនុញ្ញាតដែលបានផ្ដល់ឲ្យនៅក្នុងឆ្នាំ ១៦២៣ ដោយព្រះមហាក្សត្រជ័យចេស្ដាទី២ ទៅឲ្យស្ដេច សាយវឿង (Sai Vuong ឬ Ngu Phuc Nguyên ឬ Hytông ឯកសារខ្លះថា Trân Cao បិតារបស់ព្រះនាង ង្វៀង ង៉ុកវ៉ាន មហេសីព្រះជ័យចេស្ដា

www.elibraryofcambodia.org

ទី២) កាន់កាប់នៅក្នុងអំឡុងរយៈពេល ៥ឆ្នាំគត់ (ដើម្បីធ្វើការបណ្ដុះបណ្ដាលកង ទ័ពរបស់ខ្លួន) នៅទឹកដីដែលស្ថិត នៅជិតព្រៃនគរ ដែលបច្ចុប្បន្នហៅថា សាយ-ហ្គន នោះ ។

គេដឹងថា ស្ដេចអណ្ណាម បានរំលោភកិច្ចព្រមព្រៀងនេះ និងជាការរុញច្រាន របស់អណ្ណាមកាន់តែមានសភាពខ្លាំងឡើង ។ សាយហ្គន ត្រូវបានកាន់កាប់នៅក្នុង ឆ្នាំ១៦៩៦ ហើយដោយរុលទៅមុខនៅតាមបណ្ដោយឆ្នេរសមុទ្រនោះ ពួកអណ្ណាម បានមកដល់ពាម (ហាទៀង) នៅក្នុងឆ្នាំ ១៧១៤ ។

ប៉ុន្តែពួកវៀតណាម មិនបានសម្រេចនៅមុនឆ្នាំ ១៨៤៧ ដើម្បីដាក់បង្ខំនូវ អំណាចរបស់ពួកគេទៅលើខ្មែរក្រោមនោះឡើយ ។ មានតែដល់ឆ្នាំ ១៨៤៩នោះទេ ដែលវៀតណាមបានសាកល្បងដាក់អនុវត្តប្រឆាំងនឹង ខ្មែរក្រោម នូវរបបអាណា និគមរបស់ពួកគេ" ។

ថ្វីបើនៅក្នុងការប្រយុទ្ធមិនឈប់ឈរជាមួយប្រជាជនខ្មែរដែលមានបំណងថែ រក្សាទឹកដីនៃបុព្វបុរសរបស់ខ្លួននោះក្ដី ក៏ពួកវៀតណាមបានទទួលជោគជ័យក្នុង ការថែរក្សា កូសាំងស៊ីន រហូតទាល់តែពួកគេត្រូវចុះចូលនៅក្រោមការគាបសង្កត់ របស់បារាំង ហើយដែលបារាំងក៏មានបំណងដើម្បីដាក់តាំងនូវឥទ្ធិពល និងអំណាច របស់ពួកគេនៅក្នុង ឧបទ្វីបឥណ្ឌូចិន នេះដែរ ។

**ព្រះករុណា អង្គដួង** បានឆ្លៀតឱកាសនេះ ដើម្បីបញ្ជាក់ឡើងវិញនៅក្នុងឯកសារ មួយដែលមានសេចក្ដីច្បាស់លាស់ផ្ញើទៅថ្វាយអធិរាជ **ណាប៉ូឡេអុងទី៣** នៅក្នុងឆ្នាំ ១៨៥៦ អំពីសិទ្ធិអធិបតេយ្យរបស់ប្រទេស កម្ពុជា នៅលើទឹកដី កូសាំងស៊ីន ។

ដោយបានឆ្លុះបញ្ចាំងអំពីគតិបណ្ឌិតដ៏ធំធេងរបស់អ្នកនិពន្ធ ក្រោយពីបានរំឭក អំពីកាលៈទេសៈនៃការលុកលុយនោះ ឯកសារនេះបានកត់សម្គាល់ច្បាស់នៅក្នុងទឹក ដី ពីបុរាណរបស់ខ្មែរដែលលុកលុយដោយពួកអណ្ណាមគឺ :

www.elibraryofcambodia.org

**១.** គឺទាក់ទងទៅនឹងស្រុកដូនណៃ "បានក្លាយទៅជារបស់អណ្ណាម ដោយរបៀបដណ្តើមកាន់កាប់ដោយសន្តិភាពតែប៉ុណ្ណោះ គឺមាន ២០០ឆ្នាំមកហើយ" ។ **២.** រួមមានស្រុកផ្សេងៗទៀតនៅទិសខាងត្បូងនៃស្រុកដូនណៃ ដែលពួកអណ្ណាមបានយកធ្វើជារបស់ខ្លួន ផ្នែកនេះបានចេញពី "ត្រើយខាងលិចនៃទន្លេសេកុង រហូតដល់ពាម (ហាទៀន)" ផ្នែកនេះក៏ដូចជាកោះពីរ (កោះភូគ្គុក ពូឡូកុងឌ័រ) "ត្រូវតែស្ថិតនៅជារបស់កម្ពុជាដូចពីមុន ។ ចំណែកតំបន់ដែលស្ថិតនៅត្រើយខាងកើតនៃទន្លេសេកុង ដែលពួកអណ្ណាមបានកាន់កាប់ចាប់តាំងពីយូរណាស់មកហើយ ។ យើងមិនទាមទារទេ ។ ដោយគាបសង្កត់ឲ្យមានកិច្ចព្រមព្រៀងមួយដើម្បីធ្វើឲ្យខូចប្រយោជន៍ដល់ព្រះរាជាណាចក្ររបស់ខ្លួន ដែលស្ថិតនៅចន្លោះប្រទេសឈ្លានពានទាំងពីរអ្នកឈ្លានពានចាស់ និងអ្នកឈ្លានពានថ្មី ។ ព្រះមហាក្សត្រ**អង្គដួង** ទ្រង់មិនភ្លេចព្រះលិខិតថា **"យើងសូមព្រះករុណា អធិរាជបារាំងកុំឲ្យយល់ព្រម ពីព្រោះថាទេសភូមិនេះ គឺពិតជាទឹកដីរបស់កម្ពុជា"** ។

ថ្វីបើ ឯកសារនេះ ត្រូវបានដាក់ធ្វើជាភស្តុតាងឲ្យមានការប្រុងប្រយ័ត្នក៏ដោយ ក៏បារាំងបានទទួលជាមួយអធិរាជអណ្ណាម ទឺ ឌឹក នៅក្នុងឆ្នាំ១៨៦២ ដែរ ។ កូសាំងស៊ីន បានក្លាយទៅជាអាណានិគមជនបារាំងលើកលែងតែ ខេត្ត៣ គឺខេត្តវិញឡុង ចូវដុក និងហាទៀង ។ នៅក្នុងឆ្នាំ ១៨៦៧ បារាំងបានកាន់កាប់ដោយកម្លាំងទ័ពនូវខេត្ត ចុងក្រោយទាំងនេះ ដើម្បីឆ្លើយតបទៅនឹងការបះបោររបស់ប្រទេសកម្ពុជាដឹកនាំប្រឆាំងនឹងបារាំងដែលមានក្រុងវេ គាំទ្រពីក្រោយផង ។

នៅក្នុងផលប្រយោជន៍របស់ពួកគេ បារាំងបានបញ្ចូលនូវទឹកដីនេះ ទៅក្នុងកូសាំងស៊ីន ។ ហេតុដូច្នេះហើយ បានជាទឹកដីត្រូវបានដាក់ទាំងស្រុងនៅក្រោមអាជ្ញាផ្ទាល់របស់ព្រះមហាក្សត្រកម្ពុជា ដូចជាស្រុកស្វាយទង (ឬ ទ្រីតូង) រស់នៅដោយប្រជាជនខ្មែរស្ទើរតែទាំងស្រុង ហើយនិងខេត្តតៃនិញ ត្រូវបានភ្ជាប់ជាឯកគោ

www.elibraryofcambodia.org

ភាគីទៅឲ្យ កូសាំងស៊ីន ដោយប្រទេសបារាំង ខេត្តចុងក្រោយនេះ ត្រូវបានបញ្ចូល ជា ឧបសម្ព័ន្ធ ដើម្បីអនុញ្ញាតឲ្យអាណានិគមជនបារាំង ធ្វើចំការកៅស៊ូ នៅដីក្រហម ។

ដោយការបង្ខិតបង្ខំមិនដល់មួយសតវត្សរ៍ និងក្រោយពីបានបាកចេញពី កូសាំងស៊ីន ប្រទេសបារាំង (ដោយមិនរវល់នឹងការតវ៉ាដ៏ខ្លាំងក្លារបស់ព្រះករុណា នរោត្តម សីហនុ ដែលពេលនោះ ជាព្រះមហាក្សត្រសោយរាជ្យនៅប្រទេសកម្ពុជា) គេបានប្រគល់កូសាំងស៊ីនជាទឹកដីរបស់កម្ពុជាទៅឲ្យ **បាវដាយ** ជាស្តេចវៀតណាម ។

ហេតុដូច្នេះ ពួកអ្នកកាន់កាប់បរទេសបានរំលោភអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា នៅ កូសាំងស៊ីន ។ តាមកិច្ចព្រមព្រៀងទាំងឡាយដែលបានសម្រេចដោយមិនរវល់ដល់ច្បាប់នៃអន្តរជាតិ ហើយដែលគេគ្មានសិទ្ធិអ្វីទាំងអស់នោះ ។ ពួកគេបានផ្ទេរ ទៅវិញទៅមក នូវទឹកដីមួយដែលមិនមែនជារបស់ពួកគេ ហើយដែលនៅក្រោមអំណាចតាមព្រឹត្តន័យ នៃផ្លូវច្បាប់នៃអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ។

បើប្រៀបធៀប ជាមួយនឹងកាលបរិច្ឆេទផ្សេងៗទៀត នៃការកាន់កាប់របស់អាណានិគម ឧទាហរណ៍ដូចជាទឹកដី Goa ជាដើមដែលត្រូវបានប្រទេសព័រទុយហ្គាល់ យកធ្វើជាអាណានិគមនៅក្នុងឆ្នាំ ១៦៥៤ (នៅក្នុងឆ្នាំនេះ ប្រជាជន Goanais បាន តស៊ូរួចហើយជាមួយចក្រពត្តិនិយមព័រទុយហ្គាល់) ។ ឬក៏ទឹកដី Irian ខាងលិចនៅក្នុងឆ្នាំ១៦០៥ (ការចាប់ផ្តើមអាណាចក្រអាណានិគមរបស់ Indes Neerlandai-ses) ។ ឃើញថា ការកាន់កាប់ដោយប្រទេសអណ្ណាម ហើយបន្ទាប់មកទៀត ដោយប្រទេសបារាំង នូវខេត្តរបស់ខ្មែរនៅ កូសាំងស៊ីន គឺជាកាលបរិច្ឆេទថ្មីបំផុត ។ ដោយពិតទៅពួកវៀតណាមនៅមុនការកាន់កាប់របស់បារាំង អាចអនុវត្តនូវអំណាចរបស់ខ្លួនបានតែនៅលើខេត្តទាំងឡាយនៅតំបន់បាសាក់

www.elibraryofcambodia.org

(ផ្នែកដែលចេញពី ត្រើយខាងលិចនៃទន្លេសេកុង រហូតដល់ពាម ដោយរួមទាំងកោះទាំងពីរនោះផង) តែចាប់ពី ឆ្នាំ ១៨៤៩ មកតែប៉ុណ្ណោះ ។ ចំពោះបារាំងវិញ ពួកគេអាចដណ្តើមយក ខេត្តទាំងនេះ តែចាប់ពីឆ្នាំ ១៨៦៧ មកតែប៉ុណ្ណោះ ។

ចំពោះបញ្ហានេះ គេត្រូវតែគូសបញ្ជាក់អំពីគតិបណ្ឌិតរបស់ព្រះករុណា **ព្រះអង្គដួង** ដែលព្រះអង្គទ្រង់ឈ្វេងយល់យ៉ាងខ្លាំងនៅមុនព្រះសារលិខិតស្តីអំពីស្ថានភាពគតិយុត្តអន្តរជាតិនៃទឹកដី កូសាំងស៊ីន ។

ស្ថានភាពគតិយុត្ត ដែលមួយផ្នែកគឺចាក់ឫសទៅលើ កិច្ចព្រមព្រៀង ដ៏ជាក់លាក់ទាំងឡាយ អនុសញ្ញា ឬក៏សន្ធិសញ្ញា ដែលបានសរសេរដោយត្រឹមត្រូវ និងផ្តល់សច្ចានុមតិ ដែលបានសម្រេចរវាងរដ្ឋអធិបតីទាំងឡាយ និងមួយផ្នែកទៀតគឺចាក់ ឫសទៅលើ កិច្ចព្រមព្រៀង ប្រកបដោយ តុណ្ហីភាព ដែលជាលទ្ធផលនៃការបញ្ជាក់ដោយពិត ដោយពេលវេលា និងត្រូវបានយល់ព្រមដោយភាគីដែលពាក់ព័ន្ធ ។

ហេតុដូច្នេះហើយបានជាព្រះករុណា **ព្រះអង្គដួង** មិនបានប្រកាសថា ត្រូវតែទាមទារមកវិញសម្រាប់ប្រទេសកម្ពុជានូវស្រុកដូនណៃ ដែលជាអតីតទឹកដីខ្មែរ "បានក្លាយទៅជាទឹកដីអណ្តាម តាមរយៈការកាន់កាប់ដោយសន្តិភាព" អស់រយៈពេល ២០០ (ពីររយ) ឆ្នាំនោះទេ ។

គឺមិនដូចជាស្រុកផ្សេងៗទៀតនៅ កម្ពុជាក្រោម នោះទេ ដែលការកាន់កាប់អណ្តាមមិនមានលក្ខណៈសន្តិភាពឡើយ គឺមានការប្រយុទ្ធគ្នាជាប់ជាប្រចាំជាមួយប្រជាជនម្ចាស់ស្រុក ។

ដូចបានរំលឹកនៅក្នុងភាគីទី១ ហើយថា **"អធិបតេយ្យភាព របស់រដ្ឋមួយនៅលើផ្នែកមួយនៃទឹកដីរបស់ខ្លួន និងមិនត្រូវបានបង្វែរ ដោយគ្មានការយល់ព្រម ពីរដ្ឋនេះឡើយ"** ។

www.elibraryofcambodia.org

ប្រសិនបើការលុកលុយនេះ បានធ្វើឲ្យខូចខាតដល់បូរណភាពទឹកដីរបស់រដ្ឋ ដែលបានពិនិត្យពិចារណានេះក្តី ក៏វាមិនបានធ្វើឲ្យបាត់បង់ដល់ អធិបតេយ្យភាព នៅលើផ្នែកនៃទឹកដីរបស់ខ្លួនដែលត្រូវបានលុកលុយ និងកាន់កាប់ដោយមិនត្រឹមត្រូវនោះដែរ ។

អធិបតេយ្យភាពនេះ ស្ថិតនៅពេញលេញ និងទាំងស្រុងដរាបណា កិច្ចព្រមព្រៀង មួយមិនបានធ្វើអន្តរាគមន៍រវាងភាគីទាំងពីរ ដើម្បីអនុវត្តការផ្ទេរនោះ ។ ដើម្បីឲ្យ មានតម្លៃ កិច្ចព្រមព្រៀងនេះ នៅត្រូវបានសម្រេចនៅឡើយ ដោយពុំមាន ការអត់ឱន ដោយការគាបសង្កត់ដែលត្រូវបានអនុវត្ត ដោយភាគីមួយទៅលើ ភាគីមួយទៀតនោះ ។ យើងនិយាយថា មិនមានការអត់ឱនឲ្យបាន ពីព្រោះថា វាកម្រណាស់ ដែល កិច្ចព្រមព្រៀងទាំងឡាយ គឺជាប្រភេទ កិច្ចព្រមព្រៀង ដែល ត្រូវបានចុះ ហត្ថលេខាដោយការបង្ខិតបង្ខំ ដោយភាគីមួយទៅលើភាគីមួយទៀត ។

ដើម្បីកុំឲ្យត្រូវបានចាត់ទុកថា ជាការយល់ព្រមដោយ តុណ្ហីភាព ចំពោះការផ្ទេរ អធិបតីភាពនេះ ការកាន់កាប់នេះ មិនអាចប្រព្រឹត្តទៅបានដោយសន្តិភាពនោះ ឡើយ ហើយការបដិសេធនៃការយល់ព្រម ត្រូវបានប្រព្រឹត្តទៅព្រមជាមួយនិងការ តស៊ូ ជាប់ជាប្រចាំទៅលើអ្នកកាន់កាប់ ។ **ការតស៊ូនេះ ត្រូវបានសំដែងចេញ ជូន កាលៈដោយការធ្វើសកម្មភាព គឺថាដោយការប្រយុទ្ធរបស់កងទ័ព, ជួនកាលនៅ ក្រោមរូបភាពនៃការតវ៉ា ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ម្តងទៀត នៅ ពេលដែល ឱកាសហុចឲ្យ ។**

លក្ខខ័ណ្ឌទាំងនេះត្រូវបានបំពេញ, អធិបតេយ្យភាពរបស់រដ្ឋទៅលើផ្នែកនៃទឹកដី របស់ខ្លួន ដែលត្រូវបានលុកលុយ និងកាន់កាប់ដោយបរទេស បានស្ថិតនៅពេញ លេញ និងទាំងស្រុង ថ្វីបើខ្លួនមិនមានសមត្ថភាព ដើម្បីធ្វើក៏ដោយ ។ ច្បាប់ អន្តរជាតិដូចយើងបានឃើញស្រាប់ហើយ បានរៀបចំឲ្យឃើញមានភាពខុសគ្នា

www.elibraryofcambodia.org

វាងអធិបតេយ្យភាព និងការអនុវត្តនូវ អធិបតេយ្យភាព ។ ព្រឹត្តិការណ៍ទាំងឡាយ ដែលបានរារាំងបញ្ហានេះ មិនបានធ្វើឲ្យបាត់បង់នូវអធិបតេយ្យភាពនោះឡើយ ដែលតាមផ្លូវច្បាប់គឺ ស្ថិតនៅមិនអាចប៉ះពាល់បានឡើយ ។ ដរាបណា បានបំពេញនូវលក្ខខ័ណ្ឌ ដូចបានរៀបរាប់ខាងលើ ដែលទាក់ទងទៅនឹងការបដិសេធ នូវការយល់ព្រមចំពោះការផ្ទេរ នូវអធិបតេយ្យភាព ដូចបាននិយាយមកនេះ ។

ស្ដីពីបញ្ហាកម្ពុជាក្រោម លក្ខខ័ណ្ឌទាំងនេះ គឺការតស៊ូចំពោះអ្នកកាន់កាប់ ឬក៏ការតវ៉ាប្រឆាំងនឹងអ្នកកាន់កាប់ ដូចយើងបានឃើញផងដែរ, ត្រូវបានបំពេញទាំងនៅក្រោមការកាន់កាប់ របស់អណ្ណាម ក៏ដូចជានៅក្រោមការកាន់កាប់ របស់បារាំង និងជាពិសេសទៅទៀត ចាប់តាំងពីការបញ្ចប់ការកាន់កាប់របស់បារាំង និងការផ្ទេរនៅឆ្នាំ ១៩៤៨ នូវទឹកដីកម្ពុជាក្រោម ទៅឲ្យរដ្ឋមួយដែលបានក្លាយទៅជាសាធារណរដ្ឋវៀតណាម ។

ដោយបានដឹងច្បាស់នូវស្ថានភាពជា "នីតិន័យ" របស់កម្ពុជាក្រោម ដែលអះអាងដោយសារវត្តមាន របស់ប្រជាជនខ្មែរ នៅលើទឹកដីនេះ ចំនួន ៦០០.០០០ នាក់នោះ (១៩៤៨), រដ្ឋាភិបាលរបស់សាធារណរដ្ឋវៀតណាម ពិតជាចង់ពង្រីកនូវផលប្រយោជន៍របស់ខ្លួន ដោយធ្វើឲ្យបាត់បង់នូវវត្តមានរបស់ខ្មែរនេះ នៅលើទឹកដីមួយដែលខ្លួនមិនបានអធិបតេយ្យ "តាមព្រឹត្តិន័យ" ណាមួយ ដែលមិនធ្វើឲ្យខូចអ្វីឡើយ នូវអធិបតេយ្យភាពជា "នីតិន័យ" របស់ប្រទេសកម្ពុជានោះ ។

ដោយហេតុនេះ, រដ្ឋាភិបាលនេះ បានបដិសេធមិនទទួលស្គាល់ អត្ថិភាពរបស់ខ្មែរ ដែលខ្លួនរស់នៅលើទឹកដី នៃបុព្វបុរសរបស់ខ្លួននោះ ។

ចាប់តាំងពីការចាកចេញ របស់បារាំងមក ប្រជាជនខ្មែរ បានក្លាយទៅជាកម្មវត្ថុនៃនយោបាយធ្វើឲ្យដូចគ្នារបស់វៀតណាមកាន់តែខ្លាំងឡើង ដែលនៅចំពោះមុខនឹងការតស៊ូដែលពួកគេបានជួបប្រទះ ពួកគេបានអនុវត្តនយោបាយបំបាត់ពូជ

www.elibraryofcambodia.org

សាសន៍, ហើយជាច្រើនផង ពួកគេបានប្រកាន់យកនូវដំណើរការប្រល័យពូជសាសន៍ ។

ចំពោះនយោបាយកំចាត់ប្រជាជនខ្មែរ នៅកម្ពុជាក្រោមនេះ រដ្ឋាភិបាលនៃសាធារណរដ្ឋវៀតណាម បានបន្ថែមនូវការបន្តគោលដៅអនុត្តរភាពនិយម របស់អតីតរាជវាំង វេ ហើយចាប់តាំងពីឆ្នាំ ១៩៦០ រដ្ឋាភិបាលវៀតណាម បានទាមទារនូវកោះ ៥នៅតាមឆ្នេរសមុទ្រ របស់កម្ពុជា នៅជិតជ្រោយរាម ។

ចំពោះសភាពការណ៍ពិតស្ដីពីការខូចខាត បូរណភាពទឹកដីរបស់ខ្លួននោះ ប្រទេសកម្ពុជា បានធ្វើការប្រឆាំងតវ៉ាជាច្រើនដង ។ ការបណ្ដឹងអន្តរជាតិ អង្គការសហប្រជាជាតិ និងស្ថាប័នរបស់ខ្លួនចំពោះរឿងហេតុនេះ គឺជាការពឹងផ្អែកតែមួយគត់ របស់ខ្លួនក៏ដូចជាការពឹងផ្អែក ទៅលើបណ្ដាប្រជាជាតិតូចតាច ។

បើគ្មានទទួលបានអំណាចគាំទ្រ ពីបណ្ដឹងអន្តរជាតិទាំងនេះ ដើម្បីយកខេត្តរបស់ខ្លួននៅ កម្ពុជាក្រោម វិញនោះ, ប្រទេសកម្ពុជាយ៉ាងហោចណាស់ក៏ចង់ឃើញអង្គការសហប្រជាជាតិ ធ្វើអន្តរាគមន៍ ដើម្បីការពារអាណិកជនខ្មែរ ទាំងនេះដែរ ។ ខ្មែរក្រោមទាំងនេះ ដែលប្រទេសកម្ពុជាមិនអាចអនុវត្ត នូវអធិបតេយ្យភាពមួយដែលខ្លួនមិនបានឈប់ឈរទាមទារដោយសារមូលហេតុនៃអត្ថិភាព របស់ពួកគេនៅទីនោះ ។

គឺសេចក្ដីអំពាវនាវរបស់សម្ដេចព្រះ "នរោត្តម សីហនុ" ដែលព្រះអង្គបានថ្លែងទៅកាន់មហាសន្និបាតរបស់អង្គការសហប្រជាជាតិលើកទី១៦ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ១៩៦១ ដែលមានសេចក្ដីដូចតទៅនេះ :

"បញ្ហានេះ បានប៉ះពាល់ដោយផ្ទាល់ចំពោះយើង ពីព្រោះថា ជនរួមជាតិរបស់យើងចំនួន ៦០០.០០០នាក់បានរស់នៅវៀតណាមខាងត្បូងនៅក្នុងលក្ខណៈជី

www.elibraryofcambodia.org

លំបាកក្រៃលែង ហើយនិងពុំមានការពឹងផ្អែកណាមួយប្រឆាំងនឹងវិធានការណ៍លើកលែងដែលពួកគេបានទទួលរង ។ សហគមន៍កម្ពុជានៅវៀតណាមខាងត្បូង បានបង្កើតការកាន់កាប់ជាលើកដំបូង នៅលើទឹកដីដែលលិចលង់ដោយការលុកលុយរបស់វៀតណាម, ប៉ុន្តែពួកគេបានរក្សានូវការឯកភាពខាងសាសនា និងភាសាជ្រាលជ្រៅមួយ ព្រមទាំងទំនៀមទម្លាប់ និងប្រពៃណី ។ អាស្រ័យដោយការសម្រេចផ្ដាច់ការរបស់រដ្ឋាភិបាលវៀតណាមខាងត្បូង, សហគមន៍នេះ បានឃើញការដាក់បង្ខំឲ្យចូលជាសញ្ជាតិវៀតណាម និងការបដិសេធរបស់វៀតណាម នូវសិទ្ធិដើម្បីរក្សាទុកនូវទំនៀមទម្លាប់ ភាសា និងការគោរពព្រះពុទ្ធសាសនា របស់ពួកគេ(...)។ ការបំពាល់ ចំពោះសិទ្ធិដ៏ពិសិដ្ឋ របស់មនុស្សត្រូវបានបន្ថែម (...) ដោយវិធានការណ៍លើកលែងដោយសភាពព្រៃផ្សៃបំផុត (...) ។ ជនរួមជាតិដ៏អភ័ព្វទាំងនេះ ជាច្រើនរយនាក់ បានព្យាយាមរត់គេចចេញពីការជិះជាន់សង្កត់សង្កិន ដើម្បីស្វែងរកការជ្រកកោន នៅក្នុងទឹកដីជាតិកម្ពុជា ពួកគេត្រូវបានគេដេញតាម ចាប់ខ្លួនធ្វើ ទារុណកម្ម និងបាញ់សម្លាប់ (...) ។

"បញ្ហានៃជនជាតិភាគតិចកម្ពុជា នៅវៀតណាមខាងត្បូង មិនមែនដូចគ្នា នៅលើពិភពលោកនោះទេ ។ ដោយហេតុនេះ ខ្ញុំជឿថា វាជាការចាំបាច់ដែលអង្គការសហប្រជាជាតិ យកចិត្តទុកដាក់ការពារឲ្យបានល្អ នូវសិទ្ធិទាំងឡាយរបស់ក្រុមមនុស្ស ដែលជាប់ដៃជាប់ជើងទាំងអស់ នៅក្នុងអំណាចផ្ដាច់ការនោះ ។

www.elibraryofcambodia.org

# ឧបសម្ព័ន្ធ ១

# ដកស្រង់ចេញពី

# "បុរាណវត្ថុវិទ្យា

# នៅដែនដីសណ្ដ ទន្លេមេគង្គ"

# របស់លោក Louis Malleret

www.elibraryofcambodia.org

## I. ឈ្មោះនៃឈូងសមុទ្រសៀម

ភ្នំអង្គុលបានព្រលយវែងទៅទិសខាងត្បូង ដោយកំពូលខុបសម្ព័ន្ធនៃភ្នំបារាំង (ដើម្បីជាអនុស្សាវរីយ៍ចំពោះជនជាតិបារាំងលោក Pigneau de Béhaine, អេវេក d'Adran, ចៅហ្វាយខេត្តនៅពញាព្ន, នៅដំណាច់សតវត្សរ៍ទី១៨) ។

"ហាទៀង គឺជាអតីត Bâm (Pâm) កម្ពុជា, ជាឋាននាមវិទ្យាដែលពួកអ្នកស្រុកនៅ Mac cuu បានធ្វើ Cang Khâu និងសាសនទូត Cangcas, Kancao ឬ Can cao" ទំព័រ ១៤ ។ "Pâm" (គេអានត្រឹមត្រូវគឺ Peam = ពាម) ដែលមានន័យថា "ប្រសព្វមុខគ្នា" ។

តំបន់នេះ ត្រូវនឹងពាក្យ "Pontiamas" ដែលប្រែក្លាយមកពីពាក្យបន្ទាយមាស ដែលនិយាយដោយពួក អតីតអ្នកដំណើរអឺរ៉ុប ដូចជាលោក Pierre Poivre នៅកណ្ដាលសតវត្សរ៍ទី១៨ ។

### ក) ភ្នំតូចនៅភាគខាងលិច

នៅជិត "Nui Thach Dông" មាន "ថ្មលើកជាបន្តបន្ទាប់ដែលប្រជាជនកម្ពុជាហៅថា ថ្មកុល ហើយត្រូវបានគេគោរពដូចជា "Linga" ។

គេឃើញមានរូងភ្នំ នៅភ្នំទទឹង (Bhnâm Dadin) នៅជិតទូកមាស ឬឪកមាស នៅជិត យ៉ាងថាញ់ នៅភ្នំប្រាសាទ និងនៅភ្នំខ្យង (ទំព័រ ១៥) ។

នៅទីក្រុងពាម (ហាទៀង) "វត្តមួយដែលគេហៅថា China Phât Lon ស្ថិតនៅជម្រាលខាងជើងនៃភ្នំតូច ប៊ិញ ស៊ីន, ដែលមាន ព្រះពុទ្ធរូបខ្មែរ មួយព្រះអង្គគង់អង្គុយក្នុងឥរិយាបថជា "Paryankasana" "បរិយត្តិ វិបស្សនា" ។

វត្តបាធំ ឬ (បឋម = Pân Dham) នៅភូមិឆ្លកនៅតំបន់ជ្រោយប៉ៃអ៊ុត ឬ (Bâi Ot) មានកេរដំណែលដ៏ចំណាន (ទំព័រ ១៦) ។

ភ្នំ Nui No So ស្ថិតនៅជួរភ្នំពេញ ប៊ិញទ្រី នៅជ្រោយ de la Table ។

www.elibraryofcambodia.org

រូបភ្នំ Sapèques នៅកន្លែងដែលគេហៅថា "ព្រះចៅកែវ" មានព្រះពុទ្ធរូបខ្មែរនៅសតវត្សរ៍ទី១៤ (វៀតណាមហៅថា Hai Son Tu) ។

នៅជួរភ្នំបិញទ្រី មានរូបបដិមា ភេទស្រី មួយគ្មានក្បាលនៅក្នុងសម័យអង្គរ ។

**១) ភ្នំតូចៗ ហន់ដីក** (Hon Dât)

ភ្នំ ហន់ដីក ប្រជាជនកម្ពុជា ហៅថា ភ្នំដី (កំណត់សម្គាល់ទំព័រ ២-១៩) នៅជម្រាលពាយ័ព្យនៃភ្នំ "Nui Hon Soc" មានកន្លែងមួយហៅថា ក្នុងទួល នៅជិតជម្រកមួយនៅក្រោមថ្មហៅថា "អ្នកតាសម្រែង" ។

នៅជម្រាលចុងក្រោយនៅទិសឦសាននៅក្នុងភូមិតូចមួយរបស់កម្ពុជាមាន "វត្តក្រក" ឬ វត្តប្រែក ។

**គ) មជ្ឈមណ្ឌលនៃទីក្រុង រ៉ាច់យ៉ា អតីតក្រមួន ស**

ពាក្យថា ក្រមួន ស គឺជាការរំឭកដល់អតីតកាលរបស់ប្រទេស ដែលពីមុនបានគ្របដណ្តប់ទៅដោយព្រៃ ហើយដែលធនធានសំខាន់របស់អ្នកស្រុកគឺការប្រមូលផលទឹកឃ្មុំ... (ទំព័រ ២០) ។

វត្តឧដុង្គមានជ័យ (វៀតណាមស្គាល់នៅក្រោមឈ្មោះថា Chuà Phât Lon ឋិតស្ថិតនៅផ្លូវនៃប្រទេសកម្ពុជា នៅលើទ្រូងផ្លូវចាស់ពី រ៉ាច់យ៉ា ទៅកាន់ ហាទៀង "គឺមានព្រះពុទ្ធរូបធ្វើអំពីមាសរាប់រយអង្គ" ។ គេបានស្គាល់រូបបដិមាខ្មែរដ៏តូចមួយអង្គ ដែលជាសិល្បៈអង្គរ មានព្រះកេស ៥ និងព្រះហស្ត ៨ ដែលព្រះសង្ឃនៅទីនោះបានឲ្យឈ្មោះថា "ព្រះនរាយណ៍" ។

រូបព្រះវិស្ណុ មួយអង្គធ្វើអំពីថ្មភក់ ដែលនាំមកតម្កល់ទុកនៅក្នុង "វត្តព្រះពុទ្ធជា" នៅក្នុងឆ្នាំ ១៩៤១ នៅរមណីយដ្ឋានតាកែវ ។

**ឃ) ច្នេរខាងលិចកាម៉ៅ ឬទឹកខ្មៅ**

ប្រជាជនកម្ពុជាហៅថា ទឹកខ្មៅ ពីព្រោះថា "ទឹកនៅជ្រោយដែលស្ថិតនៅ

www.elibraryofcambodia.org

ចន្លោះ ស៊ីងចាយបាយ ...ងណាមកិន មានពណ៌ខ្មៅ" ។ គេបានរកឃើញឈ្មោះ ស៊ីង ទាំងឡាយនៅប្រទេសកម្ពុជា ប៉ុន្តែត្រូវបានប្រែក្លាយទៅជាឈ្មោះអណ្ណាម ។ ស៊ីង មួយនៅក្នុងចំណោមស៊ីងទាំងនោះមានឈ្មោះថា "ស៊ីងដូងកែវ" ។

**ង) កោះភូក្វុក**

កោះភូក្វុក ប្រជាជនកម្ពុជាហៅថា កោះស្រល់ ឬកោះត្រល់ ។ បានលយទៅក្នុង សមុទ្រនូវរចនាសម្ព័ន្ធដូចជាភ្នំដីរ និងបានតភ្ជាប់ទៅដីគោក ដោយកោះតូចៗពីរ ជាអន្តរការី, កោះទឹក ឬកោះកុងសួរ និងកោះកណ្តាល ឬកោះសេះ... មានបណ្តោយ ប្រវែង ៤៨គ.ម និងទទឹងប្រវែង ២៥គ.ម ទៅទិសខាងជើង ។ ទំហំរបស់កោះនេះ លើសទំហំរបស់កោះ Martinique ។

ប្រពៃណីដែលគេប្រមូលបាន គឺជាប់ទាក់ទងទៅនឹងប្រជាជនកម្ពុជា ។ ព្រះអង្គ ង្វៀន អាន់ ដែលគេចខ្លួនបានមកគង់ស្នាក់នៅជាច្រើនដង នៅចន្លោះឆ្នាំ ១៧៨២ និង១៧៨៦ ។

"ប៉ុន្តែគេបានបញ្ជាក់អះអាងថា មានអំបែងបានថ្នាំង ដែលធ្វើដោយប្រជាជន កម្ពុជានៅរាយប៉ាយដេរដាសនៅលើដីនៅក្នុងជ្រលងតូចនៅតំបន់ Cua Can នៅ លើឆ្នេរសមុទ្រខាងលិច" ។

"បើតាមព័ត៌មានដែលប្រមូលបាននៅក្នុងឆ្នាំ ១៩៤២ នៅជ្រោយ de la Table (ជ្រោយតុ) និងដែលមានការបញ្ជាក់អះអាងនៅហាទៀងនោះ គឺមានរូបដិមាដី តូចមួយធ្វើអំពីទង់ដែង ដែលបើតាមការពិពណ៌នាបានឲ្យយើងដឹងថានោះគឺជា រូបបដិមាដែលតំណាងឲ្យព្រះ Viçvakarman ត្រូវបានគេរកឃើញនៅហាយប៊ូន នៅកោះកណ្តាល ។ វាអាចមានលទ្ធភាពថា ស្លាកស្នាមនៃការកាន់កាប់ពីរ...ត កាលមួយរបស់ខ្មែរ អាចរស់នៅនៅក្នុងកោះដីធំនេះ ដូចនៅក្នុងឧបសម្ព័ន្ធរបស់ខ្លួន ហើយនឹងមិនមែនជាការឥតប្រយោជន៍នោះទេ ក្នុងការចាប់ផ្តើមទទួលស្គាល់ឲ្យ បានស៊ីជម្រៅនោះ" ។

www.elibraryofcambodia.org

**ច) ប្រជុំកោះនៅឈូងសមុទ្រ**

"នៅខាងអាយនៃជ្រោយកែប និងកោះត្រសេះ បានលេចឡើងនៅក្នុងលំហសមុទ្រនៅ ហាទៀង មានប្រជុំកោះតូចៗ នៃកោះចោរសមុទ្រ មានចំនួនលើសពី ១៥ កោះ ។

**ឆ) ប្រទេស ហង់ បុង**

នៅក្នុងអតីតកាលបានស្ថិតនៅចន្លោះ ឆ្នេរសមុទ្រសៀម រហូតដល់ ហង់ ដីកទន្លេយ៉ាងថាញ់ ព្រែកជីក វីញតេ និងជួរភ្នំ ៧ ។

**ជ) ព្រែកជីក វីញតេ និងអតីតមាត់ជ្រូក**

ព្រែកជីក វីញតេ គ្រាន់តែជាការកែប្រែនូវអតីតព្រែកជីក ដែលខ្មែរជីកចាប់តាំងពីយូរណាស់មកហើយប៉ុណ្ណោះ ។

នៅលើកំពូលនៃ "ព្រះបាទជាន់ជុំ" អតីតគំនូសព្រំដែនបានតម្រង់ទិសទៅរកមាត់ជ្រូករបស់ប្រជាជនកម្ពុជា (កំពង់ក្រសាំង), នៅកម្រិតមាត់ទឹកនៃស្ទឹងតាកែវ គំនូសថ្មីត្រូវបានជីក នៅក្រោមរជ្ជកាលរបស់ព្រះអង្គចន្ទ និងរបស់ស្តេច យ៉ាឡុង បានតម្រង់ទិសត្រង់ឆ្ពោះទៅរក ទីក្រុងចូវដុកថ្មី ។

"គំនិតផ្តួចផ្តើមរបស់ពួកគេ (ទំព័រ ២៨) ត្រូវបានអនុវត្តជាសំខាន់ដើម្បីកែប្រែជាផ្នែកនូវគំនូសនេះ ដោយបើកនូវកំណាត់ថ្មីនៅចន្លោះបន្ទាយថ្មីនៅ ចូវដុក និងអាងទឹកកាអាម ឬកាម ។

បុរាណវត្ថុវិទ្យានៃដែនដីសណ្តទន្លេមេគង្គ Cite Gérini ដែលយោងទៅតាម Trinh Hoai Duc (វស្សិកប្រវត្តិសៀម) គឺ ប៉ុស្តិកម្ពុជានៅ ភូម៉ាត់លឿក គឺស្ថិតនៅត្រើយខាងកើតនៃទន្លេចូវដុក" នេះបើតាមអ្នកនិពន្ធនេះបានសរសេរ ។

"នៅទីនេះ គេស្គាល់យ៉ាងងាយស្រួលនូវឈ្មោះចាស់ Màt Jruk (មាត់ជ្រូក) ជាវេហាសាស្ត្រ ដែលប្រជាជនកម្ពុជាបានប្រើប្រាស់នៅឡើយ ដើម្បីបង្ហាញ

www.elibraryofcambodia.org

តំបន់ចូវដុកនេះ ហើយដែលបានទាក់ទងទៅនឹងហេតុការណ៍នៃតំបន់មួយដែលស្ថិតនៅទិសពាយ័ព្យនៃទីក្រុងបច្ចុប្បន្ន..." ។ ក្រោយពីបានធ្វើដំណើរ ១៥គ.ម នៅមាត់ត្រើយខាងលិចនៃស្ទឹងនេះ គេឃើញមានព្រែកជីក Phung Can Tan និងក្រោយពីធ្វើដំណើរបានចម្ងាយ ២៦គ.ម នៅតាមព្រែកជីកចាស់មួយរបស់កម្ពុជាដែលត្រូវបានជីកនៅកន្លែងនេះកាលពីលើកមុន គេបានទៅដល់ អាង កាអាម" ។

អាង កា អាម នេះ គឺស្មើទៅនឹងវាលទំនាប ភក់ល្បាប់ដែលស្ថិតនៅខាងជើង និងខាងកើតភ្នំបាយ៉ាន (ផ្លាម ប៉ា យ៉ាន) គឺថានៅចម្ងាយ ២៧គ.ម (68lis) ពីមាត់ជ្រូក (ទំព័រ ២៨) ។

វស្សិកប្រវត្តិអាយុធ្យា បានរាយការណ៍ថា នៅឆ្នាំ ១៥៥០ "នាវាសៀមបានមកដល់លង្វែកដោយឆ្លងកាត់ ពាម Phuttaimàc (Pandây - Màs) និងព្រែកជីក Cun Krajum (Chong Krachum)" ។ "Pandây Màs" គឺស្របនឹងឈ្មោះ Bàm (Pàm), ពាម ជាឈ្មោះចាស់របស់ ហាទៀង, ស្ទឹង Cun Krajum នឹកទៅដល់ឈ្មោះរបស់ភូមិ Brah Pàd Jàmn - Jum (ព្រះបាទជាន់ជុំ ឬ Càn Cum ដែលជានិវេសនដ្ឋានរបស់ចៅហ្វាយខេត្តកម្ពុជានៅ Dràmn (ត្រាំង) ជាយូរមកហើយនោះ" ។

អនុសេនីយឯក ហាមីលតុន បានសរសេរនៅក្នុងឆ្នាំ ១៧២០ ថា

"កំពង់ផែមួយទៀតរបស់ប្រទេសកម្ពុជា គឺ Ponteamas គឺជាកន្លែងធ្វើពាណិជ្ជកម្មដ៏សំខាន់គ្រាន់បើមួយជាយូរមកហើយ...។ ទីក្រុងរបស់ប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងនៅលើមាត់ស្ទឹងធំ នៅចម្ងាយប្រហែល ៥០ឬ៦០ Lieus (1 lieu = 4 គ.ម) ពី Ponteamas តាមផ្លូវដី ឬតាមផ្លូវទឹកនៅក្នុងខ្យល់រដូវ (Mousson) មកពីទិសនិរតី" ។

លោក Malleret បានបញ្ជាក់ថា "ផ្លូវទឹកនេះគេហៅថា ខ្ទននៅក្នុងវស្សិកប្រវត្តិរបស់អាយុធ្យាដែលគេអាចឮផងដែរថា ជាព្រែកជីកមួយជាជាង ផ្លូវ

www.elibraryofcambodia.org

គមនាគមន៍ពីធម្មជាតិ ។ ផ្លូវទឹកនេះ ត្រូវបានប្រជាជនកម្ពុជាហៅថា គុមនីក ព្រែកតែន (Cumnik-Prek-Tén) (ទំព័រ៣០) ។

អត្ថិភាពនៃព្រែកជីក "វិញតេ (Cumnik - Tên)" ត្រូវបានបញ្ជាក់ថែមទៀត នៅក្នុងលិខិតមួយរបស់ Père levavasseur ដែលមានកាលបរិច្ឆេទនៅក្នុងឆ្នាំ ១៧៧០ ដែលសាសនៈទូតបានរៀបរាប់អំពីដំណើររបស់ខ្លួន នៅប្រទេសកម្ពុជាតាម បាសាក់ថា "ថ្ងៃទី៣ ឧសភា ១៧៦៨ យើងបានមកដល់ព្រែកជីកមួយ ដែលបាននាំ ទៅដល់ខាងផ្នែក Cancao ។ កន្លែងនេះប្រជាជនកម្ពុជាហៅថា Mat che ron"។ គេត្រូវតែយល់ថា Mat Che ron ឬ Mat Jruk (មាត់ជ្រូក) បានចង្អុលបង្ហាញ នូវចំណុចដើមនៃព្រែកជីកនៅ បាសាក់កានកាវ គឺដូចជាគេបានឃើញនូវការចម្លង ដោយសេរីនូវឈ្មោះចាស់របស់ចិននៅហាទៀង (ទំព័រ ៣០) នោះដែរ ។

ចំណែកនៅ ចូវដុក មែនតែននោះ គឺជាការបង្កើតថ្មីរបស់វៀតណាមពីព្រោះថា ក្រុងចាស់របស់កម្ពុជា គឺស្ថិតនៅមាត់ជ្រូក គឺស្ថិតនៅចម្ងាយជាង ១០គ.ម ពី បន្ទាយថ្មី ជាជាងនិយាយថា "កំពង់ក្រសាំងនោះ"។

"ផ្លូវទឹកចាស់ បានហូរចាក់ទៅខាងក្រោមនៃមាត់ស្ទឹងចូវដុក ដែលត្រូវបានជីក ចាប់តាំងពីចំណុចនេះទៅ នៅក្នុងសម័យនៃទីក្រុងចាស់ Angkor Puri (អង្គរបុរី)។ រមណីយដ្ឋានសម័យមុនអង្គរ មានច្រើនហូរហៀរនៅក្នុងសម័យនោះ ។ ប្រជា ជនខ្មែរបានបើកនូវ ព្រែកជីកទាំងឡាយដែលព្រែកមួយនោះ ត្រូវបានបង្ហាញ ដោយ ការរុករកតាមផ្លូវអាកាសភ្ជាប់ "អង្គរបុរីទៅទីក្រុង d' Oèkêr (ឬ ឧកឯរ= អុកអែរ) និងបានបន្តទៅឆ្ងាយទៅទៀតទៅទិសអាគ្នេយ៍ ។

"ដូច្នេះគេឃើញថា ប្រជាជនខ្មែរ និងបុព្វបុរសរបស់ខ្លួននៅតំបន់ បាសាក់ បាន ដោះស្រាយនូវបញ្ហាការរៀបចំផ្លូវទឹក ដែលព្រែកជីកចាស់វិញតេ បានផ្តល់ឲ្យ យើងនូវទិដ្ឋភាពមួយ" ។

www.elibraryofcambodia.org

នៅលើមាត់នៃព្រែកដឹក វិញគេ គេបានឃើញសិលាចារិក ៣ជាភាសាសំស្ក្រឹត នាំមកពីបន្ទាយ "នៅប្រទេសកម្ពុជា" ។

II. **ភ្នំស្វាម** (ឬភ្នំសាម)

ស្ថិតនៅទិសនិរតីនៃចូវដុក កន្លែងនេះត្រូវបានគេស្គាល់ជាយូរមកហើយ ថាជាអតីតចំណុចកាន់កាប់របស់ខ្មែរ ។

"លោក Aymônier បានចង្អុលបង្ហាញអំពីប្រជាជនមួយ ដែលភាគច្រើន គឺជាប្រជាជនកម្ពុជានៅក្នុងពេលនោះ ហើយដែលបុព្វបុរសរបស់ពួកគេ បានកសាងនៅកន្លែងនោះ នូវប្រាសាទមួយចំនួន" ។

លោក Lunet de Lajonquière បានបញ្ជាក់អំពីការរកឃើញនៅ ភ្នំស្វាម នូវចានទាបពីរធ្វើអំពីប្រាក់ (ដែលរកឃើញដោយនាង សេក) ប្រពន្ធរបស់លោកជំជាប្រជាជនកម្ពុជានៅភូមិ Tu-Tê (ទំព័រ ៣៥) ។ អក្សរនៅលើចានទាប មានកាលបរិច្ឆេទនៅមហាសករាជ ១០៨៨ (១១៦៦ ក្រោយគ្រិស្តសករាជ) និងព្រះនាមរបស់ព្រះមហាក្សត្រមួយអង្គគឺ ព្រះបាទ ត្រៃភព ទិត្យាវរ្ម័ន "Tribhuvanà Dityavarman" ។

លោក Malleret បានរកឃើញនៅភ្នំស្វាមនូវបូរាណវត្ថុខ្មែរជាច្រើន ។ ប្រពៃណីរបស់ខ្មែរនៅតែរស់នៅជានិច្ច ។

"គេបានឃើញនៅភ្នំស្វាមនូវបាតុភូមិនៃការយកលំនាំតាមប្រពៃណីខ្មែរដោយពួកវៀតណាមដែលយើងបានពិនិត្យឃើញនូវគំរូដ៏សំខាន់ក្រៃលែងនៅក្នុងតំបន់ផ្សេងៗទៀត ។

"Linga (លិង្គ?) ខ្មែរដ៏ធំនៅកន្លែងនេះ គឺជាកម្មវត្ថុនៃការបូជាពិសេសរបស់នារីវ័យក្មេង និងស្ត្រីមានប្ដីជនជាតិអណ្ណាម និងចិន" (ទំព័រ ៣៨-៣៩) ។

នៅកន្លែង "វាលទំនាបអណ្ដូងប្រាំពីរ" ឬក៏វាលទំនាបនៅតាមវត្ថុទាំងឡាយ

www.elibraryofcambodia.org

លោក Malleret បានរកឃើញ "Linga, ឥដ្ឋ បដិមាតូចៗ... គុហា, វត្ថុអារ៉ាម... ដែលមានដើមកំណើតខ្មែរជាច្រើន" ។

III. **ជួរភ្នំច្រាំពីរ**

**ជួរភ្នំទាំងនេះ បើតាមរបទាសម្ព័ន្ធនៃភូគព្ភសាស្ត្រ បានរក្សាទំនាក់ទំនងជាមួយ និងរបទាសម្ព័ន្ធនៃជួរភ្នំទន្លាប់** (Tam Làp) **ដែលរួមបញ្ចូលភ្នំប៉ាយ៉ន** (Bhnâm Payân) **និងភ្នំជិននៅក្នុងទឹកដីកម្ពុជា ។**

**នៅក្នុងចំណោមភ្នំទាំងច្រាំពីរនេះ គឺមាន "ជួរភ្នំ** Tap Campâ **(ទ័ពចំប៉ា និង** Bhnôm Babâl (Phnom Popâl **ពពាល នៅកណ្តាល និងនៅទីបញ្ចប់ គឺក្រុម** Bhnam Khdo (Phnom Khtô **ខ្មៅ** ) **នៅខាងត្បូង ។**

***ក) លោក*** L. Malleret **បានរកឃើញនៅលើកំពស់នៃខេត្ត ចិញបៀន និង ញ៉ាំ បាង**

– សំណល់នៃប្រាសាទមួយនៅភ្នំ កែត Nui Két

– សិលាស្តម្ភដែលមានពន្លួញ (នៅមុនសម័យអង្គរ) ធ្វើអំពីថ្មភក់បាក់បែក ខ្លាំង ហើយនៅខាងចុងមានស្នាមខ្សែ ៥ដែលជាវត្ថុបូរាណរបស់ខ្មែរ និងត្រូវបាន កំណត់ឲ្យសារមន្ទីរសាយហ្គូននៅសតវត្សរ៍ទី៧ ។

– រូបចម្លាក់បាក់ដៃ បាក់ជើង ចំនួន ៩ .

– រូបបដិមារបស់ព្រះពុទ្ធធ្វើអំពីថ្មភក់លាបទឹកមាស នៅថ្កើងខ្នងមានអក្សរ បារិក ជាភាសាខ្មែរសម័យថ្មី ។

– នៅខាងលើទ្រីតូង (ស្រុកស្វាយទង) នៅវត្តខ្មោតមានរូបចម្លាក់គោពីររបស់ ខ្មែរ ធ្វើអំពីថ្មភក់ ។

– កន្លែងសំណង់ចាស់មួយនៅជិត "អ្នកតាដុក" និង "អូត្រពាំងត្រាវ" (ភូមិតូច កំពង់ដុក ភូមិវិញទ្រុង) និងបន្ទប់លំនៅ ៣ជាសិល្បៈខ្មែរ ។

www.elibraryofcambodia.org

- នៅអ្នកតាទួលជីនុក មានរូបចម្លាក់ ៤ នៅជាមួយគ្នា ។

**១) ភ្នំ...ៗនៅកណ្តាល**

មានភ្នំ អកយំ ឬភ្នំយាម និងភ្នំស្តេចឌី ។ កំពូលដែលខ្ពស់បំផុតនៃភ្នំទាំង ៧ គឺ Bhnam Babàl (ភ្នំ Popâl = ពពាល) ប្រាកដហើយពាក្យនេះ គឺមកពីពាក្យខ្មែរថា "Bram Pi" (ប្រាំពីរ)។

គេបានបង្ហាញនៅតាមជម្រាលថ្មភ្នំថ្ងក់ (Thngok) នូវចំណុចវត្ថុបុរាណចំនួន ៣ គឺ :

- នៅអ្នកតាភ្នំថ្ងក់ (Thngok) "នៅភូមិខ្មែរបន្ទាយដែក គេបានរកឃើញរូបចម្លាក់ ៤ ធ្វើអំពីថ្មភក់ បច្ចុប្បន្នរក្សាទុកនៅសារមន្ទីរសាយហ្គន ។

- វត្ត "ស្វាយតាសោម" មានកម្រាលឥដ្ឋ និងរូបចម្លាក់ធ្វើអំពីថ្មភក់ ។

- នៅ "វត្តកុកគំរូ" មានកម្ទេចឥដ្ឋរបស់វត្តមួយ និងចេតិយមួយ ។

នៅវាលទំនាប Pandây Tèk ខ្មែរហៅថា "វាលទំនាបបន្ទាយដែក" គេបានរកឃើញ ។

- អាងទឹកមួយដែលខ្មែរក្រោមហៅថា "ត្រពាំងថ្នល់"

- រូបចម្លាក់ទេវរូបស្រីមួយអង្គ ជារូបចម្លាក់នៅមុនសម័យអង្គរ នៅវិហារ Dhâm ឬវិហារធំ ។

- រូបចម្លាក់ផ្សេងៗទៀត ត្រូវបានគេប្រមូលទុកនៅក្រោមដើមឈើមួយដើម នៅកន្លែងដែលគេហៅថា "ថ្មតម្រួត" ។

- ព្រះពុទ្ធរូបឈើមួយអង្គនៅកន្លែងដែលគេហៅថា "ថ្មចុងយូ" ។

**ភ្នំក្រសាំង**

គេបានឃើញ

- នៅកន្លែងដែលគេហៅថា "អ្នកតាកូនភូមិ" (អ្នកតាជាន់ភូមិ) នូវប្រឡាយ

www.elibraryofcambodia.org

Somasûtra ធ្វើអំពីថ្ម (សិល្បៈខ្មែរពីដើម) ។

– នៅទល់មុខវត្តទឹកផុស នៅកន្លែងដែលហៅថា "ទួលចេតិយ" មានកម្ទេចនៃសំណង់ចាស់មួយ ។

– ប្រាសាទមួយដែលហៅថា "វត្តស៊ិកាអែន" មានកាំជណ្តើរមកពីប្រាសាទបុរាណ ។

– នៅកន្លែងដែលហៅថា "អ្នកតា ភិភក្តនេស មានសំណល់របស់ប្រាសាទចាស់មួយ ។

– មាន "ទួលព្រះចេតិយ" មួយ

– "ស៊ីកំណប់" កន្លែងត្រីះដែលមានការបញ្ជាក់ដោយប្រពៃណីខ្មែរ ។

**តន្លង់ឧត្តិលខាងកើត ភ្នំយាម (ភ្នំអកយំ)**

គេបានរកឃើញ :

– ភ្នំផ្លុក

– "អូ ទឹករាំ" (ប្រហែលជារំលឹកទៅដល់រឿងព្រេងមួយរបស់ខ្មែរដែលមានចំណងជើងថា "ទឹករាំផ្ការាំ" ។

**វាលទំនាបល្អង់ភី**

– មាន "Trapên Ven" (ត្រពាំងវែង)

– រូបបដិមាតូចធ្វើអំពីលង្ហិននៅវត្ត Tabun Loe (ត្បូងលើ)

– វត្ត "កុករមៀត" ។

**គ) ផ្លូវភ្នំខ្មោច (Khtô) (នៅខាងត្បូងភូមិធំ ទ្រឹត្នង)**

"ទ្រឹត្នង" ខ្មែរហៅថា "ស្វាយទង" គេឃើញមានវត្តមួយហៅថា វត្តស្វាយទង ដែលមានរូបបដិមារបស់ព្រះពុទ្ធមួយអង្គ ធ្វើអំពីថ្មភក់រីង (សារមន្ទីរសាយហ្គន)

– វត្តព្រៃវែន (ព្រៃវែង) មានរូបចម្លាក់ ៣ផ្សេងទៀត

www.elibraryofcambodia.org

- ផ្លូវទឹក "ស្វាយសេក" (អូ ស្វាយចេក) អ្នកតាកុល
- អ្នកតា ភ្នំស្តេចគង់
- ភ្នំអណ្តើក ។

"តំបន់ភ្នំច្រាំពីរនៅជិត វ៉ែព្រែកជីកចាស់ដែលតភ្ជាប់ ហាទៀង ទៅស៊ឹងចូវដុក ផ្លូវលុកលុយពីបុរាណសម្រាប់កងទ័ពសៀម ។ ប្រពៃណីក្នុងស្រុក បានរក្សាអនុស្សាវរីយ៍នៃអំពើហិង្សារបស់ពួកអ្នកលុកលុយ ភូមិទាំងឡាយជាមួយស្ត្រីនិងកូនក្មេងត្រូវជាប់ឃុំឃាំង ទីជម្រកដែលគេបានស្វែងរកនៅក្នុងគុហានៅភ្នំ Khtô ឬក៏នៅ Bhnam Babâl" (ភ្នំខ្ទារ ឬភ្នំពាពល) ។

សិលាចារិក ៣ត្រូវបានគេរកឃើញ "គិតតាមលំដាប់នៅចន្លោះសតវត្សរ៍ទី៦ និងសតវត្សរ៍ទី៧ នូវ Çaka និងព្រះកេសរបស់ព្រះពុទ្ធពីរអង្គអាចត្រូវបាននាំមកនៅក្នុងសម័យក្រោយបន្តិចដែលបានចង្អុលបង្ហាញថា គឺជាការបន្តដ៏ប្រសើរនូវលំនៅស្ថានរបស់មនុស្សចាប់តាំងពីសតវត្សរ៍ទី៦ រហូតដល់យូរក្រោយមកទៀត នៅជុំវិញជួរភ្នំនេះ ។

## IV ភ្នំបាថេ និង ភ្នំពណាបរបស់វា

ជាដំបូងគេត្រូវតែកត់សម្គាល់ចំពោះ ប្រភេទ នៃពាក្យ "បា" និងពាក្យ "មេ" គឺជាពាក្យខ្មែរយ៉ាងជាក់ស្តែង ។ នៅប្រទេសកម្ពុជាគេបានសម្គាល់បុព្វបុរស ឬឪពុកម្តាយដោយពាក្យថា **"មេបា"** ពាក្យ**មេ**គឺសម្រាប់ភេទស្រីហើយ**បា** គឺសម្រាប់ភេទប្រុស (លោក François Martini "អំពីអត្ថន័យនៃពាក្យ បា និងពាក្យ មេ ដែលជាសព្ទបន្ថែមទៅលើឈ្មោះនៃប្រាសាទរបស់ខ្មែរ" in B.E.F.E.O, XLIV, i-1947-1950 បារីស 1951 ទំព័រ ២០១-២០៩) ។

១) ភេរជំណែលដែលគេបានស្គាល់ពីមុននៅបាថេ

នៅឆ្នាំ ១៨៦៨ មានទាហានម្នាក់នៅក្នុងកងទ័ពជើងទឹកឈ្មោះ Duplessis បាន

www.elibraryofcambodia.org

វង្វេងផ្លូវ ក្រោយពីការបះបោររបស់វ៉ាច់យ៉ា ។ ត្រូវបានទទួលដោយអនុប្រធានឃុំម្នាក់របស់កម្ពុជានៅ ម៉ៃវ៉ែងត ។ នៅក្នុងសម័យនោះ មេឃុំនៅ វង់ ថេ គឺជាប្រជាជន កម្ពុជាម្នាក់ឈ្មោះ ម៉ៃ បុញ្ញ (Pauline Vial, "បណ្ដាឆ្នាំទី១ នៃកូសាំងស៊ីនអាណានិគមបារាំង" ប៉ារីស ១៨៧៤ II ទំព័រ ២៣៥-២៣៦) "ភ្នំបាថេ" ត្រូវបានវេជ្ជបណ្ឌិត A. Corre ជាគ្រូពេទ្យនៃកងម៉ារីន បានទៅធ្វើទស្សនកិច្ចជាលើកដំបូង ។ ទំនាក់ទំនងតែមួយចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ១៨៧៩ បោះពុម្ពផ្សាយនៅក្នុងសៀវភៅ "Excursions និង Reconnaissance" (ដំណើរកម្សាន្ត និងការដឹងគុណ) ។

"ការយកចិត្តទុកដាក់របស់អ្នករៀបចំមុននេះ ត្រូវបានទាក់ទាញនៅលើតំបន់នេះដោយឆ្លងកាត់ការបកប្រែរបស់លោក d' Aubaret (Gia Dinh Thung Chi) នៅ យ៉ាឌិញ ធុងជី" ស្នាដៃ របស់ Trinh Hoai Duc មន្ត្រីជំនាន់ មិញម៉ាង ដែលគាត់បាននិយាយថា "មានប្រជាជន កម្ពុជារស់នៅភ្នំបាថេ ជួនកាលរស់នៅក្នុងរូងភ្នំ ឬនៅក្នុងគុហាដែលមាននៅជើងភ្នំនេះ ជួនកាលនៅលើភ្នំតែម្ដង" ។ ("បុរាណវត្ថុវិទ្យា..." ទំព័រ៧៦) ។

ដូច្នេះ គេបានសង្កេតឃើញថា វត្តមានរបស់ប្រជាជនកម្ពុជានៅកូសាំងស៊ីនត្រូវបានបញ្ជាក់អះអាងដោយអ្នកនិពន្ធវៀតណាមផ្ទាល់តែម្ដង ។

លោក Malleret បានបន្ថែមថា "ការពិតប្រជាជននៅកន្លែងនោះ នៅពេលនោះ ភាគច្រើនគឺជាប្រជាជនកម្ពុជា ដែលបានរស់នៅក្នុងឆ្នាំ ១៨៧៩ នៅក្នុងករណីដែលបានបង្ហាញថា មានលក្ខណៈត្រឹមត្រូវពិតប្រាកដ" ។

ដូច្នេះ នៅក្នុងសម័យដែលថ្មីបំផុតនោះ ប្រជាជនកម្ពុជាបានរស់នៅភាគច្រើននៅក្នុងផ្នែកជាច្រើននៃទឹកដី កូសាំងស៊ីន ។ គឺទើបតែនៅក្នុងសម័យកាន់កាប់របស់បារាំងនោះទេ ទើបចំនួនប្រជាជនវៀតណាមបានកើនឡើង ដូចដែលលោក Malleret បានកត់ត្រាដោយត្រឹមត្រូវនោះ (កំណត់ត្រា បុរាណវត្ថុវិទ្យា... ទំព័រ ៧៦) :

www.elibraryofcambodia.org

"ចាប់តាំងពីប្រជាជនវៀតណាម បានទទួលឧត្តមានុភាព ។ នៅឆ្នាំ ១៩៤៣ គេបានរាប់ប្រជាជនវៀតណាមនៅ វ៉ង់ថេ ចំនួន ៥.១២៨នាក់ ទល់នឹងប្រជាជនកម្ពុជាចំនួន ១.៨៦៤នាក់ ចិន ៩១នាក់ និងមិញហួង ៩៤នាក់" ។

វេជ្ជបណ្ឌិត Corre បាននិយាយអំពីគុហាដែលស្ថិតនៅកន្លែងខ្ពស់ៗ ដែលមនុស្សអាចរស់នៅបាន... និងវត្តចំនួន ៧ដែលគេមានព្រៃកដីកចាស់មួយរបស់ខ្មែរហៅថា ព្រែក "រ៉ាច់ ជាត្រាច" ភូមិតូចមួយរបស់កម្ពុជាឈ្មោះ "ភូមិព្រះធាតុ - Prah Dhat" ដែល សព្វថ្ងៃនេះវៀតណាមហៅថា វ៉ង់ដុង (Vong Dong) និងភូមិតូច នៅខាងកើត ។

ភូមិតូចនេះ នៅក្នុងចំណុះភូមិវ៉ង់ថេ ដែលប្រជាជនកម្ពុជារស់នៅស្ទើរតែផ្តាច់មុខ ។ "ភូមិវ៉ង់ថេ ឃុំ ឱញក្ង ខេត្តឡុងស្បៀន មានភូមិតូចៗ ៤ គឺភូមិវ៉ង់ដុងជាភូមិតូចនៅខាងកើត ភូមិព្រះធាតុរបស់កម្ពុជា ភូមិវ៉ង់តី (Vong Tây) ជាភូមិតូចនៅខាងលិច ភូមិ Ur Dham (ឧត្តម) របស់កម្ពុជា (ភូមិតូចនៃព្រែកដីកធំ) ភូមិទ្វីងសឺន ជាភូមិតូចនៅកណ្តាលដែលដូចគ្នានឹងភូមិធីបច្ចុប្បន្ន នៅទីបញ្ចប់គឺ ភូមិតឹង ហ៊ីប (Tan Hiêp)" ។

ពួកបុរាណវិទូ បានស្រាវជ្រាវឋាននាមវិទ្យាត្រឹមត្រូវរបស់ បាថេ ។ ក្រោយពីបានសិក្សាកន្លែងចាស់នៃព្រែកដីកកម្ពុជានៅកន្លែងនេះ លោក Malleret បានសន្និដ្ឋានថា នៅក្នុងឈ្មោះរបស់វៀតណាម **បាថេ** គេត្រូវតែស្គាល់អំពីការប្រែក្លាយសំឡេងរបស់ឋាននាមវិទ្យារបស់កម្ពុជានេះ គឺ**ព្រះធាតុ**" ។

លោក Malleret បានរៀបរាប់នៅក្នុងកំណត់សម្គាល់របស់លោក (២ទំព័រ៧៩) V.Vuvernoy (ឯកលេខនារបស់ខេត្តឡុងស្បៀងហាណូយ ១៩២៤ ទំព័រ ៤) "ឈ្មោះ **បាថេ** គឺជាការអានច្រាសចាកពីឈ្មោះដើមរបស់កម្ពុជាហៅថា **ព្រះធាតុ** លោក Malleret បានបញ្ជាក់ថា បញ្ហានេះ "គេមិនចង់និយាយឲ្យបានត្រឹមត្រូវពិតនោះ

www.elibraryofcambodia.org

ទេ" ហើយលោកបានបន្ថែមថា "ជាទូទៅវាមិនមានអ្វីដើម្បីស្រង់ចេញពីកូសាំងស៊ីននូវឫសរបស់ពាក្យដែលប្រែជាជនវៀតណាមជាអ្នកធ្លាប់និយាយនោះទេ ។

"ឋានទាមវិទ្យាមួយចំនួនធំ ជួនកាលជាការបកប្រែដោយសុទ្ធសាធ និងងាយស្រួលនូវឈ្មោះចាស់របស់កម្ពុជា ជួនកាលដោយការក្លែងនៃសំឡេង" ។

នៅបាថេ គេបានរកឃើញវត្ត ៤គឺ

- វត្តព្រះធាតុ (Prah Dhat)
- វត្តក្រាប៉ូវ ប្រ៊ិក (Krapau Brik) (កប៉ូវព្រឹក្ស)
- វត្ត សូឌី ស៊ូខាំ (Saudi Sukham) (សុទ្ធិសុខុម)
- វត្តកាំប៊ូល ភ្នាំ (Kambul Bhnam) (កំពូលភ្នំ)

ពួកបូរាណវិទូ បានរកឃើញរូបបដិមារបស់ព្រះវិស្ណុដ៏ធំមួយ និងមេទ្វារមួយចំនួន ។

២) គេរដិវ័ណលថ្មីៗទទួលស្គាល់នៅបាថេ និងនៅកន្លែងជិតៗនោះ

លោក Malleret បានបង្ហាញចំណុចកាន់កាប់ចាស់ចំនួន ១៤ដែលគេមិនបានស្គាល់នៅជុំវិញនៃជួរភ្នំគឺ

- អ្នកតាថ្មគោល
- Dwl សាលី (ទួលសាលី) ឬទួលអ្នកតានាងខ្មៅ)
- ទួលកណ្តាប់វែង និងស្រែត្រពាំង, (ស្រែត្រពាំង)
- ទួលតាដុក
- ទួល អនទុន តាដាន
- កន្លែងមុនអង្គរ និងកន្លែងរបស់លោក Lieu Phanh
- ទួលអ្នកតាប៊ូនមុខ និងរូបចម្លាក់ ៧ធ្វើអំពីថ្មភក់
- ទួលកំណប់

www.elibraryofcambodia.org

- ទូលអំណែន
- ទូលដា ឬគោណែន ដែលគេបានរកឃើញចិញ្ចៀនមាសមួយវង់
- ជណ្តើរចាស់មួយនៃប្រាសាទខ្មែរ
- ដង់ខ្លួនរបស់ព្រះពុទ្ធមួយអង្គទ្រង់អង្គុយធ្វើអំពីថ្មភក់
- ទូល ដើមអំពិល, ទូលដើមទន្លាប់ និងរូបចម្លាក់មួយចំនួន
- វិហារតូចមួយធ្វើអំពីឥដ្ឋ
- កន្លែងមួយក្រាលដោយថ្មភ្នំ និងអាងទឹកពីរ
- ជម្រកមួយរបស់អុងតា និងព្រះកេសរបស់ព្រះពុទ្ធធ្វើអំពីលង្ហិន ។
- ទូលត្រាអុន
- មេទ្វារ សមួយមុនអង្គរធ្វើមិនទាន់ហើយ

(DWL ត្រូវអានថាទូល)

បើតាមលោក Malleret លោកបានធ្វើឲ្យឃើញច្បាស់ អំពីកេរដំណែលទាំងនេះថា ភ្នំនេះត្រូវបានរស់នៅចាប់តាំងពីសម័យយូរណាស់មកហើយ ។ រមណីយដ្ឋានទាំង ១៨ ដែលត្រូវបានធ្វើជំរឿន, ដែលនៅក្នុងនោះមានរមណីយដ្ឋានចំនួន ១៤ បានបង្ហាញឲ្យឃើញថា មានដង់ស៊ីតេខ្លាំង ។ ខាងលំនៅស្ថានរស់នៅរបស់មនុស្ស នៅជុំវិញភ្នំនេះ ក្នុងសម័យមុ. អង្គរ ។

"វាហាក់ដូចជាថា ក្រោយពីការបំផ្លាញទីក្រុង Oc-Eo ពួកអ្នកស្រុកនៅក្នុងតំបន់បានស្រាវជ្រាវដើម្បីតាំងទីលំនៅ ជាលើកដំបូងនៅតាមជម្រាលភ្នំ ដែលត្រូវបានស្ថិតនៅផុតពីទឹកជំនន់ ។ ប៉ុន្តែបាថេ ហាក់ដូចជាកន្លែងខ្ពស់មួយរបស់ប្រទេសកម្ពុជា ចាប់តាំងពីយូរណាស់មកហើយ ថាជាកន្លែងខ្ពស់របស់ប្រទេសកម្ពុជា។

**V. វាលអុក-ឯវ (Oc-Eo) និងឧបសម្ព័ន្ធរបស់វាលនេះ**

"Oc-Eo" កើតចេញពីការកែប្រែសំឡេងរបស់ពាក្យខ្មែរថា "អូកែវ"

www.elibraryofcambodia.org

"សំនួនវោហារ ដែលធ្វើឲ្យទៅជាភាសាវៀតណាម Oc-èv នោះ គឺថា យក តាមលំនាំនៃឋានទាមវិទ្យារបស់កម្ពុជានៅក្នុងស្រុកដែលនៅក្នុងនោះ លោក Pierre Bitard ស្នើឲ្យទទួលស្គាល់អក្ខរាវិរុទ្ធ អូរកែវ ដែលបានផ្តល់សំឡេងស្ទើរតែ ដូចគ្នានឹងពាក្យ អូកែវ នៅក្នុងការអាន ។ គឺថាជា "អូមានតម្លៃ" ជា អូរតនៈ ឬ អូ ត្រីស្តាល់ ។ តាមការពិតពាក្យថា (Ur) អូរ គឺចង្អុលបង្ហាញទៅលើព្រែក ព្រែកជីក- ព្រែកសិប្បនិម្មិត ដែលត្រូវបានជីកនៅមាត់ពាមនៃទឹកជ្រៅរបស់ទន្លេ ឬក៏របស់ សមុទ្រ ។ ការពន្យល់នេះ គេឃើញមានទឡ្ហីករណ៍ដ៏សំខាន់នៅក្នុងអត្ថិភាពនៃព្រែក ដីធំមួយហូរកាត់ទីក្រុង Oc-Eo និងតភ្ជាប់ទីក្រុងនេះទៅកាន់សមុទ្រ ។ ចំពោះព្រែក សិប្បនិម្មិតនេះអាចធ្វើឲ្យនាវាចូលបាន ហើយថា : ឋានទាមវិទ្យាកម្ពុជាហាក់ដូច ត្រូវបានរក្សាទុកដោយភាពស្មោះត្រង់នូវអនុស្សាវរីយ៍ ដោយប្រយោលទៅលើអតីត កំពង់ដែមួយ" ។

ម្យ៉ាងទៀតបុរាណវិទូ បានបន្ថែមថា អក្ខរាវិរុទ្ធ Oc-Eo ដែលបានផ្តល់ដោយអ្នក ស្រុកនោះ គឺខុសទេ ។ ប៉ុន្តែដោយសារពាក្យនេះត្រូវបានធ្វើឲ្យក្លាយទៅជាសាមញ្ញ តាមការសរសេរនោះ វាក៏បានថែរក្សានៅក្នុងការបោះពុម្ពផ្សាយរបស់ខ្លួន ។

**១) ផ្នែកទាំងអស់នៃវាល Oc-Eo**

គឺវាលដីធំទូលាយមួយ ដែលបានលាតសន្ធឹងនៅខាងកើតនៃភ្នំប្រាំពីរនៅចន្លោះ បាសាក់ និងឈូងសមុទ្រសៀម គឺ "បាថេ បានស្ថិតនៅកណ្តាល ហើយភាគច្រើននៃ ព្រែកចាស់ៗ ដែលបានបង្ហាញតាមការសង្កេតមើលលើយន្តហោះនោះ គឺសំដៅ ទៅរកទីក្រុង Oc-Eo ដែលលាក់ខ្លួន ឬក៏បានបែកខ្ញែកទៅទិសខាងកើត និងទិសខាង ត្បូងនៃភ្នំសំ" ។

រមណីយដ្ឋាន Oc-Eo និងតាកែវបានផ្គុំគ្នាដោយព្រែកជីកមួយ ។

**២) ទីក្រុង Oc-Eo និងផ្លូវទឹកចាស់នៃវាល Oc-Eo**

www.elibraryofcambodia.org

តាមការពិនិត្យ ទៅលើផ្លូវទឹកចាស់នៅតំបន់បាសាក់, គម្រោង XII ផែនការបូរាណវត្ថុវិទ្យា នៃដីសណ្តទន្លេមេគង្គ) ។

គេបានបង្ហាញច្បាស់ថា ទីក្រុង Oc-Eo មិនបានស្ថិតនៅតែឯងពីទឹកដីផ្សេងៗទៀតនៃប្រទេសកម្ពុជានោះទេ ។ ព្រែកជីកចាស់ដ៏វែងមួយចេញពីអង្គរបុរី ឆ្លងកាត់ស្ទឹងតាកែវ គឺព្រែកជីក វិញតេ ហូរសសៀរ តាមភ្នំច្រាំពីរ កាត់ព្រែក ម៉ាកកាន់ខុង ទៅព្រែកជីករ៉ាច់សូយ ។ ដូច្នេះទីក្រុង Oc-Eo មានទីតាំងអំណោយផលបំផុតសម្រាប់ការធ្វើគមនាគមន៍ និងធ្វើជំនួញ ។

"ទីតាំងនេះ បើកឲ្យទីក្រុង Oc-Eo នូវព្រំដែនសមុទ្រមួយ ហើយគេមិនចាំបាច់គូសបញ្ជាក់អំពីសារសំខាន់នោះទេ... ព្រោះវាបានធានាឲ្យទីក្រុងនេះទំនាក់ទំនងជាមួយបរទេសនូវអំណោយផលមួយផ្នែកពាណិជ្ជកម្ម"(បូរាណវត្ថុវិទ្យា..." ទំព័រ ២០០) ។

"នៅដំណាច់ឆ្នាំ ១៩៤២ ការទទួលស្គាល់នូវតំបន់ទាំងមូលបានធ្វើឲ្យខ្ញុំជឿជាក់ក្នុងខ្លួន (ទំព័រ ១០១) ថា គេបានស្ថិតនៅចំពោះមុខនៃទីក្រុងមួយដែលលាក់ខ្លួន និងដែលបានលាតសន្ធឹងនៅលើផ្ទៃដីដ៏ធំទូលាយ ។ ការផ្តុំឡើងវិញនូវរូបថតពីលើកប៉ាល់ហោះ ហើយមាត្រដ្ឋានធំ ដោយផ្នែកភូមិសាស្ត្រអាចឲ្យគេកំណត់បាននូវព្រំដែននៅលើដី និងចាន់ប្រមាណផ្ទៃក្រឡាបាន ។ ក្រុងនេះមានរាងចតុកោណកែងដ៏ធំមួយ មានទទឹង ១.៥០០ម បណ្តោយ ៣.០០០ម ដោយរួមទាំងបរិវេណ ៤៥០ហិកតាផង គឺមានទំហំស្មើនឹងពាក់កណ្តាលនៃអង្គរធំ" ។

ម្យ៉ាងទៀតគេអាចប្រៀបធៀបគំនូសនៃទីក្រុង Oc-Eo ទៅនឹងគំនូសអង្គរធំបាន ។ ពីព្រោះថានៅទីក្រុងមួយក៏ដូចជានៅទីក្រុងមួយទៀតដែរ ប្រព័ន្ធបញ្ចូលទឹកមានលក្ខណៈស្ទើរតែដូចគ្នា គំនិតនៃការកសាងទីក្រុងនៅលើគំនូសមួយដ៏ត្រឹមត្រូវដោយមានកន្លែងកណ្តាល និងបរិវេណរាងចតុកោណកែងស្មើ បានស្ថិតនៅស្ទើរតែគ្រប់ទីកន្លែង ។

www.elibraryofcambodia.org

"គំនិតនេះ ត្រូវបានបញ្ជាក់អះអាងនៅអង្គរធំ ជារដ្ឋធានីដ៏បុរាណតាំងនៅបារ័ងក៏ដូចជាទីក្រុងរបស់ព្រះបាទជ័យវរ្ម័នទី៧ គឺមានការបញ្ចូលនូវបរិវេណរាងការ៉េ ។ ម្យ៉ាងទៀត គេបានឃើញឧត្តមានុភាព នៃគម្រោងរេខាគណិតនៅក្នុងការបែងចែកកំពូលប្រាសាទ ផ្លូវទឹក និងបរិវេណ ។ ការពិនិត្យពិចារណាអំពីការតម្រង់ទិស បាន ដើរតួដ៏សំខាន់មួយ នៅលើទីតាំងនៃមណ្ឌលរស់នៅ ។ ទំនោរទាំងនេះ មានតាំងពីមុនយូរមកហើយ នៅក្នុងរេខាគណិតសាស្ត្រ Oc-Eo និងបានឆ្លើយតបទៅនឹងប្រពៃណីពីបុរាណមួយ" ។

ចំណែកផ្លូវទឹកចាស់ គឺលោក Pierre Paris ដែលបានចង្អុលបង្ហាញនៅឆ្នាំ ១៩៣១ អំពីអត្ថិភាពនៃព្រែកជីកដ៏សំខាន់មួយ ដែលមានជីល្បាប់ស្ទើរតែទាំងស្រុង នោះ បានតម្រង់ទិសទៅ Angkor Puri (*អង្គរបុរី*) ទៅរកបាថេ..." ។ នៅឆ្នាំ ១៩៤៦ លោក Malleret បានរកឃើញវិញ នូវព្រែកជីកនេះ "បានបន្តផ្លូវយ៉ាងឆ្ងាយទៅទិសអាគ្នេយ៍ បន្ទាប់ពីបានធ្វើដំណើរសសៀរតាមមុំនៃបរិវេណទីក្រុង Oc-Eo" ។ ក្រៅពីព្រែកជីកទាំង៥ ដែលដាក់លេខដោយលោក Pierre Paris នោះ លោកបានស្គាល់ ព្រែកជីកចំនួន ២៣ផ្សេងទៀត ដែលនៅក្នុងនោះផ្លូវទឹកបី បានបើកនៅក្នុងអំឡុងសម័យកាន់កាប់របស់បរទេសបានយកមកប្រើនូវផ្លូវទឹកចាស់ (*ទំព័រ ១១៨*) គឺម៉ាក់កាន់ខុង ព្រែកជីកវិញតេ ព្រែកឡុងស្វៀង-ៗរ៉ាច់យ៉ា ។ ព្រែកជីកធំ Oc-Eo បានបញ្ចេញ "ចាប់ពីទួលដែលហៅថា Go Oc-Eo ដែលត្រូវបានកត់សម្គាល់ថា ជាចំណុចកណ្តាលនៃទីក្រុងនោះ គឺជាសាខាមួយដែលលោក Malleret បានស្គាល់ដីនោះនៅក្រោមឈ្មោះថា Lung Lang ឬផ្លូវក្រាពី (*ផ្លូវក្របី*) (*ទំព័រ ១២០*) ។

គឺនៅកន្លែងនេះហើយដែល "Go Oc-Eo" ដែលប្រែជាជនកម្ពុជាហៅ "ទួល អូរកែវ" ដែលជាចំណុចខ្ពស់បំផុត នៃទីក្រុង អូរកែវ ឬ អុកឯវ ដែលការប្រើប្រាស់

www.elibraryofcambodia.org

បានឲ្យគេអះអាងថា Oc-Eo (ទំព័រ ២០៦) ។

៣) Lung Gieng Da និងរមណីយដ្ឋានតាកែវ

ឋានលេខា Oc-Eo បានបង្ហាញថា ទីក្រុងនេះបានដើរ នៅក្នុងអ័ក្សដីធំរបស់ខ្លួន តាមវាលទំនាបមួយត្រង់ទៅទិសឦសាន និងទិសនិរតី ដែលបានបន្តយ៉ាងឆ្ងាយទៅទៀតតម្រង់ទៅឈូងសមុទ្រសៀម ។ គឺ Lung Gien Da ឬ Antun Bhtak Kay ដែលត្រូវបានកាត់ផ្តាច់នៅចម្ងាយ ១៥គ.ម ពីត្រើយបច្ចុប្បន្ន នៅកន្លែងដែលហៅថា តាកែវ ។

គេបានរកឃើញបុរាណវត្ថុជាច្រើន (ទំព័រ ១០៣ទៅ១០៦) ។

VI. វាល XA NO

គឺតំបន់ដែលស្ថិតនៅខាងជើងនៃទន្លេ "Sông Cai bé" និងនៅខាងកើតនៃព្រែកជីកវ៉ាច់សួយ នៅបាសាក់រហូតដល់ជិត កិនថី និង Phung hiep (ហ្វុងហ៊ីប) ។ គឺបេះដូង (តំបន់បាសាក់ Trans bassac) បានប្រមូល "ដីទំនាបចាស់" ដែលប្រជាជនកម្ពុជាហៅថា វាលត្នោត ដែលទំនងជាបានកើតចេញនូវវាលដែលហៅថា XA NO ។

មានរមណីយដ្ឋានជាច្រើនត្រូវបានគេរកឃើញ ។

"មានស្លាកស្នាមមួយចំនួនស្តីពីប្រជាកិវឌ្ឍន៍ របស់ប្រជាជនកម្ពុជា ពីបុរាណបានស្ថិតនៅភាគខាងជើងនៅជុំវិញ O-môn និង Thôt nôt" (ត្នោត) និងនៅទិសខាងត្បូងនៅជិត Giong rieng នៅក្នុងចំណោមទេសភាពនៃសួនច្បារ" ។

VII. Giong **នៅស្រុកក្រាំង និងឆ្នេរនៃសមុទ្របិទ**

***ក) កំពង់ផែចាស់ បាសាក់***

រឿងព្រេងរបស់ស្រុកបាសាក់ដែលរាយការណ៍ដោយព្រះតេជគុណ ថាច់ ប៉ាង បាន កើតមាននៅមុនគ្រិស្តសករាជ ។

www.elibraryofcambodia.org

ប៉ុន្តែ ទើបតែមកដល់រជ្ជកាលរបស់ព្រះអង្គច័ន្ទទី១ ដែលស្រុកបាសាក់ត្រូវបាន រៀបចំឡើងវិញ ។ កាលពីដើម ស្រុកនេះ បានស្រូបយកនូវតំបន់ទាំងនេះទាំងអស់ ដែលចង្អុលបង្ហាញដោយលោក Malleret នៅក្រោមការ ការពារថា Trans-bassac ។ កាលពីមុន Trans bassac (តំបន់បាសាក់) ទាំងអស់បានយកឈ្មោះថា សុកទ្រាំង ដើម្បីធ្វើ ជាផ្នែកនៃខេត្តទ្រាំងរបស់កម្ពុជា" ។ យោងតាមព្រះអង្គ "ថាច់ ចាំង" សុកទ្រាំង គ្មានអ្វី ក្រៅពីស្រុកឃ្លាំងរបស់កម្ពុជានោះឡើយ ។

"ទឹកដីស្រុកទ្រាំង គឺជាអតីត Sruk Ghlama (ស្រុកគឺជាជង្រុកស្រូវ) ជាទឹកដី ដែលប្រជាជនកម្ពុជាបានប្រើប្រាស់នៅឡើយ នៅមួយផ្នែកធំនៃ Trans bassac និង បានលាតសន្ធឹង នៅលើទេសភូមិមួយ ដែលរីកចម្រើន និងត្រូវបានគេធ្វើ អាណានិគមអស់ពេលយ៉ាងយូរ ។ គឺដែនដីខាងក្នុងនៃកំពង់ផែចាស់ចាំសាក់ (បាសាក់ វៀតណាម ហៅថា ចាំសាក់) ដែលបានបែងនៅក្នុងកាលប្រវត្តិរបស់ កម្ពុជា... ។ នៅដំណាច់សតវត្សរ៍ទី១៨ បើតាមឃ្លាសរសេររបស់ Père Levavasseur បានឲ្យដឹងថា ទីក្រុងនេះនៅតែជា "កំពង់ផែសមុទ្ររបស់កម្ពុជានៅ ឡើយ" ដែលសាសនទូតបានចូលមកបតនៅ..." (ទំព័រ ១៣៩) ។

បើតាមព្រះតេជគុណ "ថាច់ ចាំង" បានឲ្យដឹងថា តំបន់ Trans bassac ទាំង អស់នេះត្រូវបានបែងចែកជាច្រើនខេត្តនៅក្រោមរជ្ជកាលរបស់ពញាតាត ។ ព្រះអង្គពញាតាតបានឲ្យទាហានរបស់ព្រះអង្គកសាងនូវជង្រុកស្រូវមួយសំដៅផ្គត់ ផ្គង់ដល់អ្នកស្រុក នៅស្រុកទ្រាំងក្នុងករណីមានការរាំងស្ងួត, ឬគ្រោះទុរ្ភិក្ស ដែល បេញពីនោះហើយ ទើបបានកើតចេញជាពាក្យទី២ ដែលហៅថា "ឃ្លាំង" ។

បុរាណវត្ថុវិទ្យា នៅដែនដីសណ្តទន្លេមេគង្គ ដកស្រង់ពីសៀវភៅកត់ហេតុការណ៍ របស់លោក M. Levavasseur សាសនទូត ខាងផ្សាយគំនិតថ្មី (សៀវភៅកត់ ហេតុការណ៍របស់ M. levavasseur នៅក្នុង Adrien Launay ប្រវត្តិសាស្ត្រនៃ

www.elibraryofcambodia.org

បេសកកម្មកូសាំងស៊ីន ។ ឯកសារប្រវត្តិសាស្ត្រ II 1728-1771 ក្រុងប៉ារីសឆ្នាំ ១៩២៤ ទំព័រ ៣៨៨-៣៨៩ ។ សៀវភៅកត់ហេតុការណ៍បានរាយការណ៍នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៧៦៨ ថា "ការគ្រប់គ្រងកំពង់ផែគឺ កម្ពុជា" ។

"ទីក្រុងនេះ អាចមានបណ្តោយ ២គ.ម និងទទឹង ១០០ជំហាន... ។ បាសាក់បានបើកចំហរទៅគ្រប់ជ្រុង ដែលធ្វើឲ្យខ្ញុំជឿថា ព្រៃនេះពុំមានខ្លា និងពុំមានដំរីឡើយ ប្រហែលជាដោយសារទឹកដីនេះមានលក្ខណៈទាបបំផុតដែលអំណោយផលដល់ទឹកជំនន់ និងពេញដោយដីល្បប់" ។ ("បូរាណវត្ថុវិទ្យា..." ទំព័រ ១៣៩-១៤០) ។

ក្រោយពីបានរៀបរាប់ថា គាត់បានឃើញអ្នកស្រុកចិននោះ (សាសនទូតនេះបាន) បញ្ជាក់យ៉ាងច្បាស់ថា "រដ្ឋាភិបាលគឺ កម្ពុជា" ។

តាមលោក Malleret បានឲ្យដឹងថា សុកត្រាំង ឬស្រុកទ្រាំង គឺជាកន្លែងប្រមូលផ្តុំផ្នែករដ្ឋបាលជាយូរមកហើយ ក្បែរពីបាសាក់ ។ ចំណែក "ឃ្លាំង" គឺជាលំនៅដ្ឋានរបស់ចៅហ្វាយខេត្តបាសាក់ ។

**៣) សារសំខាន់នៃ កំពង់ផែ បាសាក់**

ប្រសិនបើគេជឿតាមលោក Doudart de Lagrée គឺថា "បាសាក់គឺជាកំពង់ផែ ដែលមានសារសំខាន់ដ៏ធំធេង ទទួលស្គាល់ដោយជនជាតិ ពែរ្ស អេហ្ស៊ីប អារ៉ាប់ ប្រជាជន Phéniciens ហើយប្រជាជនចិន កូសាំងស៊ីន ជប៉ុន ម៉ាឡេ Pegouans និងឥណ្ឌាក៏ទៅមកជាញឹកញាប់ដែរ ។ ហើយយូរក្រោយមកទៀត មានប្រជាជន Gênois Venitiens ព័រទុយហ្គេ និងហូល្លង់" ។ (បូរាណវត្ថុវិទ្យា... ទំព័រ ១៤២) ។ ប៉ុន្តែ "ប្រសិនបើកំពង់ផែមួយរបស់តំបន់ទាំងនេះ អាចមានទំនាក់ទំនងជាមួយលោកខាងលិចនេះ គឺច្បាស់ជាមិនមែនកំពង់ផែបាសាក់នោះទេ" ។ គឺប្រហែលជា "Kamban Dhom (កំពង់ធំ) ដែលបច្ចុប្បន្ននេះក្លាយទៅជាដីទាំងអស់នោះ" ។ នៅក្នុងផែនទីបូរាណវត្ថុវិទ្យា (PLX) កំពង់ផែ កំពង់ធំ នេះ បានស្ថិតនៅភាគជើងនៃ

www.elibraryofcambodia.org

ទីក្រុងសុកត្រាំងនៅចន្លោះទន្លេបាសាក់ និង គាន់ឡូង ។

គេបានកត់សម្គាល់ថា បាសាក់អាចចូលទៅដល់ព្រមគ្នាដោយផ្ទាល់តាមសមុទ្រ ឬក៏តាមទន្លេគឺវាតាម" Bam Mê Càn និង Bàm Mê Sên" និងថាទីតាំងរបស់វាប្រហែលជាស្ថិតនៅ Bài Xau ។ មាត់ពាមទាំងពីរនេះ " Bàm Mê Càn និង Bàm Mê Chan" (Péam Mê Cên និង Péam Mê Sên) (N. 2 "បុរាណ វត្ថុវិទ្យា..." ទំព័រ ១៤២) បើតាមប្រពៃណីបានយកឈ្មោះមហេសីទាំងពីររបស់ព្រះមហាក្សត្រនៃប្រទេសកម្ពុជាមួយអង្គ ដែលត្រូវបានគេធ្វើគតនៅកន្លែងទាំងពីរ នេះ ( Son Diêp រឿងព្រេងរបស់ប្រទេសបាសាក់ កូសាំងស៊ីន "នៅក្នុងសមាជ អន្តរជាតិលើកទី២ នៃការសិក្សានៅចុងបូពាំប្រទេស, ហាណូយ ១៩០៣ ទំព័រ ៨១-៨២) ។ ចំណែកនៅ Bài-Xàu (បាយឆៅ), Son Diêp ដដែលនេះបានរាយការណ៍អំពីរឿងព្រេងដូចតទៅនេះ គាត់បានពន្យល់ថា "អំពីឈ្មោះនេះគឺ:

"ជារឿងរបស់សត្វក្រពើមួយក្បាល កំពុងត្រាំងនៅក្រោមដី ត្រូវបានឆាឆៅនៅក្នុងការស្មឹងស្មាធរបស់ខ្លួន ដោយសារកំដៅនៃចង្ក្រានដែលពួកអ្នកកាប់អុសបានដុតនៅលើដីបូកមួយ ដើម្បីរៀបចំបាយទឹករបស់ពួកគេ ។ សត្វក្រពើបានធ្វើឲ្យឆ្នាំងបាយដួលរលំនៅមុនពេលដែលបាយឆ្អិន ។ ហើយដើម្បីឧទ្ទិសដល់ហេតុដ៏អស្ចារ្យនេះហើយ ទើបបានជាកន្លែងនេះ ត្រូវបានគេជ្រើសរើសដើម្បីកសាងនូវបដិមាររបស់អាទិទេពបាសាក់" (កំណត់ ២ ទំព័រ ១៤២) ។

**៤) កេរដំណែលខ្មែរ នៅក្នុងស្រុកឃ្លាំង**

នៅក្នុងសុកត្រាំង មានវត្តកម្ពុជាចំនួន ៥៦ ។ លោក Malleret បានសរសេរ- ថា "យើងបានឲ្យគេធ្វើការស៊ើបអង្កេតដ៏មំត់ចត់មួយទៅលើវត្តកម្ពុជាទាំង ៥៦ នៅក្នុងខេត្តនេះ ដោយមានការចូលរួមពីព្រះសង្ឃដែលបាននិមន្តមកជួបជុំគ្នានៅក្នុងឱកាសនៃការធ្វើកម្មសិក្សាផ្នែកគរុកោសល្យនៅសុកត្រាំង" ។ កេរដំណែលទាំង

www.elibraryofcambodia.org

នេះ "ស្ទើរតែត្រូវបានប្រមូលផ្តុំទាំងអស់នៅ Giông"។

**ក) Giông មហាទប់**

កំណត់ ២ (ទំព័រ ១៤៣) បានបញ្ជាក់ថា ការស៊ើបអង្កេតនៅកន្លែងនេះ ត្រូវបានដឹកនាំធ្វើជាមួយការសហប្រតិបត្តិការណ៍របស់លោក ឡាំ ស៊ិ សូមុត កូនប្រុសរបស់លោក ឡាំ ឯម (និយាយនៅក្នុងកថាខណ្ឌ "របបដែលអនុវត្តន៍នៅខ្មែរក្រោមនៅក្រោមការកាន់កាប់របស់បារាំង) អតីតប្រតិភូរដ្ឋបាលរបស់ទីរួមខេត្តសុខ ត្រាំង។

**ការស៊ើបអង្កេតនេះ អនុញ្ញាតឲ្យគេរកឃើញ :**

- វត្តមហាទប់ ជាមួយនឹងបរិវេណរបស់ខ្លួន ខ្ទមរបស់អ្នកតាមួយ និងរូបចម្លាក់ចំនួន ៧ ។

- នៅកន្លែងដែលហៅថា អ្នកតា "តាមាក់" រូបបដិមាស្រីដ៏តូចមួយត្រូវបានប្រគល់ទៅឲ្យអ្នកយាមនៅគេហដ្ឋានរបស់សមាគមកម្ពុជា នៅសុកត្រាំង" ។

**ខ) Giông សុកត្រាំង**

"ញ្ញញខ្សាច់ដ៏វែងនេះ ដែលនៅក្នុងនោះ ត្រូវបានបង្កើតឡើងដោយការប្រមូលផ្តុំបច្ចុប្បន្ននៃសុកត្រាំង ឬ ស្រុកខ្លាម (ស្រុកខ្លាន) ហើយដែលផ្លូវថ្នល់ Dai ngai បានរត់ទៅចាក់លើវនោះ ត្រូវបានបង្ហាញឲ្យឃើញ ថា សម្បូរទៅដោយកេរដំណែលបូរាណវត្ថុ" គឺ

- រូបចម្លាក់ពីរនៅជិតគេហដ្ឋាន Huynh loi ។

- រូបចម្លាក់បី នៅក្នុងខ្ទមរបស់អ្នកតានៅទិសហ្លួសាននៃ វត្តសង្កែ ។ នៅខាងក្នុងព្រះវិហារគេឃើញរូបបដិមាអាទិទេពស្រីមួយអង្គ ធ្វើអំពីថ្មភក់ដែលតំណាងឲ្យព្រះ នាងលក្សី ប៉ុន្តែត្រូវបានគោរពនៅក្រោមព្រះនាមថា "ណាងខ្មៅ" ។

- នៅកន្លែងដែលហៅថា អ្នកតា "Joen Palàn" (ជើងបល្ល័ង្ក) មានជើងទម្រូរបចម្លាក់ ៣ដុំ និងលិង្គធ្វើអំពីថ្មភក់មួយ ។

www.elibraryofcambodia.org

– នៅវត្ត Ghlàmn ជាវត្តដ៏សំខាន់នៅទីរួមខេត្ត (វត្តឃ្លាំង) ស្ថិតនៅខាងជើងនៃទីក្រុងសុកត្រាំង មានរូបចម្លាក់៤ ដែលត្រូវបានប្រមូលផ្តុំនៅក្នុងវិហារដ៏តូចមួយ។

– មានរូបអាទិទេពរបស់ខ្មែរពីរនៅក្នុងវត្តដែលហៅថា " វត្តអុងបុទ" ។

– នៅវត្ត "ព្រែកអណ្តើក" "មានផ្ទាំងដ៏ធំមួយរាងដូចផ្លែពីរ ធ្វើអំពីដីដុត មានពណ៌ត្នោតដែលជាគំរូដ៏ល្អមួយនៃកុលាលភាជន៍ (ក្អម, ផ្ទាំងធ្វើអំពីដី) ពីបុរាណរបស់កម្ពុជាដែលត្រូវ បានបញ្ចូលទៅក្នុងសារមន្ទីរ នៃទីក្រុង សាយហ្គន" ។

**គ) Giông Joen Pau**

ស្ថិតនៅភាគខាងលិចនៃទីក្រុងសុកត្រាំង "Giông Joen Pau (ជើងពោធិ៍) នៅទិសខាងជើង វាមានអ្នកស្រុកដែលមានឈ្មោះថា Joen Palan" (ជើងបល្ល័ង្ក) ។

**គេបានរកឃើញ :**

– នៅអ្នកតាជើងពោធិ៍ ឬជើងបល្ល័ង្ក នូវរូបដិមាប្រុសដ៏តូចមួយធ្វើអំពីថ្មភក់គ្មានក្បាលគ្មានដៃ និងរូបចម្លាក់មួយចំនួនស្ថិតនៅលើទួលមួយ ។

– នៅកន្លែងប្រសប់មុខដែលហៅថា "ក្បាលថ្នល់" នៅក្នុងខ្ទមអ្នកតាចាស់មួយមាន "រូបព្រះនរាយណ៍" មួយ ។

– នៅអ្នកតា "ដនឯក" មានរូបចម្លាក់ ៩ ។

**ឃ) Giông Phu Nô** (ផ្កោរ) < ផ្នូក < ក្នុកខ្សាច់

"ព្រៃញនៃខ្សាច់នេះ បានធ្វើដំណើរតាមផ្លូវសុកត្រាំងទៅ (ខ្សាច់) (Kê sach)" ។ គឺនៅក្នុងតំបន់នេះហើយ "ដែលប្រពៃណីយ៍បានរៀបរាប់អំពីកំពង់ដែចាស់មួយហៅថា Kamban Dham (កំពង់ធំ)" ។ គេបានរកឃើញចំណុច ៤នៃបុរាណវិទ្យា

–នៅវត្ត (តាមព្រះតេជគុណ ថាច់ ចាំង គឺ "វត្តបួនព្រះភ័ក្ត")(វត្តព្រះបួនមុខ) ដែលត្រូវបាន"គេរៀបចំទុកចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ប្រាសាទខ្មែរនៅក្រោមលេខ ៩០៧ Bis" មាននៅក្នុងការបង្ហាញនូវប្រាសាទ (Prasad) ដ៏តូចមួយដែល

www.elibraryofcambodia.org

មានជាន់ថយចុះ ។

-"បើតាមប្រពៃណីយ៍ដែលប្រមូលបានដោយលោក ត្រឹង ក្វាង់ទ៊ឹង (ព្រះតេជគុណ ថាច់ ប៉ាង់ បានរាយការណ៍ថា កន្លែងនេះ គឺជាកម្មវត្ថុនៃបំណង់ជើងពីមុន) ជាស្រុកចាស់នៅក្រោមការត្រួតត្រារបស់ សុកត្រាំង ។ រូបចម្លាក់នេះ ត្រូវបាននាំមកពីប្រទេសស្រីលង្កា នៅក្នុងពេលវិលត្រឡប់របស់ឯកអគ្គរដ្ឋទូតដែលត្រូវបានបញ្ជូន ទៅកាន់ប្រទេសនេះនៅក្នុងឆ្នាំ ១៤៣១ នៃគ្រិស្តសករាជដោយព្រះញាតិវង្សខ្មែរមួយអង្គព្រះនាម ព្រះរាម ។ ដូច្នេះ សំពៅដែលបានដឹកគង់មួយ និងរូបបដិមាពីររបស់ Sambau Dhlay (សំពៅធ្លាយ)... ត្រូវបានពន្លិចនៅក្នុងតំបន់, ជាសម័យមួយដែលសមុទ្របានបួលទៅដល់ Giông Phu Nô (ផ្នោរ) ។ ដោយប្រមូលបានជាមួយនឹងអ្នកដំណើរមួយចំនួន និងមួយផ្នែកនៃនាវាភ័ណ្ឌ រូបចម្លាក់ទាំងនេះ ត្រូវបានរិបអូសដោយពួកសៀម នៅក្នុងអំឡុងពេលនៃការលុកលុយឆ្នេរសមុទ្រខាងត្បូង របស់ប្រទេសកម្ពុជាឆ្នាំ ១៥២២ ។ ពួកសៀមបានសម្រេចនាំយករូបចម្លាក់ទាំងនេះទៅស្រុករបស់ខ្លួន ប៉ុន្តែរូបចម្លាក់ទាំងនេះ ត្រូវបានជួយសង្គ្រោះដោយអព្ភូតហេតុរបស់ដីរីចេញមកពីក្នុងព្រៃ..."។

ប៉ុន្តែ បើតាមប្រពៃណីយ៍មួយទៀត "ដែលរៀបរាប់ដោយលោក ស៊ីន ឡៀបអតីតរដ្ឋមន្ត្រីកម្ពុជា ។ រូបចម្លាក់ដែលមានមុខ ៤ ត្រូវបានកសាងឡើងដោយ ព្រះមហាក្សត្រ ព្រះបាទ Pudum Suryavong (បទុមសុរិយាវង្ស) ដែលទាក់ព្រះទ្វយដោយរមណីយដ្ឋាន Giông ហើយដែលបានលេចចេញពីសមុទ្រនៅពេលថ្មីៗនេះ ទើបព្រះអង្គបានឲ្យគេកសាងនូវវត្តនេះ (ទំព័រ ១៥២) ។

នៅប្រទេសកម្ពុជាប្រភេទនៃប្រាសាទដែលមានព្រះពុទ្ធព្រះភ័ក្ត្រ ៤ "ដូចគ្នានេះបានស្ថិតនៅរាយប៉ាយ ហើយរូបចម្លាក់មួយចំនួនដែលមានទំហំដីធំក្រៃលែងបែបនេះ ត្រូវបានធ្វើការសិក្សាដោយលោក Louis Finot" ។ ចំណែកឈ្មោះ "សំពៅ

www.elibraryofcambodia.org

ផ្លាយ" បានស្ថិតនៅក្រោមការបង្កុលបង្ហាញដូចគ្នានៅ "ភ្នំគូលេន" ដែលត្រូវបានបញ្ចូលទៅក្នុងប្រពៃណី នៃការលិចទូកមួយ ហើយឋាននាមវិទ្យា "ក្បាលសំពៅ និងកន្ទៃសំពៅ" បានស្ថិតនៅ Giông da នៅ Trans bassac (កំណត់សម្គាល់ ២ និង ៣ ទំព័រ ១៥២)។

– នៅក្បែរវត្តព្រះបួន ព្រះភ័ក្ត្រ គេបានជួបអ្នកតាមួយឈ្មោះ "អ្នកតាសំពៅផ្លាយ" ជាមួយនឹងវិហារដ៏តូចមួយធ្វើអំពីឥដ្ឋ និងរូបចម្លាក់មួយចំនួន ។

– គេបានឃើញនៅទិសឦសាននៃ សំពៅផ្លាយ នូវអាងទឹករាងចតុកោណកែងពីរ គឺស្រះស្រី និងស្រះប្រុស ។ គេបានរកឃើញនៅក្នុងស្រះមួយនោះ នូវបំណែកមួយដែលដូចគ្នានឹងមុខនៃបដិមា ភេទប្រុសមួយ និងរូបព្រះនរាយណ៍ មួយដោយមានព្រះទ័យទន់ទេញ" ។ ស្រះទាំងពីរ និងរូបបដិមាទាំងពីរនេះត្រូវបានបញ្ចូលទៅក្នុងប្រពៃណីក្នុងស្រុកដែលស្ទើរតែដូចគ្នា និង "ភ្នំស្រី ភ្នំប្រុស" នៅជិតខេត្តកំពង់ចាម។

"ស្រះមួយនោះដែលមានវិជ្ជមាត្រធំ ដែលហៅថា ស្រះស្រី ត្រូវបានប្រគល់ឲ្យស្រីៗជីក និងស្ថិតនៅពីមុខវិហារនៃរូបបដិមាស្រី ។ ស្រះមួយទៀតដែលមានទំហំតូចច្រើនជាង ហើយមកដល់សព្វថ្ងៃនេះ ត្រូវបានលុបទាំងស្រុងហើយនោះ ហៅថាស្រះប្រុស ដែលត្រូវបានជីកដោយមនុស្សប្រុស និងលាតសន្ធឹងនៅពីមុខវិហារនៃរូបបដិមាប្រុស ។ ការជីកស្រះទាំងពីរនេះ ដែលស្ថិតនៅសងខាងផ្លូវពី Kê sach (ខ្សាច់) ទៅសុកត្រាំង ។ គឺជាលទ្ធផលនៃការភ្នាល់គ្នាមួយដែលយុវនារី ។ បានដាក់ជាមួយយុវបុរសទៅតាមទំនៀមទម្លាប់ពីបុរាណ ដែលទាក់ទងទៅនឹងការស្តីដណ្តឹងកូនគេ ។ រឿងនិទាននេះមានទំនោរចាត់ទុកដូចគោលការណ៍មួយដែលថា "ស្រីមានឧត្តមភាពជាងបុរស" និងទាក់ទងទៅនឹងអ្នកដែលរស់រានមានជីវិតដទៃទៀតដែលប្រហែលជា ការចាត់ចែងតាមបែបមាតុយ្យការ (របបដែលនិយមយកមាតាជាធំ) ពីបុរាណដែលមាននៅពាសពេញកូសាំងស៊ីន និងនៅកម្ពុជា" ។ (លោក L.

www.elibraryofcambodia.org

Malleret "ប្រពៃណីនៃរឿងព្រេងរបស់ប្រជាជន កម្ពុជានៅកូសាំងស៊ីន ។" in BIIEH 1931, IV ភាគ ១-២ ទំព័រ ១៦៩-១៨០ "បូរាណវត្ថុវិទ្យា." ទំព័រ ១៥៤)។

– នៅវត្ត "Bamn Samret" វត្តដែលស្ថិតនៅតាមផ្លូវថ្នល់ពីសុកត្រាំងទៅកិនថី គេបានប្រមូលទុកនូវវត្ថុពីបូរាណដ៏សំខាន់ដែលធ្វើអំពីសំរិទ្ធិ ដីដុត វត្ថុធ្វើអំពីហៃយ៉ង់ ព័រសឺឡែន និងកុម្ភការភ័ណ្ឌខ្មែរ ។

នៅកន្លែងនេះ ("បូរាណវត្ថុវិទ្យា..." ទំព័រ ១៥៥) គេឃើញមានជើងមួយរាងជាសត្វដំរី ត្រូវបានប្រគល់ឲ្យសារមន្ទីរនៅសាយហ្គននៅក្នុងឆ្នាំ ១៩៣៣ ដោយលោក ឡាំ ឯម ។ ពេលនោះ លោកជាប្រតិភូមិរដ្ឋបាលនៃទីរួមខេត្ត សុកត្រាំង (BEFEO, XXXIII ទំព័រ១១០៦) ។

ដូចយើងបាននិយាយរួចមកហើយថា នៅក្រោមការកាន់កាប់របស់បារាំង វត្ត-មានរបស់ប្រតិភូរដ្ឋបាលកម្ពុជានេះ បានបង្ហាញឲ្យឃើញច្បាស់នូវការទទួលស្គាល់ឡើងវិញដោយ អាជ្ញាធរអាណាព្យាបាល នូវអធិបតេយ្យភាពខ្មែរ នៅលើកូសាំងស៊ីន ។ នៅជាន់ខាងលើនៃសាលាវត្ត "Bamn Samret" (Peang Samret) គេឃើញមានពាងដ៏ធំមួយដែលផ្នែកខាងលើរហូតដល់មាត់របស់វា គឺធ្វើអំពីសំរិទ្ធិ និងពោះរបស់វាធ្វើអំពីដីដុត" ។ វត្ថុនេះគេឲ្យឈ្មោះថា ពាងសំរិទ្ធិនៅក្នុងវត្ត។

លោក Malleret បានរាយការណ៍អំពីប្រពៃណីយដូចតទៅនេះ ("បូរាណវត្ថុវិទ្យា..." ទំព័រ ១៥៦ "ឯកលេខនា (Monographie) សរសេរដោយដៃនៅខេត្តសុកត្រាំង ទំព័រ ៤២-៤៣ ស៊ីនឡៀប "រឿងព្រេងនៃប្រទេសបាសាក់ កូសាំងស៊ីន ដោយ ស៊ីនឡៀប នៅក្នុងសេចក្តីរាយការណ៍របស់សមាជជាតិលើកទី១ ស្តីពីការសិក្សានៅចុងបូព៌ាប្រទេសហាណូយ ១៩០៣, ទំព័រ ៨១)

"បើតាមប្រពៃណីក្នុងស្រុក ព្រះមហាក្សត្រអង្គរ មួយអង្គបានឲ្យគេកសាងនូវក្នុងខេត្ត ៤ដ៏សំខាន់គឺខេត្ត បាទី បារាយ បាភ្នំ និងបាសាក់ នូវរូបបដិមារបស់ព្រះពុទ្ធ។

www.elibraryofcambodia.org

នៅចាសាក់ គេបានកសាងនៅលើ Giông Phu Nô នៅក្នុងតំបន់ដែលឥឡូវនេះ គេឃើញមានវត្ត Bamn Samret ។ រូបបដិមាទាំងនេះ ត្រូវបានលួចយកដោយពួកសៀម ក្រោយពីបានកាន់កាប់លង្វែកនៅឆ្នាំ ១៥៩៣ នៃគ្រិស្តសករាជ ។ ហើយរូបបដិមាទាំងនេះត្រូវបាននាំយកទៅក្រុងអយុធ្យា ។ នៅក្នុងពេលជាមួយគ្នានេះដែរ ពួកអ្នកលុកលុយបានដណ្ដើមយករូបបដិមាដ៏ធំមួយដែលទ្រង់ឈរ, នៅលើ Giông មួយដែលស្ថិតនៅភាគខាងត្បូងនៃ Bai Xau (បាយឆៅ) បាស់ ក៏ដូចជាគាវរូប ពីរទៀត ដែលហៅថា "ព្រះគោព្រះកែវ" ។ រូបទី១ តំណាងឲ្យព្រះ Ind (Indra) និង ធ្វើអំពីកែវ ។ គាវរូបទី២ គឺជារូបគោដ៏ធំមួយ ដែលនៅក្នុងពោះរបស់គោនេះ មាន "សៀវភៅទិព្វក៏ដូចជាអក្សរចង្អុលបង្ហាញនូវទីកន្លែងពិតប្រាកដស្ដីពីការលាក់កំណប់នៅក្នុងកន្លែងផ្សេងៗ នៅក្នុងព្រះរាជាណាចក្រខ្មែរ ។ មានពាងចំនួន ៣៦ ដែលមានដាក់វត្ថុធ្វើអំពីមាស និងអំពីប្រាក់ពេញនោះ, ត្រូវបានចោរសៀមយកទៅអស់ ។ គេបានបន្ថែមថា ពាងទាំងនោះត្រូវបានគេកប់នៅក្រោមដើមពោធិដ៏ធំមួយដើមនៅ Giông នៃសុកត្រាំង, នៅក្បែរតេស៊ុម ស្ថិតនៅចម្ងាយ ៦គ.មពីទីរួម ខេត្តនៅតាមផ្លូវទៅបាក់លីវ ។ បំណែកដែលត្រូវបានរក្សាទុកនៅក្នុងវត្ត គឺជារបស់មួយនៅក្នុងចំណោមរបស់ទាំងនេះ" ។

តាមលោក Malleret បានឲ្យដឹងថា រូបចម្លាក់នៅតំបន់សុកត្រាំងបានបង្ហាញនូវលក្ខណៈដូចគ្នាបង្គួរ ដោយមានលក្ខណៈ (ស្ទីល) អាចឲ្យគេភ្ជាប់ជាសម្ព័ន្ធនៃរូបបដិមាខ្មែរនៅសតវត្សរ៍ទី១១ ។ មានរូបបដិមាមុនសម័យអង្គរតែមួយគត់ ដែលត្រូវបានរកឃើញ ។ លោក Malleret បានបន្ថែមថា សិល្បៈអង្គរ ត្រូវបានគេយកលំនាំតាមយ៉ាងសម្បូរ ។ ហើយវាហាក់ដូចជាថា នៅពេលមើលដំបូងគេឃើញថាទឹកដីសុកត្រាំង ត្រូវបានថែរក្សានូវទំនាក់ទំនងដ៏ជិតស្និទ ជាមួយរដ្ឋធានីនៅក្នុងសតវត្សរ៍ទី១១ និងសតវត្សរ៍ទី១២ ដែលត្រូវបានសំដែងចេញនៅក្នុងរូបមន្តនៃការ

www.elibraryofcambodia.org

ច្នៃនិពន្ធដែលមានអត្ថន័យយ៉ាងច្បាស់លាស់ ។

ប្រាសាទទាំងនេះ ជាការសំដែងចេញនូវសិល្បៈខ្មែរ នៅសតវត្សរ៍ទី១១ និង សតវត្សរ៍ទី១២ នោះ, គឺជាស្នាដៃរបស់ព្រះ "បទុម សូរិយាវង្ស" ដែលអាចជា ព្រះបាទសូរិយាវរ្ម័នទី១ ។

**ង) ប្រាសាទត្រាឡុង**

"បាក់លីវ និងកាម៉ៅ ជាដាច់ខាតមិនមែនជាការបង្កើតថ្មី ដូចដែលគេជឿនោះទេ ។ កន្លែងទី១ គឺជាអតីត Bo Lyer (Pô Lieu) ។ កន្លែងទី២ គឺ Kik Khmau (Tuk Khmau) របស់កម្ពុជា ។ ប្រសិនបើកន្លែងទី១ គឺជាការរំលឹកដល់ "ដើមពោធិព្រឹក្ស" មួយដើម, នោះ កន្លែងទី២ បានចង្អុលបង្ហាញអំពី "ទឹកខ្មៅ" ជាឋាននាមវិទ្យា ដែលទាក់ទងជាមួយនឹងហេតុការណ៍ភូមិសាស្ត្រដែលមានជាញឹកញាប់ នៅក្នុងផ្នែកនៃដែនដីសណ្តនេះ ។ គឺជាលទ្ធផលនៃការរលួយរបស់រុក្ខជាតិជាមួយនឹងបាតុភូត នៃភាពនឹងថ្កល់ នៅក្នុងតំបន់ដែលគ្មានការហូរចេញ ឬហូរចូលនៅលើទឹកដីទាំងឡាយដែលនៅក្នុងនោះ អសាធារណនាម វៀតណាម បានប្រើពាក្យ U-minh"។

"ប្រាសាទខ្មែរដ៏ចាស់មួយសង់អំពីឥដ្ឋ កំត្រូវបានរកឃើញដោយលោក Malleret ដែរ ។

**ច) ជ្រោយកាម៉ៅ**

នៅក្នុងផ្នែកនេះ លោក Malleret បានផ្តល់ដល់យើងនូវការពន្យល់លម្អិតស្តីពីការបង្កើតភូមិសាស្ត្រនៅជ្រោយកាម៉ៅ ។ ចំពោះកំណើតដើមរបស់វា គឺមានកាលបរិច្ឆេទនៅក្នុងសម័យ ព្រះបាទសូរិយាវរ្ម័នទី II (ព្រះបទុមសូរិយាវង្ស) ។ លោក ឈុំ ឈៀក (ជុំជាតិ?) (កាសែត "La Dépêche du Cambodge លេខចេញផ្សាយថ្ងៃទី១៩ ខែធ្នូ ១៩៦២), បានសង្កត់ទៅលើសៀវភៅសរសេរដៃរបស់ព្រះតេជគុណ ថាច់ ប៉ាង ដែលបានពន្យល់ដូចតទៅនេះ ស្តីអំពីការបង្កើតនូវបន្ទាយ

www.elibraryofcambodia.org

ចំនួនបួន (១.ពាម, ២.ពាមទន្លេចាសាក់, ៣.ពាមទន្លេមេគង្គ, ៤.ព្រៃបុរីនៅបារៀ បច្ចុប្បន្ន នៅមាត់ ពាមដូនណៃ បច្ចុប្បន្ន គឺអូកាប់ ឬកាបសេសាក់) និងការតាំងទីលំនៅ របស់ប្រជាជនកម្ពុជានៅជ្រោយកាម៉ៅ)

ព្រះមហាក្សត្រ សូរិយាវង្សទី២ បានចាត់តាំងឲ្យពញាតេជោ ទៅស្រុកចាសាក់ ដើម្បីបំពេញបេសកកម្មត្រួតត្រា ឆ្នេរសមុទ្រខាងត្បូង ។

ពញា តេជោ បានប្រមូលអ្នកស្រុកនៅជ្រោយកាម៉ៅ នៅកន្លែងដែលព្រះអង្គម្ចាស់ខ្មែរមួយអង្គ និងព្រះអង្គម្ចាស់ក្សត្រិយ លាវ បានបង្កើតនូវរាជធានីរបស់ព្រះអង្គនោះ ។ ព្រះអង្គបានប្រទានឈ្មោះថា ជា"ជ្រោយខ្មែរ" នៅតំបន់នោះ ។

ពាក្យជ្រោយខ្មែរនេះ បានក្លាយទៅជា "ច្រុងខ្មែរ" ។ ការបកប្រែនេះ ហាក់ដូចជាត្រឹមត្រូវណាស់ ពីព្រោះថា ប្រជាជនអឺរ៉ុបដំបូង គឺប្រជាជនព័រទុយហ្គេ និងហូល្លង់ បានចង្អុលបង្ហាញជ្រោយនេះ នៅក្នុងផែនទីរបស់ពួកគេនៅក្រោមឈ្មោះថា "ជ្រោយ Cambodia"ឬជ្រោយកម្ពុជា ដែលគេអាចបកប្រែដោយឥតល្អៀងថា "ជ្រោយខ្មែរ"។

## VIII. វាលបក្សី

នៅក្នុងវាលនេះ ដែលបានលាតសន្ធឹងទៅក្នុងខេត្តចាក់លីវ និងខេត្តរ៉ាច់យ៉ា គេឃើញរមណីយដ្ឋាន ដូចតទៅនេះគឺ

### រមណីយដ្ឋាន ថ្នល់មួយរយ

បើតាមលោក Malleret បានឲ្យដឹងថា ប្រជាជនកម្ពុជាបានចង្អុលបង្ហាញអំពីប្រភេទនៃរមណីយដ្ឋានទិក្រុង ដោយមានថ្នល់ ឬទំនប់ទឹកដែលបានបញ្ជាក់បង្ហាញនូវឈ្មោះថ្នល់មួយរយ ដើម្បីសន្មត់ឲ្យតំបន់នេះ ។ ប្រជាជនកម្ពុជាត្រូវបានបង្ខំចិត្តរត់គេចចេញពីតំបន់នេះ នៅឆ្នាំ ១៩២៦-១៩២៧ បន្ទាប់ពីការបះបោររបស់ "ដូចុក" ។

គេបានឃើញ វត្ថុបុរាណ និងកុម្ភការភ័ណ្ឌ (ចានឆ្នាំង) ដោយមានការតុបតែងលម្អ ដូចវត្ថុបុរាណ ដែលរកឃើញនៅ អុកកែវ ដែរ ។

www.elibraryofcambodia.org

## IX. ទីប្រជុំកោះ ពូឡូកុងឌរ

ប្រជាជនកម្ពុជាបានហៅកោះនេះថា កោះត្រឡាច "ទាំងអស់នេះ ("បូរាណវត្ថុវិទ្យា..." ទំព័រ១៧២) មានន័យថា Les iles de la courge ហើយប្រជាជនកម្ពុជាបានប្រើប្រាស់ពាក្យនេះ ដោយមានន័យដូចគ្នា ដោយបានកំណត់ឈ្មោះទីប្រជុំកោះនេះថា ជាកោះត្រឡាច" ។

ពួកម៉ាឡេ បានហៅកោះនេះ ថា ពូឡូ កុងដ័រ, ម៉ាកូ ប៉ូឡូសុងដូរ និងកុដដូរ, ពួកអារ៉ាប់ នៅសតវត្សរ៍ទី៩ ឬទី១១ បានហៅកោះនេះថា Cundur-fûlàt ។

បើតាមលោក G. Ferrand ពាក្យ Cundur fùlàt (គេអានថា Cundur) កើតចេញពីឋាននាមវិទ្យារបស់ប្រជាជនពែរ្ស (fùl តាមទម្រង់ភាសាអារ៉ាប់ចេញពីភាសាម៉ាឡេ Pùlau មានន័យថា កោះ និងបច្ច័យពហុវចនៈ Persan àt, cundur = Courge (ត្រឡាច) ។

ប្រជាជនចិន បានហៅរហូតមកដល់សព្វថ្ងៃនេះថា "K'ouen - Louen" ដែលវៀតណាមដោយការបន្លួចសំឡេង បានហៅថា "Côn Nôn" (La Grande) ។

គេបានឃើញ អូរពីរដែលប្រជាជនក្នុងស្រុកបានហៅអូរនេះថា "ព្រែកកម្ពុជា" និង "ព្រែកថាមីន" បានធានាការហូរទឹកដើម្បីបង្កើនទឹកនៅត្រើយខាងក្រោយជាមួយនឹងកម្លាំងទឹកភ្លៀងដ៏ខ្លាំង និងខ្យល់រដូវពីទិសបស្ចិម ។

ទីប្រជុំកោះនេះ ត្រូវបានកាន់កាប់ដោយប្រទេសបារាំងនៅឆ្នាំ ១៨៦១ លោកអនុនាវីឯក Lespès បានកាន់កាប់ជាមួយនាវាទាំសារ Norzaragay ។

នៅឆ្នាំ ១៨៧២ ប្រជាជននៅកោះធំនេះ មានចំនួន ២០០នាក់ រស់នៅក្នុងភូមិតូច ៗ៤, ដោយរស់នៅក្នុងធនធានស្ទើរតែមិនគ្រប់គ្រាន់ ។

តាម "កំណត់ស្តីអំពីកោះ ពូឡូកុងដ័រ " ព្រឹត្តិបត្ររបស់សមាគមសិក្សាអាណានិគម និងសមុទ្រ ឡាអេ ឆ្នាំ ១៨៣៨ ទំព័រ ៧៩-៨១) ភូមិទាំង៤ គឺជាភូមិរបស់

www.elibraryofcambodia.org

កម្ពុជា ភូមិចិន ភូមិអ្នកស្រែ និងភូមិហ្គ័រហុង" (បុរាណវត្ថុវិទ្យា..."ទំព័រ ១៧៥) ។

អត្ថបទទាំងនេះ បានបញ្ជាក់អំពីវត្តមានរបស់ប្រជាជនខ្មែរ តាំងពីយូរណាស់មក ហើយនៅទីប្រជុំកោះ ពូឡូកុងដ័រ, ដែលស្ថិតនៅក្រោមការកាន់កាប់របស់បារាំងគឺជា "កន្លែងនិរទេស" មួយនោះ ។

តាមលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន លោក Malleret បានសន្និដ្ឋានថា Trans bassac បានបង្ហាញនូវនិរន្តរភាពដ៏ប្រសើរនៃប្រជាភិវឌ្ឍន៍ តាំងពីសម័យបុរេប្រវត្តិសាស្ត្ររហូតដល់សម័យទំនើប, គេបានឃើញស្លាកស្នាមនៃវិហារពីបុរាណរបស់ខ្មែរ ដែលភាគច្រើនធ្វើអំពីឥដ្ឋ ហើយដែលចាប់ពីហេតុការណ៍នេះ បានផ្តល់នូវសម្ភារៈដើម្បីធ្វើការកសាងថ្មី" ។ (បុរាណវត្ថុវិទ្យា...) ទំព័រ ១៧៩ ។

លោក Malleret បានសម្គាល់នូវប្រភេទវប្បធម៌ ៤ ដ៏សំខាន់ ស្របទៅនឹងសម័យ វិវត្តន៍ប្រវត្តិសាស្ត្រ ៤នៅកម្ពុជាក្រោម គឺ :

១- សម័យថ្មរលីង មុន ហ៊្វូណន

២- សម័យវិបុលភាពសេដ្ឋកិច្ច

៣- សម័យរូបចម្លាក់ មុន សម័យអង្គរ នៅសតវត្សរ៍ទី VI និងទី VIII

៤- សិល្បៈអង្គរ ដែលបានបង្ហាញជាពិសេស នៅភាគខាងកើត និងនៅតាមមាត់ទន្លេនៅសតវត្សរ៍ទី XI និងទី XII ។

"ហត្ថូបករណ៍ដែលធ្វើអំពីថ្មនៅក្នុងគុហា កុម្ភការភ័ណ្ឌ នៃយុគដំបូង រួមបញ្ចូលជាមួយទីងការពួនផ្តុំ នៃសំបកខ្យងខ្មៅ ដំណើរទាក់ទងគ្នា បន្តិចបន្តួចនៃសាក្សីទាំងនេះ ជាមួយសិល្បៈ Culao Hua និង Samrong Sèn, បានចង្អុលបង្ហាញនូវសម័យកាល "ថ្មរលីង"ដែល គេអាចវាយតម្លៃបានថា ស្ថិតនៅក្នុងសម័យមុន "ហ៊្វូណន" ។ រូបសណ្ឋាននៃវាល គឺ ត្រូវគ្នាទៅនឹងភូមិធំៗ របស់មនុស្សរស់នៅរហូតមកដល់បច្ចុប្បន្ន ដែលកប់នៅក្នុង ដីល្បាប់ ហើយជាទូទៅវាទាក់ទងគ្នាទៅវិញទៅមក

www.elibraryofcambodia.org

ដោយប្រព័ន្ធព្រែកជីកពីបុរាណ ដែលហាក់ដូចជាបានឆ្លុះបញ្ចាំងឲ្យឃើញនូវសម័យមួយ ដែលមានការរីកចម្រើនខាងកសិកម្ម និងភាពសម្បូរណ៍ខាងសេដ្ឋកិច្ច ដែលបានបញ្ជាក់ដោយរបស់របរដ៏មានតម្លៃយ៉ាងច្រើន ដូចជាគ្រឿងអលង្ការធ្វើអំពីមាស និងត្បូងជាដើម ។ វប្បធម៌ នេះបានរក្សាទុកនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអារ្យធម៌ឥណ្ឌា ។ វប្បធម៌នេះ វ៉ាអាចទាក់ទងគ្នាទៅនឹងចលនាធ្វើអាណានិគមរបស់ឥណ្ឌា ដែលបានចារទុកនៅក្នុងប្រវត្តិសាស្ត្រ របស់អតីត"ហ៊្វូណន" ។ ទ ទី៣ បានលេចឡើងនូវរូបចម្លាក់ដ៏មានតម្លៃ នៅមុនសម័យអង្គរ ដែលរូបចម្លាក់មួយចំនួនប្រហែលជារូបចម្លាក់នៅក្នុងសម័យ "ហ៊្វូណន". ហើយដែលអាចចាត់ថ្នាក់នៅក្នុងសតវត្សរ៍ទី៦ និងសតវត្សរ៍ទី៨ ។ រូបចម្លាក់ទាំងនេះត្រូវបានស្ថិតនៅរាយប៉ាយច្រើនកន្លែងនៅផ្នែកខាងជើងនៃភ្នំទាំងឡាយ គឺជាវត្ថុដែលគេត្រូវការនៅក្នុងសម័យមួយដ៏ពិតប្រាកដ ។ ហើយដែលគេ ស្វែងរកដីដែលរឹងមាំ ដើម្បីកសាងព្រះវិហារ, ប្រាសាទ និងដើម្បីឲ្យរួចផុតពីគ្រោះថ្នាក់នៃទឹកជំនន់ ឬ ក៏គ្រាន់តែដាក់បញ្ចូលនូវភ្នំទាំងនោះទៅក្នុងការគោរពបូជារបស់សាសនាហិណ្ឌូ ។ នៅទីបញ្ចប់សិល្បៈអង្គរត្រូវបានបង្ហាញនៅខាងកើត និងនៅតាមមាត់ទន្លេទាំងឡាយ ដោយមានឧត្តមានុភាព នៃការកំណត់កន្លែងយ៉ាងច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍ដល់រូបបដិមានៅក្នុងសតវត្សរ៍ទី១១ និងសតវត្សរ៍ទី១២ ។

ដូច្នេះប្រវត្តិសាស្ត្រនៃកម្ពុជាក្រោម ដែលត្រូវបានផ្តុំឡើងវិញ ដោយការងាររបស់បុរាណវត្ថុវិទូដ៏ឧត្តមទាំងនោះ បានបញ្ជាក់ដោយគ្មានមន្ទិលសង្ស័យឡើយថា "តំបន់នេះ គឺជាទឹកដីរបស់កម្ពុជា" ចាប់តាំងពីយូរលង់ណាស់មកហើយ សំអាងទៅតាមរឿងព្រេង និងប្រពៃណី ដូចបានរៀបរាប់មកនេះ ។

ព្រះរាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៥

ទៀ ផេន

www.elibraryofcambodia.org

# ឧបសម្ព័ន្ធ ២

## ផែនទីនាំចង្អាយ ដើម្បី ងាយយល់នូវសៀវភៅនេះ ជាកម្មវត្ថុនៃការបោះពុម្ពផ្សាយ ដ៏មានសារៈសំខាន់

www.elibraryofcambodia.org




**(DENSITÉ DU PEUPLEMENT KHMER EN 1945)**
**Ministère de l'Information du Cambodge (1962)**

ចំនួនភាគរយនៃប្រជាជនតាមបណ្ដាខេត្តនៅកម្ពុជាក្រោមឆ្នាំ ១៩៤៥
(ផ្សព្វផ្សាយដោយក្រសួងឃោសនាការប្រទេសកម្ពុជា ១៩៦២)

www.elibraryofcambodia.org



www.elibraryofcambodia.org




www.elibraryofcambodia.org




ទីតាំងរបស់ នគរភ្នំ ពីសតវត្សរ៍ទី១ ដល់ទី៦

www.elibraryofcambodia.org




www.elibraryofcambodia.org




ផែនទីខ្មែរ នាឆ្នាំ ៩៦០ គ.ស មុនកំណើត

[illegible]

www.elibraryofcambodia.org




ដំណើរចុះពីស្រុកចិននៃជនជាតិថៃ នាសតវត្សរ៍ទី១៣
ដោយវេជ្ជបណ្ឌិត អូឡឺរីយេ

www.elibraryofcambodia.org




ផែនទី អេមោក្លូបិនអើ (HE)

www.elibraryofcambodia.org




ផែនទីបង្ហាញចេនឡាដីគោក និងចេនឡាទឹកលិចក្នុងរវាង គ.ស ៨០០

(DR. Sardesai សាកលវិទ្យាល័យ កាលីហ្វ័រនីញ៉ា L.A.)

www.elibraryofcambodia.org




បក្រកាវខ្មែរ ក្នុងគ.ស. ១២០០ (**DR. Sardesai** សាកលវិទ្យាល័យ

កាលីហ្វ័រនីញ៉ា **L.A.**)

www.elibraryofcambodia.org




**Carte publiée dans "Cambodge" édité par le Ministère de l' Information du Cambodge (1962)**

www.elibraryofcambodia.org




**D'après Fournereau, *le Siam ancien*.**

**Fig. 76 _ Carte de l' Indochine, extraite de l' Atlas historique de Gueudeville, 1713 – 1719 (E.C.F)**

www.elibraryofcambodia.org




**Carte de "l' Inde au de là du Gange", dressée pour l' histoire générale des voyageurs, de La Harpe (E.C.F)**

www.elibraryofcambodia.org




D' après *l' Univers.*

**Fig. 79.__ Carte de l' Indochine publiée en 1850, dans *l' Univers*, Japon-Indochine- Ceylan, chez Firmin-Didot, sous le titre de L' "Empire Birman" rectifiée à la table des gravures.**

www.elibraryofcambodia.org




D' après Fournereau, *le Siam ancien.*

**Fig. 73.__ Carte de l' Indochine publiée en 1638 par Jean Janson dans son "Nieu Wen Atlas ost verelt beschryvinge" (E.C.F)**

www.elibraryofcambodia.org




**Carte de l' Indo-Chine**
**par Robert 1717 (E.C.F)**

www.elibraryofcambodia.org




Les Indes Orientales.
d'après la carte de Mercator 1613

www.elibraryofcambodia.org

## សរុបសៀវភៅដែលមាននិយាយក្នុងរឿងនេះ

(BIBLIOGRAPHIE)


១- ឯកសារជំនួយស្មារតីដែលទាក់ទងទៅនឹងជនជាតិភាគតិចកម្ពុជា ក្រសួងការបរទេសភ្នំពេញ (១៩៥៨) ។

២- បុរាណវត្ថុវិទ្យានៃដែនដីសណ្តទន្លេមេគង្គ, Louis Malleret, T.I (ការរុករកបុរាណវត្ថុ និងការជីក កកាយដីរកបុរាណវត្ថុនៅ អុក ឯវ អត្ថបទ និងរូបបោះពុម្ព) ការបោះពុម្ពផ្សាយដោយសាលាបារាំងនៅចុងបូព៌ាប្រទេស, ក្បាល XLIII ។

៣- អង្គរ មនុស្ស និងថ្ម , Bernard Philippe Groslier ប៉ារីស ១៩៥៦

៤- អង្គរ និងប្រទេសកម្ពុជានៅសតវត្សរ៍ទី XVI តាមប្រភពរបស់ជនជាតិព័រទុយហ្គេ និងអេស្ប៉ាញ៉ុល , B.P Groslier ប៉ារីស ១៩៥៨ ។

៥- កូសាំងស៊ីន (អណ្ណាម ម៉ យ កម្ពុជា), ហង់រីអូរី ឡាក់, ប៉ារីស ១៨៧០) ។

៦- កូសាំងស៊ីន និងប្រជាជនរបស់ខ្លួន (ខេត្តនៅខាងលិច),បណ្ឌិត J.C. Bourac ។

៧- ការស្គាល់វៀតណាម, Pierre Huard និង Maurice Durand ហាណូយ ១៩៥៤ ។

៨- កាលប្រវត្តិវិទ្យា ឥណ្ឌូនេស៊ី លេខពិសេស នាយកដ្ឋានឥណ្ឌូណេស៊ី, ១៩៦០។

៩- ធម្មនុញ្ញអង្គការសហប្រជាជាតិ ។

១០- អាណាចក្រខ្មែរ ប្រវត្តិសាស្ត្រ និងឯកសារ, George Maspéro, ឆ្នាំ១៩០៤ ។

១១-សេចក្តីរាយការណ៍កាលប្រវត្តិវិទ្យាពីទំនាក់ទំនងរបស់ប្រទេសខ្មែរជាមួយសៀម អណ្ណាម និងបារាំង, Charles Lemire, 1870 ។


www.elibraryofcambodia.org

១២-GOA និង៨ម្មនុញ្ញអង្គការសហប្រជាជាតិ ក្រសួងការបរទេសនៃរដ្ឋាភិបាល ឥណ្ឌា ញូវដេលី ។

១៣-ប្រវត្តិសាស្ត្រ កូសាំងស៊ីន សរសេរដោយដៃជាភាសាខ្មែរ, ព្រះតេជគុណ ប៉ាច់ ប៉ាង ១៩៤៥ ។

១៤-ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, André Dauphin Meunier, ការប្រមូលបង់ក្រង "Que Sais je" ឆ្នាំ១៩៦១ ។

១៥-ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជ, Adhémard Leclère, ប៉ារីសឆ្នាំ ១៩១៤ ។

១៦- ប្រវត្តិសាស្ត្រនៃស្ថាប័នខ្មែរ Jean Imbert ភ្នំពេញ ១៩៦១ ។

១៧-ទិនានុប្បវត្តិចុងបូកើ ច្បាប់ចេញផ្សាយថ្ងៃទី២៤ ខែមេសា ឆ្នាំ ១៩៦២, រាជាធិបតេយ្យកម្ពុជា សម្តេចព្រះ នរោត្តម សីហនុ ។

១៨-ការធ្វើអាណានិគមកូសាំងស៊ីន Paul d'Enjoy, ប៉ារីស ១៨៩៨ ។ ជនជាតិភាគតិចកម្ពុជា សន្និសីទរបស់ Louis Malleret នៅ សាយហ្គន, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៤៦ (ព្រឹត្តិបត្ររបស់សមាគមសិក្សាឥណ្ឌូចិន) ។

១៩-ព្រះរាជាណាចក្រកម្ពុជា, J. Moura, ប៉ារីស ១៨៨៣ ។ ប្រទេសកម្ពុជារបស់ Louis Chminais, សាយហ្គន ១៩៦០ ច្បាប់អន្តរជាតិ ដោយលោក Vattel ។

២០-ប្រជាជនខ្មែរ ដើមកំណើតអង្គរនៅប្រទេសកម្ពុជា បច្ចុប្បន្ន, André Migot ប៉ារីស ១៩៦០ ។

២១-លក្ខខ័ណ្ឌនៅក្នុងសន្ធិសញ្ញាអន្តរជាតិដោយលោក Kaye Holloway, ប៉ារីស ១៩៥៨ ។

www.elibraryofcambodia.org

២២-អង្គការអន្តរជាតិ និងអធិបតេយ្យភាពរបស់រដ្ឋជាសមាជិក Marc Stanislas Korowicz ប៉ារីស. ១៩៦១ ។

២៣-កតិកាសញ្ញារបស់សមាគមនៃប្រជាជាតិ ។

២៤-បញ្ជីលំដាប់សំណួរស្ដីពីច្បាប់អន្តរជាតិទូទៅដាក់នៅចំពោះមុខសមាគមនៃប្រជាជាតិ ១៩២០-១៩៤០ យោង ៣៤១ S333 (បណ្ណាល័យរបស់អង្គការសហប្រជាជាតិ ញូវយ៉ក) ។

២៥-ព្រះមហាក្សត្រប្រទេសកម្ពុជា ក្រសួងការបរទេស, ភ្នំពេញ, ១៩៥៧ ។

២៦-សន្ធិសញ្ញា នៃច្បាប់អន្តរជាតិសាធារណៈ Marcel Sibert ។

២៧-សន្ធិសញ្ញាក្រុង ហ្សឺណែវ, នៅឆ្នាំ ១៩៥៤ (ស្ដីពីការបញ្ឈប់ភាពជាសត្រូវនៅឥណ្ឌូចិន) ។

២៨-អាណាចក្រអាណានិគមបារាំង ឥណ្ឌូចិន George Maspéro, ប៉ារីស ១៩២៩-១៩៣០ ។

២៩-រាជសកម្មភាពដើម្បីឯករាជ្យ បរិបូណ៌នៃកម្ពុជា (ទសវត្សរ៍ ១៩៤០-១៩៥០) ន. សីហនុ ។

៣០-អាស៊ីភាគអគ្នេយ៍ អតីត និងបច្ចុប្បន្ន, DR. Sardesai ។

៣១-ព្រំដែននៃប្រទេសកម្ពុជាជាមួយបណ្ដាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន, របស់ (សារិន ឆាក) ១៩៦៦ ។

៣២- សាស្ត្រានិយាយអំពីប្រវត្តិចម្បាំងនៅកម្ពុជាក្រោម ។

www.elibraryofcambodia.org



សម្តេចក្រុមព្រះ វរចក្រ នរោត្តម សុធារស
ព្រះបិតា ព្រះបាទ សម្តេច ព្រះនរោត្តម សុរាម្រិត
ព្រះអយ្យកោ ព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ
ព្រះអយ្យកោទួត ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

*– ព្រះត្រាស់ដែលប្រកាសថា : "នៅពេលណាដែលសម្តេចឡើងគ្រងរាជ្យ ព្រះអង្គនឹងទាមទារពី បារាំងនូវទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) មកវិញ" ។ ពេលបារាំងដឹងដូច្នោះ ក៏បង្វែររាជ្យទៅថ្វាយ សម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស ឲ្យសោយរាជ្យវិញ ។ ព្រះអង្គក៏មិនបាន សោយរាជ្យ និងមិនបាន [illegible] សីហនុ ២០០៣)*

www.elibraryofcambodia.org

# សេចក្តីបួងសួងថ្វាយ

ទូលព្រះបង្គំ ជាកូន-ចៅ របស់ "ខ្មែរកម្ពុជាក្រោម", សូមក្រាបថ្វាយបង្គំ បួងសួងចំពោះគុណព្រះរតនត្រ័យ មានព្រះពុទ្ធជាប្រធាន ព្រះធម៌ជាញាណ ព្រះសង្ឃជាសាក្សី ដើម្បីរំលឹកគុណូបការៈដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គក្សត្រា នរោត្តម សុធារស ដែលព្រះអង្គបានសំដែងព្រះហឫទ័យ សុភនិច្ឆ័យចំពោះទឹកដី "កម្ពុជាក្រោម" ។ សូមកុសលដែលកើតពីការតាក់តែងសៀវភៅនេះ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធរបស់ព្រះអង្គយាងសោយសុខក្នុងសម្បត្តិសួគ៌ និង និព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

(ទូលព្រះបង្គំ : ទៀ ថេន)

www.elibraryofcambodia.org

~~[illegible]~~

១

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]



www.elibraryofcambodia.org

[illegible]



www.elibraryofcambodia.org



ក្រាំងនិយាយអំពីរឿងចម្បាំងនៅកម្ពុជាក្រោម

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយករុណាខ្មែរ

Scan ជា eBook ដោយ សៀប ពិសិដ្ឋ

ក្រោមការឧបត្ថម្ភពី

ខ្ញៅ សំរ៉ង និង កែ ក្រានីត

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ

ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

(ឃុំ កំពង់ឃ្លាំង ស្រុក ជីក្រែង ខេត្ត សៀមរាប)

ខែ កុម្ភៈ ឆ្នាំ២០១៤

www.elibraryofcambodia.org